ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

**កំណត់ហេតុជាលាយលក្ខណ៍អក្សរ**

**នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"**

**សាធារណៈ**

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៩**

**សវនាការលើកទី៦៣**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលវីយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

កញ្ញា ណាតាចា វីស៊ែល រីស៊ើ

*(Ms. Natacha Wexels-Riser)*

លោក ម៉ាតូ គ្រីស្ពារ *(Mr. Matteo Crippa)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក វិលៀម ស្មីត *(Mr. William SMITH)*

លោក វាំងសង់ ដឺវ៉ាយឌ៍ ដេស្មាឯល

*(Mr. Vincent DE WILDE D'ESTMAEL)*

**ជនជាប់ចោទ៖**

លោក កាំង ហ្គេកអ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោកស្រី ម៉ារីប៉ូល កានីហ្សារេស

*(Marie-Paule CANIZARES)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

កញ្ញា ម៉ុច សុវណ្ណារី

កញ្ញា ទី ស្រ៊ីនណា

លោក ហុង គឹមសួន

លោក អាឡាំង វ៉ែនណឺ*(Mr. Alain Werner)*

លោកស្រី ហ្វាប៊ីយ៉ែន ទ្រូស្ស ណាព្រូស

*(Ms. Fabienne Trusse-Naprous)*

កញ្ញា ចេស្ស៊ីកា ហ្វីណែល

*(Mr. Jessica FINELLE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

# ឧបសម្ព័ន្ធ

## ដើមបណ្តឹងរដ្ឋប្បវេណី

### លោកស្រី ជុំ នៅ


ស្សួរដោយលោក ហុង គីមសួន ផ្តើមពី ....................ទំព័រ ១៦
ស្សួរចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន ផ្តើមពី ....................ទំព័រ ២២
ស្សួរដោយ លោក ដឺវ៉ាយដ៍ ដេស្មាឯល ផ្តើមពី ....................ទំព័រ ២៤
ស្សួរដោយ លោក សេង ប៊ុនឃាង ផ្តើមពី ....................ទំព័រ ២៦
ស្សួរដោយ លោក ហ្វ្រង់ស្វ័រ រូ ផ្តើមពី....................ទំព័រ ៣១


### លោកស្រី ឈិន ណាវី


ស្សួរដោយ ប្រធានអង្គជំនុំ ផ្តើមពី ....................ទំព័រ ២៨
ស្សួរដោយ លោក គង់ ពិសី ផ្តើមពី ....................ទំព័រ ៦៨
ស្សួរដោយ លោក សេង ប៊ុន ឃាង ផ្តើមពី....................ទំព័រ ៧៤


### លោក តូច មុន្និន


ស្សួរដោយ ប្រធានអង្គជំនុំ ផ្តើមពី ....................ទំព័រ ៧៦
ស្សួរដោយលោក ហុង គីមសួន ផ្តើមពី ....................ទំព័រ ៨៧

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោកស្រី ម៉ារីប៉ូល កានីហ្សារេស | បារាំង |
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយធ៍ | អង់គ្លេស |
| លោកស្រី ឈិន ណារី | ខ្មែរ |
| លោកស្រី ជុំ នៅ | ខ្មែរ |
| លោក វាំងសង់ ឌឺវ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក ការ សាវុត្ថ | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែរ៍ | បារាំង |
| លោក ហ្វ្រង់ស្វ័រ រ៉ូ | បារាំង |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោក វិលៀម ស្មីត | អង់គ្លេស |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោក តូច មុន្និន | ខ្មែរ |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |
| លោកស្រី ហ្វាប៊ីយ៉ែន ទ្រូស្ស ណាព្រូស | បារាំង |
| លោក អាឡាំង វែនណឺ | អង់គ្លេស |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលមកកាន់បន្ទប់សវនាការ)*

[០៩:០៧:៣១]

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយតាមកាលវិភាគដែលបានសម្រេចធ្វើការកែប្រែកាលពីសប្តាហ៍មុន គឺសម្រាប់ថ្ងៃនេះ អង្គជំនុំជម្រះនឹងស្តាប់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ជុំ នៅ ជាបន្ត ដែលបានអាក់ខានមិនបានធ្វើចប់ចុងចប់ដើមកាលពីរសៀលថ្ងៃព្រហស្បតិ៍មុនដោយមូលហេតុបញ្ហាបច្ចេកទេសសំឡេងនៃឧបករណ៍សំឡេង និងរូបភាពនៅក្នុងប្រព័ន្ធនៃសាលសវនាការ ។ ហើយនៅទន្ទឹមនឹងនេះដើម្បីឲ្យបានច្បាស់ ដោយសារកាលពីរសៀលថ្ងៃព្រហស្បតិ៍មុននេះ ដោយសារមូលហេតុប្រព័ន្ធសំឡេងនេះ អង្គជំនុំជម្រះបានប្រកាសជម្រាបជូនដល់ភាគីនិងសាធារណជនរួចហើយអំពីការបរិច្ឆេទនៃដំណើរការសវនាការសម្រាប់សប្តាហ៍នេះ និងសប្តាហ៍បន្តបន្ទាប់ដែលមានការកែសម្រួលនោះ។ ប៉ុន្តែ ដោយសារមូលហេតុនៃប្រព័ន្ធសំឡេងនាំឲ្យមានការមិនច្បាស់ ។

ដូច្នេះអង្គជំនុំជម្រះសូមប្រកាសជូនដំណឹងបញ្ជាក់សាជាថ្មីម្តងទៀតដល់ភាគី និងសាធារណជនថា ដោយសារតែដំណើរការនីតិវិធីសវនាការប្រព្រឹត្តទៅបានឆាប់រហ័ស និងដោយសារតែមានការបោះបង់សិទ្ធិក្នុងការធ្វើសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនក្នុងរយៈពេលកន្លងមកនេះ អង្គជំនុំជម្រះបានរៀបចំសាជាថ្មីនូវកាលវិភាគសវនាការសម្រាប់សប្តាហ៍នេះ និងសប្តាហ៍បន្តបន្ទាប់ ។ បន្ទាប់ដូចខាងក្រោម៖

នៅថ្ងៃច័ន្ទ គឺថ្ងៃនេះអង្គជំនុំជម្រះនឹងបន្តស្តាប់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ជុំ នៅ ហើយនិងស្តាប់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនបីរូប គឺឈ្មោះ ឈិន ណារី , តូច មុន្និន, និង រស់ មេន ។ ហើយក្រោយពេលស្តាប់នូវសេចក្តីថ្លែងការណ៍ដើមបណ្តឹងរដ្ឋប្បវេណីចប់ ថ្ងៃនេះអង្គជំនុំជម្រះសម្រាកដោយមានកិច្ចប្រជុំផ្ទៃក្នុង ។

នៅព្រឹកថ្ងៃអង្គារ៍អង្គជំនុំជម្រះនឹងស្តាប់នូវសក្ខីកម្មរបស់អ្នកជំនាញ CP2/5 លើបញ្ហាទាក់ទងទៅនឹងព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ នៅរសៀលថ្ងៃអង្គារ៍ អង្គជំនុំជម្រះនឹងស្តាប់នូវការជំទាស់របស់មេធាវីការពារក្តីចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងស្តាប់នូវការឆ្លើយតប

ពីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំពោះការជំទាស់នោះ ។ អង្គជំនុំជម្រះនឹងស្តាប់នូវការជំទាស់ និងការឆ្លើយតបចំពោះជំទាស់នេះសម្រាប់រយៈពេលប្រហែលជាពីរថ្ងៃ ។ បន្ទាប់មក អង្គជំនុំជម្រះនឹងចាប់ផ្តើមសួរសំណួរដល់ជនជាប់ចោទ ទាក់ទងទៅនឹងអត្តចរិតរបស់គាត់ ។

នៅសប្តាហ៍បន្ទាប់ អង្គជំនុំជម្រះនឹងចាប់ផ្តើមស្តាប់សក្ខីកម្មរបស់អ្នកជំនាញ និងសាក្សីទាក់ទងទៅនឹងអត្តចរិតរបស់ជនជាប់ចោទ ។ អង្គជំនុំជម្រះរក្សាសិទ្ធិក្នុងការកែប្រែកាលវិភាគនេះ ហើយនឹងជម្រាបដល់ភាគីប្រសិនបើការកែប្រែកាលវិភាគតម្រូវឲ្យមាន និងបន្តធ្វើបច្ចុប្បន្នភាពដល់សាក្សីប្រសិនបើការកែប្រែកម្មវិធីតម្រូវឲ្យដល់ភាគីប្រសិនបើការកែប្រែកម្មវិធីតម្រូវឲ្យមាន ។

នេះគឺជាការបញ្ជាក់សាជាថ្មីដើម្បីបំពេញប្រតិចារឹកផង ដើម្បីជម្រាបជូនដល់ភាគីនិងសាធារណជនឲ្យបានច្បាស់ផងពីការកែប្រែពីកាលវិភាគសម្រាប់ដំណើរការសវនាការសម្រាប់សប្តាហ៍នេះ និងសប្តាហ៍ក្រោយ ។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាមុន ។

[០៩:១២:៣៤]

**លោក វីលៀម ស្មីត៖**

សូមអរគុណលោកប្រធាន ។

លោកប្រធានទាក់ទងទៅកាលវិភាគយើងខ្ញុំមានសំណើខ្លីមួយ ។ ជាដំបូងគឺជនជាប់ចោទនិងអង្គជំនុំជម្រះនឹងសួរអំពីអត្តចរិករបស់គាត់ហើយអ៊ីចឹងថា តើយើងខ្ញុំដឹងថានឹងប្រើពេលប៉ុន្មានសម្រាប់ជនជាប់? ហើយប្រហែលជាពេលមួយចំនួនច្រើនត្រូវប្រើសួរទាក់ទងអំពីតួនាទីរបស់គាត់នៅស-២១ រួមជាមួយនឹងបុគ្គលិកលក្ខណៈរបស់គាត់ ហើយទាក់ទងទៅនឹងកាលវិភាគនេះ សហព្រះរាជអាជ្ញាត្រូវមានពេលមួយម៉ោង ហើយប្រហែលបើអាចធ្វើទៅបាន យើងខ្ញុំចង់បានមួយម៉ោងកន្លះលើបញ្ហានេះ ហើយភាគីផ្សេងៗទៀតនឹងត្រូវផ្តល់ពេលឲ្យគាត់សួរដែលមានពេលស្មើនឹងដែរ ។

ហើយចំណុចទីពីរ ទាក់ទងទៅនឹងការដាក់សំណើជូនអង្គជំនុំជម្រះដោយសហព្រះរាជអាជ្ញា យើងចង់ស្នើសុំដាក់ដេញដោលឯកសារទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធដូចដែលលោកចៅក្រមជ្រាប ហើយនៅពេលនោះ នីតិវិធីសម្រាប់ការដាក់ឯកសារជូនអង្គជំនុំជម្រះនោះ គឺមានភាពស្មុគស្មាញហើយត្រូវប្រើពេលច្រើនផង ។

ហើយដោយសារអង្គជំនុំជម្រះចេញគោលការណ៍នេះ ហើយដើម្បីសម្រួលដំណើរការនេះ អ៊ីចឹង

គឺយើងមានការងាយស្រួលដើម្បីឲ្យអង្គជំនុំជម្រះ ហើយនិងភាគីដាក់ឯកសារជូនអង្គជំនុំជម្រះទៅតាមការណែនាំនេះ ។ ហើយយើងខ្ញុំសូមស្នើថា ចំណុចពេលហើយនិងរយៈពេលដែលបានផ្តល់ជូនឲ្យភាគីក្នុងរយៈសប្តាហ៍នេះ ឬក៏សប្តាហ៍ក្រោយនោះ សហព្រះរាជអាជ្ញាអាចនឹងធ្វើសេចក្តីសង្ខេបលើឯកសារមួយចំនួន ហើយនិងពន្យល់អំពីគោលបំណង ហើយនិងភាពពាក់ព័ន្ធនៃជម្លោះប្រដាប់អាវុធក្នុងឯកសារជម្លោះប្រដាប់អាវុធ ហើយយើងសូមស្នើថា យើងនឹងមិនប្រើពេលលើសពីម្ភៃប្រាំមីនុត ឬកន្លះម៉ោងនោះទេ ។

ហើយបន្ទាប់មកនឹងធ្វើមតិយោបល់លើរឿងហ្នឹង ហើយប្រហែលជាពេលនោះគឺ អាចប្រើដើម្បីគេអាចដាក់ឯកសារផ្សេងៗទៀតដល់អង្គជំនុំជម្រះផងដែរ ។ ប៉ុន្តែដំណាក់កាលនេះ គោលបំណងរបស់យើងនឹងគឺយើងនឹងដាក់ជូននូវឯកសារនិយាយពីជម្លោះប្រដាប់អាវុធជូនអង្គជំនុំជម្រះ ហើយយើងនឹងជូននៅពេលណាមួយក្នុងសប្តាហ៍នេះ ។ សូមអរគុណ ។

[០៩:១៥:០៨]

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី ហុង គឹមសួន ។

**លោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំបាទសូមគោរពលោកប្រធាន និងលោក លោកស្រី ចៅក្រមជាទីគោរព ។

ជាកិច្ចចាប់ផ្តើមនេះ ខ្ញុំបាទសូមអនុញ្ញាតលោកប្រធានជម្រាបអំពីអវត្តមានរបស់កញ្ញាមេធាវីបរទេស ស៊ីលឃី ស្ទូតហ្វ៊ីនស្គី គាត់មានជំងឺចូលមន្ទីរមិនអាចចូលរួមបាន។ ទីពីរទៀត កូនក្តីខ្ញុំបាទមួយទៀតឈ្មោះ រស់ សាមេន ឬ រស់ មេន ដែលជាដើមបណ្តឹងរដ្ឋប្បវេណី គាត់មិនបោះបង់សិទ្ធិជាដើមបណ្តឹងទេ ក៏ប៉ុន្តែគាត់ក៏វិបត្តិមានជំងឺផងដែរ ហេតុនេះគាត់សូមឲ្យលោកប្រធាននិងអង្គសវនាការនៅទទួលគាត់ជាដើមបណ្តឹងតែគាត់មិនបានមកថ្លែងសក្ខីកម្មទេ ។

ហើយទីបីទៀត កូនក្តីខ្ញុំបាទឈ្មោះ តូច មុន្និន ដែលជាដើមបណ្តឹងរដ្ឋប្បវេណីផងដែរ ខ្ញុំបាទក៏សូមអនុញ្ញាតលោកប្រធានដោយសារមិនទាន់ដល់ពេលនឹងគាត់ឡើងថ្លែងសក្ខីកម្មទេ តែខ្ញុំបាទបានរកឯកសារដើមដែលជាសាច់ញាតិរបស់គាត់ស្លាប់នៅមន្ទីរស-២១ ជាឯកសារសារភាពទើបតែនៅថ្ងៃទី២២ដែលជាថ្ងៃឈប់សម្រាកគឺថ្ងៃសៅរ៍ អាទិត្យមុននេះ ។ អ៊ីចឹងខ្ញុំបាទមិនអាចនឹងបកប្រែជាភាសាអង់គ្លេស

ឬភាសាបារាំងទាន់ទេ ។ ហើយក៏មានលិខិតបញ្ជាក់ពីនាយកនៅកន្លែងសារមន្ទីរទួលស្លែងនេះបញ្ជាក់ជូនថា ជាឯកសារដើមដាក់ជូនទៅលោកប្រធានដើម្បីទទួលយកផងដែរ ។

[០៩:១៦:៣៥]

ហើយនៅក្នុងមួយទៀត អ្នកស្រី ឈិន ណារី ដែលត្រូវឡើងសក្ខីកម្មព្រឹកនេះ សូមអនុញ្ញាតលោកប្រធាន អនុញ្ញាតឲ្យគាត់ថ្លែងសក្ខីកម្មបន្តពីអ្នកស្រី ជុំ នៅ ដោយសារគាត់ជាដើមបណ្តឹងរដ្ឋប្បវេណេ ហើយឥឡូវនេះគាត់កាន់សីលទៀតផ្នែកពុទ្ធសាសនាគឺគាត់ថ្ងៃសីលគាត់ត្រូវពិសារអាហារថ្ងៃត្រង់មុនម៉ោង១១ ឬត្រឹមម៉ោង១១ ។ អ៊ីចឹងសូមលោកប្រធានអនុញ្ញាតទទួលផងបាទ ។ សូមអរគុណបាទ ។

[០៩:១៧:១០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី អាឡាំង វ៉ែនណឺ ។

**លោក អាឡាំង វ៉ែនណឺ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ។

ខ្ញុំសូមជម្រាបលោកចៅក្រម និងអង្គជំនុំជម្រះថាយើងបានទៅជួបកញ្ញា ស្លួតហ្សិនស្គី ហើយពិនិត្យឃើញថា គាត់ប្រហែលជាមិនអាចចូលរួមបានក្នុងរយៈពេលមួយចំនួន ហើយយើងនឹងធ្វើការងារអស់ពីសមត្ថភាពក្នុងអវត្តមានរបស់គាត់ ហើយនិងសហការនៅលើបញ្ហាមួយចំនួនតាមដែលយើងអាចធ្វើទៅបាន ។ ហើយគាត់អាចនិយាយជាមួយយើងនូវបញ្ហាមួយចំនួន ហើយយើងនឹងសហការជាមួយគាត់ដើម្បីឲ្យដំណើរការបានដំណើរទៅមុខ ហើយសូមជម្រាបអង្គជំនុំជម្រះជម្រាបពីបញ្ហានេះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីតំណាងឲ្យដើមក្រុមបី ។

**លោកស្រី ហ្វាប៊ីយ៉ែន ទ្រូស្សូណាព្រួស៖**

សូមអរគុណលោកប្រធាន ។ តាមពិតខ្ញុំឯកភាពជាមួយលោកមេធាវីដែលបានបញ្ជាក់ខាងដើមនោះ ប៉ុន្តែខ្ញុំមានព័ត៌មានបន្ថែមដើម្បីជម្រាបជូនអង្គជំនុំជម្រះ ហើយខ្ញុំសូមកែតម្រូវចំណុចមួយនៅកន្លែងនេះ ហើយខ្ញុំសូមជូននូវអំពីសក្ខីកម្មរបស់ អង់តូនីញ៉ា ជូឡុង ដែលអាទិត្យមុនហ្នឹងគឺ កញ្ញា អង់តូនីញ៉ា ជូឡុង នោះបានបញ្ជាក់ក្នុងសេចក្តីថ្លែងការណ៍របស់គាត់នៅទំព័រ៣១ ដែលបញ្ជាក់បន្ទាត់ទី៣១ថា គាត់បានឃើញ តុលាការកំពូលនៅបារាំងដែលបានដាក់ពាក្យបណ្តឹងប្រឆាំងមនុស្សមួយចំនួនក៏ដូចមាន ឌុច

ហើយក៏ អៀង សារី, នួន ជា ហើយនិងអ្នកផ្សេងៗទៀតដែលចោទប្រកាន់ ដែលនឹងជំនុំជម្រះនៅក្នុងរឿងក្តីទី២ នៅក្នុងសេចក្តីថ្លែងការណ៍របស់គាត់ គាត់បានភ្លេច គាត់បាននិយាយដោយខុស គាត់បានដាក់ឈ្មោះខុស គាត់ដាក់ឈ្មោះខុសហ្នឹងថា ជា សុង-- ជា ស៊ីម នោះដែលមិនមែនជាផ្នែកនៅក្នុងរឿងក្តីនេះទាល់តែសោះ ។ ដូច្នេះ នេះជាចំណុចឆ្គងទេ ។

[០៩:២០:០២]

គាត់មិនបានដឹងខ្លួនឯងថា គាត់បានបញ្ជាក់ឈ្មោះនោះដោយកំហុស នៅពេលដែលគាត់អានអត្ថបទទៅក្នុងសារព័ត៌មាន គាត់ដឹងថាគាត់បាននិយាយនោះមិន-- គាត់បានសរសេរឈ្មោះខុសនៅក្នុងសក្ខីភាពរបស់គាត់ ។ ហើយខ្ញុំគាត់បានណែនាំឱ្យពិនិត្យក្នុងប្រតិចារឹក ហើយគាត់បានកត់ត្រាដូចដែលគាត់និយាយមែន ហើយគាត់ក៏បញ្ជាក់ថា គាត់និយាយខុសទេ ។ ហើយគាត់សូមកែតម្រូវ ហើយសូមអភ័យទោសដល់អង្គជំនុំជម្រះ ហើយសូមអភ័យទោសទៅដល់លោក ជា ស៊ីម ផងដែរ ដែលថាជាកំហុសឆ្គងទេគឺជាមិនមែនពាក់ព័ន្ធទៅនឹងគាត់នោះទេ ។ ហើយវាធ្វើកឱ្យមានការភាន់ច្រឡំហើយ សូមអភ័យទោសដ៏ខ្ពង់ខ្ពស់អំពីកំហុសឆ្គងនេះ ដោយថាតាមពិតឯកសារនេះ ។

សេចក្តីសម្រេចពាក់ព័ន្ធទៅនឹងការមិនមានយុត្តាធិការរបស់តុលាការប៉ារីស នៅក្នុងសំណុំរឿងឯកសារ E5/7.2 ហើយឧសម្ព័ន្ធនោះ ERN លេខ 00271925 រហូតដល់ 00271926 ។ ដូច្នេះ នោះខ្ញុំលើកឡើងពីបញ្ហាអស់នោះ គឺថាអ្វីៗឱ្យច្បាស់នៅពេលនេះ ។ សូមគោរពលោកប្រធាន ។

**អ្នកបកប្រែ៖**

សុំកែតម្រូវគឺឈ្មោះដែលបានបញ្ជាក់ខុសនោះ គឺ ជា ស៊ីម ។

**ប្រធានអង្គជំនុំ៖**

អរគុណចំពោះការផ្តល់ព័ត៌មានទាំងអស់នេះ ខាងព័ត៌មានដែលបានទទួលពីតំណាងសហព្រះរាជអាជ្ញា អង្គជំនុំជម្រះនឹងយកបញ្ហានេះមកពិចារណា ហើយនឹងជម្រាបជូនជាក្រោយនូវក្នុងពេលណាមួយគឺអាចថ្ងៃនេះ ។ ហើយយ៉ាងយូរ គឺថ្ងៃស្អែកដើម្បីជម្រាបជូនអំពីពេលវេលាសមស្របដើម្បីធ្វើការបែងចែកដល់ភាគីនៅក្នុងការតាំងសំណួរផ្សេងៗ ពាក់ព័ន្ធជាមួយនឹងដំណើរការប្រព្រឹត្តទៅនៃការស្តាប់ចម្លើយស្តីពីអត្តសញ្ញាណរបស់ជនជាប់ចោទនេះ ។ ហើយគួរឱ្យស្តាយដែរចំពោះព័ត៌មានមេធាវី ស្ទួត ហ្សឹនស្តី ដែលមានជំងឺ ហើយដោយមានការអាក់ខានក្នុងការចូលរួមក្នុងដំណើរការសវនាការ ហើយក៏អរគុណដល់មេធាវីក្រុមផ្សេងទៀត ដែលបានបង្ហាញពីជំហរក្នុងកិច្ចប្រឹងប្រែងសហការដើម្បីឱ្យដំណើរ

ការប្រព្រឹត្តទៅនៃដំណើរការសវនាការរឿងក្តីនេះបានឆាប់រហ័ស ។

ហើយចំពោះមេធាវីក្រុមបីដែលបានលើកឡើងនេះ ឃើញថាការស្តាប់ថ្ងៃណោះ ក៏អាចមានការភាន់ច្រឡំ ដោយសារតែមានការកែតម្រូវភ្លាមៗដែរ គ្រាន់តែមិនបានបង្ហាញអំពីជំហរនៃការកែតម្រូវដោយសាររអាក់រអួលនៃការប្រើប្រាស់ឈ្មោះនៃ-- ដែលបានប្រើប្រាស់នៅទីនេះ ។ ហើយបើសិនជាមានការបញ្ជាក់យ៉ាងច្បាស់ដូច្នេះ គឺជាការឲ្យបានតែកាន់ច្បាស់លាស់ទៀត ពីព្រោះមិនឲ្យដំណើរការប្រព្រឹត្តទៅនេះ មានការប៉ះពាល់ដល់កិត្តិយសសេចក្តីថ្លៃថ្នូររបស់បុគ្គលដទៃនោះទេ ។ យើងត្រូវតែប្រព្រឹត្តទៅឲ្យបានត្រឹមត្រូវជាអតិបរមា ។

ហើយចំណែកឯសំណូមពររបស់មេធាវី ហុង គឹមសួន ដែលបានស្នើសុំចំពោះអង្គជំនុំជម្រះ យើងយល់ព្រម យល់ស្របតាមសំណូមពរនេះ ។

មន្ត្រីតុលាការ--

អញ្ជើញ!

[០៩:២៤:០៥]

**លោក វីល្មៀម ស្មីត៖**

តំណាងសហព្រះរាជអាជ្ញា សូមអរគុណ លោកប្រធាន ។

ឥឡូវនេះបញ្ហានេះបានលើកហើយ ហើយខ្ញុំសូមអនុញ្ញាតនឹងលើកឡើងបញ្ហានេះ បន្ទាប់ពីឈប់សម្រាកព្រឹកនេះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការ អញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ជុំ នៅ ។ ឈ្មោះ ជុំ នៅ មកកាន់ទីកន្លែងសម្រាប់-- ទុកសម្រាប់ដើមរដ្ឋប្បវេណី នៅចំពោះមុខអង្គជំនុំជម្រះ ។

*(លោកស្រី ជុំ នៅ ចូលមកកាន់បន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

លោកស្រី ជុំ នៅ ឥឡូវនេះដោយសារកាលពីរសៀលថ្ងៃព្រហស្បតិ៍សប្តាហ៍មុន ដំណើរការប្រព្រឹត្តទៅក្នុងការស្តាប់សេចក្តីថ្លែងការណ៍របស់លោកស្រី ក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តីនេះ។ មានបញ្ហាមិនអាចធ្វើចប់ចុងចប់ដើម ដោយមូលហេតុបញ្ហាបច្ចេកទេសខាងប្រព័ន្ធសំឡេងនៃប្រព័ន្ធព័ត៌មានវិទ្យាដែលប្រើប្រាស់នៅក្នុងសាលសវនាការមិនអាចប្រព្រឹត្តទៅបាន ។

ហើយឥឡូវនេះ អង្គជំនុំជម្រះអនុញ្ញាត ឬក៏ផ្តល់វេទិកាជូនទៅលោកស្រីដើម្បីធ្វើសេចក្តីថ្លែង-ការណ៍បន្តពីថ្ងៃមុន ក្នុងនាមលោកស្រីជាដើមបណ្តឹងរដ្ឋប្បវេណី ។ សូមអញ្ជើញ ។

**លោកស្រី ជុំ នៅ៖**

ចាំ, សូមអរគុណ ។

តុលាការជាទីគោរព! នាងខ្ញុំកាលពីសប្តាហ៍មុនបាននិយាយដល់កូនខ្ញុំស្លាប់ ហើយនាងខ្ញុំបានវិលត្រឡប់ពីមន្ទីរពេទ្យមកអង្គភាពកង១៤ នៅឯបាគូ ។ តែថ្ងៃនេះ ព្រឹកនេះ នាងខ្ញុំសូមការអនុញ្ញាតបកក្រោយបន្តិចដើម្បីរំឭក ព្រោះយើងនិយាយមិនទាន់អស់នៅថ្ងៃទីមួយ ដែលនាងខ្ញុំបានចូលទៅដល់មន្ទីរស-២១ ឯស្ទឹងជ្រៅនោះ គឺនៅកន្លែងដែលរស់នៅថ្ងៃដំបូង តាមការនឹកឃើញរបស់ខ្ញុំគឺកន្លែងដែលរស់នៅហ្នឹងជាផ្ទះដែលសល់ពីសង្គម គឺមានផ្ទះអ្នកជាប់ទោសហ្នឹងមួយ សម្រាប់ដាក់អ្នកដែលរស់នៅកន្លែងហ្នឹង ។ ហើយផ្ទះមួយទៀត សម្រាប់ដាក់បុគ្គលិកដែលគ្រប់គ្រង ហើយផ្ទះមួយទៀតសម្រាប់ដាក់កុមារដែលទៅជាមួយម្តាយ ហើយផ្ទះមួយទៀតសម្រាប់ពេទ្យៗឆ្មប ។ ហើយផ្ទះពេទ្យឆ្មបហ្នឹង គឺនៅឆ្ងាយរាងឆ្ងាយពីអាវង្វង់ដែលខ្ញុំនិយាយពីខាងដើមអំមិញ ។ ហើយទីនោះហើយ ដែលជាថ្ងៃដំបូងដែលខ្ញុំចាំ ពេលដែលយើងហូបបាយល្ងាចហើយ ។ ពេលដែលយើងយកខោអាវ ឡើងទៅលើផ្ទះហ្នឹងជុំគ្នាហើយ ។ ផ្ទះហ្នឹងគឺគេបិទសោ គេចាក់សោខាងក្រៅ ។ អ៊ីចឹង ខ្ញុំកំណត់ភ្លាមថា យើងជាទោស ទោសយើងពេលនោះ គឺយើងជាប់គុកមានជញ្ជាំង មិនដូចពាក្យថាដែរថា គុកអត់ជញ្ជាំងនៅឯសហករណ៍ទេ។

ហើយសូមជម្រាបមួយទៀត នៅពេលដែលនាងខ្ញុំរស់នៅកន្លែងនេះ គឺចាប់ពីពេលដែលនាងខ្ញុំមានទម្ងន់ រហូតដល់ពេលនាងខ្ញុំបានឆ្លងទន្លេសម្រាលបុត្រ បានកូនប្រុសមួយហ្នឹង គឺប្រហែលជានៅក្នុងខែ១ ឆ្នាំ៧៨ ខ្ញុំសម្រាលកូន ។ ហើយកន្លែងនាងខ្ញុំសម្រាលកូនហ្នឹង ពេទ្យឆ្មបហ្នឹងគឺគាត់ឈ្មោះ បងថាច គឺខ្ញុំឃើញមានតែពេទ្យហ្នឹងតែម្នាក់ ។ ប៉ុន្តែ ផ្ទះដែលយើងដេកជាផ្ទះហ្នឹង ផ្ទះហ្នឹងខ្ពស់ណាស់សរសរបេតុង តាមខ្ញុំចាំជណ្តើរពីរកាច់ហ្នឹង គឺមានដប់មួយកាំងណោះ ។ ហើយរនាបក្តារជិត ប៉ុន្តែមានប្រហោងខ្លះដែរ ។

[០៩:២៩:២៨]

ហើយសង្កើចៗច្រើនណាស់ អ្នកដែលធុំក្លិនថ្មីទៅថ្មីៗហ្នឹងគឺមិនបានដេកទេ គឺរវល់តែញេចសង្កើចហ្នឹង ។ ហើយនៅពេលដែលខ្ញុំ-- ដល់ពេលដែលខ្ញុំសម្រាលបានកូនរួចហើយ ខ្ញុំបានដេកចាក់ថ្នាំ ដោយមិនបានធ្វើការអីទេ គឺដេកចាក់ថ្នាំមួយអាទិត្យដែរ ។ ដូចយើងអត់មានអាំងភ្លើងជាឲ្យងអីទេ គឺយើង

ចាក់ថ្នាំ ។ អ៊ីចឹង ក្នុងអំឡុងពេលដែលយើងនៅសម្រាកពេទ្យហ្នឹង គឺយើងខ្វះ ខ្វះច្រើននូវប្រដាប់ប្រដាសម្រាប់កូនខ្ចី ។ សូមជម្រាបអង្គជំនុំជម្រះថា កាលហ្នឹងខ្ញុំមានសំពត់ពីរដែរ ដែលយកដោយជាប់នឹងខ្លួនទៅ យើងក៏សម្រេចយកសំពត់មួយធ្វើកន្ទបឲ្យកូន ។

ហើយអំពីអនាម័យ ខ្ញុំចង់និយាយថាអនាម័យសាប៊ូសម្រាប់សម្អាតថែទាំហ្នឹង គឺកាលនុ៎ង ដូចជាមិនចាំទេ ដូចជាគ្មានមិនដឹង អីមិនដឹងទេ ប៉ុន្តែធម្មតាដូចយើងកូនខ្ចី យើងប្រើសំពត់មួយ ដែលហែកទៅបានកន្ទបតែបួនគឺមិនគ្រប់គ្រាន់ទេ ។ វាពិបាកណាស់ ដែលចាប់បង្ខំឲ្យនាងខ្ញុំទៅរកស្លឹកចេកបន្ថែមដើម្បីធ្វើកន្ទបកូន ចៀសវាងៗប្រើអាកន្ទបបួនហ្នឹងដែលវាមិនគ្រប់ ។ វានឹកឃើញការឈឺចាប់ ពេលដែលយើងមានកូនខ្ចីហើយ កន្ទបប្រើមិនគ្រប់គ្រាន់ហើយ និងសាប៊ូមិនគ្រប់គ្រាន់និងការថែទាំទារក ។

ហើយនៅពេលដែលខ្ញុំកូនខ្ចីនៅកន្លែងហ្នឹងបានមួយអាទិត្យ គឺខ្ញុំនៅលើផ្ទះបានមួយអាទិត្យ ដោយមានមិត្តនៅ-- ដែលគេឆ្លងទន្លេមុនហ្នឹង គេជួយបម្រើ ជួយកន្ទបទៅគក់ ហើយពេលដែលខ្ញុំបានមួយអាទិត្យ គឺខ្ញុំត្រូវចុះមកក្រោមវិញ ដើម្បីងាយស្រួលក្នុងការថែទាំ ហើយចុះឡើងពីទឹកផុកអីហ្នឹង គឺយើងត្រូវតែក្លូកកន្ទបខ្លួនឯងនៅមាត់ស្ទឹង មិនជាឆ្ងាយប៉ុន្មានទេ ។ ប៉ុន្តែពេលហ្នឹងយើងឃ្លានដែរ យើង-- ដោយអាហារមិនគ្រប់គ្រាន់យើងចាប់បង្ខំយកកន្ទបហ្នឹងទៅក្រវីគក់ហ្នឹង ដើម្បីបានត្រីចង្វាមកធ្វើជាម្ហូបជាជំនួយថែមលើម្ហូបមានស្រាប់ដែលក្នុងកងហ្នឹង គេឲ្យ ។ ហើយពេលហ្នឹងទៅ ខ្ញុំបានស្រាមួយលីត្រដែរ នៅពេលដែលខ្ញុំឆ្លងទន្លេហ្នឹង គឺប្តីមុននឹងគាត់ចេញទៅ គាត់រកបានពន្លៃទុកឲ្យខ្ញុំ ព្រមទាំងដើមខ្ទុមសម្រាប់ផឹកពេលដែលយើងមានកូនខ្ចី ។ ហើយខ្ញុំក៏ព្យាយាមផឹកស្រាពន្លៃហ្នឹងអស់ ហើយខ្ញុំមិនសូវចេះហូបស្រាប៉ុន្មានទេ ខ្ញុំហូបម្តងតែមួយស្លាបព្រាបាយគឺយើងព្យាយាមហូបអស់ ។ វាៗពិបាកណាស់ ប៉ុន្តែទំហំនៃការលំបាកប៉ុនខ្ញុំនិយាយមិនអស់ និយាយមិនអស់និយាយមួយទៅនឹកឃើញមួយ ជំនួសដោយទឹកភ្នែក ។

ថ្ងៃនេះជម្រាប ខ្ញុំមិនដែលយំដូចពេលនេះទេ ។ ហើយខ្ញុំបង្កប់រឿងនេះសាមសិបពីរឆ្នាំហើយ ខ្ញុំទើបតែថ្ងៃនេះដែលខ្ញុំនិយាយ ។ ខ្ញុំនឹកឃើញរឿងមួយទៀត ដែលពេលហ្នឹង គឺឃើញគេយកអំបុកមកចេញបានមួយកំប៉ុងមួយម្នាក់ អ្នកដែលដេកពេទ្យ ។ ប៉ុន្តែពេលដែលចែកហើយ ប្រាប់ថាអំបុកហ្នឹង អ្នកកូនខ្ចីពេកហ្នឹង ហូបទៅទាស់ហើយ ប៉ុន្តែខ្ញុំឃ្លានៗ បែរទៅសួរបងពេទ្យថា បងចាច ខ្ញុំហូបបានទេ គាត់ថាហូបបាន ប៉ុន្តែបងឯងកុំទំពាអំបុកហ្នឹង ។ អ៊ីចឹង ខ្ញុំព្យាយាមហូបអំបុកហ្នឹងអស់ ក្នុងមួយថ្ងៃហ្នឹង ប៉ុន្តែខ្ញុំ បៀម បៀមហើយខ្ញុំអត់ទំពារទេ បៀមប្រឹងលេប ដើម្បីមានកម្លាំង ។ ហើយនឹកឃើញមួយ

ទៀត នៅ ពេលដែលខ្ញុំសរសៃខ្ចីហ្នឹង ដេកពេទ្យហ្នឹង ខ្ញុំទៅបេះផ្សិតកញ្ឆោរ ថ្ងៃទីមួយដែលមិនពុលទេ យើងហូបឆ្ងាញ់ជាមួយពេទ្យហ្នឹងផ្សំគ្នា ។ ដល់ថ្ងៃទីពីរ ពុល ចំា មិនដឹងពុលមកពីមូលហេតុអីឬក៏ថា ពស់វានោមដាក់ ប៉ុន្តែយើងស្គាល់ច្បាស់ថា ផ្សិតហ្នឹងជាផ្សិតកញ្ឆោរ គឺយើងខ្ចប់អាំងស្លឹកចេក ប្រឡាក់អំបិលតិចៗទៅ ហូបទៅមានជាតិមានកម្លាំង ។ អ៊ីចឹងនៅពេលដែលយើងពុលផ្សិត ពេទ្យនោះក៏ពុលដែរ គឺបានហូបជាមួយគ្នា ។ យើងមិនរាកទេ តែយើងក្អួត អ៊ីចឹងពេទ្យហ្នឹង ក៏កោសខ្យល់ឲ្យខ្ញុំ ហើយពេទ្យហ្នឹងក៏ចាក់ថ្នាំឲ្យខ្ញុំ ដើម្បីបន្សាបជាតិពុល ហើយពេទ្យហ្នឹងក៏ចាប់បង្ខំឲ្យមិនថា នេះដើម្បីជីវិតរស់ទាំងអស់គ្នា ខ្ញុំមិនចេះចាក់ផង គាត់ឲ្យខ្ញុំ គាត់បូមថ្នាំហើយគាត់ឲ្យខ្ញុំចាក់ជើង-- ចាក់ភ្លៅគាត់ហ្នឹង ។ ប៉ុន្តែកូនខ្ញុំយប់នេះ អត់បានបៅទេ ដោយពេទ្យហ្នឹងហាមថា បើសិនជាឲ្យកូនបៅ កូនហ្នឹងត្រូវពុលដែរ ។ អ៊ីចឹងពេទ្យនោះក៏ឲ្យ គាត់មានស្ករសខ្លះដើម្បីឲ្យកូនខ្ញុំផឹកទឹកស្ករសហ្នឹងទល់ភ្លឺ លុះត្រាតែខ្ញុំហ្នឹងលែងបាត់ពុលបាន បានខ្ញុំឲ្យកូនខ្ញុំបៅ ។ ហើយយប់ហ្នឹង គឺយើងភ័យណាស់ខ្លាចគេដឹង ដោយយើងលួចទៅបេះបន្លែក្រៅផ្សេងយកមកហូបអ៊ីចឹង ហើយដល់មានពុលអ៊ីចឹងយើងភ័យ ។

ហើយខ្ញុំសូមភ្ជាប់នឹងការដេកនៅដែលថា ថ្ងៃយើងមកដល់ថ្ងៃទីមួយហ្នឹង កន្លែងផ្សេងទៀតដែលខ្ញុំធ្លាប់ទៅរស់នៅដូចជាព្រៃស ដែលយើងនៅមួយរយៈខ្លី ហើយយើងនៅអាផ្ទះមុខព្រៃស ជាមន្ទីរ ហើយមន្ទីរមុខព្រៃសហ្នឹងជាពីមុនមកជាកន្លែងដែលគេដាក់ប្រុសៗ ហើយនិងផ្ទះក្នុងបាគូក៏ជាផ្ទះដែលគេធ្វើថ្មីដែរ គឺគេសង់ពីរសម្រាប់ឲ្យអ្នកទោសហ្នឹងនៅ គឺសុទ្ធតែចាក់សោរដូចគ្នា ។ អ៊ីចឹង រយៈពេលដែលនាងខ្ញុំរស់នៅកន្លែងនេះ ខ្ញុំកាលហ្នឹងវាដឹងបន្តិចៗ គ្រាន់ថាជាកន្លែងចលត់ដំ កែប្រែ ។

ខ្ញុំសូមនិយាយទៅដល់ពេលដែលខ្ញុំចេញពីមន្ទីរពេទ្យ ដែលក្រោយពីកូនខ្ញុំស្លាប់វិញ ហើយពេលហ្នឹងគឺកម្លាំងខ្ញុំ គឺគេលែង ខ្ញុំចង់និយាយថា គេលែងប្រណី គឺយើងបាត់បង់កូនហើយ អ៊ីចឹងយើងនៅម្នាក់ឯង គឺគេប្រើដោយគ្មានញញើតអីទៀតទេ ។ ពេលហ្នឹង គឺគេប្រើយើងគ្មានញញើតអីទៀត ។ ខ្ញុំនឹកឃើញព្រឹត្តិការណ៍មួយនៅឆ្នាំ៧៨ ជាឆ្នាំទឹកធំ ហើយនៅបាគូហ្នឹង មានការបាក់ទំនប់ ហើយគេក៏រើផ្ទះឲ្យយើងនៅទៅមុខមន្ទីរព្រៃសហ្នឹង ដែលជាកន្លែងប្រុសៗនៅហ្នឹង ជាដំបូងដែលខ្ញុំទៅឃើញហ្នឹងគឺពិតជាឃើញកន្លែងគេឃុំខ្លួនប្រុសៗ គឺគេដាក់ជាឈើផ្ទាន ឈើផ្ទានហ្នឹង គេវាលសម្រាប់ដាក់កជើងអ្នកទោសហ្នឹង ហើយគេដាក់ដែករនុកខ្នាស់ ចាក់សោ។ ប៉ុន្តែ ដល់ពេលពួកខ្ញុំទៅ ខ្ញុំគ្រាន់តែឃើញៗទេ ។ ពួកខ្ញុំហ្នឹង គេមិនបានដាក់ចូលដូចប្រុសៗទេ ប៉ុន្តែ ដេកយប់ចាក់សោដូចគ្នា ប៉ុន្តែគេគាស់អាឈើផ្ទានហ្នឹងចេញ ដើម្បីងាយស្រួលក្នុងការសណ្ដូកជើង ។

[០៩:៣៩:០៥]

ខ្ញុំនៅតែមានអារម្មណ៍ឆ្ងល់រហូតទាល់តែដល់ពេលសក្ខីកម្ម ជិន ម៉េត ដែលធ្លាប់នៅជាមួយគ្នាហ្នឹងឡើងថាទៅធ្វើការយប់ ។ ពេលដែលខ្ញុំនៅហ្នឹងដំបូង ខ្ញុំចេះតែឆ្ងល់ ចុះក្រុមណាក៏លឿនម្ល៉េះ ព្រលឹមឡើងពួកដែលខ្ញុំទៅដល់ស្ទូងហ្នឹង គឺសំណាបគេរាយអស់ហើយ ពេញស្រែ ហើយមិនដឹងជាគេភ្ជួររាស់ពីថ្មើរម៉ានទេ ពួកខ្ញុំទៅដល់ស្រែហ្នឹងគឺ ស្រែហ្នឹងគឺគេភ្ជួររាស់ហើយ ហើយសំណាបគេរាយឱ្យយើងរួចហើយស្រេច មិនឱ្យយើងពិបាកក្នុងការដើរយកសំណាបស្ទូងអស់មួយកណ្ដាប់ៗហ្នឹងទេ ។ ចេះតែឆ្ងល់ ហើយទើបម្ងៃមុនទេ បានខ្ញុំថា អូ៎ ក្រុមកង១៧ហ្នឹង ។ ហើយ ម៉េត ដែលធ្លាប់នៅហ្នឹង ក៏ខ្ញុំមិនចាប់អារម្មណ៍ថា បានជួប បានស្គាល់ដែរ ទើបស្គាល់នៅថ្ងៃបើកអង្គសេចក្ដីទេ ដែល ម៉េត ឃើញខ្ញុំហើយគេស្គាល់ខ្ញុំមុន ព្រោះគេនៅក្មេង គេចាំខ្ញុំបានច្បាស់ ដោយខ្ញុំកាលនុ៎ង ឆ្នាំ៧៨ហ្នឹង គឺមានភារៈគេឱ្យចែកទូកព្រោះខ្ញុំចេះចែកទូក ដើម្បីដឹកនាំពាំងដីហ្នឹងយកមកទប់ទំនប់ហ្នឹង ។ ប៉ុន្តែ ចៃដន្យទប់វាមិនឈ្នះហ្នឹង បាក់ទំនប់ហ្នឹង ។ ហើយពេលដែលបាក់ទំនប់ធ្លាយហ្នឹង គឺបាក់ចំមុខប្រធានកងហ្នឹងទៀត អ៊ីចឹងវាបាត់មាត់ដូចគេចុក ហើយនៅពេលដែលបាក់ទំនប់ធ្លាយហ្នឹង គឺក្នុងរយៈពេលមួយយប់ហ្នឹង គឺទឹកល្ហល្ហេវដូចសមុទ្រមើលលែងឃើញសន្ទូងហើយ ។ ហើយកម្លាំងយើងស្រីៗមិនមានលទ្ធភាពអីទៅទប់ៗអាកន្លែងបាក់ហ្នឹងឈ្នះទេ គឺបណ្ដោយឱ្យវាហូរទាល់តែស្មើៗគ្នាបានទប់ ហើយទប់ហ្នឹងគឺខ្ញុំឃើញគេដឹកយកកម្លាំងប្រុសៗមករែចម្រឹង ហើយគេយកបាវ ហើយមានឡានអីដឹកដីរែកនាំគ្នាជញ្ជូនដាក់បាវទប់ បានម៉្ញូឡើងទៀតបានមានម៉ាស៊ីនគ្រប់ទិស បូមទឹកចេញពីៗកន្លែងទឹកទន្លេលេចហ្នឹង ។

ហើយខ្ញុំចេះតែឆ្ងល់ខ្ញុំថា ស្រូវធ្វើបានខ្លាំងណាស់ ហេតុអីក៏ពួកយើងហូបមិនឆ្អែត ហើយនៅឆ្នាំ ៧៨ ហ្នឹងទៀត ពេលហូបហ្នឹងគឺ គេប្រកាសថា យើងលេចអស់ហើយ អ៊ីចឹងយើងត្រូវហូបបាយលាយពោត ។ ខ្ញុំកាលនោះ ក្រពះមិនធានាដោយយើងឆ្លងកាត់ពីសង្គ្រាម អ៊ីចឹងយើងហូបបាយលាយពោតអត់បានទេ ពោះខ្ញុំកាលនោះ តែដាក់បាយលាយពោតទៅ គឺត្រូវតែឆ្អល់ រាក ។ អ៊ីចឹងខ្ញុំត្រូវកេះយកតែគ្រាប់អង្ករទោះបីក្នុងមួយចានហ្នឹងបានតែមួយស្លាបព្រាក៏ដោយ ក៏ប្រឹងហូបដែរមិនឱ្យមានលាយពោត អ៊ីចឹងសុខភាពខ្ញុំពេលនោះ ត្រូវចុះៗស្រឹតៗ ។ តែការរស់នៅរបស់ខ្ញុំពេលនោះ គឺខ្ញុំមិនដែលមានទឹកភ្នែកមួយតំណក់ទេ គ្មានទេ គឺយើងលត់ដំអារម្មណ៍យើង ដើម្បីឱ្យគេមើលឃើញថា យើងពេញចិត្តនឹងការងារលត់ដំ ធ្វើស្រែ ។

[០៩:៤២:២១]

បើសិនជាយើងទឹកភ្នែកដូចពេលនេះ ប្រហែលជាមិនរស់ទេ ព្រោះរយៈពេលដែលយើងនៅកន្លែងនោះយូរៗ ហើយខ្លួនខ្ញុំហ្នឹងយូរជាងគេ ខ្ញុំមិនដឹងថា ខ្លួនខ្ញុំមានចំណុចពិសេសអី ដែលគេមិនយកទៅកម្ទេច ខ្ញុំអត់ដឹង ចេះតែនៅទៅ ប្រឹងធ្វើការលត់ដំអារម្មណ៍យើងដើម្បីរស់ ។ ហើយពិបាកណាស់ ខ្ញុំចេះតែឆ្ងល់ ពេលខ្លះ ខ្ញុំបែរបន្តិចដែលនឹកឃើញ កាលដែលខ្ញុំនៅស្ទឹងជ្រៅ អ្នកដែលបញ្ជូនទៅៗហ្នឹងគឺនៅមិនបានយូរទេ យ៉ាងយូរដប់ថ្ងៃ គឺត្រូវមានអ្នកថ្មីមក ។

ហើយនៅឯបាគូនោះវិញ គឺមិនសូវឃើញមានអ្នកចេញចូលអីប៉ុន្មានទេ ប៉ុន្តែ ខ្ញុំក្រឡេកភ្នែកទៅឃើញឡានដឹកយុទ្ធជន ដែលផ្ទះសង់តាមមាត់ស្ទឹងហ្នឹង ព្រោះក្នុងហ្នឹងគេមិនឲ្យនៅជុំគ្នាទេ គេប្រុសស្រីនៅផ្សេងពីគ្នា ។ ប៉ុន្តែ យើងអាចមើលឃើញឡានដែលគេដឹកទាំងឡានៗចេញចូលហ្នឹង គឺច្រើនប្រុសៗហើយចំណែកពួកខ្ញុំហ្នឹងដូចរាងរយាល ដល់ពេលទៅបាគូរាងរយាលការដឹកចេញ មុនដូចកាលនៅស្ទឹងជ្រៅទេ ។ ប៉ុន្តែ នៅពេលហ្នឹង ខ្ញុំបានឃើញគេដឹកនិស្សិតបញ្ញវន្តចូលនៅម្តុំផ្ទះ លន់ ណុន បងប្អូន លន់ នល់ តែនៅយើងមិនដឹងទេ យើងសួរគេថា “ចុះពួកណាៗដែលមកអត់ទាន់ដូរខោអាវហ្នឹង?” គេថា “ពួកនិស្សិត បញ្ញវន្តគេមកពីក្រៅមកធ្វើ ទស្សនកិច្ច” ។ ខ្ញុំថា “អ្ហឺ! មកធ្វើទស្សនកិច្ច ដូចអត់ដឹងខ្លួន” ។

កាលដែលខ្ញុំរស់នៅកន្លែងហ្នឹង គឺតាមពិតកាលនោះខ្ញុំមាត់នៅដែរ ខ្ញុំមិនសូវបណ្តាក់ប៉ុន្មានទេ គឺខ្ញុំឃើញអ្វីខ្ញុំថា ខ្ញុំសួរ ហើយពាក្យសំណួរមួយដែលខ្ញុំនៅចាំជាពាក្យសំណួរដែលខ្ញុំសួរទៅ ហើយគេឆ្លើយមកវិញថា “ពួកអស់ហ្នឹងដែលទៅៗហ្នឹង គឺទៅអូរខ្វែះ” ។ ហើយខ្ញុំថា “ចុះអូរខ្វែះហ្នឹងនៅទីណា?” គេថា “ក៏ចង់ដឹងម្ល៉េះ មើលតាមផែនទីទៅ” ។ អ៊ីចឹងក្រោយព្រឹត្តិការណ៍៧៩មក ខ្ញុំមកអង្គុយមើលផែនទីប្រទេសកម្ពុជាយើង វាមិនឃើញអាភូមិអូរខ្វែះហ្នឹងសោះ ។ ខ្ញុំនៅតែចម្ងល់រហូតមកដល់សព្វថ្ងៃហ្នឹង ហើយបានខ្ញុំដឹងតាមរយៈសវនាការថា អូ៎អាអូរខ្វែះហ្នឹង គឺការកម្ទេចចោលយ៉ាង តែគេមិនប្រាប់យើងត្រង់ពាក្យ ជាអូរខ្វែះហ្នឹង ។ អ៊ីចឹង ខ្ញុំនៅបាគូនោះ រហូតដល់ឆ្នាំ៧៨ ពេលហ្នឹងខ្ញុំបានច្រូតនៅហ្នឹងដែរ ស្រូវទុំពេលច្រូតហើយប្រហែលជាខែ១២ ៧៨ហ្នឹង រយៈពេលមិនទាន់ឈានដល់ថ្ងៃខែមករា ៧៩ទេ គឺយើងបានទៅលើកទំនប់ ។ ទំនប់ហ្នឹង គឺខ្ញុំមិនចាំទេ គឺយុទ្ធជនគេនៅផ្នែកផ្សេងទៅដែលយើងមើលទៅឃើញដែរ ហើយពួកនារីៗហ្នឹង នៅផ្សេងទៅ ប៉ុន្តែគឺមានមេក្រូគេចាក់ចម្រៀងបដិវត្តន៍ហ្នឹង ទ្រហឹងអឺងកង ពេលនោះខ្ញុំទៅបានតែមួយអាទិត្រទេ ខ្ញុំរែកដីឡើងទំនប់លែងរួចហើយ ។

[០៩:៤៥:៤៨]

ពេលដែលខ្ញុំរែកដីឡើងទំនប់លែងរួចហ្នឹង គឺឲ្យខ្ញុំកាប់ ប៉ុន្តែខ្ញុំថា ខ្ញុំសូមប្រើអាការងារណាដែល

កាន់ដងចបហ្នឹង ព្រោះដៃខ្ញុំវាមិនមានកម្លាំងទេ ម្ខាងទៀតហ្នឹង វាមានតែម្ខាងអ៊ីចឹង អ៊ីចឹងគេក៏អនុញ្ញាតឲ្យខ្ញុំឡើងទៅលើទំនប់ ហើយឈរតប់ដីលើខ្នងទំនប់ ។ ព្រឹត្តិការណ៍មួយទៀត ដែលខ្ញុំចាំដោយល្បិចរបស់ខ្ញុំហ្នឹងថា បើសិនជាយើងនៅតែមិនមានត្បិតពុតត្បុតសម្រាប់ជីវិតទេគឺយើងស្លាប់ ។ ចួនកាលខ្ញុំធ្វើពុតឈឺដែរ ធ្វើពុតឈឺហ្នឹងខ្ញុំដើរៗទៅខ្ញុំលូកឲ្យក្អួតទៅ ខ្ញុំប្រាប់គេថា ខ្ញុំទៅមិនរួចទេថ្ងៃហ្នឹង មិនស្រណុកខ្លួន ។ គេថា បើអ្នកឈឺដេកពេទ្យស៊ីបបរ ខ្ញុំថាបបរក៏ហូបដែរ ។ អ៊ីចឹង វាធូរកម្លាំងបានមួយពីរអ៊ីចឹងវាគ្រាន់បើជាងយើងទៅធ្វើការ នេះខ្ញុំសូមរំឭកឡើងវិញនូវៗការចងចាំរបស់ខ្ញុំ ហើយមានច្រើនណាស់ដែលខ្ញុំព្យាយាមខំរំឭកឡើងវិញនូវរឿងរបស់ខ្ញុំហ្នឹង តែរឿងខ្លះរំឭកមិនឃើញ រឿងខ្លះនឹកឃើញ ហើយតែចួនកាលទៅនិយាយមិនអស់ ។

ហើយនៅពេលដែលខ្ញុំនិយាយទៅវាចេះតែសាចុះសាឡើងនៅក្នុងអាប្តុកកន្លែងដែលយើងឆ្លងកាត់ហ្នឹង អំមិញយើងនិយាយដល់ទៅការលើកទំនប់តែភ្លេតឡើងយើងនឹកឃើញដល់ការដែលយើងទូលកណ្តាប់ ព្រោះពេលដែលយើងដកហើយឡើងពីស្ទូង យើងទៅដកហ្នឹងវាគ្រាន់តែកាលហ្នឹង គ្រាន់អ៊ីចេះគ្រាន់ត្រង់ថា ដកសំណាបបើសិនជាយើងដកមិនបានម្នាក់មួយផ្លូនទេ គឺមិនបានឡើងសម្អាតរាងកាយងូតទឹកអីទេ គឺគេឲ្យយើងដក គ្រាន់តែខ្ញុំពូកែដកសំណាបបោកហ្នឹងខ្នងជើង ពេលដែលសំណាបជាប់ដីហ្នឹង គឺយើងបោកហ្នឹងម្រាមជើងវាមិនសូវស្អាត មិនសូវលឿន ។ អ៊ីចឹងខ្ញុំបានហ៊ុនគ្នាពីរបីនាក់អ៊ីចឹងទៅខ្ញុំថា ពីណាចង ពីណាជ្រំ ខ្ញុំអ្នកផានាដកចុះ ។ អ៊ីចឹងយើងដកបានលឿនហើយយើងមានពេលមុនគេឡើងមកសម្អាតមុជទឹក ហើយមុជទឹកហ្នឹងគឺយើងមិនទៅមុជទឹកឯណាឆ្ងាយមុជទឹកស្រែហ្នឹងដដែលហ្នឹង ។ មុជទឹកស្រែហ្នឹង ហើយយើងគក់ មុជហើយហើយសម្អាតខ្លួនប្រាណហើយគក់ខោអាវយើងហ្នឹង យើងផ្លាស់ហើយយើងពូតឲ្យស្ងួតទៅយើងស្លៀកទៅវិញទៅ ដល់ពេលយើងមកផ្ទះយើងយកអាស្ងួតទៅស្លៀកទៅ ហើយយើងយកអាហ្នឹងហាលទៅព្រលឹមឡើងយើងស្លៀក ។ អ៊ីចឹង កាលហ្នឹងគ្រាន់តែជម្រាប់ថា គេមិនមានដកសម្ភារៈខោអាវខ្ញុំអីទេ គឺយើងរយៈពេលពីរឆ្នាំហ្នឹង គឺយើងមានខោអាវបួនកំប្លេដែរ គឺសំពត់ពីរកំប្លេ ប៉ុន្តែសំពត់ហ្នឹងខ្ញុំធ្វើកន្ទបអស់មួយទៅនៅសល់តែមួយ អ៊ីចឹងយើងមានខោពីរកំប្លេហ្នឹងសម្រាប់ផ្លាស់ប្តូរ និងសំពត់មួយសម្រាប់ផ្លាស់ប្តូរ ។

[០៩:៤៨:៥៣]

ហើយនៅពេលដែលថ្ងៃ០៦ មករា ចាំ ខ្ញុំនិយាយឲ្យលឿនបន្តិចចុះ នឹកទៅវាអត់ទាន់ឃើញភ្លាមៗជួនកាលអាចនិយាយហើយបាននឹកឃើញតាមក្រោយ បាននិយាយ ដល់ថ្ងៃទី០៦ មករា ថ្ងៃហ្នឹងអត់មាន

ទៅធ្វើពលកម្មទេ ហើយយើងក៏អត់ដឹងពីសភាពការណ៍នៅទីក្រុងភ្នំពេញដែរ ។ ហើយចេះតែនាំគ្នាឆ្ងល់ហេតុអីក៏ថ្ងៃហ្នឹងពួកាំភ្លើងជិតម្លេះ? ហើយចុះថ្ងៃហ្នឹងហេតុអីគេមិនឲ្យយើងទៅធ្វើការ? គេប្រាប់ថាឲ្យយើងត្រៀម ត្រៀមទៅកន្លែងផ្សេង យើងក៏ត្រៀមហូបបាយហូបទឹកហើយ ហើយយើងអត់បានចេញទៅពេលថ្ងៃទេ គឺពេលយប់ ។ យើងគេប្រាប់ថា ចាំយើងចាំជុំគ្នា អ៊ីចឹងយើងបានត្រៀមខោអាវយើងវ៉ាឡូយើងមិនជាច្រើន គឺម៉ាសម្ពាយៗនៅខ្ទងហ្នឹង អង្គុយចាំលើខ្នងទំនប់ហ្នឹង ម៉ោងប្រហែលជាប្រាំពីរកន្លះ ឬប្រាំបីហ្នឹង បានគេថា អ្ហ៎! តោះយើងទៅចំា ។ ពេលទៅហ្នឹងពេលហ្នឹង គឺយើងទៅពេលយប់ហ្នឹង គឺយើងមិនដឹងទិសតំបន់ភ្លេចភ្លាំងកន្លែងណាៗ ព្រោះណាមួយវាយូរហើយ យើងអត់ស្គាល់ភូមិសាស្ត្រ។

កាលដែលយើងទៅហ្នឹង គេប្រាប់ដែរភូមិណាៗ តែយើងភ្លេចអស់ គ្រាន់បានថាទៅៗហ្នឹង គ្រាន់តែដល់ភ្លឺឡើងយើងទៅដល់ចម្ការឪឡឹកមួយហ្នឹង មិនដឹងដឹងជាអ្នកណាអ្នកណាខ្លះទេ ឃ្លានចេះតែនាំគ្នាកម្ទេចចម្ការឪឡឹកហ្នឹងហូប ។ ម្នាក់មួយម្នាក់ពីរទៅអស់ មិនដឹងជាចម្ការរបស់អ្នកណាផង សហករណ៍មិនដឹង របស់ប្រជាជនមិនដឹង របស់អង្គភាពមិនដឹងទេនាំគ្នាហូប ។ អ៊ីចឹងរយៈពេលដែលយើងទៅដល់មិនដឹងជាកន្លែងណាៗ ប៉ុន្តែគ្រាន់តែខ្ញុំចាំបានថា នៅថ្ងៃមួយក្រោយពី៧ មករា បន្តិចហ្នឹងទៅ គឺនៅចន្លោះភ្នំជរាយ គឺភ្នំជរាយ គឺនៅក្នុងស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ហើយនិងនៅចន្លោះអមលាំង ។

ពេលហ្នឹងមុនដែលគេរើគ្នានៅអមលាំង គឺខ្ញុំបានជួបលោក ឌុច ជនជាប់ចោទ ដែលយើងតទល់គ្នានៅថ្ងៃនេះ ។ ជួបហ្នឹងជួបអ៊ីចេះទេ មិនមែនយើងទៅជួបគាត់ទេ គឺប្រធានកងហ្នឹង គេរាយការណ៍ប្រាប់ថាខ្ញុំហ្នឹងមានគំនិតរត់ តាមពិតខ្ញុំរត់មែន ប៉ុន្តែរត់វាមិនរួចវាជាប់ខ្សែត្រៀម។ អ៊ីចឹង គេរាយការណ៍ទៅ អ៊ីចឹងពេលហ្នឹង គេនាំខ្ញុំទៅជួប ខ្ញុំឃើញគាត់អង្គុយនៅក្នុងផ្ទះមួយសង់អំពីឫស្សី ដែលគេទើបសង់ថ្មីៗទេ ហើយរនាបគេក្រងប្រក់ដំបូលស្លឹក ។ ហើយចៃដន្យអីអ្នកដែលនាំខ្ញុំទៅហ្នឹងគេជិះសេះ ហើយគេស្គាល់ខ្ញុំច្បាស់ តែខ្ញុំអត់ស្គាល់គេទេ រកនឹកមិនឃើញទេ ទល់ឥឡូវហ្នឹង ។ គេភ្ញាក់ពេលដែលឃើញខ្ញុំទៅដល់កន្លែងហ្នឹង គេភ្ញាក់ រួចហើយគេថា "បងៗមកហ្នឹងដែរ?" ខ្ញុំថា "ម៉េចក៏ស្គាល់ខ្ញុំ?" "អ្ហេ! ស្គាល់ច្បាស់ណាស់អត់ភ្លេចគុណបងឯង" ខ្ញុំថា "មានគុណអីឲ្យ?" "អ្ហ៎កាលបងឯងនៅសមរភូមិ យក បាយឲ្យខ្ញុំហូប ខ្ញុំឧស្សាហ៍ចូលផ្ទះបងឯង ហូបបាយផ្ទះម៉ែ" ខ្ញុំថា "ខ្ញុំមិនចាំទេ" "បងឯងកុំភ័យ បងឯងទៅកន្លែងខ្ញុំឆ្ងាញ់ណាស់ បងហូបបរិបូរណ៍" ។ ខ្ញុំថា "មិនបាច់ភូតទេៗ ប្អូនឯងមិនបាច់ភូតទេ" ហើយគេឲ្យខ្ញុំឡើងជិះសេះជាមួយតែខ្ញុំបដិសេធ ខ្ញុំថា "មិនជិះទេ ខ្ញុំមិនចេះជិះទេ ខ្លាចធ្លាក់" រួចក៏គេបណ្តើរខ្ញុំតាមសេះហ្នឹង តាមផ្លូវតូច ។ ប៉ុន្តែ ខ្ញុំនៅចាំបានព្រៃដែលខ្ញុំទៅជួបលោក ឌុច ហ្នឹង គឺមិនជ្រៅទេព្រៃហ្នឹង

គឺមិនចូលដល់ព្រៃជ្រៅទេ គឺព្រៃដែលថាយើងហៅថា ព្រៃល្បោះៗតិចៗហ្នឹង ។ អ៊ីចឹងថ្ងៃដែលខ្ញុំជួបហ្នឹង រួចខ្ញុំក៏មិនភ័យដែរ ខ្ញុំមិនខ្លាច កាលហ្នឹងក៏ខ្ញុំមិនខ្លាចដែរ ។

ពេលដែលខ្ញុំជួបហ្នឹង គេហៅទៅដល់ជួប លោក ឌុច ហ្នឹង ជាទម្លាប់របស់ខ្ញុំៗជម្រាបសួរ ។ កាលហ្នឹងខ្ញុំមិនហៅលោកអ៊ីចឹងទេ ខ្ញុំហៅ “បង” ហើយខ្ញុំក៏មិនប្រើពាក្យ “សមមិត្ត” ដែរ ខ្ញុំហៅ “បង” ពេញមាត់ ជម្រាបសួរធម្មតា ។ ខ្ញុំនៅចាំ គាត់អង្គុយពែននៅគ្រែឫស្សីហ្នឹង ខ្ញុំនៅឈរ ស្រាប់តែដក កាំភ្លើងខ្លីពីចង្កេះភ្ជង់សៀតផ្កាខ្ញុំ ។ ប៉ុន្តែ ខ្ញុំក្រឡេកភ្នែកទៅហ្នឹងកាំភ្លើងខ្លីគាត់ហ្នឹង មិនបើកសោទេ អ៊ីចឹង ខ្ញុំមិនមានអារម្មណ៍ភ័យទេ ។ ប៉ុន្តែ ពេលហ្នឹងខ្ញុំត្រៀមខ្លួន រួចខ្ញុំដកខ្លួនមួយកន្លះជំហាន ដើម្បីត្រៀម ជំហរ ។ ខ្ញុំថា ខ្ញុំតាំងចិត្តបើសិនជាមានហេតុការណ៍អីមួយមិនស្រួល ខ្ញុំនឹងប្តូរស្លាប់ប្តូររស់ដណ្តើម កាំភ្លើងគ្នាហើយពេលហ្នឹង ប៉ុន្តែវាចៃដន្យដែរដែលខ្ញុំពេលហ្នឹង ខ្ញុំអត់ភ័យខ្ញុំតក់ស្លុត ហើយខ្ញុំនៅតែឆ្លើយ ជាមួយគាត់ញឹមញែមៗ ហើយគាត់មិនបានសួរឈ្មោះខ្ញុំ គ្រាន់តែសួរថា “មិត្តនារីឯងមកប៉ុន្មានថ្ងៃ ហើយ?” ខ្ញុំគ្រាន់តែជម្រាបថា “ចាស! បង ខ្ញុំមកតាំងពី៧៧” ។ គាត់ដូចជាភ្ញាក់ខ្លួន “អ្ហឺ!ម៉េចមិត្តនារី ឯងនៅបានយូរម្ល៉េះ? ហើយមិត្តនារីឯងដឹងដែរ ដឹងមានរឿងអីមកនេះ?” ខ្ញុំថា “អត់ដឹងទេ” ។ “យីមិត្ត នារីឯងអ៊ីចឹងគ្រាន់បើ” នេះជាការសរសើររបស់គាត់កាលណោះ ។

[០៩:៥៤:៣៦]

ហើយគាត់ថា អ៊ីចឹងកុំអាលទៅកងវិញអី នៅហ្នឹងហើយ ប៉ុន្តែ ទទួលបានមួយថ្ងៃក្រោយមកក៏ មានព្រឹត្តិការណ៍វ៉ៃគ្នាប្រាវៗទៅបានរត់ៗទៅក៏មិនទាន់បែកពីកងហ្នឹងទៀត គឺទៅដល់អាភូមិមួយខ្ញុំអត់ ចាំទេ នៅក្បែរអមលាំងហ្នឹង ពេលដែលសម្រាកហ្នឹង ។ ខ្ញុំនឹកឃើញ ខ្ញុំមិនស្គាល់ប្រពន្ធគ្រួសាររបស់ គាត់ទេ របស់លោក ឌុច ខ្ញុំមិនស្គាល់ទេ ។ ប៉ុន្តែ មានអ្នកផ្សេងដែលនៅក្បែរខ្ញុំ គេខ្សឹបប្រាប់ថា “នុ៎ង ហើយប្រពន្ធលោកប្រធានយើង” ប៉ុន្តែខ្ញុំក្រឡេកភ្នែកទៅឃើញគាត់បីកូន ហើយនៅពេលដែលធ្វើដំណើរ បាក់ទ័ពទៅតាមផ្លូវហ្នឹង គឺមានប្រុសមានស្រីសុទ្ធតែទ័ពហ្នឹង សុទ្ធមានប្រជាជនខ្លះអីខ្លះ មានបាំងឆ័ត្រ ឱ្យ ហើយមានអ្នកយួរបាឡូ ហើយយើងនៅអង្គុយមើលធម្មតាមិនចាប់អារម្មណ៍ទេ គេគ្រាន់តែប្រាប់ ប៉ុណ្ណឹង ។ ប៉ុន្តែខ្ញុំមិនច្បាស់ទេ ព្រោះពីផ្លូវដើរមកៗកន្លែងដែលយើងអង្គុយហ្នឹង ប្រហែលជាម្ភៃម៉ែត្រ ហ្នឹង អ៊ីចឹងយើងមិនចាប់អារម្មណ៍ប៉ុណ្ណឹង ប្រាប់ក៏ប្រាប់ទៅយើងគ្រាន់តែដឹង ប៉ុន្តែយើងគ្រាន់តែយើង ចាំ ។ ដល់អ៊ីចឹងយើងថា ហេតុតែគេមេ ហេតុតែគេធំណាស់ សូម្បីតែពេលទឹកច្រមុះហើយក៏នៅតែមាន គេយកចិត្តទុកដាក់ថែទាំ ចំណែកយើងកាលដែលយើងនៅៗឆ្លងទន្លេ សូម្បីតែសាប៊ូអនាម័យកូន សូម្បី

តែកន្ទបក៏គ្មាន ។ ប៉ុន្តែមិនចាប់អារម្មណ៍ឈ្មោនីសព្យាបាទអីទេ ធម្មតាគ្រាន់តែមានអារម្មណ៍គិតអ៊ីចឹងទៅហីទៅ ។ ហើយពេលហ្នឹង ខ្ញុំព្យាយាមរត់ណាស់ រត់ចេញ ប៉ុន្តែរត់មិនរួច ដោយមានសេះគៀងជាប់តែបែកខ្ញែកបន្តិច គឺសេះហ្នឹងមកដល់ហើយ រំពាត់ខ្សែតីមួយឆ្វាត់ៗអ្វឹះៗ ណាមួយគ្រាប់ណាមួយខ្ទាចទៅប៉ះផង ។

អ៊ីចឹងរយៈពេលហ្នឹង នៅថ្ងៃដែលគេបាញ់គ្នានៅអមលាំង ខ្ញុំនៅរៀងឆ្ងាយដែរ ។ យើងមិនបានសំដៅទៅអមលាំងទេ គឺយើងរត់កាត់ទទឹងចូលព្រៃ ។ តាមខ្ញុំដឹងចាំបានខ្លះៗ គឺយើងរត់តាមទៅតាមបណ្តោយជួរភ្នំពីស ប៉ុន្តែពេលហ្នឹង ខ្ញុំមិនសូវជាចំណាំទិសត្បូងលិចកើតទេ ខ្ញុំច្រើននិយាយថា ស្តាំឆ្វេងៗព្រោះវង្វេងហើយ មិនដឹងថាអីណា អីណីទេ គ្រាន់តែចាំបានថា អមលាំង ជើងភ្នំជរាយ ស្រុកកំពង់ត្រឡាចអីអ៊ីចឹងចាំបាន ប៉ុន្តែឲ្យប្រាកដប្រជាថា ភូមិនេះៗឲ្យច្បាស់វាភ្លេច ។ ហើយមូលហេតុនៃការភ្លេចហ្នឹង មកពីខ្ញុំទេ តាំងស្មារតីថាខ្ញុំនឹងបំភ្លេចឲ្យអស់ តាំងពីឆ្នាំ៧៩ រហូតដល់ឆ្នាំ២០០៥ ទើបមានការស្រាវជ្រាវពីមជ្ឈមណ្ឌលឯកសារបានខ្ញុំខំរំឭកដែរ តែរំឭកវាអត់ចេញរឿងគេ វាចេញអារឿងខ្លួនឯងហ្នឹងច្រើនជាង អ៊ីចឹងអាហ្នឹងក៏ល្អដែរ ចេញរឿងខ្លួនឯងច្រើនជាង ។

[០៩:៥៧:៣៧]

អ៊ីចឹង រយៈពេលដែលខ្ញុំទៅនៅក្នុងព្រៃមិនមែនធម្មតាទេ គឺខ្ញុំឃើញស្រូវជង្រុកច្រើនណាស់ ដែលគេសង់ហើយ គេជម្លៀសពីជង្រុកមួយទៅដាក់ជង្រុកមួយ ហើយពេលហ្នឹង គឺយើងបាត់ឃើញអ្នកគ្រប់គ្រងដែលយើងធ្លាប់ឃើញពីមុននៅឯកង១៤ហើយ ប៉ុន្តែ ចេះតែឆ្ងល់ចុះអានីរសារពិសេសសម្រាប់ចាត់ចែងការងារហ្នឹងវានៅត្រង់ណាក៏វាច្បាស់ម្ល៉េះ ហើយធ្វើការក៏ភ្លែតៗម្ល៉េះ។ អ៊ីចឹង យើងនៅក្នុងព្រៃហ្នឹងយូរៗទៅដាច់រយៈទាក់ទងអស់ ហើយណាមួយចិត្តខ្ញុំព្យាយាមបំបែកចេញផង គឺទាល់តែខ្ញុំនៅតែឯងលែងមានពីណាស្គាល់បានយើងចេញរួច ។ ហើយចេញរួចហ្នឹងសុំគេនៅណោះនោះៗ គឺខ្ញុំនៅព្រៃហ្នឹងដាច់ស្បៀងជិតបួនខែ ដែលខ្ញុំអត់ស្គាល់ជាតិអង្ករ គឺយើងហូបតែផ្លែឈើ ហើយយើងវង្វេង យើងមិនដឹងមេកើយ មិនដឹងក្រុម មិនដឹង ។ រហូតខ្ញុំដល់ទៅឆ្នាំ៧៩ ចុងខែ គឺខែស្រូវទុំ ប្រហែលជាក្នុងខែ១២ ឬក៏ដើមឆ្នាំ៨០ ខែមួយ ប្រហែលទេណ៎ា ប្រហែលអាពេលយើងស្រូវទុំស្រូវស្រែហ្នឹង បានខ្ញុំមកដល់ផ្ទះ ។

ហើយមុនពេលដែលខ្ញុំមកដល់ផ្ទះ ខ្ញុំសូមរំឭកបន្តិចទៅខាងដើមវិញ គឺនៅពេលដែលយើងបានបាយហូប ពេលដែលអត់បីបួនខែ អត់ស្គាល់ជាតិអង្ករ ពេលដែលយើងបានបាយហូប គឺយើងចាប់ឈឺហើយពេលហ្នឹងចាប់ឈឺ ។ វាកម្ជួល គឺយើងចូលដេកពេទ្យនៅកំពង់ស្ពឺផង ពេទ្យលោកសង្ឃនៅភ្នំពេញ

ផងជាបានយើងទៅដល់ផ្ទះនៅខែច្រូត ។ ហើយនៅពេលដែលយើងទៅដល់ផ្ទះដែលរន្ធត់ជាងកាលដែលខ្ញុំនៅសមរភូមិ គឺគ្រួសារទាំងអស់ស្លាប់គ្មានសល់ គ្មានសល់ម្នាក់ ។ ខ្ញុំរន្ធត់ចិត្តណាស់ ពេលដែលខ្ញុំដឹងថា បងប្អូនម៉ែឪកូនក្មួយសាច់បង្កើត សាច់ថ្លៃ ខ្ញុំរាប់តែបង្កើត សាច់ថ្លៃ គឺគ្មានសល់ សល់តែខ្ញុំមួយ ។

អ៊ីចឹងនៅឆ្នាំ៨០១ ពេញមួយឆ្នាំខ្ញុំអត់មានធ្វើអីកើត គឺបានញាតិមិត្តបងប្អូនជីដូនៗមួយ ឬក៏ជិតខាង គេជួយទាំងស្មារតី ទាំងសម្ភារៈ ដើម្បីឲ្យខ្ញុំពង្រឹងជីវិតដើម្បីរស់ ចាប់ពីពេលហ្នឹង ដែលខ្ញុំព្យាយាមបំភ្លេចរឿងអតីតកាល ។ ដល់ពេលនេះ ខ្ញុំមានការសោកស្ដាយអ៊ីចេះ ត្រង់ថាពេលដែលខ្ញុំទៅនៅស-២១ ខ្ញុំអត់បានយកសៀវភៅកំណត់ហេតុ ខ្ញុំសរសេរតាំងពីឆ្នាំ៧១ ព្រោះគេអត់បានរៀបចំឲ្យខ្ញុំ អត់បានយកសៀវភៅ ក៏ប៉ុន្តែក៏ជាសំណាងល្អដែរ ដែលគេមិនដាក់ឲ្យទៅ ។ បើសិនជាគេដាក់កំណត់ហេតុដែលខ្ញុំធ្លាប់ចូលប្រជុំ ចូលស្ដាប់នូវសម្ដីរបស់បក្ស របស់មេខាងលើហ្នឹង ក៏ប្រហែលជាខ្ញុំមិនរស់ដែរ។វាម៉្យាងៗដែរ ហើយខ្ញុំព្យាយាមបំភ្លេច ខ្ញុំមិនចាំ ហើយខ្ញុំចាប់រំឭកឡើងវិញរឿងផ្ទាល់ខ្លួនក៏ចាំមិនអស់ដែរ ។

ខ្ញុំសូមចប់ប៉ុណ្ណឹងចាស ។ អរគុណ ។

[១០:០២:00]

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត អង្គជំនុំជម្រះប្រគល់វេទិកាទៅ មេធាវីអ្នកតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះដើម្បីមានឱកាសក្នុងការសួរសំណួរ ដើម្បីបញ្ជាក់បន្ថែម ចំពោះអ្វីដែលមេធាវីយល់ឃើញថាមានប្រយោជន៍សម្រាប់ស្វែងរកការពិត និងផលប្រយោជន៍សម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោក ។

សូមអញ្ជើញ ។

**ការតាំងសំណួរដោយមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី៖**

**សួរដោយ លោក ហុង គឹមសួន៖**

ខ្ញុំបាទសូមអរគុណលោកប្រធាន ។ ខ្ញុំសូមគោរពអង្គសវនាការម្ដងទៀត ។

**ស៖** សូមជម្រាបសួរអ្នកស្រី ជុំ នៅ! បន្តិចទៀតនេះ ខ្ញុំនឹងសួរសំណួរទាក់ទងប្រវត្តិរឿងរ៉ាវរបស់អ្នកស្រីដែលរៀបរាប់ជូនអង្គសវនាការរួចមកហើយខ្លះទៀត ដើម្បីឲ្យបានច្បាស់លាស់ ។

ទីមួយ ទាក់ទងជាមួយនឹងការងាររបស់អ្នកស្រី នៅពេលដែលអង្គការគេបញ្ជូនមកធ្វើនៅភ្នំពេញអង្គការរបស់ពួកខ្មែរក្រហម ដែលអ្នកស្រីជម្រាបអង្គសវនាការពីថ្ងៃមុនថា ក្រោយថ្ងៃ១៧ ខែមេសាឆ្នាំ១៩៧៥ អ្នកស្រីត្រូវបានអង្គការបញ្ជូនមកនៅភ្នំពេញហើយធ្វើការផ្នែកខាងភស្ដុភារ តើផ្នែកភស្ដុភារ

មានការគ្រប់គ្រង ឬកាន់កាប់ជាទ្រព្យ ឬក៏ជារបស់របរអ្វីខ្លះ?

**ឆ៖** ចាស អរគុណ ជម្រាបប្រសាសន៍លោកមេធាវី គឺក្រោយថ្ងៃ១៧ មេសា ឆ្នាំ៧៥ គឺខ្ញុំបានត្រូវអង្គការឲ្យមកទទួលការងារនៅក្នុងក្រសួងភ័ស្តុភារ គឺនៅក្នុងផ្នែកឈ្មោះអង្គភាពស-៨០ ហើយស-៨០ ហ្នឹងគឺការគ្រប់គ្រងអាវុធយុទ្ធភណ្ឌគ្រាប់រំសេវទូទាំងប្រទេស នៅម្តុំទួលគោកភ្នំពេញនេះឯង ។

**ស៖** សូមអរគុណ ។ តើការងារប្រចាំថ្ងៃរបស់អ្នកស្រីពេលនោះ គេឲ្យអ្នកស្រីធ្វើអីខ្លះដែលនៅក្នុងតែទួលគោកហ្នឹង ឬមួយក៏ក្នុងទីក្រុងភ្នំពេញទាំងមូល?

**ឆ៖** ចាស, ជម្រាបប្រសាសន៍! កាលហ្នឹងខ្ញុំមានមួយកងអនុសេនាតូចដែលមកនៅអង្គភាពស-៨០ ហ្នឹង គឺខ្ញុំសូមបញ្ជាក់ខាងដើមបន្តិចថា ពេលដែលយើងមកនៅអង្គភាពស-៨០ ភ័ស្តុភារសេនាធិការហ្នឹង យើងចេញពីអង្គភាពទ័ពនារីភូមិភាគីបូព៌ា ពួកនាងខ្ញុំមានមួយអនុសេនាធំៗ ។ ហើយគឺយើងបែងចែកមកស-៨០ មួយអនុសេនាតូច ហើយមួយអនុសេនាតូចទៀតទៅក-២០ ហើយមួយអនុសេនាតូចទៀត គឺមាន៣អនុសេនាតូច គឺទៅយ-៥១ គេហៅថាកន្លែងគ្រប់គ្រងជួសជុលអាវុធ នៅក្បែរកន្លែងខ្ញុំដែរ គឺម្តុំទួលគោកហ្នឹងដែរ ។ គឺការងាររបស់ខ្ញុំកាលហ្នឹង គឺយើងរៀបចំៗឃ្លាំង ហើយឃ្លាំងហ្នឹង គឺមានតែមួយទេ ដែលខ្ញុំឃើញ ដែលគេសង់ថ្មីអំពី-- សង់ជាឃ្លាំង ហើយក្រៅពីហ្នឹង គឺយើងយកផ្ទះប្រជាជនដែលនៅសល់ពីសង្គមហ្នឹងធ្វើជាឃ្លាំងដាក់គ្រាប់ ។ ហើយប្រមូលគ្រាប់ជយភណ្ឌផងតាមតំបន់នៅក្នុងទីក្រុងភ្នំពេញផង ហើយយើងប្រមូលពីតាមខេត្ត តាមព្រៃ ពិសេសព្រៃកំពង់ឆ្នាំង យើងដឹកជញ្ជូនហើយយើងមានការបែងចែក ។ ដែលយើង-- ចំពោះខ្លួនខ្ញុំមិនសូវបានចេញទៅក្រៅទេ គឺច្រើននៅក្នុងទីក្រុងភ្នំពេញហ្នឹង ដើម្បីទទួលគ្រាប់ពីក្រៅមក រៀបចំបែងចែកជាមួយគេជាមួយឯងក្នុងហ្នឹង ។ ហើយយាមឃ្លាំងផង យាមពេល-- ពេលយប់យើងចាត់ចែងវេណ វេណយាម ។

**ស៖** បាទ, សូមអរគុណ ។ អំមិញអ្នកស្រីថា ទទួលការងារជំនាន់នោះប្រមូលសព្វាវុធ គ្រាប់រំសេវផង និងចែកចាយផង ។ តើអ្នកស្រីផ្ទាល់ មានដែលបានទៅជាមួយ ឬក៏ដឹងជញ្ជូនគ្រាប់ ឬអាវុធនោះទៅចែកចាយនៅក្នុងអង្គភាពយោធា ឬពួកប្រដាប់អាវុធផ្សេងៗនៅក្នុងភ្នំពេញហ្នឹងដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍! អត់ទេ ។

**ស៖** សំណួរមួយទៀត ទាក់ទងនៅក្នុងទីក្រុងភ្នំពេញដែរ តើអ្នកស្រីបានស្គាល់បរិវេណ ឬក៏ទីតាំងរបស់មន្ទីរស-២១ និយាយឲ្យខ្លីអ្នកស្រីដែលឮ ឬក៏ដែលស្គាល់ឈ្មោះមន្ទីរស-២១ ហ្នឹងដែរទេ នៅភ្នំពេញ?

**ឆះ** ចាស, ជម្រាបប្រសាសន៍! បើនិយាយពីមន្ទីរ ស-២១ គឺគេច្រើនសំដៅទៅលើតែសារមន្ទីរទួលស្លែង ។ គឺឃ្លាង អត់ដែលឮ អត់ដែលឃើញ អត់ដែលមកដល់ក្បែរហ្នឹងទេ ។ ប៉ុន្តែ ចង់ជម្រាបបញ្ជាក់ថា ខ្ញុំនៅធ្លាប់ឮនៅឯព្រៃស ព្រោះកាលហ្នឹងខ្ញុំទៅដឹកគ្រាប់នៅចម្ការដូង ។ ចម្ការដូង ហើយបងថា ដែលគាត់ជាអ្នកដឹកនាំផ្ទាល់នៅកន្លែងហ្នឹង ពេលទៅដល់ចម្ការដូង គាត់ចង្អុលប្រាប់ថា នុ៎ងហើយកន្លែងសន្តិសុខស-២១។ ហ្នឹងខ្ញុំគ្រាន់តែឮប៉ុណ្ណឹងទេ ប៉ុន្តែបើពាក្យថានៅទួលស្លែងហ្នឹងអត់ដែលឮសោះ។

[១០:០៧:៥៤]

**សះ** សូមអរគុណ ។ ពីថ្ងៃមុនអ្នកស្រីបានជម្រាបអង្គសវនាការអំពីរឿងស្វាមីរបស់ស្រីត្រូវបានចាប់ខ្លួនមុនពេលគេចាប់បញ្ជូនអ្នកស្រីហ្នឹងបីថ្ងៃ ។ តើអ្នកស្រីអាចរៀបរាប់បន្តិចបានទេ ទាក់ទងជាមួយនឹងស្វាមីអ្នកស្រីថា ទីមួយតើគាត់មានមុខងារជាអ្វី? ហើយខាងណាដែលចាប់ខ្លួនគាត់ និងបញ្ជូនទៅដាក់កន្លែងណា? អ្នកស្រីបានដឹងដំណឹងទេអំពីស្វាមីរបស់អ្នកស្រី?

**ឆះ** ចាស, ជម្រាបប្រសាសន៍លោកមេធាវី! ខ្ញុំទើបតែបានទទួលឯកសារច្បាស់ពីម្សិលមិញថា ប្តីរបស់នាងខ្ញុំគេបញ្ជូនពីរដង បានមកដល់ទួលស្លែងហ្នឹង ។ ប៉ុន្តែ នៅតាមរយៈឯកសារទេ តាមការចងចាំរបស់ខ្ញុំ ។ គឺលើកទីមួយ បើឯកសារហ្នឹង តាមខ្ញុំពិនិត្យឃើញ គឺមានការខុសគ្នា ថ្ងៃខែ ។ តាមខ្ញុំចាំនៅថ្ងៃទីមួយដែលគេបញ្ជូនប្តីខ្ញុំមកហ្នឹង នៅឆ្នាំ៧៧ហ្នឹង ខ្ញុំអត់បានចាំថ្ងៃខែកាលនុ៎ង ទើបនឹងឃើញឯក-សារ ។ ពេលហ្នឹងខ្ញុំទៅដេកពេទ្យនៅក-២០ ហ្នឹង ខ្ញុំដល់ខ្ញុំចាញ់កូន គេបញ្ជូនប្តីខ្ញុំមក ប៉ុន្តែខ្ញុំដឹងៗថា គេប្រាប់ថា ប្តីផ្លាស់ទៅនៅកន្លែងផ្សេងហើយ ។ អ៊ីចឹង អារឿងការផ្លាស់ប្តូរការងារ ខ្ញុំកាលហ្នឹងចាត់ទុកជារឿងធម្មតាទេ ប៉ុន្តែខ្ញុំចូលដេកពេទ្យ ។ ប៉ុន្តែ ដល់ក្រោយមកខ្ញុំចេញពីពេទ្យ រួបខ្ញុំនឹងគេអត់ឲ្យខ្ញុំទៅអង្គភាព ស-៨០ វិញទេ គឺគេមានខោអាវខ្ញុំដែលនៅកន្លែងនុ៎ង គេយកមកឲ្យខ្ញុំដល់កន្លែងពេទ្យរួចទៅហើយ គេគ្រាន់តែប្រាប់ថា “អ្ហឺ! នែ៎ ថ្ងៃហ្នឹងបើបងឯងចេញពេទ្យហ្នឹង គេជូនបងឯងទៅជុំប្តី” ។ គេក៏ជូនឡានខ្ញុំទៅ ។ ពេលដែលគេជូនឡានខ្ញុំទៅ ពេលហ្នឹងខ្ញុំជួបប្តីខ្ញុំមែន ប្តីខ្ញុំ គឺនៅបង្កើនផលម្តុំខាងត្បូងច្បារពៅ ដែលជិះតាមស្ពានក្បាលថ្នល់ ច្បារអំពៅហ្នឹងតាមមាត់ទន្លេទៅត្បូងហ្នឹង គឺម្តុំវត្តកំសាន្ត ។ ខ្ញុំនៅចាំច្បាស់ ជួបប្តីខ្ញុំមែន ។

ក៏យើងនៅបានមួយរយៈប្រហែលជាមួយខែជាងប៉ុណ្ណឹងទេ បានឃើញមានឡានមួយទៀតគេមកយកប្តីខ្ញុំទៅ ។ ប៉ុន្តែពេលហ្នឹង ប្តីខ្ញុំគ្រាន់តែពេលដែលខ្ញុំជូនឡើងឡានហ្នឹង គាត់គ្រាន់តែខ្សឹបប្រាប់ខ្ញុំមួយបន្តិចទេ គាត់ថា គាត់មិនរត់ទេ ដើម្បីជីវិតខ្ញុំ និងជីវិតកូនខ្ញុំ ។ ហើយគាត់គ្រាន់តែផ្តាំថា បើខ្ញុំនឹក

គាត់ខំធ្វើការទៅបាត់នឹកហើយ ។ មានប៉ុណ្ណឹងគត់ ដែលជាសម្ដីចុងក្រោយ ហើយមានផ្ដាំថា ពេលខ្ញុំកូនខ្ចីឱ្យខ្ញុំដាំថ្នាំផឹកទៅ មិនទាស់ទេថ្នាំហ្នឹង គឺៗ ដើមខ្ទឹម ។ ខ្ញុំទទួលព័ត៌មានបានប៉ុណ្ណឹង ។

[១០:១១:១៣]

**លោក ហុង គីមសួន៖**

សូមអរគុណ ។ ខ្ញុំបាទ សូមអនុញ្ញាតលោកប្រធាន សូមដាក់បញ្ចាំងឯកសារប្រវត្តិរូបសង្ខេបរបស់អ្នកស្រី ជុំ នៅ ដែលគាត់បានរកបាននៅមន្ទីរស-២១ ។ ឯកសារប្រភេទនេះដែលមាននៅក្នុងសំណុំរឿងហើយស្រេច ។

**ប្រធានអង្គជំនុំ៖**

ឱ្យលេខ ERN ជាភាសាខ្មែរ ។

**លោក ហុង គីមសួន៖**

សូមអ្នកស្រីបង្ហាញលេខ ERN ដែលនៅជួរលើ ព្រោះខាងខ្ញុំអត់បានថតជាប់ទេ ដាច់ ។

សូមជម្រាបលោកប្រធាន! ដោយឯកសារនេះ ខ្ញុំថតដាច់ ហើយខាងនេះមាន លេខ ERN ជាភាសាខ្មែរ 00211380 ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីខាងសោតទស្សន៍ដាក់បង្ហាញឯកសារដែលមានលេខERN00211380 នៅលើកញ្ចក់អេក្រង់ទូរទស្សន៍ ។

**លោក ហុង គីមសួន៖**

សូមជម្រាបលោកប្រធានផងដែរ លេខឯកសារជាភាសាអង់គ្លេសមានលេខ ERN00289729 ។

**ប្រធានអង្គជំនុំ៖**

ដំឡើងវាទៅលើ ដើម្បីឱ្យឃើញរហូតដល់ក្រោមទៅ ។ បញ្ចុះមកវិញមកនៅចំណុចកណ្ដាលបានៗ ។ បាទ, អញ្ជើញ ។

**សួរដោយលោក ហុង គីមសួន៖**

សូមអនុញ្ញាតភ្ជាប់នឹងរូបនេះ ខ្ញុំបាទ សូមសួរលោកស្រី ជុំ នៅ ។ អ្នកស្រី ជុំ នៅ ឈ្មោះរបស់ស្វាមីអ្នកស្រីដែលនៅក្នុងប្រវត្តិរូបសង្ខេបនេះដាក់ថា នូ មឿន ឈ្មោះប្រែហៅ សែម ។ ប៉ុន្តែ ឈ្មោះនៅក្នុងឯកសារឧបសម្ព័ន្ធស្ដីពីអ្នកទោស ភេទប្រុសនៅក្នុងមន្ទីរស-២១ ដែលមានលេខ ERN00331076

និងលេខ ERN00331803 ដាក់ថា-- ត្រង់លេខរៀង៣២១០ នៅក្នុងឯកសារ 00331076 ។ ដាក់ឈ្មោះ នូ សមឿន ហៅ សែម តួនាទីយុទ្ធជនមន្ទីរ៦២ “ខ” ភស្តុភាសេនាធិការ ។ ចូលនៅថ្ងៃទី៣០ ខែប្រាំមួយ ឆ្នាំ១៩៧៧ និងឯកសារលេខ ERN00331803 លេខរៀង១៨២៧ ឈ្មោះ នូ សមឿន ដូចគ្នាដែរ ។

ខ្ញុំសួរថាហេតុអីបានមាននៅក្នុងប្រវត្តិរូបសង្ខេបដាក់ថា នូ មឿន ហើយខុសគ្នាយ៉ាងម៉េចជាមួយ នឹង នូ សមឿន? អ្នកស្រីអាចពន្យល់បានទេ?

[១០:១៥:២៩]

**ឆ៖** ចាស, ជម្រាបប្រសាសន៍! លោកមេធាវី ឈ្មោះ នូ សមឿន ឬក៏ នូ មឿន ដែលហៅ សែម ខ្ញុំអាចទទួលយកបាន ព្រោះឈ្មោះនេះជាឈ្មោះប្ដីរបស់ខ្ញុំ នេះប្រហែលជា*អ៊ើរ៉ើ*ច្រឡំទេសក្នុងការសរសេរខ្លះ។ ក្នុងហ្នឹងខ្ញុំក៏បានជម្រាបដល់សហចៅក្រមដែរ ខ្ញុំថា ប្ដីខ្ញុំឈ្មោះដើម គឺ នូ សាមឿន ។ អ៊ីចឹងបើសិន ជាមាន នូ មឿន អីបន្តិចបន្តួច គឺខ្ញុំទទួលស្គាល់ ព្រោះវាមកច្បាស់ហ្នឹងឈ្មោះប្រែ ដែលខ្ញុំចាំ គឺឈ្មោះ សែម ។ ហើយខ្ញុំ ចាំបានថា នៅក្នុងព័ស្តុភាសេនាធិការហ្នឹងជាមួយគ្នា ។ វាចម្លែកត្រង់ថា នៅមន្ទីរម-៦២ ហ្នឹងដែលខ្ញុំចម្ងល់ ចម្ងល់ត្រង់ថាប្ដីខ្ញុំកាលដែលនៅជុំគ្នា ជាយុទ្ធជននៅស-៨០ អ៊ីចឹង ចម្ងល់នេះប្រហែល ជាចាំដល់ពេលនេះ ខ្ញុំនឹងតាំងសំណួរមួយចំនួនសួរទៅជនជាប់ចោទ ។

**ស៖** អរគុណ ។ ជាសំណួរចុងក្រោយសួរអ្នកស្រីទាក់ទងជាមួយនឹងប្រវត្តិរូបសង្ខេបហ្នឹង អ្នកស្រីបានចាំទេ ថាធ្វើនៅឯណា? ឬនៅពេលណា?

**ឆ៖** គឺធ្វើ--

**លោក ហុង គីមសួន៖**

សូមអនុញ្ញាតលោកប្រធានយករូបភាពប្រវត្តិរូបចេញពីអេក្រង់វិញ បាទ ។

[១០:១៧:១០]

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការត្រឡប់-- ដកឯកសារនេះចេញ ហើយត្រឡប់ទៅរូបភាពប្រក្រតីឡើងវិញ ។

**លោកស្រី ជុំ នៅ៖**

ចាស, គឺធ្វើនៅថ្ងៃដំបូង ដែលខ្ញុំទៅដល់ស្ទឹងជ្រៅ ប៉ុន្តែខ្ញុំនៅចាំពេលនោះ គឺអត់មានអង្គុលីលេខ វាយអ៊ីចឹងទេ គឺគេសួរឈ្មោះខ្ញុំចូលក្នុងសៀវភៅតែម្ដង ហើយជាអក្សរអង្គុលីលេខនេះ គឺនៅកន្លែងនោះ តាមខ្ញុំចាំ អត់មានទេ ។ ប៉ុន្តែ ជាដំបូងគេសួរឈ្មោះខ្ញុំរួចហើយ ចុះក្នុងបញ្ជីគេហ្នឹង ។

**លោក ហុង គីមសួន៖**

សូមអនុញ្ញាតលោកប្រធានដាក់បង្ហាញរូបភាពគាត់ចុងក្រោយមួយទៀត ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការដាក់បង្ហាញនូវភាព យករូបភាពពីមេធាវីដាក់បង្ហាញនៅម៉ាស៊ីនស្លាយដើម្បីបង្ហាញរូបភាពនៅកញ្ចក់អេក្រង់ទូរទស្សន៍ ។

**លោក ហុង គីមសួន៖**

សូមជម្រាបលោកប្រធានផងដែរ រូបថតនេះ គឺយើងពង្រីកចេញពីរូបប្រវត្តិរូបនេះអម្បាញ់មិញ ដែលរូបក្នុងប្រវត្តិរូបវាអត់សូវច្បាស់ ។

**សួរដោយលោក ហុង គីមសួន៖**

**ស៖** ខ្ញុំបាទ សូមសួរសំណួរចុងក្រោយថា តើរូបថតនេះ គឺពិតជារូបថតអ្នកស្រីដែរឬទេ? ហើយអ្នកណាសរសេរឈ្មោះនៅពីក្រោម?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! គឺពិតជារូបរបស់ខ្ញុំកាលពីសាមសិបពីរឆ្នាំមុន ចាស ។ ហើយឈ្មោះដែលសរសេរនេះ គឺខ្ញុំមិនដឹងពីណាសរសេរទេ ហើយគេថតខ្ញុំហ្នឹង គេថតទៅ ខ្ញុំមិនចាប់អារម្មណ៍អារឿងសរសេរឈ្មោះនេះ ខ្ញុំមិនដឹងទេ ។

**លោក ហុង គីមសួន៖**

បាទ, សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ ។ សូមអរគុណអ្នកស្រី ជុំ នៅ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រគល់វេទិកាទៅតំណាងឲ្យសហព្រះរាជអាជ្ញា បើមានសំណួរអ្វីត្រូវសួរដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ សូមអញ្ជើញ ។

**លោក វ៉ាំងសង់ ដឺវ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

សូមផ្អាក១បន្តិចសិនលោកតំណាងសហព្រះរាជអាជ្ញា ព្រោះចៅក្រម ហ្សង់ម៉ាក គាត់មានបញ្ហាចង់និយាយ ។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** សូមអរគុណលោកប្រធាន ។ ខ្ញុំបានស្តាប់សេចក្តីថ្លែងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រឹកមិញនេះគាត់បាននិយាយថា គាត់បានជួបប្រឈមជាមួយជនជាប់ចោទ ហើយមិនបានកើតឡើងនៅក្នុងរយៈពេលដែលអង្គហេតុ ដែលយើងបានធ្វើសវនាការទេ ។ ប៉ុន្តែ ខ្ញុំពិនិត្យឃើញថា មានសារសំខាន់ទាក់ទងទៅនឹងបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ ដែលយើងបានទទួលព័ត៌មានបន្ថែមទៀត ។ តើអ្វីកើតឡើងក្នុងពេល ដែលប្រឈមជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីនេះ?

ដូច្នេះ លោកស្រីបានប្រាប់យើងអំពីការប្រឈមមុខមួយជាមួយជនជាប់ចោទ នៅពេលដែលគេនាំលោកស្រីទៅជួបជនជាប់ចោទនៅពេលដែលលោកស្រីរត់ចេញពីស-២៤ នោះ ព្រៃស ។ តើហ្នឹងជាលើកដំបូងឬទេ ដែលលោកស្រីបានជួបជាមួយជនជាប់ចោទនោះ? តើលោកស្រីប្រាកដដែរឬទេ ថាគាត់ពេលនោះ គឺជា ឌុច? បើសិនជាច្បាស់ ហេតុអីបានជាលោកស្រីច្បាស់ថា ជាគាត់នៅពេលនោះ?

**ឆ៖** ចាស, សូមអរគុណ ជម្រាបប្រសាសន៍លោកចៅក្រមអន្តរជាតិ ។ ថ្ងៃដែលខ្ញុំជួប ពេលដែលលោក ឌុច យកកាំភ្លើងខ្លីមកភ្ជង់ខ្ញុំហ្នឹង គឺក្រោយថ្ងៃ៧ មករា ឆ្នាំ៧៩ ។ ខ្ញុំប្រាកដថា ឈ្មោះជារូបគាត់ដោយខ្ញុំបានជួបគាត់ជាលើកទីបីទេនេះ ។ លើកទីមួយ លើកទីពីរ លើកទីមួយ ខ្ញុំជួបគាត់នៅដើរលើខ្នងទំនប់ តែយើងមិនប្រាកដថា រូបគាត់ទេ ដោយគេប្រាប់ថា ហ្នឹងហើយប្រធានយើង ដែលយើងមិនបាននិយាយស្តី ឬក៏សួរនាំអីទេ យើងនៅកំពុងដកស្ទូងស្រូវសន្ទូង ។

ហើយលើកទីពីរ គឺជួបក៏មិនបាននិយាយស្តីអីដែរ ដោយឃើញគាត់ដើរមកក្បែរយើង ហើយពេលនុ៎ង ខ្ញុំចេះតែឆ្ងល់ថា ចុះថ្ងៃហ្នឹងហេតុអីក៏គេឲ្យខ្ញុំស្ទូងនៅក្បែរភ្លឺ ។ ព្រោះបានន័យថា ឲ្យខ្ញុំនៅក្បែរភ្លឺ ព្រោះសន្ទូងខ្ញុំស្អាត គឺត្រង់ ហើយមូលហើយស្ទូងបានល្អ ។ អ៊ីចឹងខ្ញុំសួរថា អូយ! ថ្ងៃហ្នឹងម៉េចក៏ចាំបាច់ឲ្យខ្ញុំស្ទូងក្បែរភ្លឺ? ព្រោះក្បែរភ្លឺដីមិនសូវស្រួលទេ វាអត់សូវទន់ ដូចនៅកណ្តាល ព្រោះវាច្រើនល្បែង។ អ៊ីចឹងគេថា ថ្ងៃនេះប្រធានធំមកហើយ បងឯងស្ទូងល្អ ដាក់ក្បែរភ្លឺទៅ ។ តែយើងអត់បានចាប់អារម្មណ៍ទេ ។ ដល់ពេលលើកទីបី ដែលយើងជួបហ្នឹង បានយើងថា មុខហ្នឹងដដែល បានយើងប្រាកដថា ហ្នឹងហើយជាប្រធានស-២១ ។ ចាស, ប៉ុណ្ណឹង ។

[១០:២៤:០៦]

**ស៖** ដូច្នេះតាមដែលខ្ញុំយល់ត្រឹមត្រូវនោះ លោកស្រីប្រាប់យើងថា នៅពេលដែលលោកស្រីនៅស-២៤ លោកស្រីបានឱកាស បានឃើញជនជាប់ចោទនោះពីរដង ។ លោកស្រីបានឃើញថា ពិនិត្យ

មើលការងារដកស្ទូងនៅក្នុងវាលស្រែ តើអ៊ីចឹងមែនឬទេ?

**ឆ៖** ចាស, ជម្រាបប្រសាសន៍! គឺឃើញអ៊ីចឹងមែន ។

**ស៖** ខ្ញុំសូមត្រឡប់ទៅការប្រឈមមុខគ្នាម្តងទៀត លោកស្រីបានជម្រាបយើងថា គេបាននាំលោកស្រីទៅជួបជាមួយ ឌុច ដោយថា គេចោទថា លោកស្រីបានព្យាយាមរត់គេចខ្លួន ។ តើគេចោទប្រកាន់ទេនៅពេលដែលទៅជួបគាត់នោះ? តើលោកស្រីអាចប្រាប់យើងលម្អិតបានទេ តើគាត់ប្រាប់ឈ្មោះគាត់ទេនៅពេលនោះ? នៅពេលជួប តើគាត់ដកកាំភ្លើងខ្លីភ្លាម ឬក៏រយៈពេលប៉ុន្មានដែលគាត់ដកកាំភ្លើងខ្លីមកភ្ជង់លោកស្រីនោះ?

**ឆ៖** ចាស, នៅពេលដែលគេនាំខ្ញុំទៅជួបហ្នឹង គឺអ្នកដែលនាំខ្ញុំហ្នឹង គឺគេស្គាល់ខ្ញុំច្បាស់ តាមផ្លូវគេប្រាប់ថា បងឯងទៅជួបលោកប្រធាន ។ ប៉ុន្តែ កាលហ្នឹង គេមិនប្រើពាក្យ "លោក" ទេ ចាស! យើងនិយាយឲ្យមានសីលធម៌នៅកន្លែងនេះ គឺយើងប្រើអ៊ីចឹងចុះ ។ ទៅជួបប្រធានស-២១ ហ្នឹង ហើយគេប្រាប់ទាំងឈ្មោះខ្ញុំទៀត គឺអ្នកហ្នឹងគេស្គាល់ខ្ញុំច្បាស់ តែខ្ញុំមិនស្គាល់ទេ ។ ហើយនៅដែលខ្ញុំទៅជួបហ្នឹង គឺយើងបានជម្រាបសួរគាត់ ហើយយើងហៅគាត់ "បង" ហើយយើងមិនមានការភ័យខ្លាចទេ គឺយើងញញឹមញញែមធម្មតា ។ ហើយពេលដែលមុននឹងគាត់សួរហ្នឹង គឺគាត់ដកកាំភ្លើងខ្លីរួចទៅហើយ ប៉ុន្តែកាំភ្លើងខ្លីហ្នឹង ខ្ញុំមិនបានឃើញគាត់បើសោទេ គឺដកចេញពីចង្កេះ ភ្ជង់យើងភ្លាម ។ អ៊ីចឹងក៏យើងមានអារម្មណ៍មួយថា យើងមិនខ្លាចទេ យើងមិនភ័យ ហើយសួរៗ ខ្ញុំថា មិត្តនារីឯងមកប៉ុន្មានថ្ងៃហើយ? មកកន្លែងហ្នឹងប៉ុន្មានថ្ងៃហើយ? ពេលហ្នឹងខ្ញុំសើចទៀត សើចដូចថា វាងញញឹមញញែម មិនជាសើចអីណាស់ណាទេ ញញឹមញញែមៗហ្នឹង ជាទម្លាប់របស់ខ្ញុំ ខ្ញុំថា ចាស! ខ្ញុំមកតាំងពី៧៧ ។ គាត់ដូចភ្ញាក់ពេលដែលខ្ញុំឆ្លើយថា តាំងពី៧៧ ព្រោះព្រឹត្តិការណ៍កាល ដែលគាត់សួរហ្នឹង គឺក្រោយ ៧ មករា ៧៩ ។ អ៊ីចឹង យើងនៅកន្លែងហ្នឹងជិត២ឆ្នាំ ហើយគាត់សួរថា មានរឿងអី? ខ្ញុំថា ខ្ញុំអត់ដឹង ហើយគាត់ក៏ត្រឡប់ពាក្យសួរខ្ញុំវិញ-- ឆ្លើយតបមកខ្ញុំវិញថា គ្រាន់បើនៅកន្លែងនេះបានយូរតែប៉ុណ្ណឹង ។ ហើយគាត់ក៏ឲ្យខ្ញុំនៅកន្លែងនោះសិនទៅ ។ ប៉ុន្តែ នៅសិនហ្នឹង ប្រហែលជាមិនច្បាស់ទេ ក្រោយមកក៏មានការបាញ់គ្នានៅក្បែរៗហ្នឹង ក៏រប៉ាត់រប៉ាយ រត់ទៅដល់ផ្ទៃ ជិតអមលាំង តែប៉ុណ្ណឹង ។

[១០:២៧:៤៣]

**ស៖** តើ ឌុច ក្នុងពេលណាមួយ ក្រៅពីភ្ជង់កាំភ្លើងមកត្រចៀកនោះ តើគាត់និយាយគំរាមកំហែងទេ? តើគាត់មានប្រើពាក្យអីថា ខ្ញុំនឹងបាញ់អ្នកឯង ឬក៏ប្រើពាក្យអ្វីទេ ក្រៅពីហ្នឹង?

**ឆ៖** ខ្ញុំសូមសម្តែងការពិត មិនមែនថាខ្ញុំចេះតែឆ្លើយតាមកំហឹង ដែលខ្ញុំឈឺចាប់ទេ ពេលហ្នឹង គឺគាត់មិនបានសម្លុតថា ត្រូវតែបាញ់អ្នកឯងចោល គឺគាត់គ្រាន់តែយកកាំភ្លើងមកភ្ជង់ គឺគាត់មិនបានប្រើ-- គាត់សើចដែរកាលហ្នឹង ពេលដែលខ្ញុំប្រាប់គាត់ថា ខ្ញុំមកតាំងពី៧៧ អ៊ីចឹងគាត់សើចដែរ គាត់សរសើរថាគ្រាន់បើនៅបានយូរ ។ ចាស, ប៉ុណ្ណឹង ចាស ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកស្រីដែលបានបំភ្លឺ ។ ខ្ញុំមិនមានសំណួរអ្វីទៀតទេ លោកប្រធាន ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញាអាចសួរដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបាន បើសិនបើមានសំណួរ ។ សូមអញ្ជើញ ។

**សួរដោយលោក វាំងសង់ ដឺវ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន ។

**ស៖** លោកស្រី ជុំ នៅ កាលពីថ្ងៃព្រហស្បតិ៍សប្តាហ៍មុន លោកស្រីបាននិយាយអំពីការរៀបការដោយបង្ខំតាមការបង្គាប់របស់អង្គការ ។ លោកស្រីក៏បានរៀបរាប់ថា លោកស្រីត្រូវបានគេចាប់ខ្លួនបន្ទាប់ពីគេចាប់ខ្លួនប្តីរបស់លោកស្រី ។ ការចាប់ខ្លួននោះប្រហែលគេយល់ឃើញថា ប្តីរបស់លោកស្រីជាខ្មាំង ។ ថាតើស្ថានភាពនោះធ្វើឲ្យលោកស្រីខ្លាំងសម្បាដែរឬទេនៅពេលដែលគេឲ្យលោកស្រី បង្ខំឲ្យលោកស្រីរៀបការ? ហើយនៅពេលដែលគេចាប់ប្តីលោកស្រី តើលោកស្រីព្យាយាមប្រាប់អង្គការដែរឬទេ ថាស្ថានភាពនោះ គឺវាគួរឲ្យខឹងសម្បា ហើយលោកស្រីបានធ្វើការតវ៉ាទៅនឹងអង្គការនោះទេ នៅពេលដែលលោកស្រីត្រូវបានគេចាប់បញ្ជូនមក ស-២១ ក្រោយពេលចាប់ប្តីលោកស្រីនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកសហព្រះរាជអាជ្ញា! នៅឆ្នាំ១៩៧៦ ខ្ញុំត្រូវអង្គការនៅភ័ស្តុភារហ្នឹង គេឲ្យខ្ញុំរៀបការ ។ ប៉ុន្តែការរៀបការហ្នឹង គឺប្តីរបស់ខ្ញុំហ្នឹងក៏បានស្នើទៅអង្គការត្រឹមត្រូវ ខ្ញុំចង់ឲ្យច្បាស់ថា គេមិនបានចាប់ ចាប់ផ្តួគ្គងបង្ខំទេដំបូង គឺប្តីនាងខ្ញុំហ្នឹងបានដាក់ចិត្តស្រឡាញ់នាងខ្ញុំ ហើយបានស្នើទៅអង្គការ ហើយអង្គការក៏បានស្នើហៅនាងខ្ញុំទៅសាកសួរទាំងពីរនាក់ យើងទាំងពីរនាក់បានព្រមព្រៀងគ្នា ។ ប៉ុន្តែ ចង់ជម្រាបឲ្យច្បាស់បន្តិចថា អង្កាល់ដែលខ្ញុំរៀបការហ្នឹង គឺខ្ញុំមិនទាន់-- អឺ! នែ៎ ស្តីដណ្តឹងយើងប្រើពាក្យថា “ស្តីដណ្តឹង” អ៊ីចឹងចុះ ខ្ញុំមិនទាន់គ្រោះថ្នាក់ពិការដែទេ ។

ក្រោយមកបានខ្ញុំពិការដៃ ហើយខ្ញុំចេញពីពេទ្យហើយ បានខ្ញុំការ ហើយថ្ងៃដែលខ្ញុំរៀបការហ្នឹង គឺមិនមែនការតែខ្ញុំមួយគូទេ គឺបីគូ ហើយការដែលប្រាប់ពីពេលវេលារៀបការហ្នឹង គឺវាលឿនពេក ។ លឿនត្រង់ថា ប្រាប់ពីព្រឹក ថ្ងៃហ្នឹងយើងរៀបការហើយ ថ្ងៃរសៀលម៉ោងពីរមានកម្មវិធី ។ អ៊ីចឹងក្នុងអារម្មណ៍ខ្ញុំវាក្តុកក្តួល ខ្ញុំបានសួរទៅប្រធានខ្ញុំដែលនៅអង្គភាពហ្នឹង គឺគាត់ឈ្មោះ ម៉ូត នៅក្នុងប្រធាន ស-៨០ហ្នឹង គាត់ឈ្មោះបង ម៉ូត, បង ធឹម, បង ផុន ខ្ញុំថាហេតុអីបង ក៏លឿនម្ល៉េះ? អី បងមានអញ្ជើញម៉ែឪ បងប្អូនខ្ញុំពីស្រុកមកទេ? គាត់ថា អ្ហឺ! មិនបាច់ទេ យើងកូនអង្គការហើយ ។ ពេលហ្នឹងខ្ញុំការមិនសប្បាយចិត្តទេ មិនសប្បាយចិត្តទេ កាលហ្នឹងខ្ញុំយំដែរ ។ ប៉ុន្តែពេលវេលា វាដល់ហើយ យើងមិនអាចទៅណារួច ។

អ៊ីចឹង គេថា កន្លែងគេពន្យល់ហេតុផលមក ថាកន្លែងយើងនេះ ជាកន្លែងពិសេស មិនអាចឱ្យអ្នកផ្សេងមកបានទេ ។ អ៊ីចឹងយើងមិនអីទេ អង្គការជាម៉ែជាឪហើយ បើយើងមិនព្រម យើងមិនស្តាប់គេ សួរថា យើងស្មុះរួចទេ? យើងស្មុះអត់រួចទេ ។ អ៊ីចឹងយើងត្រូវតែទៅ ទៅការក្នុងពិធីហ្នឹងទាំងទឹកភ្នែក ខ្ញុំយំដែរថ្ងៃហ្នឹង ថ្ងៃការហ្នឹង ដោយវាហួសចិត្ត ត្រង់ថាអត់មានបងប្អូនញាតិពីស្រុកមក ដែលគេអត់ផ្តល់ដំណឹងឱ្យចូលរួម ។

**ស៖** សូមអរគុណ ។ លោកស្រី ជុំ នៅ ថាតើលោកស្រីបន្ទោសទៅលើនរណាគេ នូវការស្លាប់កូនរបស់លោកស្រី នៅពេលដែលលោកស្រីធ្វើការនៅស-២៤ នោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកសហព្រះរាជអាជ្ញា! ការស្តីបន្ទោស ពេលដែលកូនប្រុសជាទីស្រឡាញ់របស់ខ្ញុំស្លាប់ គឺមកពីការទទួលខុសត្រូវចាត់ចែងរបស់ថ្នាក់លើ មិនបានមានផែនការឱ្យល្អិតល្អន់ថា ឥឡូវធ្វើអ៊ីចេះៗដោយវិធីណាមួយ ។ វាមិនដែលមាន កូនកំពុងបៅ ហើយផ្តាច់ៗចេញយកទៅ-- កូនហ្នឹង វាមិនទាន់លែងបៅណា អង្គាល់ហ្នឹងចាស ។ ហើយខ្ញុំមិនដឹងដែរ មិនដឹងត្រង់ថា ពេលដែលវាកើតកញ្ជ្រឹលហ្នឹង ពេលដែលយើងឱ្យវាបៅទៅ វាលាប់ ខ្ញុំមិនដឹងដែរ បើដឹង ខ្ញុំក៏មិនឱ្យបៅដែរ តែខ្ញុំអត់ដឹង ។ ពេលដែលខ្ញុំទៅដល់ជួបកូនខ្ញុំភ្លាម គឺគ្មានអីលើកកូនបីឱ្យបៅ ។ ប៉ុន្តែ ពេលបៅក្រោយមកប្រហែលជាមួយម៉ោង ឬពីរម៉ោង កូនខ្ញុំចាប់រាក រាករហូតពេទ្យក៏ស្មុះស្មាណាស់ ប៉ុន្តែទប់វាមិនឈ្នះ កូនហ្នឹងក៏វាស្លាប់ទៅនៅហ្នឹងដៃខ្ញុំ ។ ពេលហ្នឹងៗក៏គេយកទៅកប់ ហើយក៏គេឃាត់ឱ្យខ្ញុំនៅសម្រាក ដើម្បីឱ្យមានសុខភាព ប៉ុន្តែជាចរិតរបស់ខ្ញុំ ខ្ញុំមិនចេះនៅទំនេរ ខ្ញុំអផ្សុក ខ្ញុំចេះតែតឿនសុំគេទៅកងវិញ គេក៏ជូនខ្ញុំមក ។ ចាសប៉ុណ្ណឹង ។

**ស៖** ខ្ញុំជឿថា លោកស្រីបាននិយាយមុននឹងថា លោកស្រីត្រូវបានស្ទើរតែគេចាប់បាន-- ត្រូវបានគេចាប់ខ្លួន ហើយគេស្ទើរតែសម្លាប់លោកស្រីពីរដងនៅពេលដែលលោកស្រីនៅស-២៤ ។ តើលោកស្រីអាចរៀបរាប់ដំណើររឿងនេះបានដែរឬទេ?

**ឆ៖** ចាស, ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា គឺបាន ប៉ុន្តែក្នុងហ្នឹងខ្ញុំ-- គេហៅឡើងឡានពីរដង ប៉ុន្តែក្នុងពីរដងខ្ញុំចង់បញ្ជាក់ថា ម្តងនោះគឺខ្ញុំកំពុងដក ហើយគេហៅគេចុះមកវិញដោយថា ច្រឡំត្រកូល។ ប៉ុន្តែ ម្តងទៀតហ្នឹងគឺមិនបានចុះទេ គឺម្តងទៀតហ្នឹងគេឲ្យទៅជួបកូនខ្ញុំនៅឯពេទ្យឯភ្នំពេញហ្នឹងទេ ចាសប៉ុណ្ណឹង ។

**ស៖** តើលោកស្រីអាចជម្រាបយើងខ្ញុំបានដែរឬទេ? ថាតើលោកស្រីគិតយ៉ាងម៉េចនៅពេលដែលគេបង្ខំឲ្យឡើងឡាន? តើលោកស្រីបានគិតទេ ថាតើនឹងមានអ្វីកើតឡើងនៅពេលដែលគេនាំលោកស្រីឡើងទៅលើឡាននោះ?

[១០:៣៧:០៧]

ឆ៖ ខ្ញុំពេលដែលគេហៅឡើងឡានទាំងពីរដងហ្នឹង ខ្ញុំមានអារម្មណ៍ថា អត់ៗរស់ទេស្លាប់ហើយ។ នៅលើទីមួយចុះមកវិញដោយប្រាប់ថា ច្រឡំត្រកូល ប៉ុន្តែដល់ពេលទីពីរក៏ខ្ញុំនឹកគិតថា ខ្ញុំមិនរស់ទៀត ។ ប៉ុន្តែដល់ពេលឡានហ្នឹងបើកមកដល់កន្លែងនៅ ស្នាក់នៅគាត់ក៏ប្រាប់ថា ឲ្យខ្ញុំទៅយកខោអាវមក ។ ខ្ញុំមានអារម្មណ៍ធូរបន្តិចថា អ៎! មិនអីទេពេលដែលគេឲ្យយកខោអាវព្រោះគាត់បានប្រាប់ថា ទៅមើលកូន ប៉ុន្តែពេលដំបូងពេលដែលគេហៅឡើងឡានលើកទីពីរ ដែលថាទៅនឹងគឺគេមិនប្រាប់ហេតុការណ៍អីទេ ។ អ៊ីចឹងអ្នកដែលនៅជុំវិញខ្ញុំទាំងប៉ុន្មានហ្នឹង គឺស្វាត់ជ្រាបបាត់មាត់ដូចគេចុក ដោយគេថា ខ្ញុំទៅហើយ ប៉ុន្តែដល់ក្រោយមកខ្ញុំមកវិញ មកកង១៤ហ្នឹងវិញ ក្រោយពេលដែលកូនខ្ញុំស្លាប់ហ្នឹង ខ្ញុំមកវិញ ។ គេបញ្ជូនខ្ញុំ គេនាំខ្ញុំមកវិញ ។ ពេលហ្នឹងអ្នកដែលនៅកន្លែងហ្នឹងគេថាខ្ញុំ-- គេប្រកាសនៅក្នុងកន្លែងថា គាត់គេយកទៅហើយ *សេអ៊ីអា* ប្រយ័ត្នមាត់បន្តិចធ្វើការ ប្រឹងធ្វើការទៅ ។ ប៉ុណ្ណឹងចាស ។

[១០:៣៨:១៤]

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** ជម្រាបសួរលោកស្រី ជុំ នៅ! សូមលោកស្រីជួយបញ្ជាក់ថា នៅពេលដែលលោកស្រីថា នៅពេលដែលលោកស្រីត្រូវបានអង្គការចាប់បញ្ជូនឲ្យទៅធ្វើការជាអ្នកថែទាំកុមារ តើលោកស្រីដឹងថា ស្ថានភាពកុមារទាំងនោះយ៉ាងម៉េចដែរ លោកស្រីអាចបញ្ជាក់បានទេ?

**ឆ៖** ចាស, បានជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា ។ នៅពេលដែលគេឲ្យខ្ញុំមើលកុមារ ដោយខ្ញុំនៅសរសៃខ្ចីពេក ហើយក្នុងហ្នឹងក៏មានកូនខ្ញុំដែរ ។ អ៊ីចឹង ក្នុងកន្លែងដែលមើលកុមារហ្នឹង គឺគេឲ្យខ្ញុំមើលកុមារដែលនៅបៅដោះ ដែលម្ដាយទៅធ្វើការហ្នឹង គឺកុមារនៅបៅដោះ ។ ហើយខ្ញុំនៅកន្លែងកុមារហ្នឹង អ្នកមើលពីរបីនាក់ អ៊ីចឹងដំបូងខ្ញុំឃើញកុមារច្រើន ហើយកន្លែងដែលយើងមើលហ្នឹងគឺយើងមានគ្រែពីរបីទៅ ហើយគ្រែហ្នឹងគឺគេធ្វើជាចម្រឹងពីរបីគ្រែអ៊ីចឹងទៅ ដោយដាក់តាមប្រភេទកុមារណាដែលចេះវារ ។ កុមារណាដែលអត់ទាន់ចេះក្រឡាប់ អាហ្នឹងវានៅស្ងៀមមិនសូវលំបាកប៉ុន្មានទេ ។ ប៉ុន្តែបើកុមារវាចេះក្រឡាប់ហ្នឹងវាមានការលំបាកខ្លះ ខ្លាចវាធ្លាក់ ។ អ៊ីចឹង គេធ្វើចម្រឹងដូចៗកូនជ្រូកដូចយើងចិញ្ចឹងកូនជ្រូកនៅក្នុងទ្រុង ។ ក្នុងគ្រែមួយៗហ្នឹងមិនមែនម្នាក់ទេ ។

ហើយកុមារទាំងអស់ហ្នឹងខ្ញុំយូរៗ ដែលយើងនៅយូរៗទៅដែលយើងនៅយូរៗដូចចេះតែរលួសទៅៗមិនដឹងជាអ្នកណាស្លាប់នៅពេលណា ថ្មើរម៉ាន យកទៅកប់អីត្រង់ណា គ្រាន់តែពេលហ្នឹងខ្ញុំច្បាស់កុមារកូនមិត្តភក្តិខ្ញុំម្នាក់ដែលគាត់ឆ្លងទន្លេមុនខ្ញុំមួយខែហ្នឹងគឺ ស្លាប់ដែលខ្ញុំដឹងច្បាស់គឺស្លាប់នៅពេលដែល-- ពេលយប់ ដែលយើងដេកជាមួយគ្នាមុងក្បែរគ្នាហ្នឹងគាត់ខ្សឹបប្រាប់ខ្ញុំថា កូនគាត់ស្លាប់ហើយ ។ ខ្ញុំថា បើស្លាប់ហើយគ្មានពីណាមកយកយើងទាំងយប់ទេ ចាំព្រឹកឡើងទៅ ។ ហើយក៏យើងនាំគ្នាដេកឱបខ្មោចកូនពួកម៉ាកខ្ញុំ ហើយនិងកូនខ្ញុំហ្នឹង ។ ព្រឹកឡើងបានគេយកកូននោះទៅកប់ ។

[១០:៤០:៤៥]

**ស៖** បាទអរគុណលោកស្រី ។ តើលោកស្រីដឹងទេ ថាកុមារទាំងនោះគេផ្គត់ផ្គង់អាហារយ៉ាងម៉េចដែរ?

**ឆ៖** ចាស, ជម្រាបប្រសាសន៍លោកសហព្រះរាជអាជ្ញា! ការផ្គត់ផ្គង់អាហារកូនដែលកំពុងបៅហ្នឹងគឺព្រឹកឡើងម្ដាយគេយកមកដាក់នៅកន្លែងហ្នឹងគឺ ទាល់តែពេលល្ងាចនោះបានៗបៅដោះម្ដាយម្ដងទៀតពេលដែលមកពីធ្វើការ ។ ប៉ុន្តែ ចន្លោះពេលដែលម្ដាយមិននៅហ្នឹងគឺពួកយើងដែលជាអ្នកមើលហ្នឹងគឺដាំបបរ គេហៅថាបបរឈ្នោលចាស ។ ហើយយើងដាក់អំបិលបន្តិចៗទៅ ហើយយើងកិនៗឲ្យហ្មត់ៗទៅហើយបញ្ចុកទៅ ហូបបានមិនបានយើងចេះតែបញ្ចុកទៅ បញ្ចុកផឹកទឹកៗទៅ បាយកិនហ្នឹង។

**ស៖** អរគុណ ។ ទាក់ទងទៅនឹងសកម្មភាពនៃការចាប់ខ្លួនអ្នកដែលធ្វើការជាមួយលោកស្រី ហើយលោកស្រីបានប្រាប់អង្គសវនាការថា លោកស្រីក៏ត្រូវបានគេចាប់ខ្លួនឡើងឡានម្ដងដែរ ។ ប៉ុន្តែត្រូវគេប្រាប់ថា ច្រឡំត្រកូល លោកស្រីក៏ចុះពីឡានមកវិញ ។ តើលោកស្រីដឹងទេ ថាការចាប់នោះនៅ

ពេលនោះគេធ្វើនៅពេលយប់ឬពេលថ្ងៃ?

[១០:៤២:១៤]

**ឆ៖** ជម្រាបប្រសាសន៍! គឺនៅពេលថ្ងៃរសៀលគឺពេលដែលយើងកំពុងដក ។ យើងឡើងពីស្ទូងមកយើងដក អ៊ីចឹងល្ងាចបន្តិចទៅហើយ ។

**ស៖** អរគុណ ។ អ៊ីចឹងលោកស្រីអាចចាំបានទេ ថាអ្នកដែលប្រាប់លោកស្រីថា ច្រឡំត្រកូលនោះមានឈ្មោះអ្វីដែរ?

**ឆ៖** ចាស ខ្ញុំចាំបាន គឺគាត់ឈ្មោះពេទ្យ វ៉ាន់ ។ គាត់ហ្នឹងខ្វាក់ភ្នែកម្ខាងទៀត គាត់មានស្ពាយសាក់ការដូពេទ្យ សម្រាប់តាមអ្នកដែលទៅវាលស្រែហ្នឹង ហើយគាត់ឈរមើលឈ្មោះទាំងអស់គ្នា គាត់ក៏ថាឈ្មោះមីងហ្នឹងច្រឡំត្រកូលហើយ មិនមែនត្រកូលហ្នឹងទេ ។ អ៊ីចឹង ក៏គាត់បក់ដៃខ្ញុំចុះវិញទៅ ។

[១០:៤២:៥៧]

**ស៖** លោកស្រីនៅចាំទេ ថាការដឹកនាំការចាប់ខ្លួនទាំងនោះ? ធ្វើឡើងដោយអ្នកណាដែលជាអ្នកដឹកនាំក្នុងការចាប់ខ្លួនេះ?

**ឆ៖** ខ្ញុំអត់ដឹងចាស ។ អត់ដឹងថា ពីណាឲ្យមកដឹកនាំចាប់ខ្លួនទេ តាំងពី-- ខ្ញុំសូមលើកថា តាំងពីអង្គាល់ដែលគេបញ្ជូនខ្ញុំមកដំបូង ខ្ញុំអត់ដឹងថាអ្នកណាជាអ្នកនាំមក ។

**ស៖** អ៊ីចឹងលោកស្រីចាំទេ ថាឡានដែលមកចាប់ខ្លួនអ្នកធ្វើការនោះ ជារបស់អង្គភាពណា? លោកស្រីដឹងទេ ថាវាមានអីសម្គាល់ទេ?

**ឆ៖** ចាស, ជម្រាបប្រសាសន៍! ឡានដែលគេមកចាប់ខ្លួនខ្ញុំតាំងពីដំបូង ដំបូងដែលខ្ញុំមកស្ទឹងជ្រៅហ្នឹង គឺខ្ញុំមកគ្នាពីរនាក់ហ្នឹង ហើយដល់ឡានដែលខ្ញុំចេះមកតាងពេលគេមកចាប់ខ្ញុំលើកក្រោយដែលថាច្រឡំត្រកូលហ្នឹងក៏ជាឡានម៉ាកតែមួយ ប៉ុន្តែឡាននោះជាឡានតូចពណ៌ស្លៃ ។ ប៉ុន្តែ ខ្ញុំអត់ចាំថាឡាននុំងជាម៉ាកអីទេ ។

**ស៖** អរគុណ ។ តើលោកស្រីដែលសង្កេតមើលទេ ថាការចាប់ខ្លួនបែបនេះ ឧស្សាហ៍កើតមានឡើងទេ នៅកន្លែងធ្វើការលោកស្រីនោះ?

[១០:៤៤:១២]

**ឆ៖** ចាស, ជម្រាបប្រសាសន៍! កាលដែលចាប់ខ្លួនបញ្ជូន គឺខ្ញុំឃើញជាញឹកញាប់នៅឯស្ទឹងជ្រៅៗជាកន្លែងដែលខ្ញុំនៅដំបូង គឺញឹកញាប់ ។ ហើយឡានហ្នឹងខ្ញុំអត់ៗអាមធ្យោបាយដឹកជញ្ជូនខ្ញុំអត់ឃើញ

ទេ ។ ប៉ុន្តែគេតម្រង់ជួរគ្នានៅឯស្ទឹងជ្រៅឯនេះ ហើយបានគេនាំគ្នាដើរ បណ្ដើរដើរទៅឯថ្នល់ជាតិនៅឯថ្នល់ជាតិនេះ ហួសពីស្ទឹងជ្រៅទៅថ្នល់ជាតិហ្នឹងប្រហែលជា ថាពីរគីឡូចុះ ។ ហើយភូមិនុំងឡានចូលមិនរួចទេ ដោយមានស្ពានយោលមួយកាត់ស្ទឹងហ្នឹង គេនាំបណ្ដើរទៅ ។ ហើយជាញឹកញាប់ គឺយ៉ាងយូរគឺដប់ថ្ងៃ ឬមួយអាទិត្យអ្នកដែលមកថ្មី មកជំនួសហ្នឹងគឺ-- ប៉ុន្តែមុននឹងអ្នកថ្មីមកជំនួសហ្នឹង អ្នកចាស់ហ្នឹងទៅហើយបានមួយថ្ងៃឡើងទៀតបានមានអ្នកថ្មីមកជំនួស ។

**ស៖** អរគុណ ។ លោកស្រីបានជម្រាបជូនអង្គសវនាការអម្បាញ់មិញថា លោកស្រីបានជួប ឌុច ចំនួនពីរដងនៅក្នុងព្រៃសនោះ ។ តើលោកស្រីចាំទេ ថានៅពេលនោះ នៅក្នុងឆ្នាំណាដែលលោកស្រីបានជួប ឌុច នុំង?

**ឆ៖** គឺនៅ-- ជម្រាបប្រសាសន៍! គឺនៅឆ្នាំ៧៨ ហ្នឹង១គឺក្រោយពេលដែលខ្ញុំស្ដាប់កូនហើយមិនមែននៅព្រៃសទេ នៅអាតំបន់យើងស្ទួងដកនៅឯក្នុងអា១ប្លុកបាគូ ក្នុងហ្នឹងគេហៅ បាគូ នៅមុខព្រៃសហ្នឹង ។

**ស៖** អរគុណ ។ អ៊ីចឹងថាតើពេលនោះលោកស្រីមានសង្កេតឃើញ ឌុច ទេ នៅពេលនោះគាត់មានសភាពរីករាយ ឬក៏មានការស្រងូតស្រងាត់អីយ៉ាងម៉េចដែរនៅពេលនោះ?

**ឆ៖** ជម្រាបប្រសាសន៍! កាលតាមដានសង្កេតហ្នឹង ព្រោះខ្ញុំឃើញគាត់ដើរតែឯងទេ មិនមានអង្គរក្សអីមកជាមួយទេ ។ ប៉ុន្តែ ខ្ញុំឃើញគាត់ក្រវ៉ាត់កាំភ្លើងខ្លី ពាក់មួក ហើយបង់កក្រមាអ៊ីចេះមក គាត់មិនជាប៉ោកព្រៀវទេ គ្រាន់តែថា-- មើលទៅគ្រាន់តែថា រាងសង្ហាសប្បាយចិត្តមិនខ្វាល់នឹងការលំបាករបស់យើងដែល១រស់នៅកន្លែងនោះ ។ គាត់ដើរធ្វើហៃអីលើទំនប់ទៅមិនបានសួរនាំយើងថា អីអាម៉េចអាម៉ាអីគ្មានទេ ។

**ស៖** អរគុណ ។ ទាក់ទងទៅនឹងការដែលលោកស្រីបានជួប ឌុច បន្ទាប់ពីថ្ងៃរំដោះ ៧មករា ១៩៧៩ ហើយលោកស្រីបានទៅជួប ឌុច ហ្នឹងបន្ទាប់ពីជួបនុំង តើពេលនោះមានសភាពការណ៍អីកើតឡើងទេ?

[១០:៤៧:២២]

**ឆ៖** ជម្រាបប្រសាសន៍កាលដែលយើងទៅជួបក្រោយថ្ងៃ ៧ មករា ហ្នឹង សភាពការណ៍ដែលកើតឡើងនឹងគឺ បើយើងនិយាយអំពីសភាពការណ៍ប្រទេសហ្នឹងគឺយើងទឹកចូលច្រមុះហើយ គឺយើង-- បើយើងប្រើភាសាថា យើងបាក់ទ័ពយើងថាអ៊ីចឹង ។

**ស៖** ចង់បញ្ជាក់ថា តើលោកស្រីត្រូវទទួលទារុណកម្ម ឬក៏ទណ្ឌកម្មអីពី ឌុច ឬក៏ក្រុមរបស់គាត់អីដែរឬទេពេលនោះ?

**ឆ៖** ជម្រាបប្រសាសន៍! តាំងពីខ្ញុំចូលទៅនៅកន្លែងហ្នឹងខ្ញុំអត់ដែលបានទទួលការវាយដំជារំពាត់ ឬជាអីទេ ចាស ។ គ្រាន់តែខ្ញុំប៉ះទង្គិចផ្លូវចិត្តហ្នឹងធ្ងន់ នូវការធ្វើបាបជាព្រនង់ ជារំពាត់អីអត់ទេ ។

**លោក សេង ប៊ុនឃាង៖**

**ស៖** ចុះតើលោកស្រីមានដឹងថា មានការកម្ទេចអ្នកទោស ឬក៏អ្នកដែលទៅជាមួយនឹងលោកស្រីដែរទេ នៅពេលដែលលោកស្រីជួប ពេលក្រោយនុ៎ង?

**ឆ៖** ពេលហ្នឹង ខ្ញុំមិនបានដឹងទេ ព្រោះយើងមិនមាន-- ថ្វីដ្បិតតែយើងបាក់ទ័ពរត់ត្រណាត់ត្រណែងទៅនៅក្បែរអមឡាំងក៏ដោយ តែយើងអត់ដែលឃើញពីការសម្លាប់ ពីការចាប់ចង យើងអត់ដែលឃើញទេ ។ វាគ្រាន់តែចេះតែឮលឺ ថាទឹកចូលច្រមុះដល់ប៉ុណ្ណឹងហើយ នៅកៀងគររត់មិនរួចខ្លួនឯង ។

**លោក សេង ប៊ុនឃាង៖**

សូមអរគុណ ។ លោកប្រធានតំណាងអយ្យការអស់សំណួរហើយបាទ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទីរហូតដល់ម៉ោងដប់និងប្រាំនាទី *(ស៊ិក)* អញ្ជើញចូលវិញដើម្បីបន្តដំណើរ ។ ហើយគម្រោងនៃដំណើរការស្តាប់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ត្រឹមតែមួយម៉ោងកន្លះតែប៉ុណ្ណោះ ។ ឥឡូវពីម្សិលមិញ ពីថ្ងៃព្រហស្បតិ៍មួយរសៀល ហើយថ្ងៃនេះមួយព្រឹកទៀតអត់ចប់ផង។ ហើយដើមបណ្តឹងរដ្ឋប្បវេណីអាចរកកន្លែងសម្រាកសមរម្យសម្រាប់បម្រុងទុក សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ។ ហើយសូមឲ្យមកកាន់ទីនេះ នៅមុនពេលអង្គជំនុំជម្រះចូលមកកាន់បន្ទប់សវនាការ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាក ១០:៥០នាទី ដល់ម៉ោង ១១:១៦នាទី]*

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។ ជាបន្តនេះអង្គជំនុំជម្រះប្រគល់វេទិកាទៅមេធាវីការពារក្តីដើម្បីមានឱកាសសាកសួរដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ប្រសិនបើមាន សំណួរសូមអញ្ជើញ ។

**ការតាំងសំណួរដោយមេធាវីការពារក្ដី៖**

**សួរដោយលោក ហ្វ្រេង់ស្វ័រ រ៉ូ៖**

**ស៖** សូមអរគុណលោកប្រធាន ។ សូមជម្រាបសួរដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំជាមេធាវីម្នាក់សម្រាប់ជនជាប់ចោទ ។ ខ្ញុំចង់សួរសំណួរមួយចំនួនទៅលោកស្រី គ្រាន់តែចង់ឲ្យបំភ្លឺអំពីសេចក្ដីប្រកាសរបស់លោកស្រី ហើយនិងជូនអង្គជំនុំជម្រះផងដែរ ។ ខ្ញុំបានអានម្ដងទៀតនូវឯកសារដែលលោកស្រីបានបំពេញនៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនោះ ដើម្បីចូលរួមក្នុងតុលាការនេះ គេបានសួរព័ត៌មានលោកស្រីមួយចំនួន ហើយក៏បានសុំឲ្យលោកស្រីពន្យល់ប្រាប់យើងថាតើមានអ្វីកើតឡើងចំពោះលោកស្រី? អ៊ីចឹងខ្ញុំផ្អែកលើឯកសាររបស់លោកស្រីនេះដើម្បីសួរសំណួរទៅលោកស្រីដើម្បីឲ្យបំភ្លឺនូវចំណុចមួយចំនួន ។ ជាបឋមលោកស្រី បានបញ្ជាក់ថា លោកស្រីបានស្ម័គ្រចិត្តចូលបដិវត្តន៍តើពិតអ៊ីចឹងមែនឬទេ?

**ឆ៖** ចាស,ជម្រាបប្រសាសន៍លោកមេធាវីការពារក្ដី! កាលណោះខ្ញុំចូលបំរើសកម្មភាពជាមួយចលនាបដិវត្តន៍ខ្មែរក្រហមហ្នឹងតាំងពីឆ្នាំ១៩៧១ គឺខ្ញុំបានឆ្លើយជាច្រើនលើកហើយនៅក្នុងនុំង ។ ពីដំបូងមុនយើងសវនាការ គឺយើងទៅដោយស្ម័គ្រចិត្តដោយមានការអំពាវនាវ មានកំហឹងឈឺចាប់នៅក្រោមការជិះជាន់នៃចក្រពត្តិអាមេរិក គឺយើងទៅដោយមានការអំពាវនាវពីសម្ដេចឪថាយើងចូលព្រៃម៉ាគីដើម្បីជួយជាតិ ជួយរំដោះទឹកដី ជួយការពារបូរណភាព ដោយស្ម័គ្រចិត្ត ។

**ស៖** ហើយភ្លាមៗនោះលោកស្រីបាន ទទួលការខុសត្រូវជាដំបូងនោះ គឺលោកស្រីជាប្រធានកងយុវនារីនៅក្នុងភូមិ ហើយលោកស្រីបាននិយាយថា លោកស្រីបានដឹកនាំយុវនារីក្មេងៗនៅក្នុងឃុំមូលដ្ឋាននោះ ។ តើជាការពិតដែរឬទេ ក្នុងកាលនោះ?

**ឆ៖** ចាស, ត្រឹមត្រូវជាការពិត ព្រោះកាលពីសង្គ្រាមនឹងកម្លាំងយុវជននឹង គឺសម្រាប់ជួយដឹកជញ្ជូនកម្លាំងទ័ពទៅសមរភូមិជាមនុស្ស ឬក៏ជាស្បៀងជាអាហារអ៊ីចឹង ។

[១១:២០:៣១]

**ស៖** ហើយផ្អែកតាមលោកស្រីផ្ទាល់ថា តើលោកស្រីចូលចិត្តនៅការងារទទួលខុសត្រូវហ្នឹងដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍! កាលហ្នឹងមិនជាចូលចិត្តប៉ុន្មានទេ ព្រោះវាសាំញ៉ាំ ហើយពិបាក ។ អ៊ីចឹងដល់ពេលគេបញ្ជូនទៅទ័ពគ្រាន់បើជាងនៅសមរភូមិក្រោយ ។

**ស៖** ហើយតាមពិតទៅលោកស្រីបញ្ជាក់នៅក្នុងសេចក្តីប្រកាសរបស់លោកស្រីថា លោកស្រីបានទៅសមរភូមិមុខ តើអ៊ីចឹងមែនឬទេ?

**ឆ៖** ជម្រាបប្រសាសន៍! គឺទៅសមរភូមិមុខគឺនៅក្នុងឆ្នាំ១៩៧៣ នៅពេលហ្នឹងគឺខ្ញុំនៅជាកងទ័ព នារីស្រុកព្រៃវែង ។ ហើយក្នុងរយៈពេលដែលខ្ញុំឡើងដល់កងទ័ពនារីភូមិភាគបូព៌ា គឺមិនបានទៅដល់សមរភូមិមុខទេ ដោយយើងខ្ញុំនៅជាប់ហ្វឹកហាត់ក្បួនយោធានៅសាលាស-២០០ រហូតទាល់តែដល់ពេលបែកឆ្នាំ១៩៧៥ តែម្តង ។

**ស៖** ប៉ុន្តែ នៅពេលដែលលោកស្រីទៅសមរភូមិនោះ លោកស្រីបានច្បាំងជាមួយវៀតណាម ឬក៏គ្រាន់តែចូលរួមក្នុងការវាយប្រយុទ្ធជាមួយកងប្រដាប់អាវុធវៀតណាម ឬក៏ពួកណា?

**ឆ៖** គឺនៅពេលដែលយើងចូលសមរភូមិហ្នឹង ចំពោះក្រុមយើងខ្ញុំទាំងរូបខ្ញុំ យើងមិនមានតួនាទីច្បាំងកាន់កាំភ្លើងប្រយុទ្ធជាមួយគេទេ តែភារកិច្ចរបស់យើងគឺយើងដឹកនាំស្បៀង ស្បៀងពេលល្ងាចហ្នឹងយកទៅឲ្យយុទ្ធជននៅខ្សែត្រៀមសមរភូមិមុខ ហើយយើងនឹងត្រៀមខ្លួនសម្រាប់ជញ្ជូនអ្នកត្រូវរបួស ឬក៏ពលីចេញមកពីសមរភូមិវិញ គឺយើងអត់មានប្រយុទ្ធគ្នាទេចំពោះពួកខ្ញុំ ។

**ស៖** នៅក្នុងសេចក្តីប្រកាសរបស់លោកស្រី លោកស្រីបានបញ្ជាក់មនុស្សមួយចំនួនដែលមានតំណែងដូចលោកស្រី តើលោកស្រីមានតំណែងអីនៅកាលនោះ នៅពេលដែលបន្ទាប់ពីទទួលវគ្គបណ្តុះបណ្តាលយោធានោះ? តើលោកស្រីទទួលតំណែងអ្វីដែរក្នុងកងទ័ព ក្នុងយោធានោះ?

**ឆ៖** ជម្រាបប្រសាសន៍! កាលដែលយើងនៅទ័ពនារីស្រុកហ្នឹងគឺយើងទទួលត្រឹមជាប្រធានក្រុមទេ ព្រោះកាលនោះនៅទ័ពស្រុកហ្នឹងមានតែមួយអនុសេនាតូចទេ មានគេពីលើហ្នឹងទៀតជាប្រធាន តែខ្ញុំនៅត្រឹមប្រធានក្រុម ហើយដល់ពេលដែលយើងត្រូវទៅហាត់ហ្វឹកហ្វឺនរៀនជាយុទ្ធសាស្ត្រនៅកងទ័ពនារីភូមិភាគបូព៌ាកាលហ្នឹងមានពីរវរសេនាតូចសុទ្ធតែនារីទាំងអស់ ។ ប៉ុន្តែ ទ័ពយើងមិនបានទៅសមរភូមិទេ គឺនៅជាប់រវល់ហាត់រៀន ។ ហើយការហាត់រៀនហ្នឹងគឺអស់រយៈពេលប្រាំមួយខែ មិនមែនតិចតួចទេ គឺប្រាំមួយខែរហូតដល់ពេលបែក ។ ហើយតួនាទីនៅពេលហ្នឹង គឺគេចាត់តាំងខ្ញុំជាប្រធានអនុសេនាធំលេខ៤ ហើយនិងគ្រប់គ្រងដល់ទៅប្រធានវរសេនាតូចលេខ២ ផង ។

[១១:២៥:១៦]

**ស៖** ដូច្នេះនៅពេលដែលលោកស្រីមកដល់ភ្នំពេញនៅខែមេសា ឆ្នាំ១៩៧៥ លោកស្រីជាប្រធានកង តើពិតឬទេនៅពេលនោះ?

**ផ៖** នៅក្នុងអង្គភាពស-៨០ ហ្នឹងយើងជាប្រធានក្រុមនារី យើងចង់និយាយថា កាលហ្នឹងយើងជាប្រធានក្រុមវិញ ប្រធានព្រោះគេឲ្យមួយអនុសេនាតូចមកនៅស-៨០ ហ្នឹងមានគ្នាជាងសាមសិបនាក់ហ្នឹង គឺខ្ញុំជាប្រធាន ប៉ុន្តែវាមានលើហ្នឹងពីរបីកន្លាក់ទៀតនុះ ។ យើងជាអ្នកដឹកនាំប្រយុទ្ធផ្ទាល់ទៅជញ្ជូនចាត់ ចែងយាមជាមួយគេជាមួយឯងដូចគ្នាទេ យើងមិនមានតួនាទីអីធំដូចកាលពីយើងនៅជាកងទ័ពទេ។

**ស៖** ប៉ុន្តែលោកស្រីជាប្រធានអនុសេនាតូចនោះ តើបានទទួលការបណ្តុះបណ្តាល (សូមទោស) ខ្ញុំ មិនយល់ច្បាស់ទេ នៅពេលមួយលោកស្រីជាប្រធានកងអនុសេនាតូច តើក្នុងឆ្នាំណាដែរពេលនោះ?

**ផ៖** សូមបញ្ជាក់ម្តងទៀតសំណួរ សូមសួរម្តងទៀត ។

**ស៖** លោកស្រីបានប្រាប់យើងថា នៅពេលមួយលោកស្រីជាប្រធានកងអនុសេនាធំ តើលោកស្រីអាចប្រាប់យើងខ្ញុំទេ ថាតើពេលណាដែលលោកស្រីបានឡើងជាប្រធានអនុសេនាធំនោះ?

**ផ៖** ចាស, នៅពេលនោះ គឺពេលដែលយើងកំពុងហាត់រៀនទ័តនៅឯសាលាស-២០០ ហ្នឹងគឺចំនួនមនុស្សដែលនៅកន្លែងហាត់ហ្វឹករៀន គឺមានពីរវរសេនាតូចគឺមានគ្នាជិតមួយពាន់នាក់ឯណោះ ។ អ៊ីចឹង គឺយើងទទួលការដឹកនាំគ្រប់គ្រងហាត់ហ្វឹកហ្វឺនហ្នឹង គឺរចនាសម្ព័ន្ធចាត់តាំងហ្នឹងគឺមានតាំងពីប្រធានវរសេនាតូចរហូតដល់អនុសេនាធំ អនុសេនាតូចរហូតដល់ក្រុម ។ អ៊ីចឹង នៅពេលនោះខ្ញុំជាប្រធានអនុសេនាធំផង ហើយគេឲ្យទទួលជាប្រធានវរសេនាតូចលេខ២ ផង ។ ប៉ុន្តែ គ្រាន់តែចង់បញ្ជាក់ថា នៅពេលដែលយើងរៀនហ្នឹង គឺយើងអត់មានបានចូលសមរភូមិទេ រហូតដល់យើងបែកឆ្នាំ១៩៧៥ តែម្តង ។

**ស៖** សូមលោកស្រីបញ្ជាក់ប្រយោគចុងក្រោយរបស់លោកស្រីម្តងទៀត ពីព្រោះខ្ញុំស្តាប់ការបកប្រែអត់បាន ។

**ផ៖** ខ្ញុំចង់បញ្ជាក់ជូនថាអំមិញដែលលោកមេធាវីការពារបានសួរខ្ញុំហ្នឹង គឺខ្ញុំបានបញ្ជាក់ពីតួនាទីហើយថាអនុសេនាធំគឺយើងទទួលនៅពេលដែលយើងកំពុងហ្វឹកហ្វឺនក្បួនយុទ្ធសាស្ត្រនៅសាលាស-២០០ គឺទ័ពនារីកាលនោះ គឺមានដល់ទៅពីរវរសេនាតូច ។ ហើយយើងអត់បានទៅសមរភូមិទេ គឺយើងនៅហ្វឹកហាត់ក្រោយរហូតដល់ពេលបែក១៩៧៥ តែម្តង ។

**ស៖** សូមអរគុណដែលលោកស្រីបានឆ្លើយបំភ្លឺលើចំណុចនេះ ។ ខ្ញុំសូមឲ្យមានការបំភ្លឺមួយទៀត នៅពេលដែលលោកស្រីនៅក្នុងភ្នំពេញបន្ទាប់ពីការដួលរលំទីក្រុងភ្នំពេញ ថាតើអង្គភាពរបស់លោកស្រី ចូលរួមនៅក្នុងការជម្លៀសប្រជាជននៅក្នុងភ្នំពេញដែរឬទេ?

[១១:៣០:០០]

**ឆ៖** ជម្រាបប្រសាសន៍! អង្គភាពរបស់នាង ខ្ញុំមិនបានដឹងពីការចូលរួមសកម្មភាពជម្លៀសបងប្អូនប្រជាជននៅក្នុងទីក្រុងភ្នំពេញទេ ព្រោះនាងខ្ញុំពេលគេវ៉ៃភ្នំពេញបែកជាច្រើនខែហើយ ខ្ញុំចាំមិនច្បាស់ ប៉ុន្តែក្នុងរង្វង់៧៥ ដែរ តែពេលហ្នឹងគឺយើងមិនបានមកភ្លាមៗទេ ហើយយើងក៏អត់បានចូលរួមមកជញ្ជូនជយភណ្ឌអីៗដែរ អត់ទេ គឺពេលគេឲ្យមកគឺយើងមកធ្វើការតែម្តង ។

**ស៖** សូមអរគុណដែលលោកស្រីបានឆ្លើយបំភ្លឺលើចំណុចនេះ ។ ថាតើវាត្រឹមត្រូវដែរឬទេនៅពេលដែលយើងនិយាយថាក្នុងនាមជាទាហាន លោកស្រីបានបម្រើកងទ័ពទាហាននេះដោយមានភក្តីភាព តើអ៊ីចឹងទេ?

**ឆ៖** មួយចំណែកសូមជម្រាបប្រសាសន៍! វាត្រឹមត្រូវហើយ ប៉ុន្តែមួយចំណែកវាអត់ត្រឹមត្រូវនៃយុត្តិធម៌សម្រាប់ខ្ញុំ ដែលក្រោយពីពេលដែលខ្ញុំចូលរួមយ៉ាងសកម្មតាំងពីសង្គ្រាមរហូតដល់បានរំដោះ ហើយទីចុងបំផុតខ្ញុំទទួលបាននូវលទ្ធផលបាត់បង់ វាអត់ត្រឹមត្រូវ ខ្ញុំខឹងណាស់ មិនគួរណា-- ខ្ញុំដាក់ៗថាពួកបោកប្រាស់ទៅចុះ ។ មិនគួរមកបោកប្រាស់ចិត្តគំនិតខ្ញុំរហូតអស់រលីងសល់តែខ្ញុំម្នាក់ ។

**ស៖** នេះគឺជាសំណួរដែលខ្ញុំរៀបនឹងសួរលោកស្រី តើលោកស្រីមានអារម្មណ៍ទេថា ការងារលោកស្រីបានបម្រើការងារជូនអង្គការ ប៉ុន្តែអង្គការបានក្បត់លោកស្រី តើអ៊ីចឹងទេ?

**ឆ៖** ចាំ, ត្រឹមត្រូវ ។

**ស៖** ខ្ញុំចង់សួរសំណួរមួយទៀត នៅក្នុងសេចក្តីប្រកាសរបស់លោកស្រី លោកស្រីបានរៀបរាប់នៅហេតុការណ៍មួយនៅពេលដែលអង្គការបានមកចាប់យកស្វាមីរបស់លោកស្រីទៅឆ្ងាយ ។ លោកស្រីបាននិយាយថា នៅថ្ងៃទី៩ សីហា ឆ្នាំ១៩៧៧ អង្គការបានហៅប្តីរបស់ខ្ញុំទៅរៀនសូត្រ ខ្ញុំបានរៀបចំអីវ៉ាន់របស់គាត់ហើយខ្ញុំបានអមដំណើរគាត់ទៅឡើងឡាន ។ ស្វាមីរបស់ខ្ញុំគឺគាត់បានដឹងថា គាត់ប្រាកដជាទៅចូលគុក ប៉ុន្តែគាត់មិនបានព្យាយាមរត់គេចខ្លួននោះទេ ដោយសារតែគាត់ដឹងថា បើសិនជាគាត់គេចខ្លួន ភរិយារបស់គាត់និងកូនរបស់គាត់ នឹងប្រហែលជាគេសម្លាប់ចោល ។ ហើយលោកស្រីបាននិយាយបន្ថែមថានៅពេលនោះខ្ញុំមានផ្ទៃពោះជាងបួនខែ ។ ខ្ញុំចង់សួរដូចខាងក្រោម ។

តើលោកស្រីជឿទេថា ប្រសិនបើស្វាមីរបស់លោកស្រីពិតជារត់គេចខ្លួនមែននោះ គឺវាមានគ្រោះថ្នាក់ដែលថាគេនឹងសម្លាប់លោកស្រី ដោយសារតែលោកស្រីជាភរិយារបស់គាត់ តើអ៊ីចឹងទេ?

[១១:៣៤:៣២]

**ឆះ** កាលដែលខ្ញុំកំណត់ថា ប្ដីខ្ញុំបានផ្ដាំផ្ញើហើយបានប្រាប់ខ្ញុំនេះ កាលនុ៎ងគឺខ្ញុំមិនដឹងអីប៉ុន្មានទេ គឺទើបតែការចូលរួមសវនាការទេ ដែលគេមានផែនការកម្ទេចនោះ ។ ប៉ុន្តែ ប្ដីខ្ញុំមិនបាននិយាយប្រាប់អីវែងឆ្ងាយអំពី-- លម្អិតអំពី-- ខ្ញុំកំណត់ថាប្ដីខ្ញុំប្រហែលជាដឹងព្រោះគាត់ទៅកន្លែងនុ៎ងមុនខ្ញុំ អ៊ីចឹងគាត់អត់មាននិយាយអីទេ គាត់គ្រាន់តែប្រាប់គាត់មិនរត់ទេ គាត់ខ្សឹបប្រាប់ខ្ញុំអ៊ីចឹង ហើយខ្ញុំមិនដឹង ។ ហើយដល់ក្រោយមកគេនាំមក គេថាទៅជុំប្ដី អរ! ប៉ុន្តែមកអត់ឃើញប្ដី ។

**សះ** តាមអ្វីដែលលោកស្រីជម្រាបយើងព្រឹកមិញនេះ ក្នុងអំឡុងពេលនោះលោកស្រីមិនត្រឹមតែបាត់បង់ស្វាមីប៉ុណ្ណោះទេ លោកស្រីបានបាត់បង់សមាជិកគ្រួសារទៀត ។ នៅពេលលោកស្រីត្រលប់ទៅភូមិកំណើតរបស់លោកស្រីវិញ ថាតើអ្នកភូមិនៅចាត់ទុកលោកស្រីថាជាសមាជិករបស់ក្រុមខ្មែរក្រហមដែរឬទេ? ថាតើគេគិតដូច្នោះដែរឬទេ? ហើយថាតើអ្នកភូមិនៅតែគិតថាលោកស្រីនៅតែជាសមាជិកខ្មែរក្រហមនៅសម័យនោះទៀតដដែរឬទេ?

**ឆះ** ខ្ញុំសូមជម្រាបប្រសាសន៍! ចម្លើយនេះគឺខ្ញុំមែនថាខ្ញុំពិបាកឆ្លើយទេ ប៉ុន្តែ ខ្ញុំទប់មិនបាននូវអារម្មណ៍ឈឺចាប់ មិនមែនថាខ្ញុំឆ្លើយមិនបានទេ គឺជាដំបូងដែលខ្ញុំជួបគឺខ្ញុំជួបម្ដាយមីងខ្ញុំមុនគេ ។ ម្ដាយមីងខ្ញុំខឹងណាស់ ខឹងនឹងខ្ញុំ ថាមកពីអ្អែង ពួកអ្អែងបានជាកូនគាត់ស្លាប់ជាច្រើននាក់ ។ នេះជាសំណួរដែលខ្ញុំពិបាកឆ្លើយ ប៉ុន្តែមែនខ្ញុំឆ្លើយមិនរួចទេ ។ អ៊ីចឹង បានជាខ្ញុំសូមភ្ជាប់ទៅនឹងការសូមទោសរបស់ជនជាប់ចោទជាច្រើនលើក ។ ចំា, សូមទោស ខ្ញុំថាខ្ញុំទទួលមិនបានទេ ព្រោះថាខ្ញុំធ្លាប់សូមទោសមីងខ្ញុំនៅសាធារណៈ លុតជង្គង់នៅពេលដែលខ្ញុំជួបមីងដំបូងតាមផ្លូវ មីងថាឲ្យខ្ញុំប៉ុណ្ណឹង តែទន់ជង្គង់ លុតជង្គង់សូមទោស ។ នេះជាម្ដាយមីងខ្ញុំបង្កើត ។

ក្រោយថ្ងៃនេះ ខ្ញុំជឿថាមីងខ្ញុំនឹងអស់ចិត្ត ពេលដែលខ្ញុំមកតទល់នៅមុខសាលាក្ដីរបស់តុលាការកម្ពុជា ។ ហើយខ្ញុំមានអារម្មណ៍មួយថា ការសូមទោសរបស់ជនជាប់ចោទមួយម៉ាត់នៅក្នុងសាលសវនាការនេះ គឺខ្ញុំមិនអាចទទួលបាន ព្រោះខ្ញុំធ្លាប់សូមទោសមីងខ្ញុំ មីងខ្ញុំគាត់យកបានដោយខ្ញុំគ្មានពីណាបង្ខំអីទេ គឺខ្ញុំភ្ញាក់រឭកខ្លួនឯង ។ អ៊ីចឹង ខ្ញុំព្យាយាមទាន់មានឱកាស ខ្ញុំបានដាក់ពាក្យបណ្ដឹងដើម្បីឆ្លើយតបនឹងតម្រូវការរបស់បងប្អូនខ្ញុំទាំងអស់ ព្រមទាំងញាតិមិត្តដែលរងគ្រោះ កុំឲ្យគេថ្កោលមកខ្ញុំថា ខ្ញុំហ្នឹងអ៊ីចេះអ៊ីចុះ ជាខ្មែរក្រហមឃោរឃៅ ការពិតខ្ញុំធ្វើតាមការស្រលាញ់ជាតិរបស់ខ្ញុំ ដែលមិននឹកស្មានថាពួកបោកប្រាស់ហ្នឹង វាធ្វើបាបខ្ញុំដល់ប៉ុណ្ណឹង ខ្ញុំថាអ៊ីចុះ (សូមទោស) ដែលខ្ញុំថាពាក្យមិនសូវសម ។

[១១:៣៨:៥៨]

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកស្រី ខ្ញុំពុំមានសំណួរទៀតទេ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

មុននឹងផ្តល់ឱកាសទៅជនចោទ ដើម្បីធ្វើការកត់សម្គាល់នូវសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ អង្គជំនុំជម្រះបានស្តាប់នូវបំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីលោកស្រី ជុំ នៅ ថាលោកស្រីមានបំណងតាំងសំណួរមួយចំនួនចំពោះជនជាប់ចោទ តើលោកស្រីនៅតែមានបំណងក្នុងការតាំងសំណួរមួយចំនួនចំពោះជនជាប់ចោទដែរឬទេ ឬក៏លោកស្រីបោះបង់នូវបំណងនោះហើយ?

**លោកស្រី ជុំ នៅ៖**

ចាំ, សូមអរគុណលោកប្រធាន នេះជាចម្ងល់របស់ខ្ញុំដែលៗនៅក្នុងឯកសារបញ្ជីរបស់ប្តីខ្ញុំគឺគេដាក់ថា គាត់ជាយុទ្ធជននៅ៦២ “ខ” ភស្តុភាររបស់សេនាធិការ ប៉ុន្តែពាក្យមន្ទីរ ៦២ “ខ” នៃមន្ទីរភស្តុ-ភារសេនាធិការនេះ ខ្ញុំអត់ៗដែរឮ អ៊ីចឹងខ្ញុំគ្រាន់តែដឹងថា ប្តីខ្ញុំគឺគាត់នៅក្នុងមន្ទីរស-៨០ ជាមួយខ្ញុំដែរ អ៊ីចឹងខ្ញុំគ្រាន់តែចង់សួរ តើជនជាប់ចោទហ្នឹងដឹងទេ មន្ទីរ៦២ “ខ” ហ្នឹង តើនៅម្តុំច្បារអំពៅជាកន្លែងបង្កើនផល ឬក៏នៅម្តុំស្ទឹងជ្រៅ ឬក៏នៅម្តុំបាគូណា ខ្ញុំអត់ដឹង ប៉ុន្តែចង់ឲ្យជនជាប់ចោទហ្នឹងបំភ្លឺឲ្យច្បាស់នៅបញ្ជីៗឈ្មោះហ្នឹង ។

**ប្រធានអង្គជំនុំ៖**

យើងបញ្ជូននូវសំណួរនេះទៅជនជាប់ចោទដើម្បីឆ្លើយតបទៅនឹងសំណួររបស់ដើមបណ្តឹងរូបនេះ។ អញ្ជើញ។

[១១:៤១:៣១]

**ជនជាប់ចោទ៖**

សូមគោរពលោកប្រធាន! ឯកសារស-២១ ទាំងប៉ុន្មានឲ្យតែឃើញថាឯកសាររបស់មន្ទីរស-២១ ខ្ញុំទទួលស្គាល់ភ្លាម អត់ប្រកែកទេ ។ សលាកប័ត្រដែលយើងធ្លាប់ហៅថា ប្រវត្តិរូបសង្ខេបរបស់អ្នកស្រី ជុំ នៅ ក៏ខ្ញុំទទួលស្គាល់ភ្លាម ។ ទទួលស្គាល់សលាកប័ត្រហើយ បានទទួលស្គាល់បុគ្គលអ្នកស្រី ជុំ នៅ ជាក្រោយ ។ ដោយឡែក ឯកសារនេះក៏ខ្ញុំទទួលស្គាល់ភ្លាម ពាក្យថា នូ សាមឿន ឈ្មោះហៅ សែម យុទ្ធជនមន្ទីរ៦២ “ខ” ភ័ស្តុភារសេនាធិការ សេនាធិការវាមានមន្ទីរភ័ស្តុភារមួយឈ្មោះជាលេខរបស់គេ ខ្ញុំដូចជាចាំថា៦២ គេប្រើជាទូទៅជាង នេះគឺខ្ញុំសូមបញ្ជាក់អ៊ីចឹង មន្ទីរ៦២ ប្រើជាទូទៅជាង ។

ហើយប៉ុន្តែអ្នកស្រី ជុំ នៅ មានប្រសាសន៍អំមិញមនុស្ស៣នាក់ ដែលគ្រប់គ្រងមន្ទីរហ្នឹងគឺ បងផុន ខ្ញុំស្គាល់ច្បាស់នៅគ្រប់គ្រងខាងហ្នឹងមែន មិត្តម៉ុត ក៏ខ្ញុំស្គាល់ច្បាស់ដែរ នៅគ្រប់គ្រងខាងហ្នឹង ហើយមិត្តធឹម ដូច្នេះ ៦២ ឬ ៨០ ខ្ញុំអត់ប្រកែកទេ ទទួលស្គាល់ពេញលេញថា លោក នូ សាមឿន ឬលោក នូ មឿន ពិតជាទៅរងគ្រោះហើយស្លាប់បាត់បង់ជីវិតនៅមន្ទីរស-២១ ជាប្រាកដ ។

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីមានសំណួរអ្វីផ្សេងទៀតដែរឬទេ?

**លោកស្រី ជុំ នៅ៖**

ចាំ, លោកប្រធានគឺ រកនឹកមិនឃើញទេគឺសូមអស់ប៉ុណ្ណឹង ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ជនជាប់ចោទក្រៅពីឆ្លើយនឹងសំណួរហើយ ហាក់ដូចជាមានការកត់សម្គាល់នូវតបទៅនឹងសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីហើយដែរ ។ សំណួរសួរថា តើលោកត្រូវការធ្វើសេចក្តីកត់សម្គាល់បន្ថែមទៅលើអ្វីដែលលោកបាននិយាយអម្បាញ់មិញទៀតទេ ចំពោះសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ។

**ជនជាប់ចោទ៖**

សូមគោរពលោកប្រធាន! ខ្ញុំទទួលស្គាល់ទុក្ខវេទនាទាំងអស់របស់អ្នកស្រី ជុំ នៅ ដែលរាយ-ការណ៍ក្នុងរយៈពីពេលដែលអ្នកស្រី ជុំ នៅ ទៅរងទុក្ខវេទនានៅមន្ទីរព្រៃស ដែលហៅថា ស-២៤ រហូតដល់ថ្ងៃ៧ មករា ១៩៧៧ ហើយក្រោយមកអ្នកស្រី ជុំ នៅ រត់ទៅជាមួយយើងខ្ញុំ ។ រឿងដែលខ្ញុំប្លែកត្រចៀក ប្លែកពីការចងចាំមានបីកន្លែង ។ ទីមួយគឺអ្នកស្រី ជុំ នៅ ប្រកាសថាឃើញខ្ញុំដើរទៅត្រួតពិនិត្យគេស្ទូង ខ្ញុំមិនដែលបានទៅត្រួតពិនិត្យទេ ហើយនិងការដែលខ្ញុំទៅព្រៃស ឃើញអ្នកស្រី ជុំ នៅៗ ឃើញខ្ញុំក៏ខ្ញុំមិនបានឲ្យអ្នកណាឃើញដែរ ខ្ញុំទៅព្រៃសពិតមែនប្អូនដង ដូចរាយការណ៍ ។

ដោយឡែក ពេលអ្នកស្រី ជុំ នៅ មានប្រសាសន៍ថាខ្ញុំឲ្យគេអញ្ជើញអ្នកស្រីមកហើយខ្ញុំយកកាំភ្លើងភ្ជង់សៀតផ្កាពីរឿងរត់ មិនមែនទេ ។ ខ្ញុំមិនដែលបានភ្ជង់កាំភ្លើងអ្នកណារបៀបនេះ កូនចៅខ្ញុំមានច្រើនណាស់សម្រាប់ចាប់ចង សម្រាប់ព្រមានអ្នកផ្សេងទៀត ខ្ញុំអត់ដែលធ្វើដោយដៃខ្ញុំទេ ហើយសូមបញ្ជាក់ថានៅភូមិហុងត្នោតនេះ ជាភូមិរបស់ប្រពន្ធខ្ញុំ ផ្ទះប្រពន្ធខ្ញុំ ខ្ញុំដើរអត់បាយពីរយប់ពីរថ្ងៃ រហូតទៅដល់ផ្ទះប្រពន្ធខ្ញុំ ខ្ញុំគិតតែពីដេក ហូបបាយបានតិចៗទម្រាំតែមានកម្លាំងឡើងវិញ ហើយនាំគ្នាមកវៃនៅ

ទប់កងទ័ពដែលគេត្បុលចូលមក ទប់នៅផ្លូវរទេះភ្លើង អត់មានពេលឯណាបានទៅគិតគូរកម្លាំងស្រីៗអីទេ នេះជាក់ស្តែង ។

ដូច្នេះ ខ្ញុំគ្រាន់តែសូមបញ្ជាក់ប៉ុណ្ណេះ ដោយឡែកទុក្ខទេវនារបស់ប្រជាជននៅបូព៌ា យុទ្ធជនមកពីបូព៌ារងកម្មវេទនាជំនាន់នោះ ខ្ញុំទទួលស្គាល់ថាពិត ។ នេះគឺសូមបញ្ជាក់ប៉ុណ្ណេះ ដោយគោរព ។

[១១:៤៦:២០]

**ប្រធានអង្គជំនុំ៖**

ដំណើរនៃការស្តាប់សេចក្តីថ្លែងការណ៍ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ជុំ នៅ ឃើញថាដល់ទីបញ្ចប់ហើយ ។ ហើយជម្រាបជូនលោកស្រី ជុំ នៅ ថាដំណើរការសវនាការស្តាប់សេចក្តីថ្លែងការណ៍របស់លោកស្រីបានចប់ហើយ ហើយលោកស្រីអាចនៅទីនេះ នៅកន្លែងរៀបចំសម្រាប់ដើមបណ្តឹងរដ្ឋ-ប្បវេណីដើម្បីសម្តាប់ដំណើរការសវនាការតទៅទៀត ឬក៏លោកស្រីអាចចាកចេញដើម្បីធ្វើដំណើរទៅគោលដៅដែលលោកស្រីចង់ទៅ នេះជាសិទ្ធិសេរីភាពរបស់លោកស្រីក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី។ ហើយដោយសារពេលវេលាក៏ត្រូវដល់សម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកត្រឹមនេះសម្រាប់ដំណើរការសវនាការព្រឹកនេះ ដើម្បីពិសាអាហារថ្ងៃត្រង់ ហើយដំណើរការសវនាការនឹងលើកទៅបន្តនៅរសៀលចាប់ពីម៉ោងមួយនិងសាមសិបនាទី ។ ហើយដំណើរការគឺស្តាប់សេចក្តីថ្លែងការណ៍នៅដើមបណ្តឹងរដ្ឋប្បវេណីចំនួនពីររូបតាមកាលវិភាគដែលបានគ្រោងទុក ។

អនុរក្សមន្ត្រីឃុំឃាំងឲ្យនាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំ ហើយឲ្យនាំជនជាប់ចោទមកកាន់សាលសវនាការវិញនៅរសៀលនេះឲ្យមុនម៉ោងមួយនិងសាមសិបនាទី ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១១:៤៧ នាទីដល់ម៉ោង ១៣:៣៤នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។ តាមកាលវិភាគដែលបានកែសម្រួលគឺនៅរសៀលនេះគឺយើងនឹងស្តាប់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្ប-វេណីចំនួនពីររូបគឺ ឈិន ណារី ហើយនិង តូច មុន្និន ។ មុននឹងស្តាប់នូវសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងពីររូប ។

អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគីឲ្យបានជ្រាប អង្គជំនុំជម្រះយោងទៅលើសំណើរបស់សហព្រះរាជអាជ្ញា កាលពីព្រឹកមិញដែលបានស្នើសុំដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះផ្អែកតាមវិធាន៨៧ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ក្រោយពីបានបញ្ចប់នូវការស្តាប់សក្ខីកម្មរបស់សាក្សីនិងអ្នកជំនាញទាក់ទងទៅនឹងអត្តចរិតរបស់ជនជាប់ចោទ ។ អង្គជំនុំជម្រះនឹងកំណត់ពេលវេលាសម្រាប់ភាគីក្នុងការដាក់ឯកសារដែលមានរួចហើយ នៅក្នុងសំណុំរឿងចំពោះអង្គជំនុំជម្រះអនុលោមតាមវិធាន៨៧.៣ ។ ប្រសិនបើភាគីណា មានបំណងដាក់ឯកសារថ្មីដោយផ្អែកតាមវិធាន៨៧.៤ សូមភាគីដាក់ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ។

នេះគឺជាការជម្រាបជូនដំណឹងអំពីការស្នើសុំដាក់ឯកសារព្រឹកមិញ តបទៅនឹងសំណើសុំរបស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ហើយក៏ជម្រាបជូនដំណឹងដល់ភាគី ដូចខ្លឹមសារដែលបានជម្រាបជូនរួចហើយនេះ ។

អង្គជំនុំជម្រះសង្ឃឹមថា អង្គភាគីទាំងអស់នឹងបានយល់អំពីបញ្ហានេះ ហើយនិងរៀបចំនូវកិច្ចការរបស់ខ្លួន ដើម្បីដាក់ចំពោះមុខអង្គជំនុំជម្រះតាមកាលបរិច្ឆេទដែលបានជម្រាបអម្បាញ់មិញនេះ ។

មន្ត្រីតុលាការ អញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី ឈិន ណាវី មកកាន់ទីកន្លែងដែលរៀបចំទុកសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខអង្គជំនុំជម្រះ ។

*(អ្នកស្រី ឈិន ណាវី ចូលក្នុងបន្ទប់សវនាការ)*

[១៣:៣៨:៥០]

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកស្រី ឈិន ណាវី! តើលោកស្រី ឈ្មោះ ឈិន ណាវី អ៊ីចឹងពិតមែនដែរឬទេ?

**ឆ៖** ចា៎ ខ្ញុំពិតជាឈ្មោះ ឈិន ណាវី ។

**ស៖** លោកស្រីមានអាយុប៉ុន្មានហើយ?

**ឆ៖** អាយុ៧០ឆ្នាំហើយ បច្ចុប្បន្ននេះ ។

**ស៖** លោកស្រី មានទីកន្លែងកំណើតនៅឯណា?

**ឆ៖** នៅឃុំកោះខែល ស្រុកស្អាង ខេត្តកណ្តាល ។

**ស៖** លោកស្រី សព្វថ្ងៃនេះ តើមានទីលំនៅ នៅទីកន្លែងណា?

**ឆ៖** សព្វថ្ងៃនេះ ខ្ញុំទីលំនៅនៅភ្នំពេញ ។

**ស៖** ឪពុកបង្កើតរបស់លោកស្រី គាត់ឈ្មោះអ្វី?

**ឆ៖** ឪពុកបង្កើតរបស់ខ្ញុំឈ្មោះ ឈិន ចាប ។ គាត់អាយុកាល ពេលជម្លៀសចេញពីភ្នំពេញ គាត់អាយុ៥០ ជាងហើយ ទៅជាមួយខ្ញុំ ។ តែបច្ចុប្បន្ន គាត់ស្លាប់ហើយ ។

**ស៖** ចុះម្ដាយរបស់លោកស្រីវិញ គាត់ឈ្មោះអ្វីដែរ?

**ឆ៖** ម្ដាយរបស់នាងខ្ញុំ ឈ្មោះ ហុង ស្រ៊ុន ។ កាលគាត់នៅរស់ ខ្ញុំដឹងក្ដីមក ចាំដូចជាអាយុគាត់ ៤០ផ្លាយ ។ តែគាត់ឈឺស្លាប់ទៅ ខ្ញុំកំព្រាតាំងពីតូចមក ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះផ្ដល់វេទិកាទៅមេធាវីអ្នកតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីក្រុមពីរ ដើម្បីឡើងធ្វើសេចក្ដីថ្លែងការណ៍សង្ខេបដល់អង្គសវនាការ អំពីអត្តសញ្ញាណរបស់ដើមបណ្ដឹងរដ្ឋប្បវេណីអំពីហេតុដែលនាំឲ្យដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ បានតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ទំនាក់ទំនងការប្ដឹទាមទារសំណងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ទៅនឹងបទឧក្រិដ្ឋដែលបានចោទចំពោះជនជាប់ចោទឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ពាក់ព័ន្ធទៅនឹងអង្គហេតុដែលកើតមាននៅមន្ទីរសន្តិសុខស-២១ ក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ព្រមទាំងភស្ដុតាងនានាដែលមាន ដើម្បីគាំទ្រដល់ការប្ដឹទាមទារសំណងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ឈិន ណារី ។ សូមអញ្ជើញ ។

[១៣:៤២:០៩]

**លោក គង់ ពិសី៖**

សូមអរគុណលោកប្រធាន ហើយខ្ញុំបាទសូមគោរព លោក លោកស្រី ចៅក្រមអន្តរជាតិ និងជាតិ ។ ហើយខ្ញុំបាទជាមេធាវីជាតិដែលតំណាងឲ្យក្រុមពីរ ។ ហើយខ្ញុំបាទសូមបង្ហាញជាអត្តសញ្ញាណអំពីលោកស្រី ឈិន ណារី ដូចតទៅ៖

លោកស្រី ឈិន ណារី គាត់បានដាក់ពាក្យបណ្ដឹង ពាក្យបណ្ដឹងរបស់គាត់មានលេខ ERN ជាភាសាខ្មែរ 00152367 ហើយដែលមានជាភាសាអង់គ្លេស ERN00156825 ។ ចំពោះអត្តសញ្ញាណប័ណ្ណរបស់គាត់ៗលេខERN ដែរ 00152374 ឯលេខអត្តសញ្ញាណរបស់អត្តសញ្ញាណប័ណ្ណរបស់គាត់មានលេខ010154658 ។ ហើយជាបន្ទាប់នោះ គឺមានបញ្ជីដែលជាជនជាប់រងគ្រោះត្រូវកម្ទេចនៅឯស-២១ នោះ បញ្ជីនោះមានលេខ ERN ភាសាខ្មែរទេ 00080640 ដែលមានឈ្មោះនៅក្នុងនោះលេខ

រៀង៥១៦ ហៅ-- ទៀ ហាវតឹក ។ កាលដែលមុខងាររបស់គាត់ មានដូចជាសាធារណការនៅតំបន់ ២៥ ។ ចាប់ខ្លួននៅថ្ងៃទី២២ ខែ២ ឆ្នាំ១៩៧៦ ។ កម្ទេចនៅថ្ងៃទី២៥ ខែ៥ ៧៦ ហើយដែលមានរូបថតប្តីរបស់គាត់យកពីមន្ទីរស-២១ តែរូបថតនេះ ខ្ញុំនឹងសូមបង្ហាញជាលើកក្រោយតទៅទៀត ។

ទាក់ទងជាមួយនឹងលោកស្រី ឈិន ណារី ដែលឈ្មោះ ទៀ ហាវតឹក អម្បាញ់មិញនេះគឺថាជាប្តីរបសគាត់ ហើយគាត់បានដាក់ពាក្យបណ្តឹងមកអង្គជំនុំជម្រះ ។ ដូច្នេះ ខ្ញុំសូមអរគុណ សូមបង្ហាញជូនប៉ុណ្ណេះ ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ តើគួរតែត្រូវបានឲ្យគាត់ធ្វើសេចក្តីថ្លែង-ការណ៍ក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណី បង្ហាញហេតុផលនានា ដែលនាំឲ្យគាត់តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឬក៏មានដូរវិធីថា សុំតាំងសំណួរផ្ទាល់ជាក់លាក់សំដៅគាត់តែម្តង? បញ្ហានេះលោកបានគិតដែរទេ?

**លោក គង់ ពិសី៖**

ខ្ញុំបាទ សូមលោកប្រធានមេត្តាសួរសំណួរគាត់ទៅ ហើយខ្ញុំនឹងមានសំណួរបន្តបន្ទាប់ជាលើកក្រោយទៀតបាទ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

លោកគិតថា តើសុំឲ្យគាត់ធ្វើសេចក្តីថ្លែងការណ៍រៀបរាប់អំពីដំណើររឿងហេតុទាំងឡាយដែលគាត់បានជួបប្រទះក្នុងជីវិតរបស់គាត់ ហើយឲ្យគាត់តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឬក៏លោកសុំនីតិវីធីថា សុំតាំងសំណួរជាក់លាក់ចំពោះគាត់ ។ នេះជាមធ្យោបាយដែលគាត់-- លោកសម្របសម្រួលដើម្បីអាចដំណើរការបាន មធ្យោបាយណាដែលល្អសម្រាប់លោក និងកូនក្តីរបស់លោក?

**លោក គង់ ពិសី៖**

ខ្ញុំបាទបានរៀបចំរួចហើយថាឲ្យគាត់រៀបរាប់ដំណើររឿងរបស់គាត់ទៅ ហើយចំណុចដែលខ្វះខាត ខ្ញុំនឹងសួរជាបន្តបន្ទាប់តាមក្រោយទៀតទាន ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

លោកស្រី ឈិន ណារី ឥឡូវនេះអង្គជំនុំជម្រះផ្តល់ឱកាសដល់លោកស្រី ដើម្បីធ្វើសេចក្តីថ្លែងរៀបរាប់ជូនដល់អង្គសវនាការ អំពីរឿងហេតុ អំពីទំនាក់ទំនងរបស់លោកស្រីទៅនឹងបទឧក្រិដ្ឋដែលត្រូវ

បានចោទប្រកាន់ទៅលើជនជាប់ចោទ ដែលលោកស្រីបានប្តឹងទាមទារសំណងនិងអំពីស្ថានភាពព្យសន-កម្មដែលមានចំពោះលោកស្រី ជាអាទិ៍ ការខូចខាតផ្នែកខាងរាយកាយ សម្ភារៈ ឬផ្លូវចិត្ត ហើយវាជាផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋ ជាព្យសនកម្មផ្ទាល់ខ្លួនដែលបានកើតមានពិតប្រាកដរហូតដល់បច្ចុប្បន្ននេះ ។ សូមអញ្ជើញ ។

[១៣:៤៨:០៣]

**លោកស្រី ឈិន ណាវី៖**

ខ្ញុំសូមគោរពអង្គសវនាការទាំងមូល! សូមគោរពភ្ញៀវជាតិ និងភ្ញៀវអន្តរជាតិជាទីគោរពរាប់អាន និងមេធាវី និងតុលាការទាំងអស់ ដោយខ្ញុំមិនបានចេះដឹងពាក្យសម្តីតាមច្បាប់ទាំងអស់ទេ ។ ហើយក៏ខ្ញុំសូម-- កាលណាខ្ញុំភ្លេចត្រង់ណា លើសច្បាស់ផ្គាំផ្គងដោយប្រការណា ខ្ញុំសូមខន្តីអភ័យទោសឲ្យខ្ញុំផង ព្រោះអីខ្ញុំឈឺច្រើន ហើយខ្ញុំក៏ភ្លេចច្រើនទៀត ។ ពេលណាអារម្មណ៍ខ្ញុំល្អ ខ្ញុំអាចចាំបានច្រើន សុខភាពខ្ញុំមិនសូវជាល្អទេយូរយារមកហើយ ស្ទើរឆ្កួតស្ទើរជា ចួនកាលដោយគ្រប់បែបយ៉ាងហើយក្នុងជីវិតខ្ញុំ ។

លោកប្រធានចង់ឲ្យខ្ញុំនិយាយតាំងពីថ្ងៃចេញពីផ្ទះ គេចប់គ្រាប់កាំភ្លើងហ្នឹងលោក?

**ប្រធានអង្គជំនុំ៖**

អាស្រ័យលើលោកស្រី បើលោកស្រីអាចនិយាយរៀបរាបពីដើមដំបូងនៃការចេញពីភ្នំពេញជម្លៀសពីភ្នំពេញទៅ នេះជាការសង្ខេប ហើយសំខាន់គឺមានការបញ្ជាក់ឲ្យស៊ីជម្រៅពាក់ព័ន្ធជាមួយនឹងចាប់ពីពាក់ព័ន្ធជាមួយនឹងមន្ទីរសន្តិសុខស-២១ ជាមួយនឹងគ្រួសាររបស់លោកស្រី ។

ជនជាប់ចោទឥឡូវអត់ទាន់មានភ្លើងទេ ចាំអ្នកជំនួយ ចាំៗអ្នកគ្រូពេទ្យជំនួយ ចាំដល់មានភ្លើងសឹមឲ្យគាត់និយាយ ។ សូមអញ្ជើញ ។

**លោកស្រី ឈិន ណាវី៖**

ចាស, សូមគោរពលោកប្រធានជាតិ និងប្រធានអន្តរជាតិ និងអង្គសវនាការទាំងមូល ។

នាងខ្ញុំឈ្មោះ ឈិន ណាវី ការរស់នៅភ្នំពេញរបស់ខ្ញុំ តាំងពីក្មេងមកគឺខ្ញុំនៅរៀនស្រុកកំណើត ហើយអស់សាលារៀន ខ្ញុំបានប្រឡងជាប់ពេទ្យជំនាន់នោះឆ្នាំ *មីណឺហ្វសង់សែងកង់សេត* គេបានរើស *អាំងហ្វេមីញេ អាំងហ្វេមីញែរដេតា* នៅប្រទេសកម្ពុជាយើង ។ ហើយក៏ខ្ញុំបានកុងគួរចូលសាលាពេទ្យនៅក្រសួងសុខាភិបាលនេះ កាលនោះគឺខ្ញុំនៅចាំបានថា *កង់ឌីដា* ជាងប៉ុន្មានពាន់នាក់ទេ ហើយគេយកតែមួយរយសែសិបនាក់ប្លាយ ខ្ញុំក៏បានជាប់ជា *អាំងហ្វេមីញែរដេតា (និយាយភាសាបារាំង)* ។

[១១:៥០:៥៥]

ខ្ញុំបានរៀនច្បាប់ចេញ *ស្តាហ្ស៊ា* មក៥៩ បម្រើការងារនៅមន្ទីរពេទ្យព្រះកេតុមាលា បន្ទាប់ពីនោះមកទៀត ខ្ញុំបានប្រើការទៅថ្ងៃមួយបងថ្លៃខ្ញុំគាត់បានមានជំងឺ*អាប៉ង់ដេស៊ីត* នៅស្រុកបារាំងរាល់ថ្ងៃហ្នឹង គាត់មករះក៏ជួបនឹងម្តាយក្មេកម្តាយខ្ញុំនេះ ជាមកកំដរមកទៅក៏គាត់ឃើញខ្ញុំជាពេទ្យហ្នឹងធ្វើការល្អ ដល់ពេលបងថ្លៃខ្ញុំជាទៅគាត់តាមមកដណ្តឹងខ្ញុំ សួរពូជអម្បូរដណ្តឹងខ្ញុំ សួរចាស់ទុំទៅ ។ ដណ្តឹងទៅការខ្ញុំ និយាយទៅ ខ្ញុំសូមទោសខ្ញុំមនុស្សខ្ញុំមិនចេះអួត ហើយមិនចេះត្អូញទេ ខ្ញុំសុំតែនឹកឃើញពិតទេ គាត់ដណ្តឹងខ្ញុំទៅក៏ការខ្ញុំការឡើងបីដង បើអ្នកខ្លះគេចង់សួរ ការម៉េចអីម៉េច ខ្ញុំមិននិយាយទេរឿងហ្នឹង ។ ខ្ញុំដណ្តឹងខ្ញុំការនៅស្រុកកំណើតខ្ញុំទៅ ប្រហែលជា៦២ ខ្ញុំការ មានអេតាស៊ីវិល ការឡើងបីដង ។ ដល់មកភ្នំពេញអ្នកធ្វើការគ្នាច្រើន ខាងប្តីខ្ញុំ និងខាងខ្ញុំក៏ធ្វើនៅអានីវូទ្រីទីចាត់ការ ការម្តងទៀត ។ ដល់ស្រុកកំណើតប្តីខ្ញុំម្តាយក្មេកខ្ញុំថា កូនគាត់ប្រុសទីមួយ ហើយភ្ញៀវគាត់ច្រើនក៏ការនៅកំពតម្តងទៀត ។

ហើយបន្ទាប់មកទៀត ការហើយទៅប្រហែលជាឆ្នាំ៦២ ខ្ញុំបម្រើការងារនៅពេទ្យព្រះកេតុមាលា ហើយគ្រួសារខ្ញុំហ្នឹងស្វាមីខ្ញុំហ្នឹង គាត់កាលនោះគាត់ធ្វើការនៅក្រសួងសាធារណការ គឺក្រសួងគមនាគមន៍ហ្នឹង គាត់ចូលមកកាន់ជាបុគ្គលិកក្រសួងទាំងមូល កាន់*ពាក់សាណែល* គាត់កូនចៅជាមួយទ្រង់ កន្តុល កាលនោះលោកទ្រង់កន្តុល លោកឡើងរដ្ឋមន្ត្រីក្រសួងសាធារណការអីទេ ។ ហើយលោក អ៊ឹង ប៊ុច ជាខ្សែកាបីនេ ។ ខ្ញុំចាំហើយដល់បន្ទាប់បានបន្តិចមកគាត់ប្រឡងជាប់កុំមី គាត់ឡើងទៅ គេឲ្យគាត់ឡើងទៅជា*អាស្វាំងដេរិកទ័រ* អាកាសចរណ៍ស៊ីវិលនៅពោធិចិនតុងនេះ ហូតមកដល់ ប៉ុល ពត ហ្នឹង ។ កាលនោះគេនិយាយតែពាក្យបារាំង គេថាម៉ាដាម ឈិន ណារី គេអត់ហៅដូចយើងទេ ឥឡូវយើងធ្លាប់ពាក្យលោក ពត មកហើយ ។

ហើយដល់តែ ដល់ពេលខ្ញុំទិញផ្ទះនៅផ្សារទួលទំពូងជ្រុងផ្សារ ស្រុកគេច្បាំង គ្រាប់ផ្លោងចប់ថ្ងៃ១៧ ដល់តែព្រឹកថ្ងៃ១៨ ទ័ពរំដោះគេហ្នឹង កាលហ្នឹងខ្ញុំហៅតាមភ្នែកខ្ញុំមើលឃើញត្រចៀកខ្ញុំឮ សូមជម្រាបអង្គប្រជុំសវនាការ ។ ឃើញគេស្លៀកខោខ្មៅ ពាក់ខ្សែគ្រាប់ព័ទ្ធឆៀងពេញទៅស្តាំពេញខ្លួនគេ ហើយគេស្ពាយកាំភ្លើងវែងមួយនៅនឹងស្មាគេ គេចូលដើរប្រាប់តាមផ្ទះថា “សូមឲ្យមិត្តយើងចេញពីផ្ទះឲ្យអស់ពីភ្នំពេញ អត់ឲ្យនៅមួយទេ បើកាលណាអ្នកណានៅអាមេរិកាំងមកទម្លាក់គ្រាប់បែកងាប់អស់ហើយ” ។ ហើយសួរថា “មិត្តអើយឲ្យទៅប៉ុន្មានថ្ងៃ?” គេថា “តើទៅទីណា?” គេថា “ទៅស្រុកកំណើតរបស់ខ្លួន ស្រុកកំណើតនៅទីណាឲ្យទៅទីនោះ” ។ “ហើយទៅប៉ុន្មានថ្ងៃ?” គេថា “ពីរថ្ងៃមិនបាច់យកអី

ទៅទេ អីវ៉ាន់ធម្មតាស្រុកច្បាំងត្រៀមទុកសម្រាប់ខ្លួននៅក្នុងគ្រួសារមានមិនតិចទេ ពេញផ្ទះទាំងអស់" ។

[១៣:៥៩:១៩]

ដល់ពេលនោះគេថា "ទៅមិនបាច់យកអីអ៊ីចឹង" យកតែចានឆ្នាំងណាដែលអត់បែក ហើយដំណើរពីថ្ងៃ ហើយស្រុកកំណើតខ្ញុំពីភ្នំពេញទៅ បើជិះឡានជំនាន់នោះ ប្រហែលជាពីរម៉ោងទេអាហ្នឹង ផ្លូវមិនទាន់ធ្វើថ្មីដូចឥឡូវផង ។ តែដល់ពេលចេញថ្ងៃនោះយកអង្ករបានដប់ប្រាំមួយកំប៉ុងនៅចាំ ហើយនិងចានម្តាយមួយឪពុកមួយ កូនបី និងឪពុកមួយទៀត ចេញដំណើរទៅតាមផ្លូវផ្សារដើមថ្កូវនោះឯង ។ ដល់ទៅពីផ្សារដើមថ្កូវទៅ គេដេញមួយភ្នំពេញស្ងប់គ្រាប់កាំភ្លើងហើយហ្នឹង ។ ទៅដល់រង្វង់មូលក្បាលថ្នល់ស្ពានជ្រោយឌិក គេកាក់ឈប់នៅកន្លែងហ្នឹង ហើយគេថា អត់ទាន់ឲ្យទៅទៀតទេ ឲ្យឈរនៅទីហ្នឹង ។

ហើយថ្ងៃនោះខ្ញុំចេញទៅហ្នឹង បងស្រីខ្ញុំមួយគ្រួសារទៀតនៅខាងកើតផ្សារ គាត់ជាអ្នកលក់ដូចជាខោអាវក្មេងអីអ៊ីចឹង តូបគាត់មកគាត់មានឡាំបីតា គាត់មួយក៏មកចូលហៅខ្ញុំទៅហ្នឹង ទៅជាមួយគ្នា។ ដល់វានិយាយថា គេដេញភ្នំពេញឲ្យអស់អ៊ីចឹងទៅ ។ ខ្ញុំយប់ហ្នឹង អង្គការគេអត់ទាន់ឲ្យទៅទៀតទេ ឲ្យឈរនៅទីហ្នឹង ដេកមួយយប់នៅរង្វង់មូលក្បាលថ្នល់ ។ ដល់ព្រលឹមឡើងបងស្រីខ្ញុំ គាត់ដាំបាយមួយឆ្នាំង បានគេថា ហ៎! ទៅទៀត ខ្ញុំសុំទៅខាងស្តាំដៃស្រុកណា គេអត់ឲ្យទៅ គេឲ្យទៅត្រើយខាងកើត ។ ដល់ត្រើយខាងកើតអ៊ីចឹង គេចេះតែដេញៗបណ្តើរទៅ ច្បារអំពៅគល់ស្ពានហ្នឹងបត់ស្តាំដៃ ផ្លូវមុខអីគេហៅវត្តរាល់ថ្ងៃនេះហៅវត្ត ស្ទឹនេះ ជាប់ច្បារអំពៅយើងទៅ មានវត្តមួយ វត្តព្រែកប្រា ទៅដល់នោះគេឲ្យឈប់កន្លែងហ្នឹងទៀត ។

ហើយគឺឃើញពួករំដោះគេ ស្លៀកពាក់ខោអាវខ្មៅទាំងអស់ ហើយគេប្រមូលកាំភ្លើង បោះកាច់ៗដៃកាំភ្លើងហ្នឹងផ្លូងផាំងៗបោះប្រួសៗគរអ៊ីចឹងទៅ ។ ហើយខ្ញុំពួកខ្ញុំគេឲ្យនៅឈប់ហ្នឹងសិន ដល់ពេលដូចថា ឈប់យូរដាំបាយ ហូបបាយហ្នឹងដល់ថ្ងៃត្រង់អ៊ីចឹងទៅ ឃើបត់ជើងអីចុះទៅមាត់ទន្លេស្រាប់ឃើញខ្មោច ខ្ញុំនិយាយអំមិញវាហួសបន្តិច អាគល់ស្ពានជ្រោយឌិក អង្កាល់ហ្នឹងដើរទៅឃើញខ្មោចទាហានស្លាប់វាមួយយប់ទទួលប្រហែលជាហើមហើយ ដល់ជម្លៀសចេញមកដើរពេញផ្លូវអ៊ីចឹងទៅ គេយកអាស័ង្កសីមួយដាក់លើខ្មោចនោះ ដើរជាន់អ៊ីចឹងទាំងអស់គ្នាទៅ ទៅៗដល់វត្តព្រែកប្រាគេឲ្យឈប់កន្លែងហ្នឹង ឈប់បាយ ឈប់ហូប ថាឈប់ទៅមិនដឹងឈប់ធ្វើអីក៏ចេះតែឈប់ទៅ ។ ទាល់ពេលហូបបាយក៏នាំគ្នា យកឆ្នាំងបាយយកអីមកអ៊ីចឹងទៅ ចុះទៅមាត់កំពង់ថារកបត់ជើងតូចអី ក៏ឃើញអាខ្មោចទាហានហ្នឹងវាអង្គុយដាច់ខ្យល់ចោងហោងនៅច្រាំង ហើយមើលទៅទន្លេខ្មោចអណ្តែតមាត់ទន្លេ ខ្មោច

ទាហានហ្នឹងរបៀបគេអាដាក់គ្នាពីថ្ងៃ១៧ មុនថ្ងៃ១៧ ហ្នឹងវាស្ងាត់កាំភ្លើងទៅ ។

[១៣:៥៦:៥៩]

ដល់អ៊ីចឹងប្រហែលជាម៉ោងប៉ុន្មានទេកាលហ្នឹង ប្រហែលជាថ្ងៃរសៀល ហើយពេលជម្លៀសចេញទៅហ្នឹងកូនពៅខ្ញុំនៅពរចង្កេះទេ អាយុប្រហែលជា៤ឆ្នាំហើយ មិនទាន់ដល់អាយុចូលសាលាទេ ប៉ុន្តែកូនខ្ញុំឲ្យរៀនសាលាជិតខាងផ្ទះទៅ វាចេះអាចមើលអានកាសែតបានមួយម៉ាត់ៗកូនពៅខ្ញុំ ។ ហើយដល់ពេលនិយាយពីទៅមុខទៀត ទៅដល់នោះជួបលោកអាំងស៊ីញ៉ូរមួយកូនចៅម៉ុងសឺខ្ញុំហ្នឹង គាត់ថា អ្ហឺ! ខ្ញុំផ្តាំបងឯងកុំឲ្យមក ព្រោះដឹងថា ភ្នំពេញគេរើចប់ហើយ បងឯងមកធ្វើអី? គាត់ថា ម្តាយក្មេកគាត់ឲ្យមកក៏ជួបគ្នានិយាយមួយម៉ាត់ពីរទៅ ថាមិនដឹងទៅណាទៅទិសណា គេឲ្យទៅក្រោមចេះទៅ ។ ដល់ទៅៗទៅដល់ដេកតាមផ្លូវទេ សមរភូមិក្តីគេហ្នឹងសុះៗអស់ហើយវិហារដេកតាមផ្លូវហ្នឹងទៅដល់ត្រើយស្ពា ដល់ត្រើយស្ពាគេឲ្យទៅទៀតប្រហែលជាមួយខែបានទៅដល់បញ្ជិតស្រុកកំណើតខ្ញុំហ្នឹង ប្រហែលមួយខែនៅត្រើយកើតខាងភូមិតាលន់ ។

ដល់ភូមិតាលន់ហ្នឹង ដូចថាអ្នកភ្នំពេញគេជម្លៀសចេញស្ងាត់ហើយពីភ្នំពេញហ្នឹង ទៅដល់មូលដ្ឋានហ្នឹង ខ្ញុំក៏មិនដឹងអី ដូចថា អ្នកទៅហ្នឹងវាអត់ដឹងទិសតំបន់គេឲ្យចេញចេញហើយ ពេលបាយក៏រកឆ្នាំង រកអីដួសបាយចែកកូនហូបអីអ៊ីចឹងទៅ ក៏ថ្ងៃមួយស្រាប់តែគេថា ហៅប្រជុំ អាហ្នឹងដូចអស់អ្នកភ្នំពេញហើយនៅតាលន់ហ្នឹង អស់អ្នកភ្នំពេញហើយទៅប្រជុំនោះវាសម្បូរអាចម្ការល្មុត ប្រជុំហ្នឹងគ្នាច្រើនមិនដឹងពីណាពីណី ឃើញមនុស្សច្រើនគេថា "អ្ហឺ! គេគណៈសហករណ៍" ។ ប៉ុន្តែ មនុស្សហ្នឹងពូហ្នឹងខ្ញុំភ្លេចឈ្មោះគាត់ហើយ នៅត្រើយលិចទេធ្វើជាងធ្វើផ្ទះ ហើយគាត់និយាយប្រជុំពីរឿងអី គាត់និយាយពីរឿងបដិវត្តន៍គាត់ជោគជ័យ គាត់ធ្វើបដិវត្តន៍ជោគជ័យពីឆ្នាំ៧២ បងប្អូនអត់ដឹងទេអានេះភ្នែកខ្ញុំមើលឃើញត្រចៀកខ្ញុំឮផ្ទាល់ ។

សូមជម្រាបលោកប្រធានជាតិ និងប្រធានអន្តរជាតិ និងអង្គសវនាការទាំងមូល គឺថាខ្ញុំសូមជម្រាបថាភ្នែកខ្ញុំមើលឃើញត្រចៀកខ្ញុំឮ ខ្ញុំនិយាយនេះខ្ញុំនិយាយនេះ ខ្ញុំអត់ដឹងរឿងអីទាំងអស់ ទៅជួបស្អីខ្ញុំនិយាយឃើញអ៊ីចឹង ។ ឲ្យគាត់ប្រជុំគាត់អួតពីថាបដិវត្តន៍ គាត់ជោគជ័យ និយាយដូចលោក ឌុច គាត់និយាយអ៊ីចឹង ផែនការគាត់ប៉ុនម៉ាត្រូសអ៊ីចឹងយើងមិនអាចចាំប៉ុនគាត់ថា គាត់អួតថា គាត់ផ្លៀតចូលទៅភ្នំពេញចាក់សេរ៉ូមឲ្យសម្រេចសង្ឃ ជួន ណាត ស្លាប់នៅពីកាលនោះគាត់ថា ៧២ ហើយយ៉ាង។ គាត់អួតអ៊ីចឹងគាត់ប្រជុំអីហើយៗ ហើយដល់ប្រជុំចប់ទៅក៏ឲ្យមកផ្ទះ ឲ្យមកផ្ទះទៅអាហ្នឹងគាត់ចង់

ផ្សាយពីរឿងបដិវត្តន៍គាត់ជោគជ័យ ។ ខ្ញុំមិនដឹងរឿងអីទេ ដឹងតែពីព្រួយមិនដឹងទិសដៅអីយ៉ាងម៉េចអីយ៉ាងម៉េចទេ ។ ដល់ពេលស្អែកឡើងស្រាប់តែបងខ្ញុំវាបញ្ឆោកគ្នាមុខទន្លេអីចេះ គាត់យកទូកមួយយ៉ាងធំមកយកមកនាំខ្ញុំ ហើយសុំនៅផ្ទះក្រោយផ្ទះគេហ្នឹងដើរសុទ្ធពីងពាងអីទង្គិចក្បាលពកក្បាលប៉ុន្មានយប់ហ្នឹងដេកផ្ទះគេហ្នឹង គាត់ថាសុំទៅនៅផ្ទះឪពុកខ្ញុំត្រើយលិច ស្រុកកំណើតខ្ញុំហ្នឹង គាត់សុំអ្នកម្ចាស់ផ្ទះហ្នឹងទៅ ក៏គេឲ្យទៅពីរគ្រួសារទាំងបងស្រីមួយទៀតហ្នឹង មួយទូកធំហ្នឹងទៅនៅផ្ទះពុកខ្ញុំទៅ ។

ទៅដល់ផ្ទះពុកខ្ញុំស្រុកកំណើតពុកខ្ញុំហ្នឹង ស្រុកកំណើតខ្ញុំហ្នឹង គេចាត់តាំងដូចថា យើងទៅមួយខែប្លាយ ៧៥ ប្រហែលចូលមួយខែជាង ខែ០៥ ខែ០៦ គេអត់ទាន់ចូលរួម ខ្ញុំក៏មិនដឹងអីដែរនៅផ្ទះអីចឹងទៅ បងខ្ញុំគាត់ថា “អីអើយ គេល្អណាស់ និយាយពីទ័ពគេមកល្អណាស់ គេដេកយាមពេញភូមិ” អាហ្នឹងគាត់អត់ទាន់នឹកឃើញពីរឿងការងាររបស់គាត់ទេ គាត់ថា “គេល្អ” គេថា “បងប្អូនដេកកុំឲ្យបិទទ្វារអីខ្ញុំចាំទ្វារផ្ទះ ម្ទេសមួយគ្រាប់ក៏ខ្ញុំអត់លួចបេះដែរ” ។ នៅពេញតែហ្នឹង ប្រាប់ ខ្ញុំថា “ធ្វើស្អីគេទេចែ” គាត់ថា “អីអញមិនដឹងហៅស្អីទេហា មិនដឹងហៅយួន ឬអីគេទេ? ក្មេងខ្មៅៗ” គាត់ថា អីចឹងឲ្យខ្ញុំឮ ហើយខ្ញុំស្តាប់ទៅនិយាយទៅ គាត់ថា អត់ដឹងគេហៅអីនិយាយស្តាប់អត់បាន គេមកយាមផ្ទះឲ្យ ។ ក៏ហើយពីហ្នឹងទៅទៀត ក៏គាត់ឈប់និយាយទៅ ឈប់និយាយចេះនិយាយអីចឹងសិនមិនទាន់ចូលរួមទេៗ ។ គេឲ្យទៅធ្វើការតាមភូមិហ្នឹង មកវិញហូបបាយផ្ទះ ហើយរែកទឹករែកអីប្រើខ្លួនឯង ។

ដល់ពេលវាជម្លៀសឡើងថា “ហ៎! អង្គការទិសដៅឡើងទៅបាត់ដំបងៗ” ជម្លៀសមួយសាៗប៉ុន្តែ ជម្លៀសពីអ្នកភ្នំពេញ វាគ្រប់ស្រុកទៅពេញភូមិទាំងអស់ មួយសាៗអស់ទៅ ដល់ពេលនែ៎អាទីកជិតចុះនេះ វានៅសល់ខ្ញុំ ពួកខ្ញុំ ក្រុមខ្ញុំចុងក្រោយគេថាជម្លៀសឡើងឲ្យអស់អ្នក១៧ គេទុកតែអ្នកមូលដ្ឋានទេ ។ ខ្ញុំនិយាយនេះ គឺខ្ញុំចាំពាក្យគាត់អ្នកមូលដ្ឋាននិយាយឲ្យខ្ញុំឮ ។ ហើយដល់ពេលមុននឹងថ្ងៃជម្លៀសហ្នឹងវាមានឈ្លបគេហើយកាលហ្នឹង គេហៅឈ្លបអីចឹងហើយ គេមកសួរខ្ញុំ ហើយមនុស្សហ្នឹងគាត់ធ្លាប់រៀនជាមួយគ្នាទៀត ពីកាលគួរអង់ហ្វង់តាំងរៀនសាលាជាមួយគ្នា ។ គេមកសួរសុខទុក្ខ ខ្ញុំថាស្វាមីខ្ញុំនៅភ្នំពេញធ្វើការអី? បងស្រីខ្ញុំមូលដ្ឋានហ្នឹងណា គាត់មកនាំខ្ញុំទៅហ្នឹងណា គឺគាត់ផ្ទះវាបីល្វែងគាត់ឡើងចូលទៅក្នុងបន្ទប់ៗសងខាង គាត់ធ្វើដៃ គាត់ថា ទៀ ហាវតឹក ធ្វើការអីមីស៊ីអ្អែងនៅភ្នំពេញ? អាឈ្លបវាចេះសួរអីចឹង ខ្ញុំមិនទាន់បានឆ្លើយផងហ្នឹងណា គាត់ចូលក្នុងបន្ទប់ពីរនាក់កូនគាត់ កូនគាត់ដែលធ្វើឈ្លបកូនប្រុសគាត់មួយនៅសល់សព្វថ្ងៃ ។

គាត់ថា “គាត់បបួលទៅចុះលោកប្រធាន សូមលោកប្រធាន”-- ខ្ញុំជម្រាបនេះ ខ្ញុំអត់លាក់កើត

មួយជាតិនេះ ខ្ញុំភ្ញូតគេដាច់ខាត ។ *សេអ៊ីអា* អាមេរិកាំង វាសួរទៀត “ផ្ទះអាតឹកធ្វើការអីនៅភ្នំពេញ?” “សេអ៊ីអា អាមេរិកាំង” គាត់បានឆ្លើយអ៊ីចឹង ។ ហើយខ្ញុំអត់ទាន់ឆ្លើយគេសោះ គាត់ឆ្លើយមុនខ្ញុំ គាត់ចេះដឹងរឿងខ្ញុំជាងខ្ញុំទៀត ដល់ក្រោយមកខ្ញុំថា “ចៃ ឯងសុំសីលតាំងពីសង្គមចាស់ តាំងពីដើម ចៃឯងនិយាយអត់ពិត ខ្ញុំនៅភ្នំពេញវាផ្សេង ។ មីស៊្យឺខ្ញុំធ្វើការនៅកាប៉ាល់ហោះស៊ីវិលតើអាពោធិចិនតុងហ្នឹង ពេលគេដាច់ផ្លូវអស់ ឮគាត់និយាយថា អូយ! ដឹកអង្កទម្លាក់ឲ្យគេអាបិទផ្លូវអត់បាយស៊ី គេវាស់ដីមិនឲ្យទៅមកនែ៎ ។ ស្នេហាជាតិ ជួយជាតិឡើងស្គមដូចចាបចៀនអស់ទៅហើយ អត់ដេកអត់ស៊ីអីផង ចៃឯងនិយាយអ៊ីចឹងបាប” ខ្ញុំថាឲ្យគាត់អ៊ីចឹង ។

[១៤:០៣:៣៦]

ថាឲ្យគាត់អ៊ីចឹងក៏ហើយពីហ្នឹងទៅ បានប្រហែលជាចំនួនប្រហែលជាកន្លះខែមួយខែ គេមកប្រាប់ថា “បងប្អូនយើងជម្លៀសឲ្យអស់អ្នក១៧ឲ្យអស់ មួយភូមិឃុំកោះខែល ។ ឲ្យម៉ោង១២ កណ្ដាលអធ្រាត្រឲ្យរៀបទៅកម្មសិទ្ធិសមរម្យមួយបាវផ្លូត ទាំងចាន ទាំងឆ្នាំង ទាំងមុង ទាំងកន្ទេល ឲ្យចូលគ្នាមួយគ្រួសារ” ។ កម្មសិទ្ធិសមរម្យ គឺពាក្យនេះ ខ្ញុំចាំតែម្ដង ហើយម៉ោង១២ កណ្ដាលអាធ្រាត្រហ្នឹងគេយកអ្នកមូលដ្ឋាន គេយករទេះយកមកដឹករទេះគោ ឲ្យរៀបឲ្យប្រញាប់នៅយូរអត់បាន រៀបឡើងទៅ គេដឹកយើងយកទៅដាក់វត្តកោះខែល ឃុំកោះខែលហ្នឹងតែម្ដង ។ ទៅដល់មុនគេមិនទាន់មានពីណាមកទេ ។ បន្ទាប់ៗមក គេដឹកតាមផ្សេងៗមក ដល់តែជិតភ្លឺៗឡើងឃើញមនុស្សមកពេញមិនដឹងប៉ុន្មានរយគ្រួសារមួយឃុំ ហើយដឹកពីត្បូងវត្តផង ពីអីផង ។ ឃុំហ្នឹងវាទៅទល់ព្រំទល់ឃុំព្រែកអំបិល ប៉ុន្តែនៅជុំគ្នាអ៊ីចេះមួយយប់ អត់ទាន់ឃើញឡានឡើងមកក៏គេដើរប្រាប់ថា “អើមិត្តយើង អត់ទាន់បានទៅឥឡូវទេ ព្រោះឡាននៅដឹកអ្នកកោះធំ ដឹកអ្នកជម្លៀសកោះធំមុន ដល់ដឹកជម្លៀសអ្នកកោះធំហើយមកសំប៉ាន សំប៉ានហើយមកដល់ព្រែកអំបិល បានដល់យើង ។ អ៊ីចឹងរង់ចាំបន្តិចទៀតទៅ” ចាំបន្តិចទៀតទៅចាំមើលក៏មានឈ្លបគេមួយមកៗប្រាប់ថា ព្រោះអីខ្ញុំថយក្រោយបន្តិចមុនៗនឹងជម្លៀសហ្នឹង ខ្ញុំពិចារណាទៅឃើញថា អាហ្នឹង*ពួងគេ*ហើយ ព្រោះអីលោក ឌុច គាត់បានឆ្លើយដែរតើ ហើយខ្ញុំទៅក៏រៀនអ៊ីចឹងដែរ គាត់ថា សំខាន់ជាងគេគឺថា បដិវត្តន៍ គឺយកមនុស្សសំខាន់ ។ លោក ឌុច គាត់ក៏និយាយដែរថ្ងៃមុន ខ្ញុំស្ដាប់គាត់ ទីមួយមនុស្សសំខាន់ មនុស្សធ្វើធំ អ្នកចេះដឹងអីៗហ្នឹង ផែនការរបស់គាត់ គេ*ពួងគេ*ហើយ គេឲ្យទៅធ្វើការនៅមន្ទីរស្រុកគេពីរនាក់ ។

ទៀ ហាវតឹក មួយនិងពូ ងួន ហេង មួយ ។ ពូ ងួន ហេង ហ្នឹងវាធ្លាប់រៀនមួយខ្ញុំដែរអ្នកជិត

ខាងស្រុកឪពុកខ្ញុំហ្នឹង វាបើខ្ញុំដឹងវាធ្វើជាអ្នកយកផាស៊ីនៅផ្សារថ្មីទេ ដល់ពេលគេជម្លៀសចេញពីភ្នំពេញទៅ វាត្រូវទៅស្រុកជួបគ្នា ។ គេឲ្យទៅធ្វើការនៅបន្ទាយស្រុកពីរនាក់ពូ ងួនហេង ហើយនិងមីស្សឺខ្ញុំហ្នឹង ទៀ ហាវតឹក ហ្នឹង ។ ដល់ពេលថ្ងៃដែលឡើងទៅជុំគ្នាចាំឡើងឡានទៅខេត្តបាត់ដំបងនៅវត្តកោះខែល ហ្នឹង ឈ្លបហ្នឹងគេមកហៅឈ្មោះពីហ្នឹង គេថាអង្គការសុំស្នើ ទៀ ហាវតឹក និង ពូ ងួន ហេង ទៅប្រជុំនៅមន្ទីរស្រុកអ៊ីចឹងហើយ ។ នៅព្រែកតូចហ្នឹង ស្រុកស្អាងមន្ទីរស្រុកស្អាងហ្នឹងហើយ ស្រាប់តែគេយកកង់មក ហើយគាត់ៗដូចដឹងខ្លួនហើយ ។

ខ្ញុំចេះតែឮអ៊ីចឹង រាល់ថ្ងៃតែបងស្រីខ្ញុំក៏គាត់ចេះនិយាយ គាត់ថា "អើយតែមនុស្សតែអង្គការស្នើហើយ មិនដែលឃើញមកវិញទេ តែស្នើហើយទៅរៀនសូត្រអត់មានឃើញមកវិញមួយទេ" ពាក្យហ្នឹងខ្ញុំឮជានិច្ចកាល គឺទៅជម្លៀសទៅហ្នឹងឋានរកទាំងរស់ហើយ យើងរង់ចាំដូចដង្ហើមចង្រិតឯង ចាំតែមើលគេធ្វើអីៗអត់ដែលដឹងរឿងអីទាំងអស់ ។

ដល់ស្នើទៅអ៊ីចឹង ខ្ញុំនឹកឃើញរឿងហ្នឹង ដល់ពេលស្នើមីស្សឺខ្ញុំ គាត់ទាញអាវពាក់មកហើយគាត់ហុចនាឡិកាមួយឲ្យខ្ញុំ ខ្ញុំមើលមុខគាត់ ។ ខ្ញុំសួរគាត់ គាត់ថា "អូនកុំមាត់" គេអ៊ីចឹងដែរមួយប្រទេសហើយ កូនពង្រឹងគោលជំហាធ្វើម៉េចឲ្យសុខភាពខ្លួនមាំមួន ហើយមើលកូនប៉ុណ្ណឹងបានហើយ អប់រំកូន" អត់ប៉ានផ្តាំអី ព្រោះគេថា ទៅប្រញាប់ ខ្ញុំក៏មិនទាន់នឹកឃើញអីដែរ ។ នឹកឃើញថា គេហៅទៅរៀនសូត្រដឹងតែទៅអ៊ីចឹងហើយ ។

[១៤:០៧:២៦]

ដល់ពេលហើយអ៊ីចឹងទៅ ពេលឡានពីក្រោមមក គេដាក់អ្នកក្រោមអស់ មកដល់វត្តកោះខែល គេហៅមនុស្សពេញមួយវត្តកោះខែល មិនដឹងប៉ុន្មានគ្រួសារទេ ខ្ញុំមិនចាំទេមួយឃុំច្រើនណាស់ អ៊ូរអែៗ។ ស្រាប់តែគេហៅឡើងឡានៗអស់ ដល់ឈ្មោះខ្ញុំប្រពន្ធកូនពីរគ្រួសារដែល ទា ហាវតឹក ហើយ ពូ ងួន ហេង គេថា "គេអត់ឲ្យឡើងទៅទេ ។ គេឲ្យដឹកទៅផ្ទះមូលដ្ឋានហ្នឹងវិញ" ។

គេឡើងទៅស្វាត់ស្រុក ពេលនោះខ្ញុំចាំ ព្រលប់ពេលព្រលប់ៗ ហើយនៅក្នុងវត្ត ទីទុយយំ ទីទុយពើតៗឡើងព្រឹក្សាល ហើយនៅក្មេងខ្លាចណាស់ ប៉ុន្តែនឹកឃើញពង្រឹងជំហរគេមួយប្រទេសហើយ ។ ព្រឹក្សាលអ៊ីចឹង ក៏មានរទេះគេពីរមកដឹកខ្ញុំប្រពន្ធកូនត្រឡប់មកផ្ទះឪពុកម្តាយវិញ ផ្ទះនៅជិតគ្នាប្រពន្ធកូនហ្នឹង ។

ដល់បន្ទាប់ពីហ្នឹងទៅទៀត គេថា "អ៊ូ ប្រពន្ធកូនហ្នឹង គេយកទៅលត់ដំ អង្គការភ្នែកម្នាស់ចាំ

មើលប្រពន្ធកូនហ្នឹងគេនៅតែយកទៅទៀតទេ គេយកទៅឲ្យសម្រុកក្តៅជាមួយកងស្រួចគេក្រមុំចាស់នោះ វាពេញកម្លាំង ។ យកកងស្ត្រីទៅធ្វើជាមួយ" ។ យកខ្ញុំទៅលត់ដំៗ និយាយទៅពាក្យចាស់លោកថា តែអាយុមិនអស់មិនទាន់ងាប់គេធ្វើបាបយ៉ាងណាក៏វាមិនទាន់ងាប់ដែរ ។ គេឲ្យខ្ញុំទៅអណ្តូរ គេចេញពីហ្នឹងទេ កូននោះចូលអង្គភាពអស់ គេយកកូនខ្ញុំពៅហ្នឹងគេយកចូលអង្គភាព កូនចូលអង្គភាពរៀងខ្លួនហើយកុមារ ។ ខំធ្វើការហើយគេជេររហូតហើយអ្នកស្រុកហ្នឹង អ្នកភូមិហ្នឹង សុទ្ធតែកូនអាចក្រពត្តិហើយខ្ញុំមិនដឹងរឿងអី គេចេះតែដៀលតែអ្នក១៧អ៊ីចឹងឯង ។ កូនអាចក្រពត្តិៗ ដល់ធ្វើទៅ ខ្ញុំគេឲ្យចូលកងនេះហ្នឹង គេឲ្យលើកភ្លឺមួយថ្ងៃមួយរយម៉ែត្រ ហើយវាស់បាតប៉ុន្មាន ដូចជា៧តឹកអី៨តឹកអី កំពស់៧តឹក ។ កន្លែងៗនោះគេឲ្យលត់ដំ និយាយបន្តិចទៅ ព្រោះអីខ្ញុំក៏មិនចង់និយាយវែង ប៉ុន្តែរឿងបើនិយាយវាមិនចេះអស់ទេ ច្រើនណាស់គេធ្វើយើង ។

កន្លែងនោះគេថា អ្នកមូលដ្ឋានគាត់អើយៗអាសូរគាត់ចាស់ៗគាត់ថា ដីកន្លែងហ្នឹងបួនឆ្នាំប្លាយអត់ដែលភ្ជួរទេ ហើយយកឲ្យគ្នាមកធ្វើលើកភ្លឺអ៊ីចឹង ។ គេឲ្យចបកាប់ខ្ញុំ គេវាស់ឲ្យខ្ញុំ ខ្ញុំកាន់អាចបកាប់ៗទឹសទៅអ៊ីចឹងទៅមួយទិស គ្រាន់តែឈឺទេដៃហ្នឹង ដល់កាប់ យើងលត់ដំតាមគេ នឹកឃើញងាប់អង្កាល់ងាប់ទៅ ។ តាំងចិត្តថាអ៊ីចឹងតែម្តង គោរពវិន័យផែនការអង្គការ ។ កាប់មួយទឹសទៅទៀតស្រាប់តែឈឺៗខ្ញុំមើលបាតដៃខ្ញុំពងហើយបែក អាពងហ្នឹងចេញមកទៀត ក្រហាយជាប់ៗរហូត អ៊ីចឹងខ្ញុំអត់ប៊ានមាត់ទេ ព្រោះអីធ្វើទាំងអស់គ្នាមួយកងៗមេម៉ាយដាក់ជាមួយកងស្រួច ។

ដល់ពេលមានមនុស្សអាណិតខ្ញុំដែរ ប្រធានកងហ្នឹងគាត់ថា អើយមិត្តអើយកុំមាត់ ហើយឲ្យអត់ធ្មត់ ។ ដល់គេឲ្យខ្ញុំទៅ-- គេលត់ដំខ្ញុំសម្បើមណាស់ យកធ្វើក្នុងបន្ទាក្នុងអី គេថា "យើងអីធ្លាប់ធ្វើពេទ្យធ្វើអី" ឃើញខ្ញុំកាន់កំសៀវទឹកអី គេថា "ពេទ្យចេះអនាម័យផឹកទឹកឆ្អិនអីដែរ" ហ្នឹងអ្នកនិយាយទៅអ្នកជិតខាងហ្នឹងគ្នាដូចថា ផ្ទះគ្នាវារហែកមុខរហែកក្រោយដល់ពេលហ្នឹង ដូចគេនឹកឃើញថា គេវាឡើងធំបានដៃ គេមានសិទ្ធិលើយើងហើយ ។ ខ្ញុំតាមមើលគេហ្នឹង គេថាឲ្យអស់ចិត្ត ខ្ញុំថា "អើ! ខ្ញុំគោរពអង្គការឲ្យផឹកឆ្អិន ខ្ញុំចេះតែដាំទឹកឆ្អិនមកផឹកទៅ បើមិត្តឯងយល់ឃើញយ៉ាងម៉េច នោះរឿងរបស់មិត្តឯង" ។

ដល់ពេលជម្លៀសអ៊ីចឹងទៅ គេធ្វើហ្នឹងធ្វើដល់តែគេថា ដល់ពេលខែទឹកលិចៗពេញមេៗមានប្រធានអីនោះធំជាងគេទៀត ប្រធានគណៈសហករណ៍មួយនោះគេថា "អ្នកឯងប្រឡងជាប់ ឧទាហរណ៍ថា *គួកអេឡេមីទែរ គួកស៊ុបពែរីយ៉ែរ* (និយាយភាសាបារាំង) អីជាប់ហើយ តែនៅអ្នកឯងប្រឡងមួយគន្លាក់ទៀត មួយគន្លាក់នេះ គឺទីបញ្ចប់ហើយ ។ មួយគន្លាក់នេះ បើអ្នកឯងលត់ដំបាន អ្នកឯងនៅរស់

អ្នកឯងលត់ដំ អត់បានអ្នកឯងស្លាប់" ។ មេខ្ញុំភ្លេច អាខែងមេប្រធានសហករណ៍ធំ តាមពិតគាត់ស្គាល់ខ្ញុំ ខ្ញុំអត់ចាំគាត់ កាលគាត់ប៉ាននិយាយអ៊ីចឹង ខ្ញុំធ្លាប់ជិះឡានគាត់មករៀនភ្នំពេញ ។

[១៤:១១:៥៥]

គាត់លត់ដំខ្ញុំអ៊ីចឹងហើយទៅ អីទៅ កូនខ្ញុំអីលត់ដំឡើងបាក់ធ្មេញហើយកូនខ្ញុំអាប្រុសមួយហ្នឹង ។ ដល់ពេលបែក និយាយពីបែកនិយាយកាត់ឲ្យយ៉ាងខ្លីបើនិយាយរឿងហ្នឹង ច្រើនណាស់ គេធ្វើបាបខ្ញុំវាមិនងាប់នោះ ។ មានបំណងឲ្យយើងស្លាប់នោះណ៎ា ដល់ខ្ញុំគេទៅឲ្យអស់លេខអ៊ីចឹង ពេលបែកពេលបែកអង្គភាពខ្ញុំវាឈឺជិតបែកអង្គភាពឮសូរគ្រាប់កាំភ្លើងក្ពិលៗមកទិសអី គេហៅទិសស្អីទិសខាងកើតនេះ ។

អ្នកជំងឺ ជាមួយខ្ញុំនៅកងជាមួយខ្ញុំគាត់ឈឺដែរ គាត់ថា "មិត្តអើយ យើងបែបជិតបែកហើយ" ហើយមីក្រូគេឫស្សីមួយដើមគេចាក់ក្រឡៅៗ គេផ្សាយឲ្យស្តាប់ហើយ ។ ដល់ពេល គេថាជិតបែក ឮសូរកាំភ្លើងដេញក្ពិលៗមកដល់ភ្នំពេញ យប់ហ្នឹងឃើញថាខ្ញុំមើលតាមមេឃ ឃើញមើឃក្រហមតើចាស់ៗគាត់ឯងមើលមេឃក្រហមៗនោះភ្នំពេញអគ្គិសនីភ្នំពេញ ។

[១៤:១២:៥៣]

រួចទៅក្ពិលៗដល់ភ្នំពេញក៏បាត់ស្ងាត់ជ្រាបៗទៅ អង្គការគេមកដេកអង្រឹងតាម គេថា "មិត្តយើងទៅលិច" គេថា មិត្តយើងបែកអង្គភាពទៅត្រូវនាំគ្នាត្រូវទៅទិសលិច ទាំងអស់គ្នាឡើងភ្នំ ។ គេមកដេកយាមចាំអ៊ីចឹង ហើយពួកខ្ញុំសុទ្ធអ្នកស្រុកមាត់ទន្លេជិត វាទៅទន្លេវាជិតដែរ ។ ចាស់ៗអីចេះខ្សឹបខ្ញុំ យើងទៅលិចធ្វើអីបើអត់មានផ្ទះសម្បែងផង ។ ខ្សឹបគ្នាចាំមើលៗ បើម៉េចៗយើងទៅផ្ទះយើងតាមមាត់ទន្លេ។ ដល់ភ្លឺស្រាងៗអ៊ីចឹង គេថា ដូចមានសិទ្ធិសេរីភាពអាណាទៅណាទៅរៀងខ្លួន ហើយអាប្រធានសហករណ៍ប្រធានក្រុមហ្នឹង គាត់វារត់ប៉ោងជើងដូចគ្នា គាត់ក៏រត់ប្រះអាយុដែរ អាណាទៅតាមគាត់ក៏ទៅ ។

ខ្ញុំចេញមកទន្លេវិញ ចេញមកស្រុកកំណើតឪពុកវិញមក ផ្ទះស្រុកកំណើតឪពុកខ្ញុំវិញ ឃុំកោះខែល ស្រុកស្វាយជ្រុំ នោះវិញ ។ មកឃុំនុំងវិញ បានកូនខ្ញុំអីមកវិញមកតាមអង្គភាពកូនបីហ្នឹង គឺមកតាមអង្គភាព មកទម្រាំជួបគ្នាជួបជុំអីស្វាត់អ៊ីចឹងទៅ ។ ខ្ញុំឮវ៉ាដ្យូផ្សាយៗថា និយាយពីពេលដែលខ្ញុំអំមិញ ខ្ញុំមិនបានៗនឹកឃើញនេះ ខ្ញុំនិយាយបែរទៅក្រោយ អាពេលហ្នឹងដែលគេហៅប្តីខ្ញុំទៅ អង្គការស្នើប្តីខ្ញុំទៅ ខ្ញុំពេលនោះខ្ញុំនឹកឃើញថា ឧទាហរណ៍ថា គេស្នើទៅខ្ញុំនឹកឃើញគេថា តែហៅទៅមិនដែលមកវិញ ។ អ៊ីចឹងពេលនោះហើយ ដែលខ្ញុំនឹកឃើញថា ខ្ញុំបែកគ្នាមួយជីវិតហើយ អ៊ីចឹងផ្ទៃអាកាសទូទាំងពិភពលោកហាក់ដូចជាខ្ញុំជីវិតខ្ញុំហ្នឹង អារម្មណ៍ខ្ញុំនៅក្នុងលំហអាកាសទាំងមួយសាកលលោក គេ

ហៅប្ដីទៅ ខ្ញុំមិនដឹងនិយាយថា ម៉េចទេ ។ ខ្ញុំល្ហល្ហេវរហូត ខ្ញុំនឹកគ្រាំខ្ញាំពេញក្នុងខ្លួនខ្ញុំហ្នឹង ព្រោះគេថាតែយំតែឃើញយំគេយកទៅទៀត គេលបចាំមើលរហូតទៀត ។

ដល់អ៊ីចឹងទៅបែរមកដល់នេះ ដល់បែកអង្គភាពមកផ្ទះវិញ គេផ្សាយវ៉ាដ្យូថា អ្នកណាមានក្រសួងណា រណៈសិរ្សសង្គ្រោះជាតិ-- អានេះ ខ្ញុំនិយាយតាមឮក្នុងវ៉ាដ្យូ វាចាំពាក្យហ្នឹង សង្គ្រោះៗ--រណសិរ្សសង្គ្រោះអន្តរជាតិមកជួយសង្គ្រោះជាតិ ។ អ្នកណានៅក្រសួងណាមានបច្ចេកទេសអីឲ្យមករកក្រសួង រកមន្ទីរវិញរៀងខ្លួន ។ ខ្ញុំឮសូរវ៉ាដ្យូផ្សាយអ៊ីចឹង អាខ្ញុំអស់សង្ឃឹមមិនបាច់និយាយទេ ខាតពេលវេលាណាស់ ។ ខ្ញុំរាល់ថ្ងៃម៉ោងឲ្យស្លាប់ម៉ោង ឲ្យខ្ញុំស្លាប់ម៉ោងហ្នឹង ក៏ខ្ញុំសុខចិត្តស្លាប់ដែរ ខ្ញុំយល់ឃើញថាជីវិតខ្ញុំរស់គ្មានន័យទេ ។ ខ្ញុំរស់ពីថ្ងៃនេះ ម៉ោងនេះតទៅ ខ្ញុំយល់ថា បើជីវិតខ្ញុំមិនទាន់អស់ ខ្ញុំរស់ដោយសុច្ចរិត ខ្ញុំនឹងប្រាថ្នាចង់ធ្វើបុណ្យ ធ្វើទានសន្សំកុសលទៅជាតិមុខទេ បើក្រៅពីហ្នឹងខ្ញុំគ្មានន័យចង់រស់ទេ ខ្ញុំគ្មានន័យចំពោះខ្ញុំតែម្ដង ។ ដល់ពេលអ៊ីចឹង ខ្ញុំឮសូរអ៊ីចឹងហាក់ដូចជាមានអារម្មណ៍មួយថា អារម្មណ៍ចង់មើលៗ ផ្លូវស្វាមីខ្ញុំនោះ ដូចថា ខ្ញុំដាក់នៅស្មៀមសិន ខ្ញុំនឹកឃើញថា យី! អ៊ីចឹងមើលទៅ ខ្ញុំត្រូវទៅរកក្រសួង រកមន្ទីរខ្ញុំវិញហើយ ដើម្បីចិញ្ចឹមកូនខ្ញុំ ។

ដូច្នេះ អ្នកមូលដ្ឋាននៅជិតខាងគ្នា ធ្លាប់នៅភ្នំពេញហ្នឹង ប៉ុន្តែគេអត់ធ្វើការទេ គេមុខរបបគេរកស៊ីអីនៅផ្ទះអីហ្នឹង គេថាមកយើងទៅមើលភ្នំពេញ មើលផ្ទះយើង ក៏វិចបាយស្មុគហ្នឹងដើរមកបីនាក់ ។ វិចបាយស្មុគហ្នឹងមករកមើលផ្ទះនៅឯភ្នំពេញ ។ ដើរមកចេញពីព្រលឹម ដើរមកពីកោះខែល មកដល់ទួលក្រសាំង មើលចេះតែមើលទៅ ឃើញស្ងាត់ជ្រាប ។ ដល់មកដល់ចាក់អង្រែ ស្រាប់ឃើញ--ឃើញទ័ពវៀតណាត គាត់ស្រីទេ គាត់អង្គុយយាមផ្លូវថា អត់ឲ្យចូលភ្នំពេញ *ៗ* អត់ឲ្យចូលភ្នំពេញ ។

បើអ៊ីចឹងបើអត់ឲ្យចូលភ្នំពេញ យើងធ្វើម៉េចបានទៅចូលមើលផ្ទះទៅហ្ន៎? អ៊ីចឹងសូម-- វាដល់ពេលត្រឡប់មកផ្ទះវិញក៏វាមិនទាន់ដែរវិលល្ងាច សូមគេដេកម្ដុំចាក់អង្រែហ្នឹង អ្នកនៅចាក់អង្រែ កន្លែងរោងចក្រ កន្លែងអីអាម៉ុងប៉ុងបាំងពេញអីហ្នឹង ដេញមួយនៅទីហ្នឹងទៅ ។ តែគិតមិនដឹងជាធ្វើយ៉ាងម៉េចបានចូលទៅមើលផ្ទះយើងហ្ន៎? គ្នាបីនាក់ អើយ! គិតៗ មិនចេញទេ បើនៅទ័ពវៀតណាមនៅពេញអ៊ីចឹង ។ ខ្ញុំក៏ត្រឡប់ទៅស្រុកវិញ ។ ទៅស្រុកវិញ ប្រហែលជាប៉ុន្មានថ្ងៃទេ គេថាអ្នកនៅចាក់អង្រែហ្នឹងគេថាប្រហែលយ៉ាងម៉េច-- អើយ ចេះតែស្ដាប់វ៉ាដ្យូ គេថាដូចផែនការគេដល់ណាៗ ធ្វើបានអីៗ ឲ្យយើងចេះតែចូលទៅភ្នំពេញហើយ ។ ប៉ុន្តែ អ្នកមូលដ្ឋាន គេអ្នកចូលយកអីវ៉ាន់ យកអី គេប៉ានហើយព្រោះគេដឹងគ្រលុកគ្រលៀត តិកតាក់ ធ្វើទ័ព ធ្វើអី ។

ដល់ពេលខ្ញុំត្រឡប់ទៅផ្ទះវិញម្តង ខ្ញុំទៅប្រាប់បងខ្ញុំ បងស្រីខ្ញុំធំជាងគេហ្នឹង បងថ្លៃខ្ញុំឥឡូវអាយុ ៩០ហើយ ។ បងខ្ញុំទីមួយហ្នឹង គឺខ្ញុំទុកដូចម្តាយខ្ញុំ ព្រោះអីពេលម្តាយខ្ញុំស្លាប់ ខ្ញុំនៅស្រាតងូតទឹកនៅឡើយទេ ខ្ញុំគ្រាន់តែចាំពាក្យខ្ញុំ គាត់ឈឺ គាត់ថា "កូនអើយ តែអត់ពីម៉ែទៅ កូនវេទនាហើយ" ខ្ញុំចាំពាក្យគាត់តែប៉ុណ្ណឹងទេ ។

[១៤:១៨:៣៣]

ខ្ញុំបើខ្ញុំនិយាយឲ្យអស់រឿងខ្ញុំ ខ្ញុំនិយាយទាល់សុំឲ្យសិទ្ធិឡើងច្រើនម៉ោង ។ ចាំប៉ុណ្ណឹង ហើយខ្ញុំមិនដឹងជាកើតថ្ងៃណាទេ ។ ដល់ពេលបងខ្ញុំធំទៅ បងខ្ញុំថា ខ្ញុំកើតថ្ងៃចូលឆ្នាំខ្មែរ ហើយខ្ញុំហ្នឹងចោះអ៊ីចឹងទៅ ហើយខ្ញុំចាំបានត្រង់ហ្នឹងហើយាបានមកធ្វើបញ្ជីជាតិហ្នឹង ចូលរៀនហ្នឹង ។

ដល់ពេលខ្ញុំមកដល់ភ្នំពេញម្តងទៀតនេះ ខ្ញុំទៅប្រាប់បងធំជាងគេ ខ្ញុំថា ចែខ្ញុំភ្នំពេញហើយ គេថាឲ្យទៅរកក្រសួង រកមន្ទីរ ហៅគាត់មកភ្នំពេញ គាត់អត់ព្រមមកទេ គាត់ឲ្យខ្ញុំថា ទៅចុះ គាត់មិនចេះនៅទេ ស្រុកភ្នំពេញដាំស្រូវលើផ្ទះថ្ម ដំបូលផ្ទះ អត់បានទេ អត់ចេះដាំទេ អត់អង្ករស៊ីទេ ។ ហើយនឹកដែលថាក្រសួងមន្ទីរ ហើយចេះមកៗទៅ មើលទៅ ។ មកទៅក៏ខ្ញុំ មកលើកក្រោយនេះ ខ្ញុំបានមកជាមួយកូនខ្ញុំ អាមួយប្រុសសព្វថ្ងៃនោះ ដុកទ័ររាល់ថ្ងៃនេះ ។

ចូលដល់ផ្សារទួលទំពូង មើលឃើញផ្ទះពីចម្ងាយអស់រលីងហើយ ហើយទៅជួបគ្នីគ្នាអី ធ្វើពេទ្យជាមួយគ្នាអី ក៏គេប្រាប់ថាឲ្យដាក់ប្រវត្តិរូបទៅក្រសួង ។ ខ្ញុំសូមនិយាយបន្តិចទៀតចុះ ខ្ញុំមិនចង់វែងទេ រឿងខ្ញុំនិយាយហ្នឹងវាច្រើនហើយ យំហើមភ្នែកគ្រប់គ្នាអស់ហើយ ។ ដល់តែខ្ញុំនៅជួបលោកគ្រូ ងិន នៅផ្សារទួលទំពូង ខ្ញុំសម្រាកនៅផ្ទះគាត់ថ្ងៃហ្នឹង ។ គាត់ជូនខ្ញុំទៅមើលក្រសួង ពេលខ្ញុំឡើងក្រសួងដល់ពេលខ្ញុំទៅមើលប្រវត្តិរូប អាហ្នឹងពេលទៅដាក់ប្រវត្តិរូប ។ ទៅជួបគ្នាទៅ សួរៗគ្នា សុទ្ធសាច់ៗនិយាយអត់រួចហើយ ដល់ពេលខ្ញុំទៅតាមប្រវត្តិរូប គេថាមួយអាទិត្យទៀតចាំមក ។ ទៅតាមប្រវត្តិរូបជួបពូមួយៗ គឺ ទៀ ប៊ុនលាង ។

ទៀ ប៊ុនលាង គាត់*អង់ត្រឺប៉ឺណឺ* ក្នុងវាំងចតជាមួយសម្តេច សីហនុ ពីសង្គម ហើយផ្ទះវីឡាគាត់ជាប់ផ្ទះវីឡា ចេង ហេង កាលលើកអាទំនប់ថ្មីអី បែកត្រឡោកគេឥឡូវនេះ លើកផ្លូវថ្មី គឺមានតែវីឡាពីហ្នឹងជិតគ្នា ជាប់គ្នា ។

ដល់ពេលចូល៧៩ មកជួបគាត់ចុះពីក្រសួង ខ្ញុំក៏គាត់*អង់ត្រឺប៉ឺណឺ* គាត់អ្នករកស៊ី ហើយគេថាអត់ឯកជនទេ មានតែអ្នកធ្វើការ ។ គាត់ចុះមកវិញ ខ្ញុំចេះមើលមុខគាត់ ជិតប្រេះហើយខួរ ចេះតែរក

មើលផងប្អូនសាច់ឈាមវាអត់មានឃើញមនុស្សពីណាសោះ ឃើញគាត់ចេះមើលថា មុខហ្នឹងស្គាល់ណាស់ ប៉ុន្តែមិនដឹងឈ្មោះអី មិនដឹងពីណាគេ ចេះអាគំនិតមួយឡើងហួសប្រាំប្រាំមួយម៉ែត្រគ្នាជ្រួសឡើងទៅ ខ្ញុំថា "ពូៗ សូមទោស ពូឈប់សិន" ក៏សួរមួយសិន ។ ទាល់គាត់ឈប់អ៊ីចឹង គាត់ដើរមកបន្តិច ខ្ញុំដើរបន្តិច ជួបគាត់ខ្ញុំថា មើលមុខហ្នឹង ក៏មិនដឹងគាត់ឈ្មោះអី បីឆ្នាំប្រាំបីខែលេងស្គាល់គ្នា ។ មា ហើយនិងក្មួយ ន៎ែ ពូ សូមទោស ពូឈ្មោះអី? ចេះនឹករកសួរហ្នឹងចង់បែកខួរហើយ ល្មមនឹកឃើញពាក្យហ្នឹង? បាទ, ខ្ញុំឈ្មោះ ទៀ ប៊ុនលាង ។ អើ! ជម្រាបសួរឡៅចឹក អ៊ីចឹង ។

[១៤:២១:២៩]

សូមឲ្យបងប្អូនយើងពិចារណាមើល បីឆ្នាំប្រាំបីខែលែងស្គាល់គ្នាមនុស្ស ។ ដល់ជម្រាបសួរគាត់អ៊ីចឹង គាត់សួរខ្ញុំ-- គាត់ហ្នឹងគាត់នឹកម្តងទៀត គាត់ថា នាងពីណាគេ? គាត់ក៏ភ្លេចខ្ញុំ ខ្ញុំក៏ភ្លេច ។ ខ្ញុំថាខ្ញុំ *ម៉ាដាម* ទៀ ហាវតឹក ដល់អ៊ីចឹង *ម៉ាដាម* ទៀ ហាវតឹក ចុះ តឹក នៅឯណាក្មួយ? ដល់គាត់សួរ តឹក នៅណាខ្ញុំវាអួលដើមកខ្ញុំ ខ្ញុំនិយាយអត់រួច យំងក់ៗ ។ គាត់លួងខ្ញុំថា អ៊ីចឹងកុំយំអី ខ្ញុំអត់សួរ មកខ្ញុំអត់ទេ ។ ដល់អ៊ីចឹង ក៏អ៊ីចឹង កាលហ្នឹងដូចជាខ្ញុំបានចេញ*ណាសេរីស* ហើយប្រហែល ។ ខ្ញុំប្រាប់គាត់ថា អាចឹក ខ្ញុំប្រហែលជាធ្វើការនៅពេទ្យ ៧មករា ព្រោះដាក់ប្រវត្តិរូបនៅពេទ្យ ៧មករា ។ ដល់ចឹក គាត់ថា ចឹកអត់នៅទេស្រុកខ្មែរ ព្រោះអីគេអត់មានរកស៊ីឯកជន គេមានតែអ្នកធ្វើការ ។

ដល់អ៊ីចឹង ថ្ងៃមួយគាត់រៀបចេញទៅ កាលហ្នឹងគេដល់ហើយទៅស្អីគេហ្នឹងនោះ ជំរំស្អីគេហ្នឹងហើយខ្ញុំដឹងតែពីគោរពវិន័យធ្វើការ ខ្ញុំក៏សុំថ្នាំសុំអីជូនគាត់ទៅ ជូនគាត់ឲ្យគាត់ធ្វើដំណើរទៅ គាត់បែកពីប្រពន្ធគាត់ ប្រពន្ធគាត់ទៅស្រុកបារាំងមុន គាត់អាលែងសប្បាយជាមួយអាឡាន ដែល*កាប៉ូតា* បើកដំបូលសម្តេច សីហនុ ប្រទានឲ្យគាត់ បានខ្ញុំនៅចាំ ។ ម្តាយក្មេកខ្ញុំប្រាប់ ហើយស្វាមីខ្ញុំប្រាប់ខ្ញុំ ព្រោះគាត់ធ្វើការនៅហ្នឹង ។ ហើយអាល្អីម៉ង់អីៗ គេធ្វើឡានម៉ូតថ្មី ម៉ូដែលហ្នឹងគេប្រទានឲ្យសម្តេចពីរ ក៏ប្រទានឲ្យគាត់មួយ គាត់អាលែងតែវក់អ៊ីចឹងទៅ គាត់ក៏នៅក្នុងលោក ពត អ៊ីចឹង ។ គាត់ចេញទៅវាល់ថ្ងៃគាត់ចាស់ណាស់ហើយ ។

បន្ទាប់ពីហ្នឹងមកទៀត ខ្ញុំក៏មកធ្វើការៗ ដល់ពេលប្រហែលជា មើលខ្ញុំចូលមកវា៧៩ កាល*សឺរ៉ុស*ខ្ញុំចេញថ្ងៃ១២ ខែ៧ ឆ្នាំ៧៩ ។ *ណូតសឺរ៉ុស* ខ្ញុំចេញ ឲ្យខ្ញុំធ្វើការនៅមន្ទីរពេទ្យ ៧មករា ពេទ្យចិនហ្នឹងឯង ។ ដល់ថ្ងៃមួយមួយស្រាប់តែ ប្រហែលជាឆ្នាំ៨០ ហើយចូល៨០ ហើយប្រធានមន្ទីរចេះតែប្រជុំអ៊ីចឹង គាត់ថាក្រសួងៗ គេឲ្យ អាគេ-- ក្រសួងរៀននយោបាយអី ខ្ញុំមិនចង់និយាយទេ ខ្ញុំរៀននយោ-

បាយហើយអស់ហើយ ឲ្យទៅរៀនទៅអីហ្នឹង ទៅរៀនអារឿងស្អីៗហ្នឹង ។ ដល់ហើយគេថា ក្រសួងឲ្យយើងមកអង្គភាពទៅមើលគុកទួលស្លែង អត់ឮពាក្យស-២១ ។ ទៅមើលគុកទួលស្លែងទាំងមួយមន្ទីរពេទ្យយើង ទាំងកម្មករ ទាំងប្រធាន ទាំងបុគ្គលិកអីទាំងគាត់ទៅ ហើយដើរខ្លាចខ្មោចទេពេលនោះ ។ ផ្ទះនៅហ្នឹងខ្លាចខ្មោចពិតប្រាកដមែន ដឹងថាមន្ទីរគុកទួលស្លែង ។ ដល់ទៅមន្ទីរគុកទួលស្លែង សាលាពញ៉ាយ៉ាត ។ ជាប់សាលាពញ៉ាយាតហ្នឹង ផ្ទះម្ដាយមីងក្មេកខ្ញុំជាប់ហ្នឹង គាត់ក្មួយអីគេហៅ តាន់ប៉ា អ៊ីចឹងហើយយ៉ាង ខ្ញុំខ្ជិលរំឭកវែងឆ្ងាយនាំខាតពេល ។

បងថ្លៃខ្ញុំគាត់ធ្វើការនៅអាអេសសូល (ឮមិនច្បាស់) ផ្ទះជាប់ចូលមន្ទីរទួលស្លែងហ្នឹងតែម្ដង ។ ដល់ទៅៗចូលទៅក៏ចូលទៅវាទៅមួយមន្ទីរតែម្ដង ទៅអង្គភាពហ្នឹង ក៏ទួលស្លែងហ្នឹង គុកទួលស្លែងវាមានថា អ្នកនៅរស់ នៅរស់នៅសល់ អ្នកទោសនៅរស់ហ្នឹង គាត់គេឲ្យគាត់នៅទទួលភ្ញៀវនៅសារមន្ទីរទួលស្លែងហ្នឹង ដើម្បីប្រាប់ភ្ញៀវ ។ កាលនោះខ្ញុំចាំលោក អ៊ឹង ប៊ិច ឈ្មោះគាត់ អ៊ឹង ប៊ិច គាត់ប្រាប់ឈ្មោះអ៊ីចឹង ។ គាត់ជម្លៀសចេញ៧៥ដូចគ្នា គាត់ជម្លៀសចេញតាមផ្លូវកំពង់សោម គាត់ទៅដល់វាលរេញ គាត់-- អង្គការគេស្រាវជ្រាវរក ដល់ពេលបែកភ្នំពេញទៅ វារលត់ភ្លើងអស់ទឹកអស់អីទៅគេងងឹត-- គាត់ងងឹតគាត់ គាត់រកអ្នកតភ្លើងមកតទៅមន្ទីរទួលស្លែងហ្នឹង ហើយបានគេហៅគាត់មកពីវាលរេញ បែកពីប្រពន្ធកូនមកដាក់មន្ទីរទួលស្លែង ។

[១៤:២៥:២២]

គេយកគាត់មកមុនដំបូង គាត់ថា គេដាក់គាត់ ដាក់គុកគាត់ប្រហែលជា មិនដឹងជាដាក់ជាមួយលោកតា ជុំ ម៉ី អី មិនដឹងបន្ទប់ណា ខ្ញុំមិនបានចាំ ប៉ុន្តែខ្ញុំចាំគេដកក្រចកគាត់ ។ គេយកនេះដកក្រចកហើយ ដកក្រចកម្រាមដៃម្រាមជើងហើយទៅ គេយកអាកុលទៅចាក់ហ្នឹង ខ្ញុំជម្រាបលោកប្រធានទាំងអស់ និងភ្ញៀវជាតិ ភ្ញៀវអន្តរជាតិទាំងអស់ជួយពិចារណាមើល គាត់ប្រាប់ឲ្យខ្ញុំពិចារណាមើលដែរ គាត់ថា ដកក្រចកអស់អ៊ីចឹងហើយ ចេញឈាមចេញជ័រត្រសក់អ៊ីចឹង គេយកអាកុលទៅចាក់ពីលើ ហើយបងប្អូនស្រមៃដូចអាត្រីរស់ប្រលាក់អំបិលអ៊ីចឹង ។ អាហ្នឹងខ្ញុំនិយាយតាមពាក្យ លោក ប៊ិច ។ គាត់ហើយទៅបានគាត់និយាយពីរឿងថា ចូល៧៥ យើងជម្លៀសចេញពី៧៥ យ៉ាងម៉េច? ៧៦ យ៉ាងម៉េច? ចុះប្រជុំមួយអង្គភាពមន្ទីរខ្ញុំ ។ ៧៧ យ៉ាងម៉េច? ៧៨ យ៉ាងម៉េច? ខ្ញុំបានឮតាមគាត់ ។

ចេញពី៧៥ទៅគេយកអ្នក១៧ មកហូរហែ ដល់ចុង៧៦ ទៅអស់អ្នក១៧ គេយកអ្នកមូលដ្ឋានសម្លាប់មួយសាឲ្យបាត់ភស្តុតាង គេយកមួយសាចូលទៀត ។ អាហ្នឹងពាក្យគាត់និយាយទេ ខ្ញុំមិនដឹងទេ

កិច្ចការរបស់គាត់ ។

ដល់អ៊ីចឹងខ្ញុំថា-- ហើយគាត់ថាអ៊ីចឹងឲ្យកូនចៅគាត់ជូនទៅមើលតាមសាល តាមសាលាដែល-- តាមមន្ទីរអាជុំវិញហ្នឹង អានៅដេប៉ាតឺម៉ង់ ខាងត្បូងមន្ទីរកណ្ដាលហ្នឹង ហើយខាង-- ជួរខាងជើង ខ្ញុំអត់បានទៅមើលទៅទេ ។ យើងមានអាមីក្រុមួយ នាងហ្នឹងគាត់ចូល៧៩-៨0 ហ្នឹងគាត់ធ្វើការនៅទួលស្លែងហ្នឹង ។ គាត់និយាយប្រាប់ គាត់ថាបន្ទប់នេះ គេចោទថា *សេអ៊ីអា* អាមេរិកាំង អ្នកទោសចោទថាសេអ៊ីអាអាមេរិកកាំង គេយកមកធ្វើទារុណកម្ម បន្ទប់ហ្នឹងតូចៗ ធ្វើទារុណកម្ម គេដាក់ខ្នោះជើង ហើយគេដាក់ខ្នោះដៃអ៊ីចឹង ហើយគេយកក្រវ៉ាត់ក្ងាមុខអ្នកទោសហ្នឹងឲ្យដាច់ខ្ទេចបន្តិចម្ដងៗ នែ៎មើលជុំវិញខ្ទាតសុទ្ធឈាមនៅធុំឃ្មិះៗនៅឡើយ ។ កម្ទេចឈាមវាកក ហើយដល់អ្នកទោសហ្នឹងដាច់ខ្យល់ទៅ គេយកចេញហើយ នៅស្នាមរូបរាងខ្មោចក្រៀនៗ នៅហ្នឹង បើជុំហ្នឹងវាខ្ទៀតសុទ្ធឈាមណាលោក ធុំឆ្អាបនៅឡើយទេ ។

ខ្ញុំពិចារណាទៅពីនោះមកច្បាស់ណាស់ បោះ*ប្រ៊ុយយ៉ុង សេអ៊ីអា* អាមេរិកាំង ប្ដីខ្ញុំច្បាស់ជាស្លាប់ហ្នឹងហើយស្វាមីខ្ញុំ ។ ដល់ទៅមើលបន្ទប់ផ្សេងៗ បន្តហ្នឹងទៀត ចោទស្អីៗទៀត នឹកឃើញថា វាមិនមែនចំការងារយើង ទៅចំណាំទាំងអស់ អត់មើលផុតទេ ។ គេរាយការណ៍ប្រាប់អ៊ីចឹងមួយមន្ទីរទួលស្លែងហ្នឹង ។ ដល់មកវិញឲ្យចូលនៅបន្ទប់ទទួលភ្ញៀវហ្នឹង លោក ប៊ុច គាត់នឹងប្រាប់ រាយការណ៍ប្រាប់ហើយខ្ញុំថា លោកមីស្សឺខ្ញុំច្បាស់ជានៅហើយ តាមពិតលោក ប៊ុច ដល់ខ្ញុំនិយាយ ឥឡូវខ្ញុំនឹកឃើញ លោក ប៊ុច បើគាត់*សេហ្សកាប៊ីនេ*សាធារណការ មុននឹងបែកភ្នំពេញ ខ្ញុំចិញ្ចឹមឆ្កែប៉ែកហ្សែអាល្លឺម៉ង់មួយ ឈ្មោះវាអារីងហ្គោ ទិញពី*ម៉ូនីទ័រស្តេក*ទៅប្រកួតអន្តរជាតិកីឡា ។ កូនចៅមីស្សឺខ្ញុំគាត់ហៅទិញ ហើយមីស្សឺខ្ញុំគាត់ស្រឡាញ់ឆ្កែ គាត់សុំខ្ញុំចិញ្ចឹមឆ្កែ គាត់ដាំបាយខ្លួនគាត់ កាត់សាច់គោកាត់អី ឆ្នាំងអីមួយផ្សេងៗ ទុកដាក់ឲ្យវាស៊ី លោក ប៊ុច គាត់ចិញ្ចឹមឆ្កែដែរ លោក ប៊ុច យកឡានដឹកឆ្កែគាត់ទៅ ឆ្កែញីគាត់ទៅយកទៅបង្កាត់ឆ្កែខ្ញុំអារីងហ្គោ ខ្ញុំនឹកឃើញ ទើបនឹងនឹកឃើញក្រោយ ។ អ៊ីចឹងបានថារឿងរ៉ាវមិនចេះអស់។

ដល់អ៊ីចឹង តែថាលោក ប៊ុចៗ នៅរស់នៅហ្នឹង គាត់នៅគមនាគមន៍ដែរ គាត់ខាងអី*អាំងស៊ីញើ អេឡិចត្រូនិច* អីៗមិនដឹងទេ ខ្ញុំមិនចាំអស់ទេ *អេឡិចត្រិច* ខ្ញុំមិនចាំអស់ទេ ខាងបច្ចេកទេសគេ ។ ហើយដល់ហើយខ្ញុំថា សុំៗមើលខ្ញុំដើរទៅមើលសាលទៀត ខ្ញុំទៅលែងរួចហើយ ។ ដល់តែមើលទៅ គេយកឯកសារមក ខ្ញុំបានចម្លងឯកសារមកឃើញដាក់ឈ្មោះមីស្សឺខ្ញុំ ទៀ ហាវតឹក ចាប់ចូលនៅមន្ទីរទួលស្លែង ថ្ងៃ២ ខែ២ ៧៦ ។ កម្ទេចថ្ងៃ២៥ ខែ៥ ៧៦ ។ ហ្នឹងឯកសារនៅទួលស្លែងណាលោក ។ ហើយខ្ញុំមើល

ទៅទៀតស្រាប់តែឃើញ ទៀ វេងថៃ ។ ទៀ វេងថៃ ប្អូនថ្លៃប្ដីខ្ញុំបង្កើត ប្អូនប្ដីខ្ញុំបង្កើត ។ វាៗពេលនោះវាពីឡូតបើកកប៉ាល់ហោះ កាលហ្នឹងបិទចរាចរអន្តរជាតិហើយ នៅតែចរាចរក្នុងប្រទេសជាតិ គឺភ្នំពេញ-បាត់ដំបង ក៏ជិះកប៉ាល់ហោះដែរ វាពីឡូតកាប៉ាល់ហោះ ភ្នំពេញ-បាត់ដំបង ដឹកស៊ីវិលហ្នឹងដូចគ្នា ។

ហើយមើលទៅទៀតឃើញ ឈូក មឹងម៉ៅ នៅក្នុងឯកសារ ខ្ញុំក៏សរសេរចូលមកៗ សរសេរមកឯកសារហ្នឹងនៅទួលស្លែង ។ ខ្ញុំមិនបានសុំគេមក ព្រោះគេថា គេទុក*អាក់ស៊ីវ* ខ្ញុំកត់តែលេខបីនាក់ហ្នឹងមក ថ្ងៃចាប់ចូល លោក ឈូក មឹងម៉ៅ ឃើញដាក់ថ្ងៃចាប់ចូល ខែ១២ ។ ខ្ញុំដល់លឿនពេកទៅ ខ្ញុំដូចជានឹកគាត់ ចាប់ចូលខែ១២ កំណាត់ចុងឆ្នាំ ឈូក មឹងម៉ៅ ខ្ញុំក៏កត់ចូលមក ។

ដល់ពេលរូបថត រូបថតហ្នឹង គាត់ដឹងអ៊ីចឹងហើយ ពេលខ្ញុំទៅមើលភ្លាមហ្នឹង គាត់ថាអាល្អីម៉ង់គេមកជួយ មកស្រាវជ្រាវ រូបថតដែលផ្តិតមិនទាន់អស់នៅសល់អ្នក១៧ គេយកទៅផ្តិតឲ្យ ។ ហើយបានគាត់យករូបថតហ្នឹងមកឲ្យខ្ញុំទៀត ទៀ ហាវតឹក ហ្នឹង ចាប់ចូលថ្ងៃកម្មេច ថ្ងៃចាប់ចូលហ្នឹង ។

ហើយខ្ញុំសូមជម្រាបថយក្រោយបន្តិច មុននឹងចាប់ចូលទួលស្លែងហ្នឹង ខ្ញុំដូចថា ហៅពីវត្តកោះខែលមកហ្នឹង គេដឹកខ្ញុំមកផ្ទះវិញនោះណ៎ា អាថ្ងៃដែលគេឡើងទៅអស់រលីង ថ្ងៃហ្នឹងគេដឹកប្រពន្ធកូនពីរគ្រួសារមកដាក់នៅផ្ទះស្រុកកំណើតឪពុកម្តាយវិញហ្នឹង ។ ដូចថាត្រមង់ត្រមោច អង្គុយ-- អ៊ីផ្ទះនៅស្រុកចម្ការ ផ្លូវជាតិអ៊ីចឹង ផ្ទះវាអមថ្នល់អ៊ីចឹង ហើយផ្ទះឪពុកខ្ញុំ ។ ធម្មតាផ្ទះយើងស្រុកចម្ការ វាបីល្វែងហើយពីដើមមក អង្គុយកៅអីនៅអាខាងមុខផ្ទះហ្នឹង ក្រៅផ្ទះហ្នឹងមើលថ្នល់ហ្នឹង អង្គុយៗអ៊ីចឹងទៅ យប់ព្រលប់ៗស្រាប់តែឃើញកង់ពីរ កង់ពីរឌុបដាក់ខ្នោះដៃជាប់វានកង់ក្រោយហ្នឹងមក ហើយបែបល្បបគេហើយយ៉ាងជិះកង់ធាក់ហ្នឹង ហើយឌុបគាត់ពីក្រោយដាក់ខ្នោះដៃទៅជាប់វានកង់ ។

ខ្ញុំវានឹកឡើង ឥឡូវនេះខ្ញុំចងខ្សោះទឹកភ្នែកហើយ នឹកឡើងថាចុះស្វាមីខ្ញុំ ខ្ញុំមួយជាតិនេះ ខ្ញុំគិតពីរឿងពូជអម្បូរ គិតរឿងថ្លៃថ្នូរ ចង់ធ្វើមនុស្សហ្នឹងគេ ខំរៀនខំសូត្រខំរៀនពាក្យរៀនសម្ដីឲ្យទៅជាមនុស្ស ជាគ្រួសារថ្លៃថ្នូរ រួចគ្រួសារប្ដីខ្ញុំ ជីតាក្មេកខ្ញុំចៅហ្វាយស្រុកកំពតគេហៅ គេហៅធម្មតា គេហៅពីដើម គេហៅ ចីៗ ជំនាន់បារាំងចាស់ពីដើម គេហៅ ចីៗ ។ ចៅហ្វាយស្រុកកំពត គាត់ឈ្មោះ ចាន់, ទៀ ចាន់ ហើយផ្នូរគាត់នៅសព្វថ្ងៃ នៅទៅសង្កត់ផ្នូរ កូនៗខ្ញុំឲ្យវាទៅសង្កត់ផ្នូរ ព្រោះកូនបង្កើតៗស្លាប់អស់ហើយ នៅតែចៅឆ្ងាយៗ ។ ហើយហេតុម៉េចក៏គេដាក់ខ្នោះប្ដីខ្ញុំនេះ ប្ដីខ្ញុំអត់មានខុសអីសោះនេះ ខ្ញុំមកនេះ ខ្ញុំមកសងគុណ មករំឭកនឹកគុណការពិតដល់ស្វាមីខ្ញុំ ម្ដាយក្មេកខ្ញុំ បងថ្លៃប្អូនថ្លៃខ្ញុំ ម្ដាយមីងខ្ញុំនេះទើបតែ០០១ទេ ។ ម្ដាយក្មេកខ្ញុំ បងថ្លៃខ្ញុំ កូនប្រាំបីនាក់មួយគ្រួសារៗ បងថ្លៃទីមួយ ទីពីរ ហើយនិង

ប្អូនថ្លៃនៅលើវយកទៅវ៉ៃទម្លាក់ទាំងឡានលោកប្រធាន ។ ហ្នឹងចូល៧៩មក បាននៅរស់សាច់ថ្លៃ គាត់ទៅមករកខ្ញុំ ។ ដឹកទៅវ៉ៃនៅឯណា វាលរេញ ទាំងឡានៗ ទាំងគ្រួសារម្ដង ហើយនៅបងថ្លៃខ្ញុំមួយថា តោងឡានគេទៅ ស្រាប់តែអាឈ្លបយកស្នូកកាំភ្លើងវ៉ៃគាត់ទម្លាក់ឡាន ថាហ្អែងមកធ្វើអី? ហ្អែងទៅរកងាប់អី ។ គាត់បាននៅរស់ គាត់មកនិយាយប្រាប់ខ្ញុំ ឥឡូវគាត់ស្លាប់ហើយ គាត់ឈឺស្លាប់ ។

[១៤:៣៣:៣៨]

តែម្ដាយមីងខ្ញុំនោះ គ្រួសារលោក ស៊ឹម វ៉ា គេហៅ អួម វ៉ាន់ៗ ចៅហ្វាងសាលាក្រមចោទមុខវាំងហ្នឹងកូនប្រសារគាត់ លោក កេង លោកអី សុទ្ធតែសិក្ដ័ប៉ុន្មាន សិក្ដ័អីអ៊ីចឹងដែរ គាត់ជម្លៀសទៅស្រុកកំណើតខាងឪពុកគាត់ នៅខាងជ្រោយអម្ពិល នោះវ៉ៃទម្លាក់រណ្ដៅអ៊ីចឹងហើយ អស់មួយពូជ ឥឡូវនៅសល់តែចៅមួយ លោកប្រធាន នៅសល់ចៅមួយ អាវង ។ មួយពូជ មួយគ្រួសារស្លាប់អស់ហើយអាហ្នឹងចូលទៅអាខាងហ្នឹង ។ តែខ្ញុំថា គេថា ស-២១ ខ្ញុំមិនដឹងថា គេមានប្ដឹងមានផ្ដល់ ខ្ញុំអរគុណអន្តរជាតិ អរគុណជាតិ និងអរគុណអង្គការសហប្រជាជាតិហើយ ដែលរកយុត្តិធម៌ឲ្យសត្វលោកប្រជាជនខ្មែរទូទាំងប្រទេសកម្ពុជា ខ្ញុំអរគុណខ្លាំងណាស់ជូនបុណ្យកុសលឲ្យបានចុំចើ្រនរុងរឿងថ្លៃថ្នូរកើតជាមនុស្សថ្លៃថ្នូរគ្រប់ជាន់ គ្រប់ជាតិ កើតជាមនុស្សចិត្តសប្បុរសគ្រប់ជាន់ គ្រប់ជាតិ កុំឲ្យមានចិត្តឃោរឃៅ អសប្បុរសដូចជំនាន់លោក ប៉ុល ពត អ៊ីចឹង ។

បន្ទាប់មកទៀត ដល់ពេលនៅទួលស្លែង ។ អំមិញ ខ្ញុំនិយាយដល់ណាទេអំមិញ ខ្ញុំត្រឡប់ទៅថាទៅដល់ផ្ទះវិញ ថយក្រោយទៅវិញ គេៗហៅទៅដែលដាក់ខ្នោះដៃហ្នឹងទៅអ៊ីចឹង ខ្ញុំយំមិនចេញ ស្រាប់មានផ្ទះជាប់ឪពុកខ្ញុំហ្នឹងនែ៎ អាផ្ទះថ្មជាប់គ្នា ជញ្ជាំងជាប់គ្នាហ្នឹង គាត់មើលឃើញដែរ ចែហ្នឹងគាត់-- ខ្ញុំហៅគាត់ចែអ៊ីចឹង ទម្លាប់ស្រុកហ្នឹងគេហៅអ៊ីចឹង ។ គាត់ដើរមក គាត់មកខ្សឹបប្រាប់ខ្ញុំ នែ៎ អាវី ហ្អែងឃើញ ហ្អែងឃើញទ្រាអំមិញ ឃើញទ្រា គាត់នោះស្ទុតមកខ្សឹបប្រាប់ខ្ញុំឲ្យញាប់ស្អេក ហ្អែងឃើញទេហ្អែងមើលអ៊ូ! ។ ចុះផ្លូវជាតិវាវែងអ៊ីចឹង លោក វែងអ៊ីចឹង ធម្មតាផ្ទះយើងវាវាល មិនមែនដូចស្រុកភ្នំពេញឥឡូវ ដូចសំបុកជ្រុកអ៊ីចឹងអី សង់ជាប់គ្នា បិទមុខ បិទពួនអ៊ីចឹង មើលក្រឡេកពីនោះ ផ្លូវជាតិត្រង់មើលមកផ្ទះរហូតដល់មុខអ៊ីចឹង ដល់ផុតអ៊ីចឹង មើលមកផ្ទះ ដល់តែផុតមើលលែងឃើញ ។ ហើយគាត់ហ្នឹង មើលឃើញអ៊ីចឹងដែរ គាត់មកខ្សឹបប្រាប់ខ្ញុំ ហ្អែងឃើញទេ ហ្អែងឃើទ្រា ឃើញប្ដីហ្អែងអំមិញហ្នឹង ខ្ញុំថា ចែខ្ញុំឃើញ ។ ហើយៗ ខ្ញុំឃើញអ៊ីចឹង ខ្ញុំនឹកឃើញនែ៎ អាបងនៅក្នុងផ្ទះ គាត់ថា គាត់អ្នករាយការណ៍នោះ គាត់អ្នកបោះប្រ៊ុយយ៉ុង គាត់ថាហ្នឹង ថានឹងមាត់ ភ្នែកមើលឃើញ ត្រចៀកឮអ៊ីចឹង ឃើញ

អ៊ីចឹង គាត់ថាហ្នឹង គាត់ថាគេចាំតែមកយកទៅទៀតទេ កុំមកចេញទឹកភ្នែក កុំមកយំអីនោះ គាត់គោរព គាត់គោរពអាដែងវិន័យគាត់ គាត់ចង់ធ្វើប្រពន្ធ ប៉ុល ពត ហើយ ។ ប្រហែលសុំទោស ខ្ញុំនិយាយពាក្យនេះមិនសមរម្យម៉េចក៏ដោយ ខ្ញុំសូមថាឲ្យធូរមាត់ខ្ញុំបន្តិច ព្រោះអីគាត់វាគាប់គន់ អាហ្នឹងនៅរឿងគាប់គន់ ខ្ញុំយល់ឃើញអ៊ីចឹង ។ ដល់ហើយ គាត់ថា បងអើយ គេយកទៅ ទៅក្រោមហ្នឹង យកដាក់មន្ទីរ១៥ ហើយនៅកោះកណ្ដុរ គាត់ខ្សឹបប្រាប់ខ្ញុំអ៊ីចឹង ។

[១៤:៣៦:២៧]

មនុស្សវាមានល្អ មានអាក្រក់ មានចិត្តធម៌ ចិត្តបាប មនុស្សវាសន្សំមកច្រើនជាតិហើយម្នាក់ៗខ្ញុំយល់ឃើញអ៊ីចឹង ប៉ុន្តែគ្រាន់តែថាយកដាក់មន្ទីរ១៥ហើយ ហ្អែងដឹងទេ ហ្នឹងហើយជាប់ទោសធ្ងន់ហើយ ដាក់ខ្នោះដៃ ។ ខ្ញុំគ្រាន់តែឃើញគេដាក់ខ្នោះដៃ ស្វាមីខ្ញុំ ខ្ញុំវាដូចថា វាធ្លាប់ជំហរកាត់ចិត្ត កាត់ថ្លើមហើយ ខ្ញុំវាហួសចិត្តទៅ ខ្ញុំអត់ប៉ានយំង៉ោងៗ អារឿងយំង៉ោងៗម្នាក់ឯង ខ្ញុំយំរោលដូចគោអីទេ ។ ប៉ុន្តែ ដល់អ៊ីចឹង គាត់ថា គាត់ប្រាប់ខ្ញុំទៀត អឺ! យកដាក់មន្ទីរ១៥ហ្នឹង ហ្អែងដឹងទេ នៅអុងកូ កោះកណ្ដុរហ្នឹង អាហ្នឹងភូមិយួនពីដើម ដូនតាមក កន្លែងហ្នឹងគេហៅភូមិយួន ។ គេមានអុងកូ មួយ ឥឡូវហ្នឹងអត់មានប្រជាជននៅទេ គេយកអុងកូ ហ្នឹងធ្វើមន្ទីរ១៥ គាត់ខ្សឹបប្រាប់ខ្ញុំអ៊ីចឹង ហើយយកទៅហ្នឹងដាក់មន្ទីរ១៥ហើយ ទោសធ្ងន់អ៊ីចឹង ហើយហ្អែងដឹងទេ មនុស្សអាដែលអ្នកទោសធ្ងន់អ៊ីចឹង គេយកទៅដាក់ គេធ្វើរ៉ែស្នូកជ្រូក ហើយគេយកដើមចេកហាន់ គេបុកជាមួយកន្ទក់ ហើយគេលាយបាយដាក់ស្នូកជ្រូកហ្នឹងឲ្យអ្នកទោសហ្នឹងស៊ីហើយ ឲ្យអ្នកទោសហ្នឹងបរិភោគហើយ ។

ឱ! លោកប្រធានហើយ ប្រធានជាតិប្រធានអន្តរជាតិពិចារណាមើល៎ នេះជាត្រចៀកឮពិត ភ្នែកក៏ឃើញពិតដែរ ដឹកយកទៅ មិនងាយពេលណា ម៉ោងណា បានយើងឮដូចស្រុកពេលវេលាបច្ចុប្បន្ននេះទេ ខ្ញុំសូមជម្រាបអ៊ីចឹង ខ្ញុំយល់ថាអ៊ីចឹងមនុស្សទូទាំងសាកលលោកហ្នឹង ។ ខ្ញុំពិចារណាទៅថា ខ្ញុំយំហ្នឹងមិនប៉ាឲ្យគេឮទេ លោកប្រធានហើយមកពីអាយុខ្ញុំមិនទាន់អស់ទេ ទុក្ខរបស់ខ្ញុំ បើអាយុរបស់ខ្ញុំអស់ ខ្ញុំស្លាប់អស់ហើយ មិនបានមកអង្គុយនៅទីនេះទេ ។ ខ្ញុំយំហ្នឹង ខ្ញុំឈឺចិត្តថា ចុះមនុស្សថ្លៃថ្នូរ មានបុណ្យសក្តិ គេគោរព ខ្ញុំបានចាំ អង្គាល់ពីគាត់នៅកាន់បញ្ជី*ពែរសូណែល* (Personnel) មួយក្រសួង ។ ចុះលោករដ្ឋមន្ត្រី លោកពីដើមហៅយើង កុង្សីកុងអី មួយក្រសួង គឺឈ្មោះនៅលើគាត់កាន់ហ្នឹង គាត់ស្គាល់ គាត់ដឹងហើយ ចៅហ្វាយគាត់អ្នកណា កូនចៅឯណា ។ គេសុំចូលថា គ្នាអត់លុយ គ្នាមកសុំចូលមកគេអង្គុយ គេអង្គុយក្រោម យើងអង្គុយលើ គេសុំថា ចៅហ្វាៗអាណិត ឲ្យខ្ញុំចូលក្របខ័ណ្ឌទៅ

ខ្ញុំទៅលក់គោ លក់ដី មកជូនចៅហ្វាយ ហើយស្វាមីខ្ញុំ គាត់ថា អត់ទេណា អត់លក់ទេ ។ បើទៅលក់ដី លក់គោ យកលុយមកឲ្យខ្ញុំ ខ្ញុំអត់យក ហើយខ្ញុំអត់ជួយអ្នកឯងទៀត អ្នកឯង*ហ្សុកណាល់លីយ៉េ* អត់ឲ្យចូលក្របខ័ណ្ឌទៀត ។ នេះខ្ញុំធ្លាប់តែឃើញចិត្តមីស្សីខ្ញុំអ៊ីចឹង ។

ហើយហេតុម៉េចទៅជួប-- ហើយបងខ្ញុំហ្នឹងទៀត ខ្ញុំសូមជម្រាប សូមជម្រាបអង្គសវនាការចុះ ឲ្យពិចារណាក្នុងជីវិតមនុស្សយើង មនុស្សគេចែកជាបួន ។ ពុទ្ធដីកា គឺពិតណាលោកប្រធាន ព្រោះអីបើបានរៀនធម៌ព្រះពុទ្ធ ស្តាប់ធម៌ព្រះពុទ្ធ ឲ្យច្បាស់មែនទែនហ្នឹង យើងនឹងយល់ដឹងហើយ ធម៌ព្រះពុទ្ធ គ្មានអ្នកណាដូចត្រាស់ដឹងពីជីវិតយើងហ្នឹង មួយជីវិតយើងជួបអីខ្លះហ្នឹង យើងត្រូវធ្វើយ៉ាងម៉េច មិនត្រូវធ្វើម៉េចហ្នឹង ។ មានបួន ចែកជាបួន មនុស្ស មនុស្ស: មនុស្សសោៗ គឺជាមនុស្ស ដែលមនុស្សគេរ៉ូ ដែលយើងជាមនុស្ស ចិត្តជាទេវតា ។ មនុស្សគេរ៉ូ ហើយទៅមនុស្សប៉ែតតោៗ ដែលយើងជាមនុស្ស ចិត្តជាប្រេត ។ ដល់មនុស្សតិរច្ឆានណោមក ដៃជើងយើងជាមនុស្ស រូបកាយយើងជាមនុស្ស តែចិត្តហ្នឹងវាជាតិរច្ឆាន ជាសត្វតិរច្ឆាន ។ ដល់ពេលហ្នឹងខ្ញុំនឹកឃើញកន្លែងហ្នឹងលោកអើយ ខ្ញុំធ្លាប់ពីតូចៗ ទៅស្រុកខ្ញុំចេះស្តាប់លោកទេស ចាស់ៗអីគេនិយាយប្រដៅរឿងព្រះពុទ្ធសាសនា ។ ខ្ញុំចាំពាក្យចាស់ផង ដល់ខ្ញុំមកស្តាប់ធម៌ព្រះពុទ្ធមក យី! ចាស់ៗពីដើមនិយាយមកសុទ្ធតែពាក្យព្រះពុទ្ធត្រាស់ដឹងសោះ ។

ហ្នឹងមនុស្សតិរច្ឆានោ យកមនុស្សទៅឲ្យស៊ីៗ ដូចអ៊ីចឹង អាសូរថាប្តីខ្ញុំ គាត់មានខុសអី គាត់មានព្រហើនអី គាត់មាន-- ដូចថានិយាយពាក្យលេងប្រផ្តេសប្រផ្តោះឥតប្រយោជន៍អី គាត់ជាមនុស្សខ្ចិលច្រអូស គាត់ជាមនុស្សអ្វីដែលខុសប៉ុនសរសៃសក់ ចុងសរសៃសក់ក៏ខ្ញុំអស់ចិត្តដែរ ។

[១៤:៤០:៣៤]

សូមជម្រាបទូទាំងសាកលលោក មនុស្សទាំងសាកលលោក ខ្ញុំជឿថា មានជីវិតរស់នៅគ្រាន់តែភាសាខុសគ្នាទេ មនុស្សកើតមកក្នុងសកលលោកនេះ អាហ្នឹងគំនិតខ្ញុំគិតឃើញពិចារណាទេ ប៉ុន្តែសូមបងប្អូនញាតិមិត្ត លោកប្រធានអីទាំងអស់ គិតទាំងអស់គ្នា យើងកើតមកជាមនុស្ស តើខុសក៏មិនដឹង? ត្រូវមិនដឹង? ប៉ុន្តែ ខ្ញុំថាមិនខុសទេ ឲ្យតែស្តាប់ឮ ហើយចេះពិចារណា ។ តែមនុស្សចង់ថ្លៃថ្នូរ ចង់បានសុខ ចង់បានមាន ចង់បានសិរីសួស្តី សុភមង្គល ចង់បានច្រើនណាស់ ។ ប៉ុន្តែ ហេតុអីមនុស្សយកមនុស្សអត់កំហុសអី ទៅធ្វើអ៊ីចឹង? ខ្ញុំវាអាណោចអាធ័ម ថាមនុស្សហេតុអីបានគេទៅធ្វើអ៊ីចឹងកើតទៀតនេះ? មនុស្សហ្នឹង មនុស្សរបៀបណា? បើប្តីខ្ញុំធ្វើអាក្រក់ ទៅលួចតែបាយជ្រូកអ៊ីចឹងចុះ ឧទាហរណ៍ ខ្ញុំថាឲ្យវាថោកអស់លេខអ៊ីចឹងចុះ លួចបាយជ្រូក វាស៊ីចុះ? ឲ្យវាសមធ្វើអ៊ីចឹង ។ រឿងអី ប្តីខ្ញុំជាមនុស្ស

ថ្លៃថ្នូរ គោរពវិន័យ ការអ្វីដែលមិនធ្លាប់ធ្វើ ខំធ្វើជូនអង្គការ មិនដឹងយប់ មិនដឹងថ្ងៃ មិនដឹងដេក មិនដឹងពួន ហេតុអីយកមនុស្សទៅធ្វើរបៀបហ្នឹង? សូមបងប្អូន និងលោកប្រធានជាតិ និងអន្តរជាតិពិចារណាមើលនៅពេលនេះ រហូតដល់ថ្ងៃមុខទៀត ហើយកើតមកជាមនុស្សទាំងអស់គ្នា គ្រាន់តែភាសាខុសគ្នាទេ ខ្ញុំយល់ឃើញអ៊ីចឹង ។

ដល់ៗយកទៅអ៊ីចឹទៅ ក៏បាត់ឈឹងៗ គេយកខ្ញុំទៅលត់ដំហ្នឹងទៅ លុតដំធ្វើការជាមួយអង្គភាពអីដល់ចូលខែទឹកខែអីហ្នឹងទៅ គេលត់ដំ ដូចថា ឈ្មោះៗ ខ្ញុំភ្លេចឈ្មោះអី គេយកខ្ញុំទៅដល់ស្រែ អង្គភាពគេដើរអស់ហើយ នៅស្រុកស្រែ ស្រុកអី គ្មានសល់ទេ ទៅធ្វើតាមអាកងស្រួចអីហ្នឹង ជីកប្រឡាយមួយថ្ងៃជម្រៅពីរម៉ែត្រកន្លះ គេឲ្យខ្ញុំគ្រប់ផែនការ តែអត់គ្រប់ផែនការ គេយកខ្ញុំទៅទៀតហើយខ្ញុំ ។ គេធ្វើបាបខ្ញុំដូចបងប្អូនយើងនិយាយគ្រប់សព្វអស់ហើយ តែខ្ញុំ គឺម៉ូតវាខុសគ្នា មនុស្សទាំងអស់គ្នារាប់លាននាក់ហ្នឹងគឺរងគ្រោះដោយម៉ូតខុសគ្នាអ៊ីចឹងតែម្តង ខ្ញុំស្តាប់យល់អ៊ីចឹង ។ បងប្អូនយើងពិចារណាមើលទៅ អត់ដូចគ្នាទាំងអស់មនុស្ស ។ ខ្ញុំហ្នឹង វាៗម៉ូតខុសគេ គេក៏ម៉ូតខុសខ្ញុំទៅទៀត ខ្ញុំពិចារណាទៅ រងគ្រោះហ្នឹងហើយក៏--

**ប្រធានអង្គជំនុំ៖**

ឈប់ៗ លោកស្រី ឈិន ណារី ឥឡូវនេះដល់ម៉ោងត្រូវសម្រាក ហើយក៏ឃើញដែរ លោកស្រីដូចជាហត់នឿយដែរហើយ ច្រើននិយាយតែម្នាក់ឯង ហើយអ្នកស្តាប់ច្រើនណាស់ ។ ឥឡូវនេះ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះទៅ រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ។ ហើយជម្រាបលោកស្រី ឈិន ណារី ថាបន្ទាប់ពីពេលចូលវិញ សូមលោកស្រីតម្រង់នៃការថ្លែងការណ៍របស់លោកស្រី ពាក់ព័ន្ធជាមួយនឹងមន្ទីរសន្តិសុខស-២១ ឬក៏ទួលស្លែង ដែលមានការពាក់ព័ន្ធទៅនឹងការចាប់ប្តីរបស់លោកស្រីទៅធ្វើបាប និងទៅកាប់សម្លាប់នៅទីនោះ ។ លោកស្រីនៅចន្លោះពេលសម្រាកនេះអាចរកកន្លែងសម្រាកសមរម្យ ហើយនិងអញ្ជើញមកទីនេះទាំងគ្រូពេទ្យ ដើម្បីបន្តដំណើរការសវនាការចាប់ពីម៉ោងបី ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង១៤:៤៥នាទីដល់ម៉ោង ១៥:០៥នាទី]*

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយផ្តល់ឱកាសទៅលើកស្រី ឈិន ណារី ដើម្បីបន្តនូវ-- ធ្វើសេចក្តីថ្លែងការណ៍ហើយសូមបង្ហាញនូវសេចក្តីថ្លែងការណ៍ដែលមានពាក់ព័ន្ធទៅនឹងអង្គហេតុនៃមន្ទីរ ស-២១ ទៅនឹងស្វាមីរបស់លោកស្រី ។ ទៀ ហាវតឹក ហើយនិងផលប៉ះពាល់ផ្សេងៗដោយសារអង្គហេតុដែលបានប៉ះពាល់អាយុជីវិតរបស់ស្វាមីរបស់លោកស្រី ។

**លោកស្រី ឈិន ណារី៖**

ចាស, ខ្ញុំ ឈិន ណារី សូមគោរពអង្គសវនាការ ភ្ញៀវជាតិ និងភ្ញៀវអន្តរជាតិជាទីគោរព! ពីឈ្មោះ ពីរឿងខ្ញុំបានដាក់ពាក្យបណ្តឹងនេះ ពីឈ្មោះ មីស៊ើ ទៀ ហាវតឹក ម៉ាស៊ីងខៀវិចទ័រ (ឮមិនច្បាស់និយាយភាសាបារាំង) អាកាសចរណ៍ស៊ីវិល មុនទៅ ប៉ុល ពត ។ ពេលចូលមកដល់ ប៉ុល ពត ខ្ញុំបានរួបថត អ! ចប់ ប៉ុល ពត ចូលមកវិញនេះ ខ្ញុំបានធ្វើការនៅមន្ទីរពេទ្យ ៧មករា គឺហៅ ពេទ្យចិននេះ ។ តែឥឡូវគេសង់សំណាងផ្សេងហើយ ប្រហែលពីឆ្នាំ៧៩ មក ៨០ ។

ប្រហែលជាឆ្នាំ៨០ ក្រសួងសុខាភិបាលបានប្រាប់ទៅប្រធានមន្ទីរពេទ្យ៧មករា ខ្ញុំ ហើយប្រធានមន្ទីរពេទ្យ៧មករា ខ្ញុំគាត់បានប្រាប់បុគ្គលិកកម្មករទាំងអស់នៅក្នុងមន្ទីរពេទ្យនោះថា ក្រសួងឲ្យយើងពួកយើងទៅមើលបនប្រល័យពូជសាសន៍នៅគុកទួលស្លែង ។ ពេលនោះ ខ្ញុំអត់ទាន់ឮថា ស-២១ នៅឡើយទេ ក៏ប្រធានមន្ទីរពេទ្យខ្ញុំនាំបុគ្គលិក និងកម្មករទាំងអស់ ។ កាលនោះទើបនឹងចូលមកប្រហែលជាមានបុគ្គលិកខ្ទង់ជាហា-ហុកសិបនាក់ទេ មិនទាន់បានមួយរយនាក់ទេ ព្រោះពេលនោះចូលមកម្នាក់ៗទោះបីអ្នកផ្សេងក៏មកសូមធ្វើកម្មករដែរយកបាយហូប ព្រោះអីអស់រលីងហើយចូលមកដល់ភ្នំពេញនេះ។

[១៥:០៨:៣០]

ចូលធ្វើការដើម្បីសូមបាយហូបសិនទៅ ក៏ចូលទៅមើលមន្ទីរទួលស្លែង ទៅពេលនោះជួបអ្នកដែលនៅធ្វើការទួលស្លែងហ្នឹង គាត់ថាអាហ្នឹងបែក ប៉ុល ពត ហើយគាត់អ្នកទោសជាប់នៅគុកទួលស្លែងហ្នឹង ។ គាត់*ប្រែសង់តេ* ថាខ្ញុំឈ្មោះ ប៊ិច, ឈ្មោះ អ៊ឹង ប៊ិច ជាអ្នកទោសជាប់នៅទីហ្នឹងដែរដល់បែកអង្គភាពទៅក៏គេឲ្យគាត់នៅធ្វើការទីហ្នឹងទៅ ។ ហើយគាត់ក៏បានរាយការណ៍ប្រាប់អង្គប្រជុំមន្ទីរពេទ្យខ្ញុំ ទាំងប្រធានមន្ទីរពេទ្យទាំងបុគ្គលិកទាំងអស់ហ្នឹង និយាយពីរឿងដូចខ្ញុំនិយាយមុននឹងអ៊ីចឹងថា ពី៧៥ របៀបម៉េច? ៧៦របៀបម៉េចនឹងទៅ ដល់ពេលចំៗគេឲ្យ-- គាត់ឲ្យ-- និយាយនេះ ខ្ញុំ និយាយ

រួចហើយអំមិញហ្នឹង ។ គាត់ឲ្យបុគ្គលិកគាត់នាំទៅមើលតាមកន្លែងគេដាក់អ្នកទោសមួយបន្ទប់ៗហ្នឹងនៅខាងត្បូងហ្នឹង ហើយនាងនឹងគាត់និយាយមីក្រូ គាត់ថានៃបន្ទប់តូចៗហ្នឹងអ្នកទោសដែលគេចោទថា *សេអ៊ីអា* អាមេរិកាំង គេធ្វើទារុណកម្មនៅបន្ទប់នេះ ហើយគេដាក់ខ្នោះជើងពីរ ដៃពីរ ពេលគេធ្វើទារុណកម្មគេកម្ទេច គេយកកង្ហារមុខហ្នឹងឲ្យដាច់ខ្ទេចអស់ ហើយខ្ទាតឈាមនៅជុំវិញហ្នឹង នៃបន្ទប់តូចនោះសម្រាប់ម្នាក់ហ្នឹង អាហ្នឹងអ្នកទសធ្ងន់គេហើយ ។

[១៥:១០:១១]

ខ្ទាតកម្ទេចឈាមហ្នឹងនៅកក ពេលខ្ញុំទៅមើលហ្នឹងឃើញកម្ទេចឈាមហ្នឹងកកមែន ហើយស្នាមក្រវ៉ង់ៗហ្នឹងកន្លែងកម្ទេចខ្មោច ។ មនុស្សហ្នឹងស្លាប់ទៅជាខ្មោចទៅ គេយកខ្មោចទៅចេញទៅកប់ទៅមិនដឹងជាកប់នៅទីណាទេ ។ បានឮប៉ុណ្ណឹងខ្ញុំគិតថា ចុះមកពីស្រុកមកហើយបងបោះប្រ៊ុយយ៉ុង--បងធ្វើដៃប្រាប់ឈ្លបអីចេះហើយ ដឹងច្បាស់ហើយ ច្បាស់ជាស្វាមីខ្ញុំនៅទីនេះហើយ ។ ដល់គាត់នាំមើលគ្រប់កន្លែងអ៊ីចឹងហើយ គេប្រាប់គ្រប់កន្លែងអ៊ីចឹងហើយខ្ញុំមិនចងចាំអាការងារផ្សេងទៀតទេ ព្រោះអីវាច្រើនមុខ ។ ខ្ញុំចាំតែថា ទារុណកម្ម អ្នកទោសគេចោទថា *សេអ៊ីអា* អាមេរិកាំងហ្នឹងធ្វើទារុណកម្មរៀបកម្ទេចធ្វើរបៀបណាហ្នឹងក៏-- ពេលចប់អ៊ីចឹងទៅគេក៏មកកន្លែងប្រជុំវិញ ប្រធានលោក ប៊ុច ។ អ៊ុង ប៊ុច ហ្នឹងនៅកន្លែងទីស្នាក់ការប្រជុំហ្នឹងគាត់ក៏លើកប្រាប់ទៀត គាត់ថា ដូចខ្ញុំនិយាយអំមិញអ៊ីចឹង ។ ថារូបថត ថាមានឯកសារ ដល់សូមឯកសារគេមើលទៅឃើញៗនៅក្នុងបញ្ជីហ្នឹងគេសរសេរថ្ងៃចាប់ចូលទៀ ហាវតឹក យកមកពីតំបន់២៥ ថ្ងៃចាប់ចូលថ្ងៃ ២២ ខែ២ ៧៦ ថ្ងៃកម្ទេច ខែ៥ ៧៦ ។

[១៥:១១:៣៥]

ហើយខ្ញុំស្រមៃឃើញថា ដល់ពេលគេប្រាប់ធ្វើទារុណកម្ម ដែងថ្ងៃកម្ទេចហ្នឹងវាស្លុត់ខ្ញុំ ដូចវាអស់ព្រលឹងពីខ្លួន ហេតុម៉េចក៏មនុស្សគេយកទៅធ្វើទារុណកម្មព្រៃផ្សៃដល់យ៉ាងហ្នឹងខ្ញុំពិចារណាទៅ ខ្ញុំអស់ព្រលឹងព្រលះពីក្នុងខ្លួនហើយ ។ ខ្ញុំមិនដឹងជាៗជាយ៉ាងណាទេ ក្នុងចិត្តនោះរកពាក្យអីនិយាយគ្មានទេខ្ញុំដូចវាចង់សន្លប់ក្នុងចិត្ត តែខំពង្រឹងជំហរកុំឲ្យពិបាកគេសែង ព្រោះទៅគ្នាច្រើន ។ ដល់ពេលមកវិញបានសុំឯកសារគេមើលទៅក៏ឃើញបញ្ជីហ្នឹងទៀត ឃើញបញ្ជីហ្នឹងគត់ចូលដូចខ្ញុំជម្រាបអម្បាញ់មិញអ៊ីចឹង ។ ដល់ពេលអ៊ីចឹងខ្ញុំ ពេលគេយករូបថតមកឲ្យទៀតហ្នឹង ខ្ញុំឃើញទាំងរូបថត ឃើញភ្លាមហ្នឹងស្លុតហើយ ខ្ញុំមិនដឹងនិយាយថាម៉េចទេឥឡូវនេះ ។ ខ្ញុំវាដូចអាពេលដែងទទួលទុកវេទនា វាសន្លប់វាអីអស់រលើងហើយ គេដូចបច្ចុប្បន្នដែរ តើគេឃើញយើងអ៊ីចឹង ។ គេមានមនុស្សលើកទឹកចិត្តយើងជួយនាំ

យើងដើរចេញ ដើរចូលអ៊ីចឹងដែរពេលនោះ ។

[១៥:១២:៤៣]

ខ្ញុំយំដូចអ៊ីចឹង ។ យំអត់មាននេះទេ-- ទៅដល់ផ្ទះវិញគឺថា មកដល់ផ្ទះវិញគឺថាល្ងាចហ្នឹងយំៗឮ ង៉ោងៗតែម្តង ។ សុទ្ធសាច់យំតែម្តង យំមិនចេះឆ្អែតតែម្តង ដល់ពេលស្អែកឡើងចូលមកធ្វើការទៀតក៏ខ្ញុំយំទៀត ដែលឃើញថា ខ្ញុំនិយាយប្រាប់គេម៉េចថា ឃើញស្វាមីខ្ញុំគេដាក់តាំងនៅទួលស្លែងមានរូបថតមានបញ្ជីអ៊ីចឹង ពេលធ្វើការក៏ខ្ញុំយំដែរ ។ បានលោក ស កំពន់ *(ឮមិនច្បាស់)* នេះគាត់ខាងក្រសួងអប់រំគាត់អ្នកជំងឺគាត់ធ្វើទៅធ្វើធ្មេញ ។ គាត់ថា *ម៉ាដាមៗ* ឯងឈប់យំទៅ គេស្លាប់-- គាត់ស្លាប់ហើយគាត់ចប់ភារកិច្ចហើយ ។ ម៉ាដាមឯងខំពង្រឹងជំហរ ម៉ាដាមកូនប៉ុន្មាន ម៉ាដាមពង្រឹងជំហរនៅភារកិច្ចយើងចិញ្ចឹមកូន ។ ជ្រងកូនឡើងជំនួសឪគេផង ម៉ែគេផង ឈ្នួលគេផង ចៅហ្វាយគេផង ។ សព្វគ្រប់ដល់អ៊ីចឹងខ្ញុំហាក់ដូចជា ទឹកភ្នែកខ្ញុំវាអន់បន្តិច វាអន់ដែរ ។ វាអន់ដែរ នៅចាំពាក្យគាត់ គាត់និយាយហ្នឹងពិតមែនគាត់ថា ម៉ាដាមឯងកាត់ចិត្ត មើល!ខ្ញុំទៅអាល្លឺម៉ង់ កាលជំនាន់ហ្នឹងគេឲ្យពួកក្រសួងទៅអាល្លឺម៉ង់ទៅអីធ្វើស្ពាន-- ទៅមើលអាល្លឺម៉ង់ ខ្ញុំជិះរទេះភ្លើងរាល់ថ្ងៃអាទិត្យ គេស្រឡាញ់គ្នាតែចិញ្ចឹមថ្នល់ ដល់កូនពីរបានគេការ ។ ម៉ាដាម ឯងកុំយំច្រើនឈប់យំ! បានខ្ញុំចេះតែពិចារណាពាក្យគាត់ទៅ ។

[១៥:១៤:១៩]

នឹកឃើញស្រមៃឃើញតែគេកម្ទេច គេដាក់ខ្នោះ គេធ្វើទារុណកម្ម ហើយៗគាត់ប្រាប់ទៀតគាត់ថាមុននឹងចាប់ចូល ពេលដែលចាប់ចូលមកហ្នឹងគេសួរយកចម្លើយដូចកន្លងមកនិយាយអ្នកទោសទួលស្លែងគ្រប់គ្នាអ៊ីចឹង ។ សួរចម្លើយ យើងៗអត់ដឹងរឿងអីទាំងអស់ហ្នឹង គឺឲ្យបង្ខំឲ្យយើងឆ្លើយ គេធ្វើទារុណកម្មឲ្យយើងយល់ព្រមឆ្លើយ ។ ម៉េចៗខ្ញុំចង់បានឯកសារហ្នឹងទៀត តែខ្ញុំទៅរកវាអត់កើតគ្រាន់តែថាទៅដល់មន្ទីរទួលស្លែងខ្ញុំសន្លប់តែម្តង ខ្ញុំខ្លាចគេសែង មានអ្នកណាសែងខ្ញុំ ខ្ញុំម្នាក់ឯង ។ ខ្ញុំចង់បានឯកសារហ្នឹងទាំងនៅពេលដែលគេបង្ខំឲ្យឆ្លើយតាមគេហ្នឹង ដូចលោក ឌុច ក៏គាត់មាននិយាយដែរ ផែនការរបស់គាត់ហ្នឹង ខ្ញុំចង់បានកន្លែងហ្នឹង ។

ចង់បានឲ្យសព្វគ្រប់ដែលខ្ញុំមិនអាចទៅយកខ្លួនឯងបាន សំខាន់កន្លែងហ្នឹង ។ ហើយខ្ញុំចង់ថតនិយាយឲ្យដល់មែនទេនពីមុនខ្ញុំខ្មាសគេអីៗរឿងគេធ្វើបាប ធ្វើទុកអីខ្ញុំចេះតែអត់ធ្មត់ដល់ឥឡូវនេះ ខ្ញុំហាក់ដូចជាចង់ថា ថតជាហ្វីលសាច់រឿងមួយទុកឲ្យកូន ឲ្យចៅមើលឲ្យពិភពលោកមើលទៅ កើតមកជាខ្មែរអីក៏អភ័ព្វយ៉ាងនេះ! ចោកទាបម្លេះទៅយកតែមនុស្សថ្ងៃថ្នូរ សំខាន់សម្លាប់ ហើយទុកដីឲ្យពីណាគេ ។

អាហ្នឹងខ្ញុំពិចារណាហើយលោក! ជួយពិចារណាទាំងអស់គ្នា មើលក្រែងដូចខ្ញុំដែរ ក្រែងខ្ញុំគិតឃើញនេះវាខុសអីត្រូវ ។

គិតអ៊ីចឹងទៅដូចឆ្អែតចិត្ត ហើយដល់វាសំខាន់ទៅទៀតថា ចាញ់តែបោកគេ ។ ចាញ់បោកម៉េចបងស្រីខ្ញុំហ្នឹង ខ្ញុំពិចារណាអ៊ីចឹង ។ ចាញ់បោកគេម៉េច? គេមកបង្រៀនគាត់កាលមនោគមន៍កុម្មុយនីស្តហ្នឹង ខ្ញុំនិយាយអ៊ីចឹងចុះ អាហ្នឹងខ្ញុំពិចារណា ។ មុនខ្ញុំសួរស្វាមីខ្ញុំ ខ្ញុំថាការមិនទាន់-- កាលស្រុកកំពុងច្បាំង ខ្ញុំថាបងអានេះកុម្មុយនីស្តហ្នឹង អាហ្នឹងវារបៀបម៉េច? ខ្ញុំវាអត់យល់ ។ គាត់ថាអូនឯងកុំសួរ កុំចង់ដឹង កុំមាត់ អ៊ីចឹងក៏ខ្ញុំនៅស្ងៀម ។ ដល់ពេលខ្ញុំឆ្លងកាត់អ៊ីចឹងមកខ្ញុំយល់ ខ្ញុំយល់ថា អ៎! កុម្មុនីស្តគេធ្វើអ៊ីចឹងតើ! តែបងប្អូនឯងសម្លាប់តែបងប្អូនឯងអ៊ីចឹងន៎ ។

[១៥:១៦:១៤]

គិតទៅច្រណែនឈ្នានីសគ្នាអ៊ីចឹង យកមកទូលស្លែងធ្វើម៉េចឲ្យវាងាប់វេទនាទៅ ។ អញឡើងធ្វើធំហើយ អាហ្នឹងខ្ញុំពិចារណាឃើញតែគាត់ហ្នឹងចាញ់តែបោកគេ ។ បែបគាត់ថា វាយការណ៍សម្លាប់ប្អូនថ្លៃឯង-- ហើយរស់ដោយសារប្អូនឯងសោះហ្នឹង! ហើយកូនគាត់ខ្ញុំយកមកចិញ្ចឹមដល់ឥឡូវលោកប្រធានយកមកធ្វើអង្គការកូនខ្ញុំទៀត ។ ហើយខ្ញុំធ្វើត្រែកចិនជូនបងស្រីខ្ញុំហ្នឹងទៀត ។ ខ្ញុំនឹកឃើញថា គាត់លទ្ធភាពដល់ពេលនោះ ខ្ញុំនិយាយទៀតទៅទាន់នឹកឃើញលោកថា ឲ្យខ្ញុំនិយាយទួលស្លែង ប៉ុន្តែសូមទោសអាហ្នឹងវាទាក់ទងទួលស្លែង ទាក់ទងស្រីមេម៉ាយ ទាក់ទងចិត្តយើងពិតប្រាកដ ។ មនុស្សវារស់នៅហ្នឹងចិត្តនឹងធំជាងគេ ។ ខ្ញុំទៅសន្និសីទហ្នឹង គាត់សុំសម្ភាសន៍ខ្ញុំអាកាសែតសាំងហ្គាពួរ ។ គាត់សួរថា ចុះរាល់ថ្ងៃអ្នកឯងខឹងបងស្រីអ្នកឯងទេ? ខ្ញុំថា ខ្ញុំអត់ខឹង ខ្ញុំឈប់ខឹង ។ ស្រាប់គាត់ខឹងជួសខ្ញុំ គាត់ថា អ្នកឯងហេតុម៉េចបានមិនខឹង ខ្ញុំខឹងជួសអ្នកឯង! អាហ្នឹងមិនក្រៅផ្លូវការទេណាលោក! អាហ្នឹងជាសាច់រឿងពិតមួយដែរ ។ អាហ្នឹងជារឿងមនុស្សលោក ធម៌លោកិយៈគឺអ៊ីចឹង គេខឹងជួសអ៊ីចឹងហើយធម៌លោកិយៈ ដែលវាខឹងត្រូវតែឈឺចាប់ជួសគេហើយ វាអយុត្តិធម៌អ៊ីចឹង ។

ខ្ញុំថា ហេតុបានជាខ្ញុំអត់ខឹង ហ្នឹងឥឡូវសម្លាប់ចិត្តបាន បានខ្ញុំរស់ឃើញមុខបងប្អូនទាំងអស់គ្នាហ្នឹង ។ មកពីខ្ញុំស្តាប់ធម៌ទៅឃើញថា គាត់ធ្វើអំពើហ្នឹង ដែលគាត់គិតកាលពេលគាត់ធ្វើ គាត់ថាសម្លាប់ប្អូនថ្លៃហ្នឹងទៅគាត់បានបុណ្យស័ក្តិនោះពីមនោគមន៍ដែលគេបង្រៀនគាត់អើយ! ដែលពេលបិទផ្លូវនោះខ្ញុំពិចារណាទេអាហ្នឹងនោះ ។ ដឹងអាណាមុខម៉េចទេ? ប៉ុន្តែខ្ញុំបានស្តាប់វ៉ាដ្យូអីឮទេ ។ គាត់ចង់ផ្តាប់ផ្គន់ចៅហ្វាយគាត់ហើយ បានគាត់ចង់-- សុំខមាលទោសដូចខ្ញុំនិយាយមួយម៉ាត់មុនអ៊ីចឹងខ្ញុំថា ឲ្យអស់

ចិត្តគាត់ ។ ខ្ញុំថា ឲ្យគាត់ហ្នឹងមុខហើយ អាពេលដែលគាត់រាយការណ៍ហើយ ខ្ញុំថាចែឯង បែបចង់ធ្វើប្រពន្ធលោក ប៉ុល ពល ហើយយ៉ាង? ខ្ញុំថាឲ្យអស់ចិត្តខ្ញុំពេលនុ៎ង ខ្ញុំថាមុខគាត់ គាត់អត់ប៊ានមាត់ដែរ ។

[១៥:១៧:៥៧]

ហើយដល់បន្ទាប់មកហ្នឹង បានខ្ញុំថា ចេះតែពិចារណាទៅថា ចុះកើតមនុស្សអីក៏អាក្រក់ម្ល៉េះ ។ ខ្ញុំឆ្អែតចិត្តហើយ ខ្ញុំជម្រាបលោកឲ្យគ្រង់ទាំងអស់គ្នាចុះ ។ ខ្ញុំឃើញមុខមនុស្សខ្ញុំស្អប់តែម្ដងមិនដឹងជាឆ្កួតអីជាទេខ្ញុំ ។ ទៅស្ដាប់ធម៌អីអ៊ីចឹង ខ្ញុំរស់បានដោយសារស្ដាប់ធម៌យល់ បានខ្ញុំថាខ្ញុំលែង-- ខ្ញុំៗនិយាយអំមិញវាដាច់មួយកំណាត់ ដែងខ្ញុំថាសម្ភាសន៍ជាមួយកាសែត ។

លោកកាសែតថា អ្នកឯងអត់ខឹង ខ្ញុំខឹងជួសអ្នកឯង ហេតុអីបានជាខ្ញុំអត់ខឹង ខ្ញុំមកពីលើរដ្ឋាភិបាលប្រកាសថា ឲ្យៗបង្រួបបង្រួមជាតិហើយ-- គ្រាន់ប៉ុណ្ណឹងភ្លេចទៀតហើយ ។ ឲ្យបង្រួបបង្រួមជាតិ ឲ្យរកយុត្តិធម៌ឲ្យជនរងគ្រោះ តែខ្ញុំចង់មើលដែរ រកយុត្តិធម៌ជនរងគ្រោះនុ៎ង តើរកបានប៉ុន្មានទៅ? តើបានប៉ុនណាទៅដែលដល់ជនរងគ្រោះ ហើយខ្ញុំមានសេចក្ដីត្រេកដែរ ដោយសាររដ្ឋាភិបាលជាតិ និងអន្តរជាតិ និងអង្គការសហប្រជាជាតិគាត់ចេះមើលខុសត្រូវ ជួយរកយុត្តិធម៌ជួយជនរងគ្រោះហ្នឹងគឺ ល្អណាស់ ហើយពិតតែរកយុត្តិធម៌ឲ្យ ខ្ញុំពេញចិត្ត ។

[១៥:១៩:០៩]

ខ្ញុំអាចៗធូរស្រាលចិត្តខ្ញុំបានមួយៗចំនួនហើយ មួយមុខហើយ ប៉ុន្តែខ្ញុំចាំមើលដែរ តើពិតឬអត់? ព្រោះខ្ញុំមិនទម្លាប់និយាយភូតគេ មិនទម្លាប់និយាយបង្កាច់បង្ខូចគេមួយជាតិនេះ ខ្ញុំមិនមែនអួតទេ គឺខ្ញុំទម្លាប់អ៊ីចឹង ។ ហើយដែលឮអ្នកនិយាយបង្កាច់បង្ខូច ខ្ញុំឮបងខ្ញុំបង្កាច់បង្ខូចប្ដីខ្ញុំហ្នឹង ខ្ញុំខឹងណាស់! ពេលនោះខ្ញុំខឹងតែដល់ឥឡូវខ្ញុំស្ដាប់ថា បង្រួបបង្រួមជាតិ ខ្ញុំគិតថា ខ្ញុំស្ដាប់ធម៌យូរ អ៎!គាត់ធ្វើយកគាត់ទេ ដូចពាក្យពុទ្ធដិកាព្រះថា “ដាំៗម្ទេសបានម្ទេសហិល ដាំរបស់ផ្អែមអំពៅវាបានអំពៅផ្អែម ដាំស្ដៅល្វីងវាបានផលស្ដៅល្វីង” ដល់អ៊ីចឹង ខ្ញុំពិចារណាទៅទៅ អ៎! អ៊ីចឹងកុំខឹងគាត់អីគាត់ធ្វើយករបស់គាត់ទេ ។ ចេះកាត់ចិត្តបានប៉ុណ្ណឹងលោកប្រធាន បានប៉ុណ្ណឹងបានរស់ បានឃើញមុខប្រធាន បានមកអង្គុយនៅទីនេះហ្នឹងរកយុត្តិធម៌ឲ្យប្ដី ឲ្យបងៗប្អូនសាច់ញាតិ សុទ្ធតែបងប្អូនសាច់ញាតិយើងទេ! មួយប្រទេសកម្ពុជាហ្នឹងពូជដទៃក៏ដោយអាហ្នឹងធម៌ព្រះពុទ្ធលោកថា សុទ្ធតែបងប្អូនសាច់ញាតិ សាច់ញាតិធ្លាប់កើតគ្រប់ជាតិទាំងអស់ ទៅជាស្អីៗព្រះពុទ្ធក៏ធ្លាប់កើតអ៊ីចឹងដែរ ។ ហ្នឹងមិនមែនវែងទេ លោកប្រធានសុំទោស អាហ្នឹងជាធម៌ពិតប្រាកដរបស់មនុស្ស ។

យើងធ្លាប់កើតគ្រប់ ព្រះពុទ្ធមុននឹង ត្រាសដឹងជាព្រះពុទ្ធលោកធ្លាប់កើតគ្រប់សព្វជាស្អីៗសព្វគ្រប់ ។ តែលោកឃើញថា ឃើញចាស់ ជរា ព្យាធិ ហ្នឹង ហើយយើងហ្នឹងយើងពិចារណាអ៊ីចេះ យើងពិចារណាថា ខ្ញុំចង់ប្រាប់លោក ឌុច ដែរ ខ្ញុំអាណិតគាត់ដែរទេតើ ដល់អ៊ីចឹងខ្ញុំអាណិតគាត់ណាស់ខ្ញុំមិននេះទេ ។ ប៉ុន្តែ ខ្ញុំមិនប៊ានថាពាក្យផ្សេងព្រោះ គេនៅធម៌លោកិយ គេខឹងខ្ញុំហើយថាខ្ញុំកាន់ជើងគាត់ ខ្ញុំមិនមែនកាន់ជើងទេ ។ ខ្ញុំពិចារណាឃើញថា ដូចអាណិតគាត់ដែរមកពីគាត់ហ្នឹង គាត់ថាគាត់ធ្វើអ៊ីចឹងទៅវាបានប្រយោជន៍របស់គាត់ទេ បានគាត់ធ្វើ ហើយខ្ញុំៗយល់ឃើញថា បងខ្ញុំគាត់វាយការណ៍បង្កាច់បង្ខូចប្តីខ្ញុំគាត់បានប្រយោជន៍គាត់ហើយ ប្រហែលគាត់ល្ងង់អ៊ីចឹង ។ គាត់បានរបស់គាត់ហើយ ខ្ញុំកុំខឹងគាត់អីខ្ញុំតាំងចិត្តអ៊ីចឹងបានខ្ញុំបានស្ងប់ បន្តិចកុំអីមិនបានទេ ងាប់ហើយអាភ្លើងចិត្តហ្នឹងមិនបានតែម្តង ។

ចិត្តហ្នឹងមិនងាយអប់រំវាទេ មិនងាយពត់វាទេ ហើយបើយើងពត់ចិត្តបានអាហ្នឹងយើងបានស្ងប់ គេធ្វើយករបស់គេ ទៅខឹងគេធ្វើអី ។ ព្រះពុទ្ធលោកចេះថាអ៊ីចឹង គេធ្វើរបស់គេ ពន្យល់រាល់ថ្ងៃបានរៀនស្តាប់ហ្នឹង ។

ហើយនៅទួលស្លែងហ្នឹងវាថា ខឹង បើថាឈឺចាប់ណាលោកឲ្យខ្ញុំនិយាយវាឈឺចាប់អស់ហើយវាទៅសន្ធប់ វាទៅស្អី ដូចជាលោកស្រី បារាំង មើលប្តីជនជាតិខ្មែរ គាត់ជនជាតិបារាំងសោះហេតុម៉េចគាត់ឈឺចាប់ប៉ុនណា ហើយកូនស្រីគាត់ ទើបអាយុ១៦ មើលគាត់ថ្លែងការណ៍មើល ខ្ញុំឈឺចាប់ដូចអ្នកទាំងអស់នោះអ៊ីចឹង ។ ហើយដូចជនជាតិអង់គ្លេសដែរ ដែលមេធាវីគាត់តែងតែសួរ មេធាវីអន្តរជាតិតែងតែសួរថា មានអើនៅទួលស្លែងមានឃើញអ្នកទោសសក់ក្រហមទេ? ដល់ខ្ញុំស្តាប់ចុងក្រោយ ខ្ញុំយល់ថា អូ! សួររកបរទេសហើយ អាសក់ក្រហមហ្នឹង គឺអ្នកដែលបារាំង ទូកក្តោងនោះ ជនជាតិអង់គ្លេសមើលគាត់គ្រាន់ត្រឹមបងគាត់ផង គាត់ឈឺចាប់ដល់ប៉ុណ្ណឹង បងគាត់ស្លាប់សោះ ។

ចុះទម្រាំប្តីខ្ញុំ ហើយខ្ញុំចិញ្ចឹមកូនខ្លួនឯងៗ ខ្ញុំត្រូវធ្វើអីឲ្យកូនខ្ញុំរស់ ខ្ញុំមានភារកិច្ចធ្វើអីខ្លះបានៗកូនខ្ញុំរស់? លោកពិចារណាមើលទាំងអស់គ្នា ជីវិតជួបទាំងអស់គ្នា? ឥឡូវលោកថា ឲ្យខ្ញុំនិយាយពីទួលស្លែង ខ្ញុំណាវាទុក្ខព្រួយ ដូចថាគេនិយាយមកហើយអស់ហើយវា ឈឺចាប់រលួយរលេះ វាអស់លែងមក ។ តែខ្ញុំយល់ថា វែងអស់លេខទៅដូចគ្នាទៅវាអស់ពេល ។ តែក៏ខ្ញុំសូម ថាទុក្ខព្រួយហ្នឹងគឺទុក្ខព្រួយដូចគ្នាអ៊ីចឹង ។ តែឥឡូវ ដើម្បីតបស្នងសងតែទុក្ខវេទនារបស់ខ្ញុំនឹងតើឲ្យសិទ្ធិខ្ញុំ ឲ្យខ្ញុំបានឃើញការពិតហ្នឹងរបៀបណា? យុត្តិធម៌ឃើញពិតហ្នឹងរបៀបណាខ្លះ? ទ្រព្យសម្បត្តិខ្ញុំអស់ រលីងមិនប៊ានស៊ីមិនប៊ានចាយ ខំសន្សំទិញផ្ទះនៅខំចិញ្ចឹមកូន មានគ្រួសារធ្វើការស្នេហាជាតិឲ្យជាតិរុងរឿង។ ដល់ទី

បំផុតគេយកយើងយកទៅឲ្យជាប់ទោស ស្អីមន្ទីរ១៥ គេនោះ វាហួសហេតុទៅណ៎ា ហើយបើនិយាយទុក្ខវិញនោះ លោកៗ ទុក្ខប៉ុនណាគឺថាទុក្ខនោះមិនដឹងយកអីមកនិយាយបានទេ តែខ្ញុំដូចជាគោកស្លុកហើយ ។ មកដល់ហ្នឹងគោកស្លុកអ៊ីចឹងទេ លោកទៅផ្ទះវិញ តែឮគេផ្សាយព័ត៌មានដល់ រឿងហ្នឹងយំតែម្នាក់ឯង ភ្នែកហ្នឹងងងឹតហើយស្ងួតទឹកភ្នែកហើយ ឥឡូវរកតែលុយទិញថ្នាំដាក់ភ្នែកមិនបានទៀតផង ។ ប្រាក់ខែខ្ញុំរាល់ថ្ងៃ ប្រាក់រ៉ៃត្រែតខ្ញុំ ខ្ញុំមិនបាច់និយាយទេរឿងហ្នឹង ។ ខ្ញុំថាស្លាប់ពេលណាពេលហ្នឹងទៅ ។

ហើយពីរឿងទួលស្លែងហ្នឹង ខ្ញុំហ្នឹងវាបានឃើញអ៊ីចឹងហ្នឹងវាមិនដឹងនិយាយថាម៉េចទៀតលោក លោកពិចារណាមើល មនុស្សមានគុណធម៌ល្អ មនុស្សមានសីលធម៌ល្អ ខំធ្វើមនុស្សល្អយកមកជួយជាតិស្នេហាជាតិ ឲ្យគេរស់ទាំងអស់គ្នា ផ្លូវយ៉ាងម៉េច អីយ៉ាងម៉េច ហើយស្លូតត្រង់សោះអត់ មានធ្វើជាប់ទាក់ទងនឹងនយោបាយអីសោះ ហេតុម៉េចក៏គេយកមនុស្សទៅសម្លាប់ដោយព្រៃផ្សៃថោកទាបរបៀបហ្នឹង? សូមលោកពិចារណាមើលទាំងអស់គ្នាមើល ។ តើយកអីមកសងឲ្យស្មើនឹងសេចក្ដីអាក្រក់របស់របបហ្នឹង ឲ្យគេអស់ចិត្ត ឲ្យបានគេធូរស្រាលចិត្ត ។

បើនិយាយអំពីស្ត្រីមេម៉ាយលោក ក៏វាច្រើនបែបដែរអត់ដូចគ្នាទេ ។ ស្ត្រីមេម៉ាយវាច្រើនបែបទៅទៀតរាប់ទៅវាវែងឆ្ងាយ អាស្ត្រីមេម៉ាយ ម្យ៉ាងមាយាទវាមិនកើតចាស់លោកថា មកឲ្យប្ដីលែង ។ ស្ត្រីមេម៉ាយម្យ៉ាងនោះមាយាទវាមិនកើត ទៅលេងបៀរ លេងប៉ោរ អាស្ត្រីមេម៉ាយម្យ៉ាងវាច្រើនបែប ។ អាស្ត្រីមេម៉ាយខ្ញុំ ស្នេហាជាតិហើយខំ ប្រឹងមើលប្ដីទៀត ខំប្រឹងមើលស្វាមីឲ្យបានរស់ហើយ យកអាយុជីវិតហ្នឹងបំរើជាតិទាំងអស់គ្នា បំណាច់ថាកើតមកជាមនុស្ស ។ ហេតុម៉េចក៏ទៅស្លាប់របៀបហ្នឹងលោកពិចារណាឲ្យខ្ញុំផង ។

**ប្រធានអង្គជំនុំ៖**

ឥឡូវមានប្រសាសន៍តែត្រឹមហ្នឹងបានហើយ ហើយចាំស្ដាប់នូវការចង់ដឹងរបស់ពីភាគីផ្សេងៗទៀតអំពីរឿងរ៉ាវរបស់លោកស្រីដែលពាក់ព័ន្ធនឹងការស្លាប់ប្ដីរបស់លោកស្រីនេះថាតើវាមានអ្វីខ្លះទៀត?

អ៊ីចឹង អង្គជំនុំជម្រះប្រគល់វេទិកាទៅមេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ហើយប្រសិនបើមានសំណួរអ្វីគឺអាចសួរបញ្ជាក់បាន ដើម្បីភ្ជាប់ទៅនឹងការគាំទ្រនៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់គាត់ក្នុងរឿងក្ដីនេះ ។ ហើយអង្គជំនុំជម្រះសូមរំឭកដល់មេធាវី តំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីសូមរៀបចំនូវសំណួរងាយៗដើម្បីឲ្យគាត់បាន កូនក្ដីបានយល់ ហើយនិងធ្វើការឆ្លើយតបនឹងឲ្យបានចំបញ្ហា ។

[១៥:២៦:៣៣]

**ការតាំងសំណួរដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី៖**

**សួរដោយលោក គង់ ពិសី៖**

**ស៖** សូមអរគុណលោកប្រធាន ចំពោះការណែនាំ ហើយចំពោះការអនុញ្ញាតឲ្យខ្ញុំបាទបានសួរ លោកស្រី ឈិន ណារី ហើយក៏ខ្ញុំបាទសូមគោរព លោក លោកស្រីថៅក្រមជាតិ អន្តរជាតិទាំងអស់ ។ លោកស្រី ឈិន ណារី ខ្ញុំអាចសួរបានទេ?

**ឆ៖** ចាស, សួរចុះលោក ។

**ស៖** ឥឡូវនេះ ខ្ញុំចង់សូមសួរលោកស្រី ឈិន ណារី ថាលោកស្រីកើតនៅឆ្នាំណា?

**ឆ៖** ខ្ញុំកើតនៅឆ្នាំ១៩៣៩ ។

**ស៖** សូមអរគុណ ។ លោកស្រីអាចបញ្ជាក់បានទេ នៅក្នុងអត្តសញ្ញាណប័ណ្ណរបស់លោក ស្រី គេដាក់ថា លោកស្រីកើតនៅឆ្នាំ១៩៤៦ ហេតុអ្វីបានជាខុសគ្នានៅចម្លើយពីរនេះ?

**ឆ៖** បានជាខុសគ្នា ខ្ញុំតាំងពីធ្វើហើយមកខ្ញុំក៏មិនបានផ្ទៀងផ្ទាត់ដែរ ប៉ុន្តែខ្ញុំនឹកគិតទៅពេលនោះ បានជាខុសនោះមកពីអាកាតនេះ ទើបធ្វើក្រោយទេ ពេលបោះឆ្នោត ហើយនគរបាលសង្កាត់ធ្វើឲ្យគេ ដាក់អាយុអ៊ីចឹងទៅ ខ្ញុំពិចារណាទៅ ខ្ញុំមិនចេះភូតគេទេ ខ្ញុំនឹកឃើញថាប្រហែលជាពេលរីត្រៃតខ្ញុំនៅមាន កម្លាំងចង់បំរើការព្រោះអីកាលគេប្រកាសរីត្រៃតដែលជួរដំបូងបំផុតចូលពី១៩៧៩ គឺអាយុ៥០ រីត្រៃត។ ដល់ពេលអ៊ីចឹង ខ្ញុំនៅមានកម្លាំងធ្វើការដែរប្រហែលជាខ្ញុំដាក់អាយុកាតហ្នឹងដើម្បីឲ្យនៅបម្រើការថែម ប្រាំឆ្នាំទៀតហើយ បានកាតហ្នឹងវាអ៊ីចឹងទៅវាប្លែកពីសំបុត្រកំណើតខ្ញុំណា ។ ហ្នឹងនគរបាលគេធ្វើឲ្យ ពេលបោះឆ្នោត ។

**ស៖** សូមអរគុណលោកស្រី ។ អ៊ីចឹង អាយុលោកស្រីពិតប្រាកដ លោកស្រីកើតនៅឆ្នាំ១៩៣៩ អ៊ីចឹងមែនទេ?

**ឆ៖** ចាស ។

**ស៖** ខ្ញុំសូមសួរសំណួរតទៅទៀត ទាក់ទងទៅនឹងលោកស្រីបានជម្រាបអង្គសវនាការហើយថា លោកស្រីបានឃើញព័ត៌មានទាក់ទងទៅនឹងការស្លាប់របស់ប្តីរបស់លោកស្រីហ្នឹងដែលឈ្មោះ ទៀ ហាវ តឹក ហ្នឹង នៅឯមន្ទីរស-២១ ។ អ៊ីចឹងសួរថា តើលោកស្រីបានឃើញ ដឹងព័ត៌មានហ្នឹងនៅឆ្នាំណា?

[១៥:៣០:១៥]

**ឆ៖** ព័ត៌មានហ្នឹងប្រហែលជាឆ្នាំ១៩៨០ ហើយពីព្រោះអីមន្ទីរពេទ្យទាំងមូលនាំទៅមើលមួយមន្ទីរពេទ្យ ។

**ស៖** សូមអរគុណ ។ សំណួរតទៅទៀត នៅពេលដែលអ្នកស្រីឃើញព័ត៌មានហ្នឹងដឹងថា ប្តីលោកស្រីត្រូវបានគេសម្លាប់នៅឯទួលស្លែងនោះហើយ តើលោកស្រីមានអារម្មណ៍យ៉ាងម៉េចដែរបាទ?

**ឆ៖** ពេលដែលខ្ញុំទៅមើលទួលស្លែងហើយឃើញ ដឹងថា ប្តីខ្ញុំសម្លាប់នៅទួលស្លែងដោយធ្វើទារុណកម្មទៀត ធ្វើទារុណកម្មដោយគ្មានអ្វីប្រៀបបានអត់អ្វីដូច ខ្ញុំស្កុតងងឹតមុខទួញយំនៅទីនោះឡើងគេមករោមខ្ញុំ មើលខ្ញុំ ហើយខ្ញុំមិនដឹងជារកអ្វីមកប្រៀបបានឡើយ ខ្ញុំគិតថា ខ្ញុំពីថ្ងៃនេះតទៅខ្ញុំដើរតួម្នាក់ឯងហើយ ។ ខ្ញុំឈឺចាប់ណាស់ គេសម្លាប់ប្តីខ្ញុំរបៀបនេះ ។ ប្តីខ្ញុំជាមនុស្សល្អ ជាមនុស្សមានអាកប្បកិរិ-យាស្លូតបូត សុភាពរាបសា ថ្លៃថ្នូរ អត់មានធ្វើអីខុសសោះ យកមកសម្លាប់ប្តីខ្ញុំដោយព្រៃផ្សៃហើយក៏បានដឹងទៀតថា មុននឹងគេសម្លាប់នឹងគេមួលបង្កាច់ វ៉ៃធ្វើទារុណកម្មឲ្យឆ្លើយតាមគេ ឲ្យទទួលតាមគេថាជា *សេអ៊ីអា*មែន ។ ប៉ុន្តែឯកសារនោះខ្ញុំមិនបានទៅរកកើតទេ ដល់ខ្ញុំក្នុងចិត្តគំនិតរបស់ខ្ញុំ កាយខ្ញុំនឹងវាចង់សន្លប់ហើយខ្ញុំគ្រាន់តែក្រឡេកមើលគេ មើលមិនឃើញផងហ្នឹង ។ មកទល់សព្វថ្ងៃខ្ញុំឃើញទួលស្លែងបន្ទប់នឹងខ្ញុំធុំក្លិនអត់បានទេ ខ្ញុំសន្លប់ហើយ ។ សព្វថ្ងៃខ្ញុំរោគា ព្យាធិក្នុងខ្លួនហ្នឹងវាពោរពេញហើយមិនដឹងនិយាយយ៉ាងម៉េចទេ ។ ខ្ញុំផឹកថ្នាំជាប់ ខ្ញុំនិយាយទៅថាខ្ញុំត្អូញ មិនមែនទេ ខ្ញុំមិនមាត់មួយម៉ាត់ទេជីវភាពខ្ញុំដែលជាស្ត្រីមេម៉ាយ ដែលពេលគាត់ឃើញគាត់ស្លាប់អ៊ីចឹងហើយខ្ញុំអស់សង្ឃឹមក្នុងជីវិត ខ្ញុំត្រូវចិញ្ចឹមកូន ខ្ញុំខំចិញ្ចឹមកូនឲ្យកើតជាមនុស្សម្នានឹងគេដូចជាប្តីនៅអ៊ីចឹងព្រោះខ្ញុំត្រូវការឲ្យកូនខ្ញុំមានការចេះដឹងមានក្រសួងមន្ទីរដូចមនុស្សម្នាទូទៅដូចជំនាន់ខ្ញុំអ៊ីចឹង ឪពុកខ្ញុំចិញ្ចឹមខ្ញុំមកអ៊ីចឹង ។ ដូច្នោះ ខ្ញុំត្រូវធ្វើអីខ្លះស្ត្រីម៉េម៉ាយ ទាក់ទងនឹងទួលស្លែងហ្នឹង ។ សម័យឃើញជានិច្ចមកទល់បច្ចុប្បន្នកន្លែងធ្វើទារុណកម្មកន្លែងឯកសារអីគឺថាជាកញ្ចក់ឆ្លុះនៅក្នុងវិញ្ញាណខ្ញុំ ក្នុងភ្នែកខ្ញុំជាប់ជានិច្ចពេលណាស្ងាត់អ៊ីចឹងចួនកាលខ្ញុំនៅម្នាក់ឯង កូនខ្ញុំចេញទៅអស់ ខ្ញុំយំម្នាក់ឯងអស់ចិត្តដល់គោកភ្នែកឡើងងងឹតអស់ហើយ តាំងទៅពេទ្យទិញថ្នាំភ្នែកដាក់ រកលុយទិញគ្មាន ។

[១៥:៣៣:៣២]

**លោក គង់ ពិសី៖**

បាទសូមអរគុណលោកស្រី ។ លោកប្រធានខ្ញុំបាទ សូមលោកប្រធានមេត្តាអនុញ្ញាតឲ្យបញ្ចាំងរូបថតប្តីលោកស្រីនៅក្នុងកញ្ចក់ទូរទស្សន៍បាទ ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការ យករូបថតដាក់បញ្ចាំងនៅម៉ាស៊ីនស្កាយដើម្បីបង្ហាញរូបភាពនៅលើអេក្រង់ទូរ-ទស្សន៍ ។

**សួរដោយលោក គង់ ពិសី៖**

**ស៖** លោកស្រីមើលទៅមើល ថាតើរូបនៅក្នុងកញ្ចក់ទូរទស្សន៍នេះជារូបអ្នកណា?

**ឆ៖** ជាស្វាមីរបស់ខ្ញុំ ឈិន ណារី ។ ហើយមើលមុខ មើលភ្នែកគាត់ គេធ្វើទារុណកម្មឡើងបែកអស់ហើយចិញ្ចើម ខ្ញុំឃើញភ្លាម ខ្ញុំសន្លប់ ។ មុខប្លែកអស់ហើយ បើមើលខ្ញុំនៅសល់រូបកាតគាត់មួយ ឃើញខុសគ្នាយ៉ាងណា ។

**ស៖** សូមអរគុណលោកស្រី ។ តើរូបថតនេះសួរថាតើបានពីណាមកលោកស្រី?

**ឆ៖** រូបថតនេះខ្ញុំបានមកពីទួលស្លែង ពីគុកទួលស្លែងមន្ទីរស-២១ ហើយទាំងលោកឃើញមើលឃើញទាំងបញ្ជីចាប់ចូលថ្ងៃចាប់ចូល ហើយនិងថ្ងៃកម្ទេចទៀត ហើយយកមកឲ្យខ្ញុំនេះប្រធានទួលស្លែងទៀត ។ ហើយអ្នកជំងឺខ្ញុំគាត់ប្រូហ្វេស៊ឺរ គាត់ធ្វើការយកអង្គរហូបគាត់ធ្វើការអ្នកស្រាវជ្រាវរូបថតរូបអីបញ្ជីទួលស្លែងម្តង ។

**លោក គង់ ពិសី៖**

សូមអរគុណ ។ ខ្ញុំបាទ សូមអនុញ្ញាតពីលោកប្រធាន ដើម្បីសុំដាក់បញ្ចាំងឯកសារដែលមានលេខ ERN 00080640 ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីខាងសោតទស្សន៍ ដាក់បង្ហាញឯកសារដែលមានលេខ ERN 00080640 នៅលើកញ្ចក់អេក្រង់ទូរទស្សន៍ ។

**សួរដោយលោក គង់ ពិសី៖**

**ស៖** ឯកសារនេះគឺជាឯកសារបញ្ជីឈ្មោះជនរងគ្រោះ ដែលបានកម្ទេចនៅមន្ទីរស-២១ ដែលជាឯកសារបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយបើរាប់ពីលើមក គឺជាបន្ទាត់ទី១៥ ។ នៅបន្ទាត់ទី១៥នេះ គឺមាន-- លោកស្រីអាចអានបានទេ ថាតើឈ្មោះអក្សរហ្នឹង គឺជាប្តីរបស់លោកស្រី ឬមួយយ៉ាងម៉េច?

**ឆ៖** ចាស, នៅលើបន្ទាត់ហ្នឹង គឺជាឈ្មោះរបស់ស្វាមីខ្ញុំពិតប្រាកដមែនហើយ ទៀ ហាវតឹក យកមកពីតំបន់២៥ ។ ខ្ញុំមិនបានពាក់វ៉ែនតា មើលអក្សរតូចៗទេ ។ យកមកពីតំបន់២៥ ថ្ងៃចាប់ចូលថ្ងៃ ០២ ខែ០២, ៧៦ កម្ទេចថ្ងៃ២៥ ខែ០៥, ៧៦ ពិតជាៗឈ្មោះប្ដីខ្ញុំពិតប្រាកដមែន ។

[១៥:៣៨:២៣]

**លោក គង់ ពិសី៖**

បាទ សូមអរគុណលោកស្រី ។ លោកប្រធានអាចដកបានហើយឯកសារនេះ ចេញពីអេក្រង់ទូរទស្សន៍ ហើយខ្ញុំបាទសូមតាំងសំណួរបន្តទៅទៀត ។

**ស៖** សូមលោកស្រីរៀបរាប់យ៉ាង-- និយាយយ៉ាងខ្លីបានហើយ ថាតើជីវិតដែលជាស្ត្រីមេម៉ាយហ្នឹងដែលគ្មានអ្នកណាជួយការពារ ឬមួយក៏ជួយគាំទ្រអ្វីអីហ្នឹង ហ្នឹងតើមានការលំបាកប្រហែលយ៉ាងណាដែរ? បាទ សូមមេត្តាកុំវែងពេក ។ សូមអរគុណ ។

**ឆ៖** ខ្ញុំជាស្ត្រីមេម៉ាយ ដោយអត់ពីប្ដីទៅខ្ញុំតាំងជំហរមួយចេញពីស្រុកមកហ្នឹងគឺ ត្រូវរកតម្រិះវិជ្ជាឲ្យកូន ហើយរកក្រសួងមន្ទីរឲ្យកូន ឲ្យដូចជាមនុស្សម្នាធម្មតាដូចគេ បានត្រឹមម៉ានត្រឹមហ្នឹងទៅហើយខ្ញុំចេញមកហ្នឹង គឺខ្ញុំបានក្រសួងមន្ទីរហ្នឹងខ្ញុំរកទីជម្រកឲ្យកូនខ្ញុំនៅក៏ពេលដែលមេម៉ាយហ្នឹង គឺអស់រលីងហើយនៅសល់តែរូបកាតប្ដីមួយសន្លឹកទេ អត់មានសល់អីទេ ឆ្នាំងចានអីគឺអត់មានទេ គឺមានតែម្រាមដៃដប់ត្រឡប់មកវិញចិញ្ចឹមកូនបី ។ តើភ័យព្រួយយ៉ាងណាគេនាំគេហៅទៅទូលអាម្សៅដេដេតេទេព្គាហើយដែលទៅស្គាល់អី ភ័យខ្លាចចិញ្ចឹមកូនមិនរស់ គេគរនៅវត្តលង្កា អ្នកជិតខាងគេថា គេទៅយកដេដេតេ ហ្នឹងការពិតខ្ញុំនិយាយនេះ ខ្ញុំទៅជាមួយនឹងគេប្រទាញប្រទង់ម៉េចហ្វូរម៉េចទេ ពុលអាហ្នឹងទៅដួលទៅហ្នឹងយកម្សៅដេដេតេ មកទុកលក់ឲ្យអេតចាយ ចូលមក៧៩ហ្នឹង ។

ហើយវាទទួលក្នុងផ្ទះហ្នឹងមានអាគេទុកគ្រាប់ស្លែងនៅហ្នឹងទៀត គ្រាប់ស្លែងនឹងបាវហ្នឹងទទួលគេមកទិញអាអេតចាយគ្រាប់ស្លែងហ្នឹងខ្ញុំអុំអាអេតចាយ-- អុំអាគ្រាប់ស្លែងហ្នឹងលក់អេតចាយឲ្យគេចិញ្ចឹមកូន គេមិនទាន់ចាយលុយទេ អង្កាល់ហ្នឹងគេចាយលុយយួន ហើយគេបើកអង្ករឲ្យ ។

សូមបងប្អូន សូមលោកប្រធានគិតមើល អត់មានចានមួយ អត់មានឆ្នាំងមួយ អ្វីក៏អត់ដែរ មានតែម្រាមដៃដប់នាំកូនមករកក្រសួងមន្ទីរ រកសម្បុកឲ្យកូននៅដូចចាបអីចឹង ។ ដើរត្បួគ្រប់សព្វអស់ហើយសូមបងប្អូនរួមជាតិនិងអន្តរជាតិលោកជួយពិចារណាមើល នូវជីវិតពិតរបស់ខ្ញុំ ។ ស្ត្រីមេម៉ាយវាមានខុសគ្នា ស្រុកគេល្អទៅ គេរស់នៅបានស្រួល ស្រុកខ្ញុំងើបមកពីគេសម្លាប់ប្ដី គេយកទ្រព្យសម្បត្តិអស់

ហើយ តើខ្ញុំនៅសល់អីខំប្រឹងតស៊ូចិញ្ចឹមកូនខ្ញុំទាំងបីឲ្យមានក្រសួងមានមន្ទីរនឹងគេ បំណាច់នឹងកើតមកជាមនុស្សចិត្តខ្ញុំយល់ឃើញយ៉ាងហ្នឹង ខំធ្វើមនុស្សឲ្យអស់លទ្ធភាព ។

[១៥:៤១:៥១]

**ស៖** សូមអរគុណលោកស្រី ។ ឥឡូវលោកស្រី ខ្ញុំសូមសួរតទៅទៀត ប៉ុន្តែលោកស្រីមេត្តាឆ្លើយឲ្យខ្លីបំផុតទៅបានហើយ ។ ទាក់ទងទៅនឹងបញ្ហាមួយទៀតថា តើលោកស្រីមានបានអញ្ជើញទៅពេទ្យព្យាបាលរោគចិត្តទេ ដែលគេហៅថា *ធីភីអូ* នោះ គ្រាន់តែថា បើបានទៅ ថាបានទៅ?

**ឆ៖** ចាស, បានទៅដែរ ។

**ស៖** សូមអរគុណ ។ ចុះហេតុអ្វីបានជាលោកស្រីអញ្ជើញទៅជួបពេទ្យផ្លូវចិត្តហ្នឹង?

**ឆ៖** បានជាខ្ញុំទៅជួបពេទ្យផ្លូវចិត្តហ្នឹងមកពី មកគេចេះហៅខ្ញុំទៅប្រជុំមុនពេលធ្វើរៀបចំធ្វើសវនាការហ្នឹងគេថា មានពេទ្យ *ធីភីអូ* ហ្នឹង បើបងប្អូនណាមានជំងឺអ្វី មានអារម្មណ៍មិនល្អអីឲ្យទៅទាក់ទងនៅពេទ្យហ្នឹងទៅ ខ្ញុំក៏ទៅ ។

**លោក គង់ ពិសី៖**

សូមអរគុណ ហើយខ្ញុំអស់សំណួរសួរទៅអ្នកស្រី ឈិន ណារី ហើយក៏ប៉ុន្តែខ្ញុំមានសំណួរពីរសំណួរដើម្បីសួរទៅជនជាប់ចោទ លោកប្រធាន សូមលោកប្រធានមេត្តាអនុញ្ញាត ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញ ហើយសូមជនជាប់ចោទស្តាប់នូវសំណួរឲ្យបានច្បាស់ដើម្បីអាចឆ្លើយទៅនឹងសំណួរ ដែលសួរដោយមេធាវី ។ ហើយអង្គជំនុំជម្រះក៏រំឭកដែរថា សិទ្ធិនេះ សិទ្ធិមិនឆ្លើយតបគឺមានសម្រាប់ជនជាប់ចោទជាដរាប ប្រសិនបើជនជាប់ចោទមិនចង់ឆ្លើយ ។

**លោក គង់ ពិសី៖**

បាទ, សូមអរគុណ ។

សំណួរទីមួយ ដោយផ្អែកទៅលើការពិភាក្សាជាមួយលោកស្រី ឈិន ណារី គាត់ចង់សួរថាតើលោកជនជាប់ចោទហ្នឹង បានដឹងអំពីការចាប់ខ្លួន ហើយនិងការធ្វើទារុណកម្មរបស់លោក ទៀ ហាវតឹកហ្នឹងទេ នេះជាសំណួរទីមួយ ។

សំណួរទីពីរ សួរថាតើជនជាប់ចោទបានត្រៀមរៀបចំខ្លួនដើម្បីសងសំណងផ្នែកខាងជំងឺចិត្តផ្នែកខាងរដ្ឋប្បវេណីហ្នឹង ទៅដល់ខាងជនរងគ្រោះហើយឬនៅ? បាទ សូមអរគុណ ។

**ជនជាប់ចោទ៖**

សំណួរមានពីរ ទីមួយខ្ញុំសូមឆ្លើយនឹងសំណួរទីមួយសិន ខ្ញុំមិនចាំថាពេលដែលខ្ញុំនៅធ្វើជាប្រធាន ស-២១ ឬក៏តាំងពីអនុប្រធានម្ល៉េះ ខ្ញុំដឹងដំណឹងថា លោក ទៀ ហារតឹក ចូលទៅដល់ស-២១ អត់ចាំ នឹក មិនឃើញ ក៏ប៉ុន្តែខ្ញុំគ្រាន់តែសូមបញ្ជាក់ថា បណ្តឹងរដ្ឋប្បវេណីរបស់អ្នកស្រី ឈិន ណារី ជាបណ្តឹងរដ្ឋប្បវេណីដំបូងបំផុតមានបី បណ្តឹងរដ្ឋប្បវេណីទីមួយ គឺ ប៊ូ ម៉េង, ទីពីរ គឺ ជុំ ម៉ី, ទីបី គឺ ឈិន ណារី ។

[១៥:៤៥:២៧]

ខ្ញុំយកបណ្តឹងរដ្ឋប្បវេណីទាំងបីនេះមកពិនិត្យយូរដែរ ប៊ូ ម៉េង និង ជុំ ម៉ី ខ្ញុំមិនប្លែកទេ ព្រោះខ្ញុំធ្លាប់ស្គាល់ ជាពិសេស ប៊ូ ម៉េង ខ្ញុំធ្លាប់ស្គាល់ បើ ជុំ ម៉ី ខ្ញុំទទួលស្គាល់ក្រោយមក ដល់ចំណែកបណ្តឹងរដ្ឋប្បវេណីរបស់អ្នកស្រី ឈិន ណារី ខ្ញុំយកមកពិចារណាជាមួយនឹងបញ្ជីអ្នកទោសបញ្ជីចាស់ ដែលមាន ៣៩០ទំព័រនោះ ។ ដល់មកខ្ញុំឃើញ ឃើញបញ្ជីនោះភ្លាមខ្ញុំទទួលស្គាល់ភ្លាមថា លោក ទៀ ហារតឹក ពិតជាចូលទៅដល់ស-២១ រងគ្រោះនៅទីនុ៎ង ហើយក៏ស្លាប់បាត់បង់ជីវិតនៅទីនោះ ។ អ្ហឹះ! អត់ប្រកែកទេ ឃើញបញ្ជីហ្នឹងគឺបញ្ជីស-២១ ដែលការិយាល័យសហព្រះរាជអាជ្ញាធ្វើ ហើយឆ្លងតាមការិយាល័យសហចៅក្រមស៊ើបអង្កេតត្រឹមត្រូវ ។ ហើយបើមើលទៅបណ្តឹងរបស់អ្នកស្រី ជុំ ណារី អ៎ន៎េ! ឈិន ណារី នេះកាន់តែច្បាស់នៅក្នុងបញ្ជីស-២១ គ្រាន់តែបញ្ជាក់ថា ទៀ ហារតឹក ក្រសួងសាធារណការ ។

ឯចំណែកអ្នកស្រី ឈិន ណារី សរសេរប្តីរបស់អ្នកស្រីអគ្គនាយករងអាកាសចរណ៍ស៊ីវិល អ៊ូ ច្បាស់ប្រពន្ធ គេមែនហើយ ដឹងតាំងពីចូលទៅខែមាឃចិន ចូលទៅមន្ទីរ១៥ អី ខ្ញុំថា អ៊ូប្រពន្ធគេមែនទែនហើយ ខ្ញុំអត់ប្រកែកទេ ។

ដូច្នេះ សរុបមក ខ្ញុំសូមទទួលស្គាល់ថា លោក ទៀ ហារតឹក ពិតជាទៅរងគ្រោះនៅទីនោះមែន ក៏ប៉ុន្តែនៅពេលដែលគាត់ទៅរងគ្រោះខ្ញុំមិនបានដឹង ហើយឯកសារហ្នឹងមិនដឹងជារាយការណ៍ទៅលើ ឬអត់ផងមិនដឹង ។ នេះសូមបញ្ជាក់ប៉ុណ្ណោះ ។ ឯចំណែក សំណងរដ្ឋប្បវេណី វាជាការហួសសមត្ថភាពខ្ញុំឆ្លើយ ខ្ញុំសូមបញ្ជាក់ប៉ុណ្ណោះ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តអង្គជំនុំជម្រះផ្តល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញា ប្រសិនបើមានសំណួរត្រូវសួរដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ សូមអញ្ជើញ ។ អង្គជំនុំជម្រះសូមរំឭកថា ការសួរនាំរបស់តំណាងសហព្រះរាជអាជ្ញាចំពោះករណីនេះ ត្រូវការបែងចែកឲ្យបានច្បាស់លាស់ រវាងតួឋានៈក្នុងនាមជាដើម

បណ្តឹងរដ្ឋប្បវេណី និងឋានៈក្នុងនាមជាសាក្សី មិនអាចច្រលូកច្រឡំគ្នានៅក្នុងការសួរចម្លើយ ដើម្បីឲ្យមុខសញ្ញាទាំងពីរនេះដូចគ្នាទេ នៅក្នុងការផ្តល់ចម្លើយសម្រាប់ដំណើរការសវនាការ ។ សូមអញ្ជើញ ។

[១៥:៤៨:០៧]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា៖**

**សួរដោយលោក សេង ប៊ុនឃាង៖**

បាទ អរគុណលោកប្រធាន ។

**ស៖** ជម្រាបសួរលោកស្រី ឈិន ណារី ។ តើលោកស្រីធ្លាប់យកបញ្ហាដែលថាស្វាមីលោកស្រីឈ្មោះ ទៀ ហាវតឹក នេះទៅប្រាប់កូនៗរបស់លោកស្រីដែរឬទេ? ហើយថាតើពួកគេមានប្រតិកម្មយ៉ាងណាដែរនៅពេលដែលដឹងបញ្ហានេះ?

**ឆ៖** ចាស, លោកព្រះរាជអាជ្ញា! ខ្ញុំបានរកឃើញរូបថតនិងបញ្ជីនៅទួលស្លែងនេះត្រឡប់ទៅប្រាប់កូនខ្ញុំ កូនខ្ញុំយំឡើងង៉ោងពេញផ្ទះអស់ហើយ ។ កូនខ្ញុំយំស្រែកឡើងង៉ោង ហើយកូនខ្ញុំថា អស់សង្ឃឹមហើយលោកឪពុកខ្ញុំលែងបានជួបមុខទៀតហើយ ។ តើបានអ្នកណាហៅឪពុកទៀត តើបានអ្នកណាទៅវាលកប៉ាល់ហោះជូនកូនទៅលែងវាលកប៉ាល់ហោះថ្ងៃឈប់ទៀត? អស់សង្ឃឹមហើយពីថ្ងៃនេះតទៅតើខ្ញុំពឹងអ្វីទៅ? អត់ពីឪពុកខ្ញុំទៅហើយ នៅម្តាយខ្ញុំខំចិញ្ចឹមខ្ញុំឲ្យបានធំធាត់មានក្រសួងមានមន្ទីរនឹងគេ តើខ្ញុំបានអីនឹងសប្បាយទៀត បើអត់មានឪពុកយ៉ាងនេះ? មានក្រសួងមានមន្ទីរហើយអន្តរជាតិទទួលស្គាល់សញ្ញាបត្រហើយ ខ្ញុំអត់មានឪពុកនឹងគេ។ តើហាក់ដូចអ្វីទៅបងប្អូនញាតិមិត្តណ្ហើយ លោកប្រធានណ្ហើយ ។ កូនខ្ញុំបានទៅស្រាវជ្រាវទៀត កូនខ្ញុំមួយពៅនោះវាទៅស្រាវជ្រាវរកឯកសារអីមិនដឹងទេឮសួរវា ខ្ញុំមិនសូវមានពេលជួបគ្នាទៀត គេរវល់ធ្វើការផង ខ្ញុំក៏រវល់ដែរ ។ សូមអស់តែប៉ុណ្ណឹង ។

**ស៖** បាទ អរគុណ ។ តើប្រតិកម្មរបស់គេទាំងនោះ មានរហូតមកដល់បច្ចុប្បន្ននេះដែរឬទេ?

**ឆ៖** មកដល់បច្ចុប្បន្ននេះ គេហាក់ដូចជាម្នាក់ៗហ្នឹង ក៏គេមានប្រតិកម្មដែរ ប៉ុន្តែដោយគេគោរពវិន័យការងារគេ ។ កូនប្រុសខ្ញុំបានចេញទៅពីព្រឹកថ្ងៃច័ន្ទហ្នឹង គេចេញទៅ*មីសហ្សុង* នៅខេត្តសៀមរាបហើយ ក្រសួងសុខាភិបាលគេចាត់តាំងទៅ គេធ្វើការមមាញឹករកពេលឈប់គ្មានទេ ។ ហើយកូនស្រីពៅខ្ញុំបានមកមើលជាមួយដែរ ។ មានគ្រួសារអាមេរិកាំង គេមកតាមមកដណ្តឹងដល់ផ្ទះ ហើយកូនស្រីបងខ្ញុំគេបាននៅផ្ទះ ដោយម្នាក់ៗ គេមានការងារមមាញឹកព្រលឹមទល់ព្រលប់ ។ សូមអស់តែប៉ុណ្ណឹង ។

**លោក សេង ប៊ុនឃាង៖**

អរគុណលោកស្រី ។ លោកប្រធាន ខ្ញុំអស់សំណួរហើយ បាទ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

បាទ តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាទៅមេធាវីការពារក្តី ដើម្បីឱ្យមានឱកាសក្នុងការតាំងសំណួរដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ប្រសិនបើមាន សូមអញ្ជើញ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណ លោកប្រធាន ។ សូមអរគុណ ចំពោះសេចក្តីថ្លែងរបស់លោកស្រី ។ មេធាវីការពារក្តី ពុំមានសំណួរចង់សួរលោកស្រីនោះទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

នេះជាកិច្ចបន្ត អង្គជំនុំជម្រះផ្តល់ទៅជនជាប់ចោទ ដើម្បីអាចឡើងធ្វើការកត់សម្គាល់នូវសេចក្តីថ្លែងការណ៍ចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ប្រសិនបើលោកមានបំណង ។

**ជនជាប់ចោទ៖**

សូមគោរពលោកប្រធាន! ពេលនេះ ខ្ញុំបាទគ្មានអីកត់សម្គាល់បន្ថែមទៀតទេ ។ សូមគោរព ។

**ប្រធានអង្គជំនុំ៖**

លោកស្រី ឈិន ណារី ដំណើរការនៃការស្តាប់សេចក្តីថ្លែងការណ៍របស់លោកស្រី ក្នុងនាមលោកស្រីជាដើមបណ្តឹងរដ្ឋប្បវេណីដែលអង្គជំនុំជម្រះសម្រេចអញ្ជើញលោកស្រី ឱ្យមកធ្វើសេចក្តីថ្លែង-ការណ៍ ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីនោះ ឃើញថាដល់ទីបញ្ចប់ហើយ ។

ឥឡូវនេះ លោកស្រីអាចអញ្ជើញត្រឡប់ទៅកាន់ទីកន្លែង ដែលបម្រុងទុកសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងពេលវេលាបន្តបន្ទាប់ គឺអាស្រ័យទៅលោកស្រីអាចចូលរួម ក៏បាន ឬក៏អាច មិនបានដែរ នោះស្រេចតែសិទ្ធិរបស់លោកស្រី ។

[១៥:៥៤:០៥]

ជាកិច្ចបន្ត មន្ត្រីតុលាការអញ្ជើញ លោក តូច មុន្និន ដើម្បីអញ្ជើញគាត់មកកាន់ទីកន្លែងរៀបចំសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខអង្គជំនុំជម្រះ ។

*(លោក តូច មុន្និន ចូលមកក្នុងសវនាការ)*

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** ដើមបណ្តឹងរដ្ឋប្បវេណី តើលោកមានឈ្មោះ តូច មុន្និន អ៊ីចឹងពិតមែនដែរឬទេ?

**ឆ៖** បាទ សូមគោរពលោកប្រធាន ខ្ញុំឈ្មោះ តូច មុន្និន ពិតប្រាកដ ។

**ស៖** លោក តូច មុន្និន តើលោកមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** ៥៤ឆ្នាំ ។

**ស៖** តើលោកមានទីកន្លែងកំណើត នៅទីកន្លែងណាដែរ?

**ឆ៖** ខ្ញុំបាទ មានទីកន្លែងកំណើតភូមិព្រែកកុយ ឃុំព្រែកកុយ ស្រុកកងមាស ខេត្តកំពង់ចាម ។ ប៉ុន្តែភូមិព្រែកកុយនេះ ទើបនឹងសម័យនេះទេ ដែលពីសម័យសង្គម គេហៅ ភូមិស្វាកោក បាទ ។

**ស៖** តើសព្វថ្ងៃនេះ លោករស់នៅទីកន្លែងណា? ហើយលោកប្រកបមុខរបររកស៊ីធ្វើអ្វីដែរ?

**ឆ៖** សព្វថ្ងៃនេះ ខ្ញុំមានទីលំនៅភូមិវារីលិច ឃុំស្វាយទាប ស្រុកចម្ការលើ ខេត្តកំពង់ចាម ។ មានមុខរបរជាគ្រូបង្រៀននៅវិទ្យាល័យហ៊ុន សែន ចម្ការលើ ។

[១៥:៥៦:១៩]

**ស៖** តើឪពុកបង្កើតរបស់លោកគាត់ឈ្មោះអ្វី? ហើយសព្វថ្ងៃនេះ គាត់នៅរស់ ឬក៏គាត់ទទួលមរណភាពហើយ?

**ឆ៖** បាទ, ឪពុករបស់ខ្ញុំ ឈ្មោះ តូច មី ។ ម្តាយឈ្មោះ ម៉ៅ ខុន សព្វថ្ងៃគាត់បានស្លាប់យូរយារមកហើយ ។

**ស៖** លោក តូច មុន្និន តើលោកមានបងប្អូនបង្កើតប៉ុន្មាននាក់? ហើយចូរលោករៀបរាប់ប្រាប់នូវឈ្មោះបងប្អូនរបស់លោក ជូនដល់សវនាការ ។

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំមានបងប្អូនប្រាំពីរនាក់ ។ បងទីមួយ ឈ្មោះ តូច ស៊ីមន, បងទីពីរ ឈ្មោះ តូច ប៊ុនថន, ទីបី ឈ្មោះ តូច សុខន, ទីប្រាំ ឈ្មោះ តូច មុន, ខ្ញុំ-- មកដល់ខ្ញុំទីប្អូនឈ្មោះ តូច មុន្និន, ប្អូនស្រី ឈ្មោះ តូច សុខឿន ហើយប្អូនពៅ ឈ្មោះ តូច សុខុម ។

**ស៖** លោកតូច មុន្និន តើឈ្មោះ ធូ មាន, ឈ្មោះ ធូ រិន, ឈ្មោះ ធូ សារ៉េន, ឈ្មោះ ព្រឿន, ឈ្មោះ ម៉ៅ ប៊ុនចន ឬក៏ ម៉ៅ ប៊ុនថន ហើយនិងឈ្មោះ ជា ខន ហ្នឹង តើអ្នកទាំងអស់នេះ ត្រូវយ៉ាងម៉េចជាមួយនិងលោក? ទំនាក់ទំនងញាតិលោហិត ឬក៏ញាតិពន្ធយ៉ាងជាមួយនិងរូបលោក?

**ឆ៖** សូមជម្រាបលោកប្រធានថា ឈ្មោះទាំងខាងលើនេះជាសាច់សារលោហិតរបស់ខ្ញុំបាទ ។ លោក ធូ មាន គឺជាឪពុកធំរបស់ខ្ញុំ ។ បាទ ហើយបងព្រឿន ជាក្មួយថ្លៃរបស់ខ្ញុំ ហើយ ធូ សារ៉េន ក៏ជាក្មួយ ទាំងអស់នេះសុទ្ធតែសាច់ញាតិ ។ ដោយឡែកបង ជា ខន ដែលជាបងជីដូនមួយរបស់ខ្ញុំនេះ គាត់ជាកូនពៅរបស់ម្តាយខ្ញុំធំរបស់ខ្ញុំ ដែលគាត់មានបងប្អូនប្រាំមួយនាក់ ជាកូនពៅ ។ ហើយកូនពៅនេះគាត់មានបងទីមួយ ឈ្មោះ ជា ផៃ បន្ទាប់មកមានបងស្រី ឈ្មោះ ជា ឡៃ, ជា ផាត់, ជា ខាត់ និងគាត់ផ្ទាល់ឈ្មោះ ជា ខន ។ ជា ខន នេះ គឺជាជីដូនបង្កើតរបស់ខ្ញុំ ព្រោះម្តាយខ្ញុំជាកូនពៅ ជាប្អូនបង្កើតរបស់ម៉ៅ អែម ឪពុកធំឈ្មោះ ជា ប៊ូ ។

[១៥:៥៩:២៥]

**ស៖** ចុះ ឈ្មោះ ម៉ៅ ប៊ុនថន ឬក៏ ម៉ៅ ប៊ុនថន ត្រូវយ៉ាងម៉េចជាមួយនិងលោក?

**ឆ៖** បាទ ម៉ៅ ប៊ុនថន នេះ គ្រាន់តែជាបងជីដូនមួយដែរ ខាងម្តាយខ្ញុំ ពីព្រោះឪពុកធំខ្ញុំឈ្មោះ ធូ មាន នេះជាបងប្អូនរបស់គាត់ ហើយបងបង្កើតខ្ញុំហ្នឹង ឈ្មោះ តូច ប៊ុនថន ដែរ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះផ្តល់វេទិកាទៅមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមបួន ដើម្បីឡើងធ្វើសេចក្តីថ្លែងការណ៍ដោយសង្ខេប បង្ហាញអំពីអត្តសញ្ញាណរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ហេតុដែលនាំឲ្យដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទំនាក់ទំនងនៃការប្តឹងទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងបទឧក្រិដ្ឋដែលបានចោទប្រកាន់ទៅលើជនជាប់ចោទឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ពាក់ព័ន្ធទៅនឹងអង្គហេតុមន្ទីរសន្តិសុខស-២១ ក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ៧៩ ព្រមទាំងភស្តុតាងនានាដែលមានដើម្បីគាំទ្រដល់ការប្តឹទាមទារសំណងរបស់ឈ្មោះ តូច មុន្និន ដែលជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខអង្គជំនុំជម្រះនេះ ។ សូមអញ្ជើញ ។

**លោក ហុង គឹមសួន៖**

ខ្ញុំបាទ សូមអរគុណ និងសូមគោរពប្រធាន លោក លោកស្រីចៅក្រមជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាទីគោរព និងអង្គសវនាការទាំងអស់ ។

ខ្ញុំបាទ ហុង គឹមសួន ជាមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី លោក តូច មុន្និន ។ សូមជម្រាបលោកប្រធានជ្រាបថា លោក តូច មុន្និន គឺជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានអត្តសញ្ញាណប័ណ្ណ

សញ្ជាតិខ្មែរ លេខ 060172611 ហើយដែលមានឯកសារលេខ ERN លេខ 00211332 និងឯកសារ D25/14/1 ។ ទីពីរ គាត់បានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមានឯកសារលេខ ERN ជាភាសាខ្មែរ 00211321 នេះជាទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ ។ ហើយត្រូវបានប្តឹងដាក់ពាក្យបណ្តឹងនេះក្នុងនាមជាបងប្អូនជីដូនមួយជាមួយនិងឈ្មោះ ជា ខន ហៅ ជិន ដែលភេទប្រុសត្រូវបានចាប់ខ្លួន នៅថ្ងៃទី២ ខែ១ ឆ្នាំ១៩៧៧ ។

[១៦:០៣:០០]

ជា ខន ហៅ ជិន សូមជម្រាបលោកប្រធានជ្រាបថា មាននៅក្នុងឯកសារបញ្ជីអ្នកទោសនៃមន្ទីរ ស-២១ ។ សូមអនុញ្ញាត នៅក្នុងឯកសារបញ្ជីទោសនៃមន្ទីរស-២១ មានលេខ ERN ជាភាសាខ្មែរ 00161084 ក្នុងលេខរៀងលេខ ៩៤ ជាភាសាអង់គ្លេស និងជាភាសាខ្មែរ ដាក់ថា ជា ខន ហៅ ជិន អាយុ៣៥ឆ្នាំ ភេទប្រុស ជាវិស្វករមកពីរុស្ស៊ី ចាប់ខ្លួនថ្ងៃទី២ ខែ១ ឆ្នាំ១៩៧៧ និងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលដាក់ចូលមកក្នុងសំណុំរឿងលេខ ERN 00161073 ។ នៅក្នុងឯកសារមួយទៀត 00161356 ដែលមានលេខរៀង១៩១ ឈ្មោះ ជា ខន ហៅ ជិន ជាវិស្វករមកពីរុស្ស៊ី ។ ឯកសារមួយទៀត ជាបញ្ជីអ្នកទោសនៅមន្ទីរស-២១ ដែលមានលេខ ERN 00171449 ដែលមាននៅក្នុងលេខរៀង០៧៦ ឈ្មោះ ជា ខន ហៅ ជិន ជាវិស្វករមកពីរុស្ស៊ីផងដែរ ។ ហើយនៅក្នុងនេះព័ត៌មានស្តីអំពីការចាប់ខ្លួនចូលមន្ទីរស-២១ ឬក៏យកទៅកម្ទេច មានតែសញ្ញាសួរ “?” ។

នៅក្នុងនេះផងដែរ ខ្ញុំបាទ សូមជម្រាបលោកប្រធាន និងអង្គសវនាការជ្រាបថា ឯកសារស្តីអំពីការសារភាពអ្នកទោសឈ្មោះ ជា ខន ហៅ ជិន ត្រូវបានបញ្ជាក់ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានឯកសារ ERN ជាភាសាខ្មែរ 00239024 និងឯកសារ ERN ជាភាសាអង់គ្លេសលេខ 00211333។ ឯកសារនេះមានលេខជាឯកសារមួយទៀត D25/14/2 ហើយដែលបញ្ជាក់អំពីឯកសារតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ដោយសារនៅក្នុងសំណុំរឿងនៃសំណុំរឿង០០១នេះ ខ្ញុំបាទមិនអាចរកឃើញលេខERNបាន ខ្ញុំបាទបានទៅសូមបញ្ជាក់អំពីនាយកដ្ឋានសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង លេខ០៤៨ ល.ប ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៩ ។ បញ្ជាក់ឯកសារដែលខ្ញុំបាទបានសុំដាក់បញ្ចូលនេះ ដែលលោកប្រធានបានទទួលព្រឹកមិញនេះ និងភាគីទាំងអស់ផងដែរ គឺពិតជាឯកសារដើមមានតម្កល់ទុកនៅសារមន្ទីរទួលស្លែងសព្វថ្ងៃនេះ ជាឯកសារដែលជាការសារភាពរបស់ឈ្មោះ ជា ខន ហៅ ជិន ពិតមែន ។

ហើយនៅក្នុងនេះផងដែរ ខ្ញុំបាទក៏ទើបតែនឹងបានទទួលរូបថតជនរងគ្រោះដែលឈ្មោះ ជា ខន ហៅ ជិន ដែលរូបដល់ពីសង្គមចាស់មុនឆ្នាំ១៩៧០ ដែលទើបនឹងបានរកឃើញតាមរយៈបងប្អូនសាច់ឈាមរបស់លោក តូច មុន្និន ផងដែរ ដែលដាក់ជូន ។ ហើយខ្ញុំបាទនឹងសូមឲ្យសួរទៅលោកជនជាប់ចោទចុងក្រោយថា តើលោកស្គាល់ឈ្មោះ ឬក៏រូបនេះមែនឬអត់?

ក្នុងនេះខ្ញុំបាទសូមបញ្ជាក់ថា ដោយសារនៅក្នុងឯកសារនេះមានជាប់ជាឯកសារដោយដៃ ខ្ញុំបាទនឹងសូមអនុញ្ញាតលោកប្រធានសូមឲ្យខាងជនជាប់ចោទ គាត់បង្ហាញផងដែរ ថាតើជាការសួរចម្លើយដោយឈ្មោះណា? ព្រោះក្នុងនេះមានឈ្មោះសមមិត្ត ហ៊ាង ហើយក៏មានបញ្ជាក់អំពីការជូនដំណើររបស់លោក កាំង ហ្គេកអ៊ាវ ហៅ-- (អ៎! សូមទោស) ។ ក្នុងនេះដោយមានឯកសារថា មានការជូនដំណើរទៅប្រទេសរុស្ស៊ីនៅក្នុងឆ្នាំ១៩៦៥ គឺឈ្មោះលោក កាំង ហ្គេកអ៊ាវ ប៉ុន្តែមិនដឹងថា កាំង ហ្គេកអ៊ាវ ឬ កាំង ហ្គេកអ៊ា ទេ? នេះខ្ញុំបាទ សូមឲ្យបញ្ជាក់តាមក្រោយ ។

ខ្ញុំបាទ សូមបញ្ជាក់បន្ថែមទៀតថា ហេតុផលនៃការបញ្ជាក់ថា ទំនាក់ទំនងរវាងលោក តូច មុន្និន ជាមួយនឹង ជា ខន ហៅ ជិន នោះ ជាបងប្អូនជីដូនមួយមែន ឬមិនមែននោះ? គឺដោយសារនៅក្នុងអត្តសញ្ញាណប័ណ្ណ ខ្ញុំបានបញ្ជាក់អម្បាញ់មិញ គឺគាត់បានជម្រាបផងដែរថា គឺខាងម្ដាយមានត្រកូលឈ្មោះ ម៉ៅ អែម ឪពុកឈ្មោះ ជា ប៊ូ ។ ឪពុក និងម្ដាយរបស់ ជា ខន ហៅ ជិន ក៏ជាសាច់ឈាមបងប្អូនជីដូនមួយផងដែរ គឺប្ដីប្រពន្ធនេះជាប់សាច់ឈាមនឹងគ្នា ហើយក៏ជាប់សាច់ឈាមជាមួយនឹង តូច មុន្និន ជាបងប្អូនជីដូនមួយ ។

[១៦:០៨:២៩]

ហើយហេតុផលនៃការគាត់ដាក់បណ្ដឹងដោយមិនមែនជាសាច់ឈាមបង្កើតនោះ ដោយសារបងប្អូនបង្កើតរបស់ ជា ខន ហៅ ជិន ឬឪពុកម្ដាយត្រូវបានសម្លាប់ចោលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យផងដែរ ។ ទើបលោក តូច មុន្និន បានតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីមកនេះ ដើម្បីស្វែងរកយុត្តិធម៌ ឬក៏ប្ដឹងសូមឲ្យតុលាការ អ.វ.ត.ក ជួយរកយុត្តិធម៌ឲ្យគាត់ក្នុងនាមជាសាច់ឈាមជីដូនមួយ ហើយដែល ជា ខន ហៅ ជិន ជាអ្នកមានគុណរបស់គាត់ និងមានគុណលើក្រុមគ្រួសារគាត់មុនឆ្នាំ១៩៧៥ នេះផងដែរ ។

បន្តទៅទៀតនេះ ខ្ញុំបាទ សូមអនុញ្ញាតឲ្យលោកប្រធានឲ្យលោក តូច មុន្និន ថ្លែងអំពីរឿងប្រវត្តិទាក់ទងជាមួយ ជា ខន ហៅ ជិន និងគាត់ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងការរកឃើញ

នៃការសម្លាប់លោក ជា ខន ហៅ ជិន នៅក្នុងមន្ទីរស-២១ ដោយគ្រួសៗ និងសង្ខេប។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

លោក តូច មុន្និន អង្គជំនុំជម្រះផ្តល់ឱកាសដល់លោក ដើម្បីធ្វើ ឡើងធ្វើសេចក្តីថ្លែងរៀបរាប់ដល់អង្គសវនាការអំពីរឿងហេតុទំនាក់ទំនងទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ចំពោះជនជាប់ចោទ ដែលធ្វើឲ្យប៉ះពាល់ចំពោះលោក នៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជានៅក្នុអំឡុងពេលនៃបង្កើត និងប្រតិបត្តិមន្ទីរ ស-២១ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ៧៩ ។ ហើយមានការជាអាទិ៍ ការខូចខាតផ្នែកខាង-- អំពីស្ថានភាពព្យសនកម្មដែលកើតមានចំពោះលោកជាអាទិ៍ ខូចខាតខាងរាងកាយ សម្ភារៈ ផ្លូវចិត្ត និងផលវិបាកផ្ទាល់ពីបទឧក្រិដ្ឋ ជាព្យសនកម្មផ្ទាល់ខ្លួន ហើយនិងកើតមានពិតប្រាកដរហូតដល់ពេលបច្ចុប្បន្ននេះ ។ សូមអញ្ជើញ ។

**លោក តូច មុន្និន៖**

[១៦:១០:២៦]

សូមគោរពលោកប្រធាន ។ ខ្ញុំសូមរំឭកសារដើមបន្តិចពីប្រវត្តិរបស់ក្រុមគ្រួសារខ្ញុំ ដែលទាក់ទងជាមួយបង ជា ខន ហៅ ជិន នេះ ។

បង ជា ខន គាត់ជាជីដូនមួយបង្កើតរបស់ខ្ញុំ ហើយជាកូនទីប្រាំរបស់ម្តាយធំខ្ញុំឈ្មោះ ម៉ៅ អែម ។ ខ្ញុំសូមបញ្ជាក់ថា ម៉ៅ អែម នេះជាបងបង្កើតគេបំផុតក្នុងចំណោមម្តាយរបស់ខ្ញុំ បងប្អូនរបស់ខ្ញុំរបស់ម្តាយខ្ញុំ គឺមានប្រាំនាក់ គឺមានឈ្មោះ ម៉ៅ អែម, ទីពីរឈ្មោះ ម៉ៅ អ៊ឹម, ទីបី ម៉ៅ អ៊ុន, ទីបួន ម៉ៅ ហ៊ុន ហើយបន្ទាប់មក គឺម្តាយរបស់ខ្ញុំ គឺ ម៉ៅ ខុន ដែលជាប្អូនស្រីពៅរបស់គាត់ ។

មុនឆ្នាំ៧០នេះ មុខរបរឪពុកម្តាយខ្ញុំ គឺជាកសិករ ដែលរស់នៅក្នុងភូមិព្រែកកុយ ។ ក្នុងការរស់នៅកន្លងមក គឺម្តាយខ្ញុំមានការទីទ័លគឺក្រជាងគេ ។ ក្រោយឆ្នាំ-- មុនឆ្នាំ៧០នេះ ក្រោយព្រឹត្តការណ៍ ១៨ មីនា ១៩៧០ ក្រុមគ្រួសារឪពុកធំរបស់ខ្ញុំ ជា ប៊ូ និងម៉ៅ អែម នេះ គាត់មានកូនជាច្រើនដែលរស់នៅក្នុងទីក្រុងភ្នំពេញ លើកលែងតែបងមួយ ជា ផាន ដែលគាត់ជាប្រជាជនធ្វើស្រែចម្ការ ។

អ៊ីចឹងទេព្រឹត្តការណ៍ដែលកើតឡើងភ្លាម ក្រុមគ្រួសារខ្ញុំបានពិភាក្សា ជាពិសេស គឺម្តាយធំខ្ញុំហ្នឹង គាត់ថាឥឡូវស្រុកកើតសង្គ្រាមប្រាកដហើយ ព្រោះទម្លាក់-- កាលណាទម្លាក់សម្តេចនរោត្តម សីហនុ ម្ល៉េងវាខ្លាចគេទម្លាក់គ្រាប់បែកផង គាត់ក៏ទាញម្តាយខ្ញុំឲ្យទៅរស់នៅទីក្រុងភ្នំពេញ ។ អ៊ីចឹងការរស់នៅក្នុងក្រុងភ្នំពេញនេះ ទៅរស់នៅជាមួយបងរបស់-- ស្រីរបស់ខ្ញុំឈ្មោះ ជា ឡៃ ដែលជាបងទីពីររបស់បង

ជា ខន នេះ ។

ការនៅរស់នៅភ្នំពេញ ការរស់នៅនេះ គឺឪពុកម្តាយបង ជា ឡៃ ហើយប្តីរបស់គាត់ឈ្មោះ ធូ រិន ជាអ្នកមន្ត្រីរាជការដែរនោះ គាត់បានគ្រប់គ្រងទាំងអស់ គឺខ្លួនខ្ញុំផ្ទាល់ ដែលរស់នៅក្នុងនេះដែរ ហើយមានប្អូនស្រី និងប្អូនប្រុសម្នាក់ទៀតរស់នៅបីនាក់ នៅក្នុងបន្ទុក ។ រីឯបងៗ គាត់បានចេញទៅធ្វើការនៅរោងចក្រ ។

បន្ទាប់មកប្អូនស្រីខ្ញុំឈ្មោះ តូច សុខឿន សុខចិត្តលះបង់ការរៀនសូត្រទៅធ្វើកម្មកររោងចក្រ ក្នុងសម័យ លន់ នល់ នេះ ដើម្បីយកលុយមកផ្គត់ផ្គង់ ។ ហើយកាលនោះម្តាយខ្ញុំត្រូវមានជំងឺវះកាត់ ។ ពេទ្យបានឲ្យដំណឹងថា ត្រូវវះកាត់ក្រពះនៅឆ្នាំ១៩៧០ នេះផង ។

ដល់ក្រោយមកទៀត ការរស់នៅចេះតែត្រដាបត្រដួស ហើយបង ជា ឡៃ នេះ គាត់បានខិតខំជួយចិញ្ចឹមជីវិតខ្ញុំ ម្តាយឪពុកខ្ញុំទៅនៅភ្នំពេញ ព្រោះគាត់ចាស់ៗអស់ហើយ គ្មានទីពឹងអីអ្វីទេ ។ ហើយកាលនោះ ខ្ញុំដឹងតែការរៀនសូត្រទេ គឺខ្ញុំបានរៀននៅវិទ្យាល័យបឹងកក់ ។ មួយថ្ងៃៗ ខ្ញុំគិតតែប្រឹងរៀនសូត្រ ហើយតស៊ូជាមួយបង ខិតខំយកចិត្តទុកជួយការងារបងក្នុងនាមគាត់ជាបង ហើយគាត់ជួយទំនុកបម្រុងខ្ញុំសព្វបែបយ៉ាងតាំងពីការរៀនសូត្រ ។

ខ្ញុំសូមបញ្ជាក់ថា ការរស់នៅទីក្រុងភ្នំពេញនេះ ខ្ញុំសូមជម្រាបថា មានប្អូនបង្កើតរបស់គាត់មួយទៀតឈ្មោះ ម៉ៅ អ៊ឹម ឪពុកឈ្មោះ ធូ សុក ជាប្អូនបង្កើតរបស់ ម៉ៅ អែម ប្អូនបង្កើតផង ជាដន្លងផង។ កូន ម៉ៅ អ៊ឹម គាត់ឈ្មោះ ធូន រិន ជាប្តីរបស់ ជា ឡៃ ។ ក្រុមគ្រួសារខ្ញុំភាគីច្រើនៗ តែជីដូនមួយគឺយកជីដូនមួយ កាលសម័យនោះ ។

អ៊ីចឹង ក្រោយឆ្នាំពេលដែលដាច់៧៥ ១៧មេសា ខ្ញុំបានរស់នៅជាមួយកៀកកើយជាមួយគាត់រហូតៗដល់ដាច់ភ្នំពេញនេះ ខ្ញុំមានការខ្វល់ខ្វាយយ៉ាងច្រើន ដោយសារបងប្អូននៅបែកគ្នា ។ ជាពិសេសបងមួយទៀតឈ្មោះ ធូ រៀម ដែលគាត់រស់នៅ ក៏គាត់មានចំណែកមួយចិញ្ចឹមខ្ញុំច្រើនដែរ ។ ហើយម្តាយឪពុករបស់គាត់រស់នៅជាមួយជួបជុំគ្នាបីនាក់បងប្អូនស្រីៗ នៅលើផ្ទះ ជា ឡៃ និង ធូ រិន នេះ ។

ក្រោយមកទៀត ការធ្វើដំណើរខ្ញុំសូមនិយាយត្រួសៗថា ការធ្វើដំណើរចាកចេញពីទីក្រុងភ្នំពេញក្រោយពីទាហាន ប៉ុល ពត ខោខ្មៅអាវខ្មៅ ដែលមានវ័យជំទង់ទៅ ចូលទៅប្រាប់ថាសូមឲ្យចេញបាទ ។ សូមឲ្យចេញតែបីថ្ងៃទេ បើសិនជាមិនចេញទេ ប្រយ័ត្នកប៉ាល់ហោះទម្លាក់ ហើយអង្គការមិនអត់ឱនឲ្យទេ ។

ពេលនោះហើយ ដែលយើងខ្ញុំមានអារម្មណ៍ខ្វាយខ្វល់មិនដឹងជាគិតយ៉ាងម៉េច បើបងប្អូនខ្លះបែកខ្ញែកគ្នា ខ្លះទៅនេះ ខ្លះទៅនោះ ។ រហូតដល់ព្រឹកឡើងគេមកប្រាប់ទៀត មកប្រាប់ទៀត ក៏ជំនុំជាមួយម្ដាយធំ បងប្អូនដែលជុំគ្នាប៉ុន្មានគ្រួសារនេះ ក៏នឹកឃើញថា ត្រូវតែចេញ បើមិនចេញទេ ប្រាកដជាគេយកយើងទៅធ្វើទោសហើយ ។

អ៊ីចឹងថ្ងៃរសៀល យើងខ្ញុំក៏សម្រេចចេញដំណើរ ចេញពីទួលគោក សង្កាត់លេខពីរនេះធ្វើដំណើរកាត់មកតាមទួលសង្កែ ហើយចេញទៅគីឡូលេខប្រាំមួយ ។ ពេលនោះហើយដែលយើងខ្ញុំនឹកឃើញមានការសោកស្ដាយថា គ្មានអ្វីដែលយកមកជាប់នឹងខ្លួនច្រើនទេ គឺខ្ញុំស្ដាយតែសៀវភៅទេ ព្រោះនឹកឃើញថា ពេលនោះគេឲ្យចេញតែពីរថ្ងៃ អ៊ីចឹងការសិក្សាខ្ញុំមិនជឿមាន-- មិនមានជំនឿថា គេបិទរហូតទេ ។ អ៊ីចឹងយកតែសៀវភៅមួយឡាំង ហើយអង្ករបន្តិចបន្តួចនៅជាប់នឹងខ្លួនជាមួយម្ដាយធំ ជាមួយម្ដាយបង្កើត ។ បណ្ដើរតាមកង់ ហើយមកដល់លេខប្រាំមួយ មិនដឹងជាបានអី ក៏ចូលទៅឃើញគេនៅជុំៗចែកអង្ករ ក៏ចូលទៅសុំគេបានអង្ករបួនដប់គីឡូយកមកចែកបងប្អូន ។

ដំណាក់កាលតាមផ្លូវខ្ញុំសូមជម្រាបលោកប្រធានថា ម្ដាយធំរបស់ខ្ញុំ ជា អែម នេះ គាត់វេចតែលុយទេ គាត់មានលុយច្រើន ដែលកូនជួយ គាត់សន្សំធ្វើបុណ្យទាន ពេលនោះហើយដែលខ្ញុំអង្វរគាត់ថាឲ្យចាយឲ្យអស់ទៅ ទាន់គេចាយ អ៊ំ បើអ៊ំ នៅតែអ៊ីចឹងទៀត ទៅមុខស្ដាយទៀតហើយ គាត់នៅតែមិនជឿថា គេអត់ចាយលុយទេ ប្រទេសណាក៏គេចាយលុយដែរ ។

[១៦:១៧:៥៦]

ទីចុងបំផុតធ្វើដំណើរទៅដល់វត្តសេដ្ឋាមុន្នី ស្រុកពញាឮ បានគាត់ភ្ញាក់ខ្លួនថាគេអត់ចាយលុយ ។ ពេលនោះហើយ ដែលក្រុមគ្រួសារខ្ញុំអង្គុយទល់មុខគ្នាមានតែទឹកភ្នែក មិនដឹងជាបានស្អីយកមកដោះស្រាយក្នុងជីវភាព ។

មានថ្ងៃមួយធ្វើដំណើររហូតដល់យប់ រហូតដល់ម៉ោងមួយម៉ោងពីរ ដេកៗបានមួយស្របក់ធុំក្លិនស្អុយ ក៏នាំគ្នារើកន្ទេលបើកមើល ឃើញសាកសពក្រៀមស្បែកទៅហើយ ក៏រើទាំងយប់។ នេះជាអកុសលមួយដែលក្រុមគ្រួសារខ្ញុំនឹកឃើញធ្វើដំណើរ ឃើញខ្មោចហើយទៅតាមផ្លូវដេកទៅដេកលើខ្មោចទៀត ។

ការធ្វើដំណើរមកដល់ព្រែកក្ដាមរយៈពីរថ្ងៃទម្រាំនឹងបានឆ្លង ហើយការធ្វើដំណើរនេះឆ្លងកាត់មកព្រែកក្ដាមនេះ ពេលនោះក៏មានអង្គការគេប្រកាសខ្លះត្រូវការទៅបាត់ដំបង គេឲ្យទៅ ខ្លះទៀតទៅ

ខាងកំពង់ចាម ក៏ឲ្យទៅ ។ យើងខ្ញុំទាំងអស់គ្នាជាមួយឪពុកធំម្ដាយធំ ក៏ធ្វើការពិចារណាថា យើងត្រឡប់ទៅស្រុកវិញ ព្រោះបាត់ដំបងអត់ដែលបានទៅទេ ។

អ៊ីចឹងក៏សម្រេចចិត្តឆ្លងសាឡាងមក មកដល់ថ្នល់កែង ក៏គេប្រកាសទៀត ប្រកាសថា បងប្អូនណាត្រូវទៅកំពង់ធំ បងប្អូនណាត្រូវទៅចម្ការលើ គឺគេឲ្យទៅ ។ កាលនោះក៏សម្រេចចិត្តថា មិនទៅទេពេលនោះហើយដែលយើងខ្ញុំធ្វើការពិចារណាសូមគេធ្វើដំណើរទៅតាមជើងផ្លូវភ្នំដិលនេះ តែកាលនោះគេអត់ឲ្យទៅទេ ផ្លូវហ្នឹងគេបិទ ។ អ៊ីចឹងគេឲ្យវៀងទៅតាម-- ចុះតាមក្រោយភ្នំដិល កាត់ទៅភូមិទួលច័ន្ទ ឃុំច្បារអំពៅ ហើយមុននឹងទៅដល់ព្រែក គេហៅស្ទឹងឆ្វេង បានក្រុមគ្រួសារខ្ញុំភ្ញាក់ព្រឺតថាមកដល់ស្រុកកំណើត គឺបកច្រាសបញ្ច្រាសទិសមកវិញ ។ បាទ, ធ្វើដំណើរតាមព្រែកនេះបាននឹកឃើញ ហើយមកដល់ទីកន្លែង--

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី ហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន ខ្ញុំសូមអភ័យទោស ដែលខ្ញុំកាត់នៅពេលនេះ ។ នៅពេលនេះ តើយើងអាចស្នើសុំខាងដើមបណ្ដឹងរដ្ឋប្បវេណី ដូចដែលលោកប្រធានធ្លាប់ជម្រាបឲ្យគាត់ផ្ដោតទៅលើព្រឹត្តិការណ៍កើតឡើងនៅស-២១ និងការបាត់បង់សមាជិកនៅទីនោះ ។ យើងដឹងថា អង្គហេតុទាំងអស់នេះ វាជាអង្គហេតុប្រវត្តិសាស្ត្រ ប៉ុន្តែវាក៏មិនមែនជាប់ពាក់ព័ន្ធទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ ។ ដូច្នេះហើយខ្ញុំសូមអនុញ្ញាតលោកប្រធាន ឲ្យធ្វើការជម្រាបដល់ដើមបណ្ដឹងរដ្ឋប្បវេណីឲ្យគាត់ផ្ដោតទៅលើអង្គហេតុដែលពាក់ព័ន្ធ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ការកត់សម្គាល់របស់មេធាវីការពារក្ដី ជាការត្រឹមត្រូវ ហើយមុននឹងអង្គជំនុំជម្រះផ្ដល់វេទិកាទៅដល់ដើមបណ្ដឹងរដ្ឋប្បវេណី អង្គជំនុំជម្រះ គឺរូបយើងផ្ទាល់បាននិយាយយ៉ាងច្បាស់លាស់អំពីទំនាក់ទំនងទៅនឹងបទឧក្រិដ្ឋ ដែលចោទប្រកាន់ទៅលើជនជាប់ចោទ ចំពោះរូបលោកក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ គឺការបង្កើត និងប្រតិបត្តិការ ស-២១ ថ្ងៃទី១៧ មេសា ៧៥ រហូតដល់ថ្ងៃទី៦ មករា ៧៩ ដែលនាំឲ្យលោកប្ដឹងទាមទារ និងផលប៉ះពាល់ផ្សេងៗចំពោះលោក មានខាងរាងកាយ សម្ភារៈ ផ្លូវចិត្ត អីជាដើម ។ នេះជាការដំណើរការ ធ្វើសវនាការនាពេលនេះ ។

អ៊ីចឹងសូមលោកបង្វែរទិសដៅឲ្យចំទៅនឹងអង្គហេតុដែលមានការពាក់ព័ន្ធ និងការចោទប្រកាន់ទៅជនជាប់ចោទ ។ លោកយល់ដែរទេ?

**លោក គួច មុន្និន៖**

បាទ, លោកប្រធាន! ខ្ញុំសូមបញ្ជាក់ថា បើឲ្យខ្ញុំនិយាយពីបញ្ហាទាក់ទងនឹងគុកទួលស្លែងនេះ ខ្ញុំក៏សូមបកទៅវិញ ។ ខ្ញុំសូមបញ្ជាក់ថា មូលហេតុដែលធ្វើឲ្យខ្ញុំបាទ មានការប្ដឹងតាំងខ្លួនជារដ្ឋប្បវេណីនេះ គឺក្នុងនាមខ្ញុំជាប្អូន ហើយខ្ញុំនឹកឃើញថា ក្រុមគ្រួសាររបស់បងខ្ញុំ បានស្លាប់អស់រលីងហើយ នៅសល់តែកូនក្មួយបន្តិចបន្តួចទេ ក្រៅពីហ្នឹងមានជីដូនមួយសុទ្ធតែមានជំងឺបាក់ស្បាត សូម្បីតែដាក់ពាក្យបណ្ដឹងហ្នឹង ក៏មានបងប្អូនខ្លះឃាត់ផង ។ តែខ្ញុំយល់ឃើញថា ប្រទេសជាតិមានច្បាប់ មានទម្លាប់ ហើយបើកសិទ្ធិសេរីភាពឲ្យមានការប្ដឹងផ្ដល់ ហើយបានជាយើងខ្ញុំប្ដឹងនេះ ។

អ៊ីចឹងក្នុងគោលបំណងដែលប្ដឹងនេះ ខ្ញុំមាន គឺចង់តបស្នងសងគុណដល់វិញ្ញាណក្ខន្ធរបស់បងជា ខន ដែលហៅ ជិន ដែលគាត់មានគុណបំណាច់លើក្រុមគ្រួសារខ្ញុំខ្លាំងណាស់ ជាពិសេសកាលដែលគាត់វិលត្រឡប់ចូលមកកម្ពុជានៅឆ្នាំ៧៥ កាលដែលគាត់ធ្វើដំណើរទៅរៀននៅប្រទេសសូវៀតនេះ គឺនៅឆ្នាំ១៩៦៥ ។ ដល់ឆ្នាំ៧៥ ក្រោយរយៈពេលពីបីខែ គឺគាត់បានចូលមកស្រុកខ្មែរ ។ អ៊ីចឹងការចូលមកស្រុកខ្មែរនេះ ខ្ញុំសូមជម្រាបថា ក្រុមគ្រួសារខ្ញុំគ្មានអ្នកណាដឹងទេ សូម្បីម្ដាយរបស់គាត់ ឪពុកគាត់បង្កើតក៏អត់ដឹងដែរថាដំបូង ។

គឺភ្ញាក់ខ្លួនត្រង់ថា ពួកក្រុមគ្រួសាររបស់ខ្ញុំចូលមកដល់ព្រៃកកុយ ចូលមកដល់ស្រុកកំណើតស្រុកកំណើតគេប្រជុំ គេយកបងថ្លៃរបស់គាត់ ដែលឈ្មោះ ធូ រិន បងប្អូនរបស់គាត់ដែលឈ្មោះ ព្រឿន ប៉ុន្មានគ្រួសារ ហើយឪពុកធំខ្ញុំ ឈ្មោះ ធូ សុខ, ធូ រាម, ធូ រ៉េន នេះយកទៅវៃចោល ។

គឺថាវៃចោលទៅចុះ ពីព្រោះកាលនោះ សម័យនោះគេយកថាទៅរៀនសូត្រ ដល់ក្រោយមកមានការខ្សឹបខ្សៀវថា គ្មានរស់ទេ អានេះប្រជាជនចាស់ ដែលខ្សឹបខ្សៀវប្រាប់ថា ពីព្រោះក្រុមគ្រួសារយើងខ្ញុំនេះ ប្រជាជនចាស់ គេត្មះតិះដៀលថា សុទ្ធតែពួកអាស្រុកមាន ពួកអាសក្តិភូមិ ។ អ៊ីចឹង ពួកខ្ញុំក៏មិនតបស្នងតទៅវិញដែរ គឺធ្វើម៉េចតាមសម័យកាល ។

[១៦:២៤:៤២]

ពេលនោះហើយដែលក្រោយមកពីរបីខែ គេជម្លៀសឪពុកម្ដាយខ្ញុំ និងឪពុកធំរបស់ខ្ញុំចេញទៅនៅស្រុកកំពង់សៀម នៅឃុំទ្រាន ។ ដំបូងគេយកទៅដាក់នៅវត្តអង្គុញដី ទើបបានគេបំបែកគ្រួសារហ្នឹង

ទៅនៅ ។ រីឯខ្ញុំ គឺទៅនៅគ្រួសាររបស់ខ្ញុំនៅភូមិពោន ។ ឪពុកធំខ្ញុំនៅភូមិប៉ែន បងខ្ញុំមួយទៀត បាទ ទាំងអស់ប្រាំគ្រួសារនៅភូមិទ្រាន ។ ត្រង់ហ្នឹងហើយ ដែលយើងខ្ញុំរស់ក្នុងចំណុចនេះ ដែលនៅចុងឆ្នាំ៧៥ ដើមឆ្នាំ៧៦ គាត់បានទៅស្រាវជ្រាវ ។ មុនដំបូងតាមដែលប្រសាសន៍ខ្ញុំទៅជួបនោះ គាត់បានថា ចូលមកដល់ស្រុកព្រៃកកុយ ស្រាវជ្រាវទៅថា គេយកបងប្អូនទៅមួយចំនួនហើយ រីឯឪពុករបស់គាត់ គឺជម្លៀស ។ បានប្រជាជនប្រាប់ថាទៅនៅទ្រាន បាទ នៅឃុំទ្រាន ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។

ពេលនោះហើយ ដែលគាត់ទៅស្រាវជ្រាវ ទៅរកយកក្រុមគ្រួសាររបស់យើងខ្ញុំពីស្រុកកំពង់សៀម យកទៅនៅក្នុងស្រុកចម្ការលើ ។ ទៅដល់ដំបូង គោលដៅដែលនៅតាមផ្លូវ បងប្អូនឪពុកធំខ្ញុំសួរថា យកទៅដាក់ចម្ការលើហ្នឹងនៅកន្លែងណា? គាត់ថា យកទៅដាក់នៅភូមិស្រែប្រាំង ឃុំតាប្រុក ស្រុកចម្ការលើ តែមកដល់ប្រមាត់ដី ក្នុងឃុំស្វាយទាបនេះ សង្កាត់ឈ្មោះ ញិប បានឃាត់ថា ឲ្យនៅហ្នឹងទៅ ។ ពេលនោះក៏បងខ្ញុំសម្រេចចិត្តថា មកនៅឃុំស្វាយទាប ផ្ញើតាមមួយផ្ទះមួយគ្រួសារៗ ។

[១៦:២៦:២២]

ខ្ញុំសូមបញ្ជាក់ថា បងខ្ញុំនេះ គាត់តាមដែលគាត់បានជួបជុំជាមួយបងប្អូន គាត់ថា គេឲ្យគាត់ទៅនៅតាប្រុកទេ នៅក្នុងមន្ទីរពេទ្យមួយ នៅឃុំស្រែប្រាំង ។ បន្ទាប់មកគេឲ្យគាត់មកនៅចម្ការលើ ហើយតួនាទីរបស់គាត់នេះ គាត់ធ្វើមុខទឹក នៅស្ពានកណ្ដាល ដែលក្នុងទឹកដីឃុំស្ពឺ រហូតដល់សព្វថ្ងៃនេះ ។ គាត់ជាអ្នកគូរប្លង់ ក្នុងប្លង់ទឹក គឺអ្នកស្ទង់ទំនប់ប្រឡាយ ទំបន់៥កុម្ភៈ នេះ ។ ដល់ក្រោយមកបានគេបញ្ជូនគាត់ទៅធ្វើទំនប់ទឹកនៅកំពង់ថ្ម ដែលគេឲ្យឈ្មោះថា ទំនប់១មករា តាមដងស្ទឹងជីនិត ។

ទាំងអស់នេះហើយដែលយើងខ្ញុំមានការសោកស្ដាយ ឈឺចាប់នៅចុងឆ្នាំ៧៦ ។ ស្រាប់តែបាត់ដំណឹងគាត់ឈឹង អាបាត់ដំណឹងឈឹងនេះ គ្រាន់តែបានតែមួយត្រឹមពិភាក្សាគ្នាទេ លោកប្រធាន មិនដឹងថាបងហ្នឹងគេយកទៅណាទេ ព្រោះកាលនោះឮថា យកទៅរៀនសូត្រៗ បាទ បានតែដឹងប៉ុណ្ណឹងទេ ។ ដល់មកព្រឹត្តិការណ៍ឆ្នាំ៧៩នេះ ក្រោយពេលដែលដាច់ យើងខ្ញុំបានទៅស្រាវជ្រាវនៅគុកទួលស្លែងដែរ ប៉ុន្តែដោយចូលទៅដំបូងឃើញតែបន្ទប់មួយតូច រៀបដោយជញ្ជាំងឥដ្ឋដែលគេដាក់ថា អតីតរដ្ឋមន្ត្រី ហ៊ូ នឹម ។ ឃើញតែកំសៀវទឹកមួយ រីឯខ្ញុំចូលទៅបន្ទប់ផ្សេងៗ ឃើញតែខ្នោះ ឧបករណ៍ធ្វើទារុណកម្ម ម្យ៉ាងឃើញឈាមឆ្អាប ខ្ញុំងងឹតមុខ ខ្ញុំស្វែងរករូបថត មិនដឹងរូបថតអត់ឃើញ ។

អ៊ីចឹងទេ ក្រោយមកបានខ្ញុំដឹងនៅក្នុងរវាងមុនឆ្នាំ១៩៨០ ខ្ញុំប្រទះសៀវភៅមួយក្បាល គេថា“បញ្ជីជនក្បត់” ក្នុងនោះ ខ្ញុំមើលនៅក្នុងស្រុកចម្ការលើ ឃើញឈ្មោះ ជា ខន ដែរ ។ ប៉ុន្តែ មិនដឹងថា ជា ខន

ហ្នឹង-- គ្រាន់តែដឹងថា ជា ខន វិស្វករមកពីរុស្ស៊ី ។ ៩០ភាគរយ គឺបងរបស់ខ្ញុំ ។ ប៉ុន្តែ អារម្មណ៍គិតថា ក្រែងលោមាន ជា ខន ណាទៀត ។

ទើបហ្នឹងក្រោយៗនេះទេៗ ដែលយើងខ្ញុំបានឯកសារនេះ ក្រោយពេលដែលបងស្រីរបស់ខ្ញុំមួយទៀតឈ្មោះ ជា ឡៃ ជាបងបង្កើតរបស់ ជា ខន ហ្នឹង គាត់ចាប់មានជម្ងឺជាបន្តបន្ទាប់ រស់នៅតាំងពីចម្ការលើ មកដល់ស្គន់ បន្តដំណើរពីស្គន់ទៅរស់នៅខេត្តសៀមរាបទៀត ។ សៀវភៅនេះ គឺខ្ញុំបានពីបងមួយទៀតឈ្មោះ ធូ រាម ប្អូន ធូ រិន ជាជីដូនមួយបង្កើតរបស់គាត់ដែរ ។ ហើយគាត់យកមកធ្វើការពិចារណាជាមួយខ្ញុំថា គួរតែយើងប្តឹង ឬយ៉ាងម៉េច បើមានឯកសារគ្រប់គ្រាន់ ។ ខ្ញុំថា បងចាំមើលបន្តិចសិន ខ្ញុំស្រាវជ្រាវមើលរបៀបច្បាប់ ហើយស្តាប់នូវការជូនដំណឹង ការផ្សព្វផ្សាយរបស់តុលាការកម្ពុជារបស់យើងនេះ បើសិនជាយើងដាក់ យើងត្រូវមានភស្តុតាងគិតពិចារណា ។

[១៦:២៩:២៩]

ដល់ក្រោយមក ខ្ញុំទទួលព័ត៌មានពីខាងសមាគមន៍អាដហុក ផ្សព្វផ្សាយដល់មូលដ្ឋានចម្ការលើ ក៏ខ្ញុំសួរទៅមន្ត្រី ដែលផ្សព្វផ្សាយថា ខ្ញុំមានសិទ្ធិប្តឹងបានទេ បើសិនជាខ្ញុំមានឯកសារ ។ ក្រោយមក គាត់ក៏ដាក់ធ្វើពាក្យបណ្តឹងតែម្តងទៅ ។ នេះខ្ញុំសូមបញ្ជាក់ថា មូលហេតុដែលខ្ញុំប្តឹងនេះ គឺខ្ញុំមានការសោកស្តាយណាស់ដែលមានបងមួយដែលជាបញ្ញវន្ត ។ ជាបញ្ញវន្តមួយរូប ខំមកជួយកសាងប្រទេសជាតិហើយ បែរទៅជាយកគាត់មកស្លាប់នៅគុកទួលស្លែង ។ នេះជាការឈឺចាប់របស់ក្រុមគ្រួសារខ្ញុំ ក៏ដូចខ្ញុំផ្ទាល់ដែរ ។ ខ្ញុំសូមអស់មតិត្រឹមហ្នឹងចុះ លោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

ជាបន្ត អង្គជំនុំជម្រះផ្តល់វេទិកាទៅមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមបួន ដើម្បីមានឱកាសក្នុងការសាកសួរបញ្ជាក់បន្ថែមចំពោះព័ត៌មានមួយចំនួន ដើម្បីគាំទ្រដល់បណ្តឹងទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ។ ប្រសិនបើមាន សូមអញ្ជើញ ។

**លោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន ។ សូមគោរពលោកប្រធាន និងអង្គសវនាការជាទីគោរព ។ ដំបូងខ្ញុំបាទ សូមអនុញ្ញាតជម្រាបសួរលោកប្រធានថា ដោយសារពេលវេលាដល់ម៉ោងបួនកន្លះទៅហើយតើលោកប្រធានអនុញ្ញាតឲ្យលោកតូច មុន្និ នឹងបន្តព្រឹកស្អែក ដើម្បីឲ្យភាគីទាំងអស់បានសម្រេចតែម្តងបញ្ចប់បានឬទេ បាទ?

**ប្រធានអង្គជំនុំ៖**

តើលោកត្រូវការ-- មានសំណួរច្រើនដែរទេ? ការប៉ុនប៉ងរបស់អង្គជំនុំជម្រះគិតថា បញ្ចប់តែម្តង បើសិនជាមិនលើសពីម៉ោងប្រាំទេ ដើម្បីឲ្យការគណនា ពេលវេលា និងកំណត់កាលបរិច្ឆេទចាប់ពីថ្ងៃស្អែក និងសប្តាហ៍ក្រោយឲ្យបានជាក់លាក់តែម្តង ពីព្រោះការគ្រោងពីព្រឹក គឺការគណនាពេលវេលាប្រហែលជាអង្គជំនុំជម្រះមានពេលសម្រាប់ទំនេរ យ៉ាងហោចក៏មួយម៉ោង ឬក៏មួយម៉ោងកន្លះដែរសម្រាប់បើកកិច្ចប្រជុំថ្ងៃនេះ ពិភាក្សាការងារផ្សេងទៀត ។

ប៉ុន្តែផែនការនេះត្រូវបានបរាជ័យ ដោយសារការគណនាពេល គឺខុស គ្រោងធ្វើមួយម៉ោង បែរជាធ្វើមួយថ្ងៃ ហើយមុនៗ គ្រោងធ្វើច្រើនម៉ោង បែរជាធ្វើតិចម៉ោង ។

ឥឡូវលោកគិតខ្លួនឯងមើល ថាតើលោកអាចពន្យល់បានទេ ថាតើលោកអាចពន្យល់បានទេ? បើសិនជាមានសំណួរច្រើន វាអាចលើសពេលវេលាវែងពេក យើងនឹងលើកទៅថ្ងៃស្អែក ហើយដោយសារហេតុថ្ងៃស្អែកនេះ យើងត្រូវស្តាប់នូវសេចក្តីថ្លែងការណ៍របស់អ្នកជំនាញមួយរូប ខាងដើមបណ្តឹងរដ្ឋប្បវេណី ហើយគាត់មានពេលវេលាជាក់លាក់មួយព្រឹកសម្រាប់ធ្វើការថ្លែងការណ៍ជូនអង្គជំនុំជម្រះ។ នេះ គឺគាត់បានសុំឡើងច្បាស់លាស់លើបញ្ហាពេលវេលា ។ អ៊ីចឹងហើយ បានជាយើងប្រឹងប្រែង សង្ឃឹមថាចប់ពេលនេះ ហើយស្អែកមិនរំខានការងារគាត់ទេ គឺប្រឹងប្រែងឲ្យចប់តាមពេលវេលាដែលគាត់សុំ ។

[១៦:៣២:៤២]

**លោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន ។ ដូច្នេះ ខ្ញុំបាទនឹងសុំប្រើពេលរបស់ខ្ញុំបាទ ឲ្យកាន់តែខ្លីមកវិញ គឺសរុបប្រហែលជាប្រាំសំណួរប៉ុណ្ណោះទេអ៊ីចឹង ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញ ។

**សួរដោយលោក ហុង គឹមសួន៖**

សូមអរគុណ ។

**ស៖** ជម្រាបសួរលោក តូច មុន្និន ។ ដោយសារលោកបានរៀបរាប់សង្ខេបបំផុតជូនលោកប្រធាន ក៏ដូចអង្គសវនាការដែរ ។ ក្នុងនេះខ្ញុំបាទ ចង់សួរឡើងវិញបន្តិចដោយសារយើងទើបតែនឹងបានទទួលឯកសារជារូបថត ដែលលោកថាជាបងរបស់លោកឈ្មោះ ជា ខន ហៅ ជិន នេះហើយខ្ញុំបាទក៏

បានសូមអនុញ្ញាតលោកប្រធានដាក់ហើយ ។ តើរូបថតនេះ លោកបានទទួលដោយវិធីណា? ហើយជារូបថតរបស់ ជា ខន ហៅ ជិន ដូចម្តេច ដើម្បីឲ្យជម្រាបជូនអង្គសវនាការ?

**ឆ៖** បាទ, លោកមេធាវី! ខ្ញុំសូមជម្រាបថា រូបថតនេះ កាលដាច់៧៩ ម្តាយធំរបស់គាត់ ខ្ញុំធ្លាប់ឃើញរើបង្ហិចរបស់គាត់ឲ្យយើងខ្ញុំមើល ហើយដល់ក្រោយមក ក៏ខ្ញុំមិនបានជាចាប់អារម្មណ៍ គ្រាន់តែដឹងថា បងមិនដឹងជានៅរស់ ឬក៏នៅស្លាប់ទេ ។ ដល់ពេលក្រោយមកទៀត ខ្ញុំខំស្រាវជ្រាវ ទៅកន្លែង *ឌីស៊ីខេម* ហ្នឹង ក៏ឲ្យគេស្រាវជ្រាវរករូបថត ក៏គេឆ្លើយថា មិនឃើញដែរ ។ អ៊ីចឹងខ្ញុំក៏ចេះតែស្រាវជ្រាវទៅតាមរយៈបងប្អូន រហូតដល់ខ្ញុំនឹកឃើញថា ម្តាយធំខ្ញុំស្លាប់ហើយ អ៊ីចឹង ខ្ញុំទៅតាមដានសួរកូនក្មួយទៀត ដែលជាចៅរបស់គាត់បង្កើត ។

អ៊ីចឹងខ្ញុំជូនដំណឹងប្រហែលជាមួយអាទិត្យឲ្យកូនក្មួយ ជួយរកថាពេលដែលបងស្រីខ្ញុំឈ្មោះ ជា ឡៃ ដែលគាត់ស្លាប់នេះ តើគាត់បានទុកនៅកន្លែងណា អីកន្លែងណា?អ៊ីចឹងក្មួយរបស់ស្រីរបស់ខ្ញុំ ឈ្មោះ ស្រីណា នេះ បានស្រាវជ្រាវរករើកកាយទៅ ស្រាប់ឃើញនៅបាតទូ អ៊ីចឹងរូបថតនេះ គឺជារូបថត ពេលដែលគាត់ថត ដែលគាត់ចេញទៅប្រទេសរុស្ស៊ី គឺជារូបថតពិតប្រាកដជាបងប្រុសរបស់ខ្ញុំមែន ។

**លោក ហុង គីមសួន៖**

សូមអរគុណ ។ សូមអនុញ្ញាតលោកប្រធាន សូមអនុញ្ញាតបញ្ចាំងរូបភាពលើអេក្រង់ទូរទស្សន៍។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការយករូបថតពីដៃមេធាវី ដើម្បីដាក់បញ្ចាំងនៅម៉ាស៊ីនស្កាយបង្ហាញរូបភាពនៅលើកញ្ចក់អេក្រង់ទូរទស្សន៍ ។

**លោក ហុង គីមសួន៖**

សូមអរគុណ ។ សូមឲ្យលោកប្រធាន សូមឲ្យលោកប្រធាន សូមអនុញ្ញាតសួរទៅលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច តើលោកចំណាំបានទេ? ថាតើរូបថតនេះពិតជា ជា ខន ហៅ ជិន មែនឬទេ?

**ប្រធានអង្គជំនុំ៖**

ជនជាប់ចោទអាចឆ្លើយនឹងសំណួរនេះ បានសូមអញ្ជើញ ។

**ជនជាប់ចោទ៖**

រឿង ជា ខន នេះខ្ញុំបានឆ្លើយជម្រាបលោក ហុង គីមសួន ខ្លួនឯងម្តងរួចមកហើយ ។ ថាមិត្តភក្តិខ្ញុំ ខ្ញុំស្គាល់ឮឈ្មោះ ជា ខន ខ្ញុំឃើញ មាឌធំ ដូច្នេះច្បាស់ណាស់ ជា ខន ។ ហ្នឹងសូមបញ្ជាក់ ។

**សួរដោយលោក ហុង គឹមសួន៖**

សូមអរគុណ ។ ដូច្នេះមិនមានជាសំណួរអ្វីវែងទៀតទេ ព្រោះច្បាស់ហើយ ។ អ៊ីចឹងខ្ញុំបាទសូមសួរចុងក្រោយមួយទៀតថា លោកបានដឹងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងនាមជាបងប្អូនរបស់លោក ជា ខន ហៅ ជិន មកទល់នឹងថ្ងៃនេះ តើលោកនឹងស្នើសុំឬទាមទារសំណងរដ្ឋប្បវេណីដោយខ្លួនលោក ឬទុកឲ្យមេធាវីជាអ្នកទាមទារជំនួស?

**ឆ៖** បាទ សូមជម្រាបលោកមេធាវីថា ការទាមទារសំណងរបស់យើងខ្ញុំនេះ ខ្ញុំសូមប្រគល់តួនាទីនេះឲ្យលោកមេធាវីជាអ្នកទាមទារជំនួសបាទ ។

**លោក ហុង គឹមសួន៖**

សូមអរគុណ ។ សូមអនុញ្ញាតលោកប្រធានដោយសារពាក្យអម្បាញ់មិញ ខ្ញុំបាទនិយាយទៅជ្រុលពាក្យថា "ចុងក្រោយ" ។

ខ្ញុំសូមអនុញ្ញាតសួរលោក ជនជាប់ចោទតែមួយសំណួរ ហើយជាចុងក្រោយពិតប្រាកដមែន ។ ទាក់ទងនឹងឯកសារនេះ ដោយសារមិនបានបកប្រែជាភាសាបារាំង ឬភាសាអង់គ្លេស ។ ខ្ញុំបាទគ្រាន់តែថា ថ្វីត្បិតតែលោក កាំង ហ្គេកអ៊ាវ ទទួលស្គាល់ហើយ ។ ខ្ញុំបាទចង់ដឹងថា តើនៅឆ្នាំ១៩៦៥ លោកបានជូនដំណើរ ជា ខន ហៅ ជិន ឡើងយន្តហោះទៅប្រទេសបារាំងមែនទេ? នៅទំព័រជាភាសាខ្មែរលេខ៤ អ៊ំ! សូមទោសទៅប្រទេសសូវៀត ។

[១៦:៣៧:៥៣]

**ប្រធានអង្គជំនុំ៖**

អនុញ្ញាតជនជាប់ចោទ អាចឆ្លើយនឹងសំណួរនេះ ។

**ជនជាប់ចោទ៖**

ខ្ញុំសូមមិនរំឭព្រឹត្តិការណ៍អីវែងទេ ។ ខ្ញុំគ្រាន់តែសូមឆ្លើយបញ្ជាក់ថា ខ្ញុំពិតជាបានជូន ជា ខន ឡើងកប៉ាល់ហោះទៅសូវៀត ។

**លោក ហុង គឹមសួន៖**

សូមអរគុណលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ហើយក៏សូមអរគុណលោក តួច មុន្និន និងអង្គសវនាការ សូមបញ្ចប់ប៉ុណ្ណេះ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះជូនវេទិកាទៅមេធាវី-- ទៅតំណាងសហព្រះរាជអាជ្ញា ប្រសិនបើមានសំណួរត្រូវសួរដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ សូមអញ្ជើញ ។

[១៦:៣៨:៣៨]

**លោក សេង ប៊ុនឃាង៖**

អរគុណលោកប្រធាន ។ តំណាងអយ្យការមិនមានសំណួរទៅលើដើមបណ្តឹងរដ្ឋប្បវេណីរូបនេះទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ជាបន្តអង្គជំនុំជម្រះផ្តល់វេទិកាទៅមេធាវីការពារក្តី ដើម្បីមានឱកាសក្នុងការសួរសំណួរចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ប្រើសិនបើមានសូមអញ្ជើញ ។

**លោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន ។ ខាងមេធាវីការពារពុំមានសំណួរទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ជាតទៅនេះ អង្គជំនុំជម្រះផ្តល់ឱកាសចំពោះជនជាប់ចោទ ដើម្បីមានឱកាសក្នុងការធ្វើការអាចធ្វើការកត់សម្គាល់នៅសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ។

**ជនជាប់ចោទ៖**

សូមគោរពលោកប្រធាន! ខ្ញុំបាទក្នុងករណី ជា ខន មិនមានអីកត់សម្គាល់ជាពិសេសថែមទៀតទេ ។ សូមគោរព ។

**ប្រធានអង្គជំនុំ៖**

លោក តូច មុន្និន ដំណើរនៃការស្តាប់សេចក្តីថ្លែងការណ៍របស់លោកក្នុងនាមលោកជាដើមបណ្តឹងរដ្ឋប្បវេណីថ្ងៃនេះ ឃើញថាដល់ទីបញ្ចប់ហើយ ហើយក្នុងនាមលោកជាដើមបណ្តឹងរដ្ឋប្បវេណី គឺលោកមានសិទ្ធិនៅក្នុងការតាមដានដំណើរការសវនាការ ហើយឬមួយក៏លោកអាចត្រឡប់ទៅលំនៅដ្ឋានរបស់លោកវិញ អានោះជាសិទ្ធិរបស់លោក ។ អញ្ជើញៗ តើលោកមានចង់សួរអីទៅ?

**លោក តូច មុន្និន៖**

ខ្ញុំចង់សួរតែមួយសំណួរទេ ដោយសារតែពេលវេលាខ្លី ។ ខ្ញុំត្រៀមលក្ខណៈសួរច្រើន ខ្ញុំសូមសួរទៅជនជាប់ចោទមួយសំណួរថា តើរូបបងខ្ញុំនេះក្រោយពីចាប់មកដាក់នៅភ្នំពេញ ហើយបញ្ជូនទៅគុកទួលស្លែងនេះ តើស្លាប់នៅគុកទួលស្លែងតែម្តង ឬក៏ស្លាប់នៅជើងឯក? ដើម្បីងាយស្រួលក្រុមគ្រួសាររបស់ខ្ញុំឧទ្ទិស ពីព្រោះពីរហ្នឹងខ្ញុំនៅមានស្រពេចស្រពិលខ្លាំងណាស់ ។ សូមឲ្យខាងជនជាប់ចោទ សូមបំភ្លឺតែខ្លីមកបានហើយបាទ ដើម្បីឲ្យយើងខ្ញុំអស់ចិត្ត ។

[១៦:៤១:០៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះជូនសំណួរនេះ ទៅជនជាប់ចោទដើម្បីឆ្លើយនឹងសំណួរនេះ ប្រសិនបើអាចឆ្លើយបាន ។

**ជនជាប់ចោទ៖**

សូមគោរពលោកប្រធាន! សំណួរនេះ ខ្ញុំឆ្លើយមួយម៉ាត់ទៅមិនរួចទេ ពីព្រោះការងារនេះខ្ញុំអត់ជាប់ជាក់ស្តែងទួលតែសោះ ដោយ-- បើតាមខ្ញុំស្មាន និយាយស្មានទៅវិញទេ លទ្ធភាពលើសពី ៥០ភាគរយទៅជើង ។ ដូច្នេះ ខ្ញុំក៏មិនបដិសេធលទ្ធភាពដែលគេកម្ទេចនៅភ្នំពេញដែរ ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ប្រធានអង្គជំនុំ៖**

ដំណើរការសវនាការសម្រាប់ថ្ងៃនេះ ឃើញថាចប់ត្រឹមនេះ ហើយអង្គជំនុំជម្រះប្រកាសផ្អាកសវនាការសម្រាប់ថ្ងៃនេះ ហើយសវនាការលើកទៅថ្ងៃស្អែក ចាប់ពីវេលាម៉ោងប្រាំបួនព្រឹក ដើម្បីស្តាប់នូវសក្ខីកម្មរបស់អ្នកជំនាញតាមកាលបរិច្ឆេទ ដែលបានកំណត់រួចហើយ ។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទ ហើយឲ្យនាំជនជាប់ចោទមកកាន់សាលាសវនាការនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោង៩ ជាកំណត់ ៕

*[សវនាការផ្អាកនៅម៉ោង ១៦:៤៣នាទី]*